
អង្គរ
៣០ឆ្នាំ
កិច្ចការអភិរក្ស និង អភិវឌ្ឍន៍ប្រែកបដោយជីវភាព
១៩៩៥-២០២៥



ខ្លោងទ្វារទន្ទេរ៉ាំ ក្រុងអង្គរធំ









អារម្ភកថា

អាជ្ញាធរដើម្បីការពារមណ្ឌលភ្នាន និងរៀបចំតំបន់អង្គរ ហៅថា អាជ្ញាធរជាតិអប្សរ ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩៥ ដើម្បីជាការឆ្លើយតបជាពិសេសទៅនឹងលក្ខខណ្ឌមួយ ក្នុងចំណោមលក្ខខណ្ឌប្រាំ ក្នុងការសម្រេចបញ្ចូលរមណ្ឌលភ្នានអង្គរក្នុងបញ្ជីបេតិកភណ្ឌពិភពលោកនៃអង្គការយូណេស្កូ ដែលបានធ្វើឡើងក្នុងខែធ្នូ ឆ្នាំ១៩៩៦ នៅទីក្រុងសាន់តាហ្វេ រដ្ឋមិចស៊ិចកូថ្មី នៃសហរដ្ឋអាមេរិក។

លើសពីនេះ នៅក្នុងសម័យប្រជុំពេញអង្គលើកទី១៩ របស់គណៈកម្មាធិការបេតិកភណ្ឌពិភពលោក នាខែធ្នូ ឆ្នាំ១៩៩៥ នៅទីក្រុងប៊ែរឡាំង សេចក្តីប្រកាសស្តីពីការបង្កើតអាជ្ញាធរជាតិអប្សរដោយរាជរដ្ឋាភិបាលកម្ពុជា ត្រូវបានទទួលការសោទរ ការពេញចិត្តយ៉ាងខ្លាំងពីសំណាក់សហគមន៍អន្តរជាតិ។

ជាស្ថាប័នជាតិដែលមានតួនាទីថែរក្សាអភិរក្សនិងរៀបចំរមណ្ឌលភ្នានអង្គរ អាជ្ញាធរជាតិអប្សរតែងតែយកចិត្តទុកដាក់ជាពិសេសក្នុងការអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវបេសកម្មនិងឯកសារគតិយុត្តពាក់ព័ន្ធនានាក្នុងក្របខណ្ឌជាតិនិងអន្តរជាតិ។អនុលោមតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ជាពិសេសការលើកតម្កើង រក្សាតម្លៃ និងបង្ហាញអំពីវប្បធម៌ខ្មែរនៅក្នុងឆាកអន្តរជាតិ អាជ្ញាធរជាតិអប្សរ បានកំណត់យកទ្រឹស្តីអភិរក្សដើម្បីអភិវឌ្ឍន៍ប្រកបដោយចីរភាព និងការអភិវឌ្ឍដោយចីរភាពដើម្បីការអភិរក្ស ជាគោលការណ៍ចម្បងក្នុងការបំពេញការកិច្ចរបស់ខ្លួន។ ការរក្សាបាននូវតុល្យភាពរវាងកិច្ចការអភិរក្ស និងកិច្ចការអភិវឌ្ឍន៍ប្រកបដោយចីរភាព គឺជាចំណុចដ៏មានសារៈសំខាន់ជាទីបំផុតដើម្បីជានាបាននូវសុខដុមរមណ្ឌីយកម្មនៃការថែរក្សាបេតិកភណ្ឌក្នុងបរិបទនៃការរីកចម្រើននៃបច្ចេកវិទ្យាទំនើប។








មួយវិញទៀតសោត ក្នុងឋានៈអង្គរជារមណីយដ្ឋានបេតិកភណ្ឌពិភពលោក អាជ្ញាធរជាតិអប្សរាតែងតែមានការទទួលខុសត្រូវខ្ពស់ចំពោះប្រជាជាតិខ្មែរ និងប្រជាជាតិដទៃនៅលើពិភពលោកដើម្បីធ្វើការថែរក្សា អភិរក្ស រៀបចំបានត្រឹមត្រូវនិងយូរអង្វែងតរៀងទៅ។

ឆ្នាំ២០២២គឺជាឆ្នាំដែលអាជ្ញាធរជាតិអប្សរាធ្វើការអបអរសាទរខួប៣០ឆ្នាំនៃការដាក់បញ្ចូលរមណីយដ្ឋានអង្គរក្នុងបញ្ជីបេតិកភណ្ឌពិភពលោក។ អស់រយៈពេល៣០ឆ្នាំនៃការថែរក្សា ការអភិរក្ស និងការរៀបចំរមណីយដ្ឋានអង្គរ ទោះបីជាបានប្រឈមនូវឧបសគ្គជាច្រើនក្តី អាជ្ញាធរជាតិអប្សរាក៏សម្រេចបាននូវលទ្ធផលជាប្រវត្តិសាស្ត្រជាច្រើនប្រកបដោយមោទកភាពជាទីបំផុត។ ទន្ទឹមនឹងនេះ ការរក្សាបាននូវការប្រតិបត្តិទៅលើជំនឿ ទំនៀមទម្លាប់ប្រពៃណីរបស់អ្នកស្រុកអង្គរដែលជាជាតុមួយយ៉ាងសំខាន់នៃតម្លៃអរូបីរបស់រមណីយដ្ឋានអង្គរ កាន់តែធ្វើឱ្យទីនេះមានភាពស័ក្តិសិទ្ធិទាំងជួងព្រលឹងនិងរូបរាង។ រីឯការធ្វើឱ្យមានជីវិតរស់រានឡើងវិញនូវប្រព័ន្ធជាកសាស្ត្របុរាណនាសម័យអង្គរក៏បានចូលរួមចំណែកយ៉ាងសំខាន់ដែរក្នុងការលើកនូវតម្លៃលេចធ្លោជាសកលរបស់រមណីយដ្ឋានអង្គរជាពិសេសការបង្កើតឡើងវិញនូវទេសភាពវប្បធម៌នាសម័យអង្គរក្នុងសតវត្សរ៍ទី៦១។ ក្រៅពីនេះ អាជ្ញាធរជាតិអប្សរាបានធ្វើការជួសជុលហេដ្ឋារចនាសម្ព័ន្ធរួបរួតជាច្រើនដើម្បីចូលរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិតាមរយៈវិស័យទេសចរណ៍។

ចក្ខុវិស័យអនាគតរបស់អាជ្ញាធរជាតិអប្សរាគឺរក្សាបន្តនូវឧត្តមភាពរបស់ខ្លួនតាមរយៈការបង្កើនសមត្ថភាពវិជ្ជាជីវៈជំនាញសំដៅក្នុងការសម្រេចបាននូវនិរន្តរភាពកូនខ្មែរ ជួសជុលប្រាសាទបុព្វបុរសខ្មែរៗ បន្ថែមពីនេះ អាជ្ញាធរជាតិអប្សរាក៏មានមហិច្ឆតាក្លាយខ្លួនទៅជាអ្នកបណ្តុះបណ្តាលអ្នកជំនាន់ក្រោយអំពីកិច្ចការថែរក្សា អភិរក្ស និងរៀបចំបេតិកភណ្ឌផងដែរ។







មាតិកា

ព្រះរាជដំណើរ
ព្រះករុណាព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ
៩

ព្រះរាជដំណើរ
ព្រះករុណា ព្រះចាន់សម្តេចព្រះបរមជាថ នរោត្តម
សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា
១០

ប្រសាសន៍
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
ជាយុគរដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
១៦

សារលោកជំទាវបណ្ឌិតសភាចារ្យ កឹង សកុណា
រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងជាប្រធាន
ក្រុមប្រឹក្សាកិច្চាលអាជ្ញាធរជាតិអប្សរា
១៨

អង្គរ
១៦-២៩

អាជ្ញាធរជាតិអប្សរា
៣០-៣៩

កិច្ចសហប្រតិបត្តិការអន្តរជាតិ
៤០-៦៣

ក្រមការងារគម្រងនិងសេដ្ឋកិច្ចដើម្បីដោះស្រាយបញ្ហាសំណង់
ខុសច្បាប់ ដីធ្លីក្នុងតំបន់រមណីយដ្ឋានអង្គរ និងតំបន់
ជុំវិញ ស្ថិតក្រោមការគ្រប់គ្រង
របស់អាជ្ញាធរជាតិអប្សរា
៦៤-៦៩

អភិរក្សប្រតិកម្មកណ្តាល
ច្រាំថ្ពក់ច្រាសាទ
៧០-១៧១
សំណង់សាសនា
១៧២-១៨៣

កំណាយស្រាវជ្រាវ
១៨៤-១៨៩

ការជុះបញ្ចីសារពើភណ្ឌ
១៩០-១៩៥

សារមន្ទីរក្នុងកិច្ចអភិរក្ស
១៩៦-២០៧


អភិវឌ្ឍន៍ប្រកបដោយចីរភាព
ប្រព័ន្ធជាសាស្ត្រសម័យបុរាណ
២០៨-២៣៥
ការថែរក្សាឯងស្ពារព្រៃឈើ
២៣៦-២៥១
អង្គភាពប្រព័ន្ធគ្រប់គ្រងបរិស្ថានអង្គរ
២៥២-២៥៧
ហេដ្ឋារចនាសម្ព័ន្ធ
២៥៨-២៧៣

ការអភិវឌ្ឍទេសចរណ៍
២៧៤-៣០៧

មាតិកាអ្វីបើជៅអង្គរ
៣០៨-៣២៣

អ្នកបង្កើត
៣២៤-៣៣៣

ព្រះរាជសកម្មភាព និង សកម្មភាព
ក្នុងតំបន់រមណីយដ្ឋានអង្គរ
៣៣៤-៣៣៩








ព្រះរាជនិពន្ធ៖
ព្រះករុណាព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ
អតីតព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា
ក្នុងការស្នើសុំនូវជំនួយអន្តរជាតិឱ្យជួយស្រោចស្រង់យន្តហោះ

"ខ្ញុំត្រូវធ្វើការអំពាវនាវសុំជំនួយអន្តរជាតិ ដើម្បីជៀសវាងគ្រោះមហន្តរាយ ហើយខ្ញុំសូមសម្តែងកតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅក្នុងចិត្តលើដល់មហាប្រទេសជាមិត្ត ដែលបានធ្វើការធ្វើយតបប្រកបដោយសប្បុរសធម៌។ ការជួយស្រោចស្រង់អង្គរ មហាប្រទេសជាមិត្តបានប្រគល់អតីតកាលដ៏រុងរឿងជូនប្រជាជាតិខ្មែរវិញ ហើយបានធ្វើឱ្យប្រទេសជាតិខ្មែរមានការទុកចិត្តកត់ក្តៅទៅលើអនាគតរបស់ខ្លួន។"



ព្រះពរជ័យដ៏ខ្ពង់ខ្ពស់

ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី

ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា

ក្នុងពិធីចិនអបអរសាទរខួបទី២៥ឆ្នាំនៃការបង្កើតអនុវិទ្យាល័យ ហេងស៊ីស៊ី-អន្តរ

ថ្ងៃពុធ ១៣រោច ខែកត្តិក ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ត្រូវនឹងថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០១៨

នៅព្រះបាទជ័យជេដ្ឋា ពិព្រុងអន្លង់

*ខ្ញុំសូមវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងយកអស់កម្លាំងកាយចិត្តរបស់សម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី ជៃគូអភិវឌ្ឍន៍ជាតិនិងអន្តរជាតិ ព្រមទាំងមន្ត្រី-បុគ្គលិកគ្រប់លំដាប់ថ្នាក់នៃអាជ្ញាធរជាតិអប្សរា ជាពិសេសអតីតថ្នាក់ដឹកនាំដែលយើងមិនអាចបំភ្លេចបាន ដែលបានលះបង់ពេលវេលា ប្រាជ្ញា ស្មារតីបំពេញការកិច្ចដឹកនាំដោយការខ្ជាប់ខ្ជួនត្រូវខ្ពស់ ធ្វើឱ្យរមណីយដ្ឋានអង្គរកាន់តែល្បីល្បាញលើពិភពលោក។ ជោគជ័យកន្ទុងមកនេះ កំបានបង្ហាញពីការអនុវត្តគោលនយោបាយវប្បធម៌ជាតិដ៏ត្រឹមត្រូវរបស់រាជរដ្ឋាភិបាលកម្ពុជាក្រោមការដឹកនាំដ៏ប៉ិនប្រសប់និងឈ្លាសវៃរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលជានិច្চকালតែងយកចិត្តទុកដាក់ខ្ពស់ក្នុងការថែរក្សា ការពារអភិរក្សនិងអភិវឌ្ឍន៍មរតកវប្បធម៌ជាតិ។*

កិច្চការអភិរក្សនិងអភិវឌ្ឍន៍សតិកកណ្ឌ ជាកិច្চការគ្មានទីបញ្ចប់ ដែលតាមតែវិមានការចូលរួមពីគ្រប់មជ្ឈដ្ឋានជាតិនិងអន្តរជាតិ ជាពិសេសតីស្រទាប់យុវជនជាអ្នកបន្តវេន។ ជាក់ស្តែងបច្চុប្បន្ននេះ ធនធានមនុស្សក្នុងវិស័យអភិរក្សនិងស្រាវជ្រាវរបស់កម្ពុជាកំពុងឈានមុខក្នុងចំណោមបណ្តាប្រទេសអាស៊ីអាគ្នេយ៍ ហើយរមណីយដ្ឋានអង្គរបានក្លាយជាទីតាំងបុរាណវិទ្យាដ៏ធំជាងគេរបស់យូណេស្កូ (UNESCO) សម្រាប់កិច្চការបណ្តុះបណ្តាលធនធានមនុស្សលើវិស័យនេះ។


ពិធីសំណេះសំណាល
ជាមួយប្រជាពលរដ្ឋដែលបានផ្លាស់ទីពីតំបន់ទី១ ទៅតំបន់ទី២ នៃអភិរក្ខដ្ឋានអប្ដរ
មកស្នាក់នៅភូមិតាមឹម ឃុំរនតាឯក ស្រុកបន្ទាយស្រី ខេត្តសៀមរាប

ព្រះសារាសន៍

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ក្នុងពិធីសំណេះសំណាលជាមួយប្រជាពលរដ្ឋដែលបានផ្លាស់ពីភូមិឋានទី១ ឋានទី២

នៃទេណីយដ្ឋានអង្គរមកស្នាក់នៅក្នុងភូមិគាត់ ឃុំព្រៃតាឯក ស្រុកបន្ទាយស្រី ខេត្តសៀមរាប

ថ្ងៃអង្គារ ៣រោច ខែភទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

ត្រូវនឹងថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២២

នៅភូមិគាត់ ឃុំព្រៃតាឯក ស្រុកបន្ទាយស្រី ខេត្តសៀមរាប

"ការដែលយើងទទួលបានន្ទូវលក្ខណៈជាសម្បត្តិវប្បធម៌របស់មនុស្សជាតិ យើងទទួលបានន្ទូវ ការគាំទ្រពីមិត្តបរទេស ទាំងហិរញ្ញវត្ថុ ទាំងបច្ចេកទេស ដើម្បីជួសជុលថែទាំ និងអភិរក្សន្ទូវ ប្រាង្គប្រាសាទនានាដែលបានចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោក ដូចជាប្រាសាទនៅតំបន់ រមណីយដ្ឋានអង្គរ សំបូរព្រៃគុក និងប្រាសាទព្រះវិហារ ហើយយើងនឹងត្រៀមខ្លួនជាក់ន្ទូវ ប្រាសាទដទៃទៀតទៅជាសម្បត្តិវប្បធម៌ពិភពលោក"



លោកជំទាវបណ្ឌិតសភាចារ្យ
ឡើង សកុណា
រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
និងជាប្រធានក្រុមប្រឹក្សាកិត្តិយស
អាជ្ញាធរជាតិអប្សរា

អង្គរត្រូវបានចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោកប្រឈមនឹងគ្រោះថ្នាក់ ដោយគណៈកម្មាធិការបេតិកភណ្ឌពិភពលោកនៃអង្គការយូណេស្កូ នាចុងឆ្នាំ១៩៩៦ ក្នុងកាលៈទេសៈនិងលក្ខណៈដោយខ្លែកពិសេសបំផុត។ មូលហេតុចម្បងបណ្តាលឱ្យខ្ញុំលើកឡើងយ៉ាងដូច្នេះ ព្រោះខ្ញុំចង់រំឭកឡើងវិញអំពីស្ថានភាពរបស់កម្ពុជា និងអង្គរនាពេល ៣០ឆ្នាំមុន ដែលចំណុចនេះជាប្រភពនៃការផ្តល់កំណើតដល់អាជ្ញាធរជាតិអប្សរា។

ខ្ញុំសូមបញ្ជាក់ថា ដំណើរការនៃការចុះរមណីយដ្ឋានអង្គរក្នុងបញ្ជីបេតិកភណ្ឌពិភពលោក បានចាប់ផ្តើមពីថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩១ ដោយ ***ព្រះអគ្គមហាព្រះបាទ សម្តេចព្រះនរោត្តម សីហនុ*** *ព្រះមហាវីរក្សត្រ ព្រះវរបិតា ឯកភាព ប្តូរណាភាពទឹកដី និងឯកភាពជាតិខ្មែរ ព្រះបរមរតនកោដ្ឋ ដែលពេលនោះកម្ពុជាស្ថិតក្នុងសភាពមានសង្គ្រាមផង និងកំពុងចាស្វែងរកដំណោះស្រាយជម្លោះនយោបាយផង និងមានការខ្វះខាតគ្រប់សព្វបែបយ៉ាងទាំងអស់។*

ស្ថានភាពជាក់ស្តែងរបស់អង្គរនាពេលនោះ ត្រូវបានវិនិច្ឆ័យថា ស្ថិតក្នុងសភាពប្រឈមនឹងហានិភ័យខ្លាំងបំផុត កំព្រោះតែរចនាសម្ព័ន្ធនៃប្រាង្គប្រាសាទបុរាណរបស់យើងត្រូវបានរងការទន្ទ្រានបំផ្លាញដោយការចាក់ឫសព្រៃនិងជុះទ្រុបរបស់ព្រៃឈើ ការគាស់រកយស្វែងរកវត្ថុមានតម្លៃឬវត្ថុបុរាណពីសំណាក់ជនទិលខ្វះ គ្រាប់មីន មានសម្បូរនៅគ្រប់ទិសទី និងកង្វះខាតជួនជួរនៃសកម្មភាពអភិរក្សជួសជុល។ ដូច្នេះបើគេះបីជាពេលនោះកម្ពុជាស្ថិតក្នុងភាពខ្វះខាតជាខ្លាំងនិងតំបន់អង្គរស្ថិតក្នុងសភាពអសន្តិសុខខ្លាំង ក៏អង្គរត្រូវបានអនុម័តជាឯកច្ឆ័ន្ទបញ្ចូលក្នុងបញ្ជីបេតិកភណ្ឌពិភពលោកដែរ ព្រោះតែស្ថានភាពតម្រូវនិងតម្លៃលេចធ្លោជាសកលនៃអង្គរដែលមិនអាចកាត់ថ្លៃបាន។

តើអ្វីដែលកម្ពុជានិងបន្តប្រឈមខ្លឹតក្រោយអង្គរបានក្លាយជាសម្បត្តិបេតិកភណ្ឌពិភពលោក។ ការប្រឈមបន្ទាប់របស់កម្ពុជា គឺការបង្កើតស្ថាប័នជាតិមួយដើម្បីការពារនិងរៀបចំរមណីយដ្ឋានបេតិកភណ្ឌពិភពលោកអង្គរ។ ត្រង់ចំណុចនេះហើយ ទើបអាជ្ញាធរជាតិអប្សរាត្រូវបានបង្កើតឡើងនៅដើមឆ្នាំ១៩៩៥។

ក្នុងបុព្វហេតុនៃកិច្ចការពារនិងរៀបចំរមណីយដ្ឋានអង្គរ ពិសេសរយៈពេល៣០ឆ្នាំកន្លងមក អាជ្ញាធរជាតិអប្សរាបានបង្កើតសមិទ្ធផលជាប្រវត្តិសាស្ត្រជាច្រើនពាក់ព័ន្ធនឹងការអភិរក្ស ជួសជុលប្រាង្គប្រាសាទ ការអភិវឌ្ឍវិស័យទេសចរណ៍ ការរៀបចំហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ការជាក់ស្តែងដំណើរការឡើងវិញនៃប្រព័ន្ធធារាសាស្ត្រអង្គរ ការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋក្នុងតំបន់រមណីយដ្ឋានអង្គរ ការរៀបចំគ្រប់គ្រងបរិស្ថាន និងព្រៃឈើ។ល។

ឆ្លៀតក្នុងឱកាសដ៏ថ្លៃថ្នូរនេះ តាងនាមអាជ្ញាធរជាតិអប្សរា ខ្ញុំបាទសូមព្រះបរមរាជានុញ្ញាតសម្តែងនូវកតញ្ញូកតវេទិតាធម៌យ៉ាងជ្រាលជ្រៅនិងស្មោះស្ម័គ្រចំពុតថ្វាយ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាដែលជានិច្চকালព្រះអង្គតែងតែយកទីកព្រះទ័យទុកដាក់ក្នុងការបំពេញព្រះរាជបេសកកម្មដ៏ឧត្តុង្គឧត្តមព្រមទាំងលះបង់កម្លាំងព្រះកាយពល និងព្រះបញ្ញាញាណមិនខ្ជាខ្ជួយហត់ចំពោះកិច្ចការថែរក្សាលើកកណ្តាប់ប្បធម៌។ ខ្ញុំសូមសម្តែងនូវការគោរពដ៏ឥតគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលតែងតែតាំទ្រនិងផ្តល់អនុសាសន៍ យុទ្ធសាស្ត្រគន្លឹះជាច្រើនក្នុងការអនុវត្តនាពេលកន្លងមក។

បុណ្យក្រោយនេះ ខ្ញុំសូមនាំនូវគ្រាល់សមិទ្ធផលទាំងអស់ដែលអាជ្ញាធរជាតិអប្សរាទទួលបានក្នុងរយៈពេល៣០ឆ្នាំ ជូនដល់វិញ្ញាណក្ខន្ធអតីតប្រធានអាជ្ញាធរជាតិអប្សរា **ឯកឧត្តមវណ្ណ មូលីវណ្ណ** សម្តេចវិបុលបញ្ញា **សុខ អាន** ព្រមទាំងថ្នាក់ដឹកនាំ និងអ្នកជំនាញការជាតិ-អន្តរជាតិ ដែលបានខិតខំបូជាកម្លាំងកាយចិត្ត ប្រាជ្ញាស្មារតីក្នុងបុព្វហេតុលើកកណ្តាប់ប្បធម៌។



អង្គរ

«អង្គរ» បានអានក្លាយមកពីសំស្ក្រឹតថា «នគរ» ប្រែថា រាជធានី។ អង្គរប្រៀបដូចនឹងវត្ថុបុរាណមួយ ដែលមានប្រវត្តិសាស្ត្រយូរអង្វែង ដែលបានវិវឌ្ឍន៍តាមសូរសៀងនៃភាសាសាស្ត្រនិងអត្ថន័យរបស់ខ្លួន។

ការវិវឌ្ឍន៍នៃពាក្យនេះ បានបង្ហាញអំពីអារ្យធម៌ទាំងមូលដែលមានលក្ខណៈពិសេស និងតីតាង បង្ហាញពីការអភិវឌ្ឍក្រុងដ៏ត្បូងឱ្យក្លាក់ផ្តើលស្ទប់ស្ទែងនៃប្រវត្តិសាស្ត្ររបស់មនុស្សជាតិ។

អង្គរមិនត្រឹមតែជារាជធានីនៃចក្រភពមួយទេ តែបានក្លាយជាអារ្យធម៌មួយដោយខ្លួនឯង ហើយបានរីកសន្ធឹងទៅសម្គាល់ដល់តំបន់ភូមិសាស្ត្រទាំងមូលទៀតផង។ ទីកដីនេះបានបង្កើតអារ្យធម៌ដ៏រុងរឿងមួយ ដែលអាចសម្គាល់បានដោយការស្ទាញបញ្ចូលគ្នារវាងស្ថានភាពភូមិសាស្ត្រលាយឡំជាមួយសំណាល់បុរាណវិទ្យា។

ទីក្រុងពិសិដ្ឋ ព្រះនគរ ដែលផ្សំឡើងដោយប្រាសាទភក់រយ អាងរក្សាទឹកបារាយណ៍ ប្រព័ន្ធធារាសាស្ត្រ និងសំណល់បុរាណវិទ្យាដទៃទៀត តាំងនៅក្នុងលំហទេសភាពធំទូលាយមួយ ដែលមានក្រុងតូចៗ ទីប្រជុំជនជារង្វង់នៅជុំគ្នា លេចឡើងជាបន្តបន្ទាប់។



ប្រាសាទបក្សីចាំក្រុង



ព្រះរាជាធិបតីដ៏ខ្ពង់ខ្ពស់បំផុតព្រះករុណាព្រះបាទ សម្តេចព្រះបរមនាថ
នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា
ក្នុងពិធីបិទអបអរខួប៦៩ឆ្នាំនៃការបង្កើត អាយស៊ីស៊ី-អង្គរ

បេតិកភណ្ឌ

បេតិកភណ្ឌគឺជាមរតកពីអតីតកាល ដែលជាស្នាដៃនិងសមិទ្ធផលរបស់បុព្វបុរសបានកសាង និងរៀបចំឬកកើតដោយធម្មជាតិ ហើយដែលបច្ចាជនជំនាន់ក្រោយបានទទួលផលប្រយោជន៍ និងផ្ទេរបន្តទៅបច្ចាជនជំនាន់បន្តបន្ទាប់ទៀតៗ បេតិកភណ្ឌមានពីរប្រភេទ៖ បេតិកភណ្ឌវប្បធម៌ និងបេតិកភណ្ឌធម្មជាតិ។

បេតិកភណ្ឌវប្បធម៌ សំដៅលើមរតកពីអតីតកាល ដែលជាស្នាដៃដៃប្រកិតបង្កើតដោយមនុស្ស រួមមាន ប្រាសាទ ស្នាដៃស្ថាបត្យកម្ម ស្នាដៃចម្លាក់ ផ្នាំងតំនូរ និងអក្សរចារឹកនានា ដោយតួបផ្សំនូវលក្ខណៈពិសេសៗដែលមានតម្លៃលេចធ្លោជាសកលតាមទស្សនៈប្រវត្តិសាស្ត្រ សិល្បៈ ឬវិទ្យាសាស្ត្រជាដើម។ បេតិកភណ្ឌវប្បធម៌ចែកជាពីរបន្តទៀត៖ ទីមួយ បេតិកភណ្ឌវប្បធម៌រូបី ដែលជាមរតកមានរូបរាងទ្រង់ទ្រាយផ្សេងៗដូចជា សំណង់ប្រាសាទ ចារុយណ៍ រូបបដិមា វត្ថុសិល្បៈ និងវត្ថុប្រើប្រាស់ផ្សេងៗ។ ទីពីរ បេតិកភណ្ឌវប្បធម៌អរូបី គឺជាមរតកគ្មានរូបរាង មិនអាចប៉ះបាន ដូចជា គតិបណ្ឌិតប្រាជ្ញាញាណ ចំណេះដឹង និងទេពកោសល្យរបស់មនុស្ស ដែលសម្តែងតាមរយៈទម្រង់សិល្បៈមានដូចជា ឧបម្រាំង តន្ត្រី ល្ខោន និងតាមរបៀបកិច្ចពិធីនានា ដែលជាប្រពៃណី ទំនៀមទម្លាប់ លើយនិងជីវភាពរស់នៅប្រចាំថ្ងៃតាមទម្លាប់តៗគ្នីមក។

បេតិកភណ្ឌធម្មជាតិ គឺជាមរតកធម្មជាតិ ដែលកើតមានឡើងនៅក្នុងបរិស្ថានធម្មជាតិ រាប់បញ្ចូលទាំងសត្វ រុក្ខជាតិ និងទម្រង់ផ្សេងៗនៃជីវចម្រុះ ដែលស្ថិតនៅជាមួយរចនាសម្ព័ន្ធ និងដំណើរការកើតផ្សេងៗនៃភូគព្ភសាស្ត្រ។ មរតកធម្មជាតិទាំងនោះតែងតែមានតម្លៃលេចធ្លោជាសកលក្នុងវិស័យសោភ័ណភាព ឬវិទ្យាសាស្ត្រ។



រមណីយដ្ឋានបេតិកភណ្ឌពិភពលោក

រមណីយដ្ឋានបេតិកភណ្ឌពិភពលោក គឺជាទីតាំងបុកណា ដែលជាបេតិកភណ្ឌវប្បធម៌ឬធម្មជាតិនៅលើផែនដីដែលមានសោភ័ណភាព អច្ឆរិយភាពនិងគុណតម្លៃជាសកលរបស់មនុស្សជាតិ ឬធម្មជាតិទូទៅ ហើយបានចុះក្នុងបញ្ជីបេតិកភណ្ឌរបស់ពិភពលោក ដែលត្រូវការពារនិងអភិរក្សសម្រាប់មនុស្សជំនាន់ក្រោយៗ។

គណៈកម្មាធិការ បេតិកភណ្ឌពិភពលោក

អនុសញ្ញាឆ្នាំ១៩៧២ បានកំណត់អំពីមុខងាររបស់គណៈកម្មាធិការបេតិកភណ្ឌពិភពលោករបៀបជ្រើសរើសសមាជិកគណៈកម្មាធិការនិងអាណត្តិរបស់សមាជិក។ គណៈកម្មាធិការធ្វើការប្រជុំមួយដងក្នុងមួយឆ្នាំ។ តំណាងរដ្ឋភាគីចំនួន៦១ ដែលជាសមាជិករបស់គណៈកម្មាធិការ ត្រូវបានជ្រើសរើសតាមរយៈការបោះឆ្នោតនៅមហាសន្និបាតនៃរដ្ឋភាគីអនុសញ្ញា សម្រាប់អាណត្តិជាអតិបរមា៦ឆ្នាំ។

គណៈកម្មាធិការនេះមានតួនាទីសំខាន់ៗដូចខាងក្រោម៖

- *ធ្វើការកំណត់អត្តសញ្ញាណកម្មនៃបេតិកភណ្ឌវប្បធម៌និងធម្មជាតិ ដែលមានតម្លៃលេចធ្លោជាសកលដែលនឹងត្រូវការពារក្រោមអនុសញ្ញា ហើយធ្វើការចុះបេតិកភណ្ឌទាំងនោះទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោក ដោយឈរលើមូលដ្ឋាននៃបញ្ជីព្រាងនិងសំណើសុំរបស់រដ្ឋភាគីនីមួយៗ*
- *ឃ្លាំមើលស្ថានភាពនៃការអភិរក្សសម្បត្តិ ដែលបានចុះបញ្ជីបេតិកភណ្ឌពិភពលោក តាមរយៈដំណើរការនៃការតាមដានបែបប្រតិកម្មតប (Reactive Monitoring) និងរបាយការណ៍ជាទៀងទាត់*


ប្រាសាទអង្គរវត្ត

- *សម្រេចថា សម្បត្តិបេតិកភណ្ឌពិភពលោកណាខ្លះត្រូវដកចេញពីបញ្ជីបេតិកភណ្ឌពិភពលោកស្ថិតក្នុងគ្រោះថ្នាក់ ឬត្រូវចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោកស្ថិតក្នុងគ្រោះថ្នាក់*
- *សម្រេចថា តើសម្បត្តិណាមួយដែលត្រូវដកចេញពីបញ្ជីបេតិកភណ្ឌពិភពលោក ប្រសិនបើការគ្រប់គ្រងរមណីយដ្ឋាននោះ មិនបានបំពេញតាមលក្ខខណ្ឌនៃការគ្រប់គ្រងបេតិកភណ្ឌពិភពលោក*



- កំណត់នីតិវិធីនៃការពិនិត្យសំណើសុំជំនួយអន្តរជាតិ និងជាក់ឱ្យមានការសិក្សា និងការពិគ្រោះយោបល់ ដែលគណៈកម្មាធិការនិច្ឆ័យថាមានភាពចាំបាច់មុននឹងធ្វើការសម្រេចចិត្ត
- កំណត់ថា តើធ្វើដូចម្តេចដើម្បីប្រើប្រាស់ឱ្យបានល្អប្រសើរនូវធនធានរបស់មូលនិធិសិតិកកណ្តាលពិភពលោក ដើម្បីជួយរដ្ឋភាគីឱ្យការពារសម្បត្តិដែលមានតម្លៃលេចធ្លោជាសកលរបស់ខ្លួន
- ស្វែងរកមធ្យោបាយសម្រាប់បង្កើតធនធានរបស់មូលនិធិសិតិកកណ្តាលពិភពលោក
- បង្ហាញឱ្យដឹងរាល់ពីរឆ្នាំម្តង នូវរបាយការណ៍អំពីសកម្មភាពរបស់ខ្លួនជូនមហាសន្និបាត នៃរដ្ឋភាគីនិងជូនសន្និសីទទូទៅរបស់អង្គការយូណេស្កូ
- ធ្វើការត្រួតពិនិត្យឡើងវិញ និងវាយតម្លៃយ៉ាងទៀងទាត់ក្នុងការជាក់ឱ្យអនុវត្តអនុសញ្ញានេះ
- ពិនិត្យកែសម្រួល និងអនុម័តឡើងវិញនូវគោលការណ៍ណែនាំ។



ប្រាសាទបាយ័ន



ប្រាសាទប្រែរូប



ប្រាសាទត្រាំង

អនុសញ្ញាឆ្នាំ១៩៧២ ស្តីពីកិច្ចការពារបេតិកភណ្ឌពិភពលោកផ្នែកវប្បធម៌និងធម្មជាតិ

អនុសញ្ញានេះជាកិច្ចព្រមព្រៀង ស្តីពីកិច្ចការពារបេតិកភណ្ឌពិភពលោកផ្នែកវប្បធម៌និងធម្មជាតិរវាងប្រទេសនានានៅលើពិភពលោក ដោយមិនពាក់ព័ន្ធបញ្ហានយោបាយនិងហិរញ្ញវត្ថុ ដែលត្រូវបានបង្កើតឡើងនៅទីក្រុងប៉ារីស នាមហាសន្និបាតនៃអង្គការយូណេស្កូ លើកទី១៧ នៅឆ្នាំ១៩៧៦ ដោយផ្អែកគំនិតយល់ឃើញថា បេតិកភណ្ឌពិភពលោកផ្នែកវប្បធម៌និងធម្មជាតិកំពុងរងការខូចខាតបំផ្លិចបំផ្លាញពុកផុយ ដោយកត្តាមនុស្ស និងធម្មជាតិ ព្រមទាំងផលប៉ះពាល់ពីការផ្លាស់ប្តូរស្ថានភាពសេដ្ឋកិច្ច-សង្គម។

អនុសញ្ញានេះចែងអំពី «កាតព្វកិច្ចរបស់រដ្ឋភាគីក្នុងការកំណត់រមណីយដ្ឋាន ដែលមានសក្តានុពល ព្រមទាំងតួនាទីក្នុងការការពារនិងអភិរក្សរមណីយដ្ឋាន។ នៅពេលផ្តល់សច្ចាប័នលើអនុសញ្ញាប្រទេសនីមួយៗសន្យាថា មិនគ្រាន់តែជានាអភិរក្សរមណីយដ្ឋានបេតិកភណ្ឌពិភពលោកដែលស្ថិតនៅក្នុងប្រទេសរបស់ខ្លួនឱ្យបានល្អប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងថែរក្សា និងការពារបេតិកភណ្ឌជាតិឱ្យបានល្អបំផុតថែរតទាំង»។ អនុសញ្ញាក៏ចែងអំពី «កាតព្វកិច្ចរបស់រដ្ឋភាគី ដែលត្រូវផ្តល់របាយការណ៍ជាទៀងទាត់ជូនគណៈកម្មាធិការបេតិកភណ្ឌពិភពលោក អំពីស្ថានភាពនៃការអភិរក្សបេតិកភណ្ឌដែលចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោក»។

លក្ខខណ្ឌចាំបាច់សម្រាប់ប្រទេសទាំងអស់មុននឹងស្នើជាតំបេតិកភណ្ឌរបស់ខ្លួន ទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោក គឺតម្រូវឱ្យប្រទេសនោះផ្តល់សច្ចាប័នលើអនុសញ្ញាឆ្នាំ១៩៧៦ ស្តីពី «កិច្ចការពារបេតិកភណ្ឌពិភពលោក» ជាមុនសិន ពោលគឺប្រទេសនោះត្រូវជារដ្ឋភាគីនៃអនុសញ្ញាឆ្នាំ១៩៧៦។ គណៈកម្មាធិការចាត់ទុកថាបេតិកភណ្ឌមួយមានតម្លៃលេចធ្លោជាសកលប្រសិនបើបេតិកភណ្ឌនោះផ្ទេីយតបយ៉ាងហោចណាស់ទៅនឹងលក្ខណៈវិនិច្ឆ័យមួយនៃបណ្តាលក្ខណៈវិនិច្ឆ័យដូចតទៅ៖

(i) *តំណាងស្នាដៃកំពូលនៃទេពកោសល្យក្នុងការបង្កើតរបស់មនុស្សជាតិ*

(ii) *បង្ហាញឥទ្ធិពលសំខាន់នូវការផ្លាស់ប្តូរនៃការជះឥទ្ធិពលយ៉ាងសម្បើមក្នុងសម័យកាលណាមួយនោះ ឬក្នុងតំបន់វប្បធម៌កំណត់ច្បាស់លាស់ទៅលើការរីកចម្រើននៃស្ថាបត្យកម្ម ឬបច្ចេកវិទ្យា សិល្បៈទាក់ទ្រង់ទ្រាយទេវ ផែនការកម្មវិធីក្រុង ឬការបង្កើតទេសភាព*

(iii) *ជាសក្ខីកម្មតែមួយគត់ ឬយ៉ាងហោចណាស់ប្លែកពីគេ នៃប្រពៃណីវប្បធម៌ឬអរិយធម៌មួយដែលមានជីវិត ឬដែលបានបាត់បង់ទៅហើយ*

(iv) *ជាគំរូដ៏ឆ្នើមមួយនៃប្រភេទសំណង់ ឬសំណុំស្ថាបត្យកម្ម ឬបច្ចេកវិទ្យា ឬទេសភាពដែលរំលេចនូវសម័យកាលណាមួយដែលមានអត្ថន័យជាប្រវត្តិសាស្ត្ររបស់មនុស្សជាតិ*

(v) *ជាគំរូដ៏ឆ្នើមមួយនៃការតាំងទីលំនៅតាមបែបប្រពៃណីរបស់មនុស្សជាតិ ការប្រើប្រាស់ដីធ្លី ឬសមុទ្រដែលតំណាងឱ្យវប្បធម៌មួយឬច្រេីន ឬទំនាក់ទំនងនៃការរស់នៅរបស់មនុស្សជាមួយធម្មជាតិ ជាពិសេសនៅពេលដែលវាងាយទទួលរងផលប៉ះពាល់ពីការផ្លាស់ប្តូរ ដែលមិនអាចត្រឡប់មកសភាពដើមវិញបាន។*

(vi) *មានទំនាក់ទំនងដោយផ្ទាល់ ឬដោយរួបរឹតទៅជាមួយនឹងព្រឹត្តិការណ៍ ឬប្រពៃណីទំនៀមទម្លាប់រស់រវើកទៅជាមួយនឹងគំនិត ជំនឿ ឬស្នាដៃសិល្បៈនិងអក្សរសាស្ត្រ ដែលមានអត្ថន័យលេចធ្លោជាសកល (គណៈកម្មាធិការចាត់ទុកថាលក្ខណៈវិនិច្ឆ័យនេះត្រូវប្រើរួមជាមួយលក្ខណៈវិនិច្ឆ័យដទៃទៀត)*

(vii) *តំណាងឱ្យបាតុភូតធម្មជាតិដ៏លេចធ្លោ ឬជាតំបន់ប្រកបដោយទេសភាពធម្មជាតិដ៏វិសេសវិសាល និងប្រកបដោយសារៈសំខាន់ខាងសោភ័ណភាព*

(viii) *ជាគំរូដ៏ឆ្នើម តំណាងឱ្យដំណាក់កាលសំខាន់ៗនៃប្រវត្តិសាស្ត្រផែនដី ដែលមានតឹកតាងនៃជីវិត ដំណើរការនៃភូគព្ភសាស្ត្រដ៏គួរឱ្យកត់សម្គាល់ ដែលនៅតែបន្តកើតមាន នៃទម្រង់ដែនដីឬសណ្ឋានដីឬភូមិសាស្ត្រដែលមានលក្ខណៈពិសេស*

(ix) *ជាគំរូដ៏ឆ្នើម តំណាងឱ្យដំណើរការអេកូឡូស៊ី និងជីវសាស្ត្រដែលនៅតែបន្តមានក្នុងដំណើរការវិវឌ្ឍន៍ និងការអភិវឌ្ឍរបស់ប្រព័ន្ធអេកូឡូស៊ីនៃផែនដី ទឹកសាប តំបន់ឆ្នេរ និងក្នុងសមុទ្រ ព្រមទាំងអម្បាវុក្ខជាតិនិងសត្វ។*

(x) *ជាជម្រកធម្មជាតិពិសេស និងចាំបាច់បំផុត សម្រាប់ការអភិរក្សជីវៈចម្រុះនៅនឹងកន្លែង ដែលក្នុងនោះមានរួមបញ្ចូលទាំងប្រភេទដែលស្ថិតនៅក្នុងស្ថានភាពប្រឈមនឹងការផុតពូជ ហើយដែលមានតម្លៃលេចធ្លោជាសកល តាមទស្សនៈវិទ្យាសាស្ត្រឬការអភិរក្ស។*

ការចុះរមណីយដ្ឋានអង្គរក្នុងបញ្ជីបេតិកភណ្ឌពិភពលោក



លោកជំទាវបណ្ឌិតសភាចារ្យ ភឿង សកុណា
ក្នុងអង្គមហាសន្និបាតលើកទី៤១ និងខួបពាក់ព័ន្ធនៃអង្គការយូណេស្កូ

រមណីយដ្ឋានអង្គរមានតម្លៃវិសេសវិសាលជាសកល ប៉ុន្តែរមណីយដ្ឋាននេះមិនអាចរក្សាបានទូវលក្ខណៈវិសេសរបស់ខ្លួនប្រសិនបើគ្មានកិច្ចការពារ និងអភិរក្សឱ្យបានស្ថិតស្ថេរឲ្យកាលនោះទេ។ ហេតុដូច្នេះហើយ ទើបនៅថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩១ ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាវីរក្សត្រ ព្រះវរាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ «**ព្រះបរមរតនកោដ្ឋ**» ទ្រង់បានព្រាយព្រះហស្តលេខា លើសំណុំលិខិតស្នើសុំចុះរមណីយដ្ឋានអង្គរក្នុងបញ្ជីបេតិកភណ្ឌពិភពលោក ហើយព្រះអង្គបានស្នើសុំឱ្យអង្គការយូណេស្កូចាត់តួនាទីជាអ្នកសម្របសម្រួលជាមួយសហគមន៍អន្តរជាតិ ដើម្បីជួយស្រោចស្រង់អង្គរ។

តាមរយៈការពិនិត្យ និងវាយតម្លៃរបស់គណៈកម្មាធិការបេតិកភណ្ឌពិភពលោក រមណីយដ្ឋានអង្គរត្រូវបានចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោក ដោយបានបំពេញលក្ខណៈវិនិច្ឆ័យចំនួនបួនក្នុងចំណោមលក្ខណៈវិនិច្ឆ័យទាំង១០ សម្រាប់ការជ្រើសរើសជារមណីយដ្ឋានបេតិកភណ្ឌពិភពលោក ដូចខាងក្រោម៖

(i) រមណីយដ្ឋានអង្គរបង្ហាញអំពីសិល្បៈខ្មែរទាំងមូលចាប់តាំងពីសតវត្សទី៩ រហូតដល់សតវត្សទី១៤ ដោយរួមមានស្នាដៃឯកផ្នែកសិល្បៈជាច្រើនដូចជា ប្រាសាទអង្គរវត្ត ប្រាសាទបាយ័ន ប្រាសាទបន្ទាយស្រីជាដើម

(ii) ឥទ្ធិពលសិល្បៈខ្មែរ ដែលបានកសាងអង្គរ គឺមានភាពអស្ចារ្យជាងឥទ្ធិពលសិល្បៈនានា នៅតំបន់អាស៊ីអាគ្នេយ៍ និងដើរតួនាទីដ៏សំខាន់នៅក្នុងដំណើរវិវឌ្ឍន៍ដោយខ្សែករបស់តំបន់នេះ

(iii) ចក្រភពខ្មែរនៅចន្លោះសតវត្សទី៩និងសតវត្សទី១៤បានគ្របដណ្តប់មួយភាគធំនៃតំបន់អាស៊ីអាគ្នេយ៍ និងដើរតួនាទីចម្បងក្នុងការអភិវឌ្ឍវប្បធម៌ និងនយោបាយក្នុងតំបន់។ សំណល់នៃអារ្យធម៌នេះ គឺបេតិកភណ្ឌដ៏សម្បូរបែបនៃសំណង់សាសនា ដែលកសាងអំពីឥដ្ឋនិងថ្ម

(iv) ស្ថាបត្យកម្មខ្មែរបានវិវឌ្ឍន៍មួយផ្នែកធំចេញពីរចនាទ្វីបឥណ្ឌា ប៉ុន្តែក្នុងរយៈពេលមួយដ៏ធាប់បានឃ្លាតពីឥទ្ធិពលឥណ្ឌាចាប់តាំងពីស្ថាបត្យកម្មនេះបានអភិវឌ្ឍន៍លក្ខណៈពិសេសដោយខ្សែករបស់ខ្លួន។ ស្ថាបត្យកម្មនេះ បានវិវឌ្ឍន៍ដោយខ្លួនឯង ហើយខ្លះទៀតបានមកពីប្រពៃណីវប្បធម៌ជិតខាង។ ជាលទ្ធផលស្ថាបត្យកម្មខ្មែរបានលេចចេញនូវលក្ខណៈថ្មីមួយដោយខ្សែករបស់ខ្លួនៅក្នុងសិល្បៈ និងស្ថាបត្យកម្មតំបន់ឬ៏។


កិច្ចប្រជុំបូកសរុបការងារ និងទិសដៅការងាររបស់
គណៈកម្មាធិការ អាយស៊ីស៊ី-អង្គរ នាទីក្រុងប៉ារីស

ការសម្រេចរបស់គណៈកម្មាធិការបេតិកភណ្ឌពិភពលោក

នៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៩២ នៅទីក្រុង Santa Fe (សាន់តាហ្វេ) សហរដ្ឋអាមេរិក គណៈកម្មាធិការបេតិកភណ្ឌពិភពលោកក្នុងកិច្ចប្រជុំលើកទី១៦ បានសម្រេចចុះរមណីយដ្ឋានអង្គរក្នុងបញ្ជីបេតិកភណ្ឌពិភពលោកប្រឈមនឹងគ្រោះថ្នាក់ ដោយគាលនោះតំបន់អង្គរពុំទាន់មានសុវត្ថិភាពពេញលេញនៅឡើយ ដូចជានៅមានបញ្ហាអសន្តិសុខ គ្រាប់មីននិងយុទ្ធភណ្ឌមិនទាន់ផុះ និងការលួចវត្ថុបុរាណជាដើម។

ការសម្រេចចុះរមណីយដ្ឋានអង្គរក្នុងបញ្ជីបេតិកភណ្ឌពិភពលោកជាលក្ខណៈពិសេសដោយសារ ប្រទេសកម្ពុជាកំពុងត្រៀមលក្ខណៈបង្រួបបង្រួមជាតិ បន្ទាប់ពីបានឆ្លងកាត់សង្គ្រាមជាច្រើនទសវត្សរ៍និងដោយសារតម្លៃលេចធ្លោជាសកលរបស់អង្គរតំណាងឱ្យស្នាដៃឯករបស់មនុស្សជាតិ ទោះបីជាលក្ខខណ្ឌទាំងស្រុងសម្រាប់ជានាជាស់កិច្ចការពារនិងអភិរក្សរមណីយដ្ឋានបេតិកភណ្ឌពិភពលោក នៅមិនទាន់បានបំពេញគ្រប់គ្រាន់ក៏ដោយ។ ប៉ុន្តែគណៈកម្មាធិការបេតិកភណ្ឌពិភពលោកបានតម្រូវឱ្យប្រទេសកម្ពុជាបំពេញលក្ខខណ្ឌមួយចំនួនក្នុងរយៈពេល៣ឆ្នាំ ដូចមានខាងក្រោម៖

- *រៀបចំបង្កើតច្បាប់សម្រាប់ការពារបេតិកភណ្ឌនៅកម្ពុជាដែលមានលក្ខណៈគ្រប់ជ្រុងជ្រាយ និងមានប្រសិទ្ធភាព*
- *បង្កើតស្ថាប័នជាតិទទួលបន្ទុកការពាររមណីយដ្ឋានអង្គរដោយមានបុគ្គលិក និងធនធានហិរញ្ញវត្ថុគ្រប់គ្រាន់*
- *កំណត់តំបន់ការពាររមណីយដ្ឋានអង្គរជាអចិន្ត្រៃយ៍*
- *បង្កើតតំបន់ទ្រនាប់ឱ្យបានសមស្រប*
- *បង្កើតយន្តការត្រួតពិនិត្យ និងសម្របសម្រួលលើគម្រោងអន្តរជាតិនៅក្នុងតំបន់អង្គរ។*



សេចក្តីសម្រេចពាក់ព័ន្ធនឹងអង្គរ លេខ ០៥៦៨ ស្តីពីតម្លៃលេចធ្លោជាសកល (សំយោគសង្ខេប)

«អង្គរ» ស្ថិតក្នុងខេត្តសៀមរាបភាគខាងជើងនៃប្រទេសកម្ពុជា គឺជារមណីយដ្ឋានបុរាណមួយយ៉ាងធំក្នុងបណ្តារមណីយដ្ឋានបុរាណនៅអាស៊ីអាគ្នេយ៍។ រមណីយដ្ឋាននេះមានទំហំប្រហែល៤០១គីឡូម៉ែត្រក្រឡា រួមមានប្រាសាទ រចនាសម្ព័ន្ធជាកសាស្ត្រ (បារាយណ៍ ទំនប់កសិន្ទ ប្រឡាយទឹក) និងផ្លូវគមនាគមន៍ជាច្រើន។ ក្នុងរយៈពេលជាច្រើនសតវត្សរ៍ «អង្គរ» គឺជារាជធានីនៃអាណាចក្រខ្មែរ។ រមណីយដ្ឋានអង្គរដែលប្រកបដោយប្រាសាទដ៏តួរឱ្យស្ញប់ស្ញែង ទីតាំងអតីតរាជធានី និងបារាយណ៍ជាច្រើន គឺជាការប្រមូលផ្តុំតែមួយគត់នៃបណ្តាលក្ខណៈជាតិកតាងនៃអរិយធម៌រុងរឿង។ ប្រាង្គប្រាសាទដូចជាប្រាសាទអង្គរវត្ត ប្រាសាទបាយ័ន ប្រាសាទព្រះខ័ន និងប្រាសាទតាព្រហ្ម ដែលជានិទស្សនាហរណ៍នៃស្ថាបត្យកម្មខ្មែរ សុទ្ធសឹងតែផ្សារភ្ជាប់យ៉ាងជិតស្និទ្ធទៅនឹងបរិបទភូមិសាស្ត្រ ហើយក៏ជិតដាមទៅដោយអត្ថន័យជានិមិត្តរូបផងដែរ។ ស្ថាបត្យកម្ម និងប្លង់រាជធានីជាតិកតាងនៃសណ្តាប់ធ្នាប់ និងឋានានុក្រមសង្គមកម្រិតខ្ពស់នៅក្នុងចក្រភពខ្មែរ។ ដូច្នេះ «អង្គរ» ក្រៅពីបង្ហាញ ឱ្យឃើញនូវសោភ:សំខាន់ខ្ពស់ផ្នែកស្ថាបត្យកម្ម បុរាណវិទ្យា និងសិល្ប:ក៏ជារមណីយដ្ឋានឧម្មត្តច្នៃបញ្ញាំងនូវតម្លៃវប្បធម៌ សាសនា និងនិមិត្តរូបផងដែរ។

ឧទ្យានអង្គរមានប្រជាជនរស់នៅ មានភូមិឋានជាច្រើននៅរាយប៉ាយក្នុងទូទាំងឧទ្យាន ក្នុងនោះភូមិឋានខ្លះមានតាំងពីសម័យអង្គរមកម្ល៉េះ។ ប្រជាពលរដ្ឋច្រើនប្រកបមុខរបរកសិកម្ម ជាពិសេសរបរដាំស្រូវ។

លក្ខណៈវិនិច្ឆ័យ(១)

រមណីយដ្ឋានអង្គរតាំងមូលបង្ហាញអំពីសិល្ប:ខ្មែរតាំងពីដំបូងនាសតវត្សរ៍ទី៩ រហូតដល់ចុងបញ្ចប់នាសតវត្សរ៍ទី១៦ ហើយនៅក្នុងរមណីយដ្ឋាននេះ គេឃើញនូវកំពូលស្នាដៃឯកផ្នែកសិល្ប:ជាច្រើន (ឧទាហរណ៍ ប្រាសាទអង្គរវត្ត ប្រាសាទបាយ័ន ប្រាសាទបន្ទាយស្រី)។

លក្ខណៈវិនិច្ឆ័យ(២)

គេអាចមានអារម្មណ៍ថាសិល្ប:ខ្មែរដូចដែលឃើញសព្វថ្ងៃនៅរមណីយដ្ឋានអង្គរបានសាយភាយឥទ្ធិពលទៅផ្នែកភាគច្រើននៃតំបន់អាស៊ីអាគ្នេយ៍។ គេឃើញថា សិល្ប:ខ្មែរជើរតួនាទីដ៏សំខាន់ណាស់នៅក្នុងដំណើរវិវឌ្ឍន៍ដោយខ្លួនរបស់តំបន់នេះ។

លក្ខណៈវិនិច្ឆ័យ(៣)

ចក្រភពខ្មែរនៅចន្លោះសតវត្សរ៍ទី៩ និងសតវត្សរ៍ទី១៤ បានលាតសន្ធឹងទៅលើនយោបាយ និងវប្បធម៌នៃតំបន់។ អ្វីដែលនៅសល់ពីអរិយធម៌នេះ គឺបតិកកណ្ឌដ៏សម្បូរបែបនៃសំណង់សាសនាកសាងអំពីឥដ្ឋនិងថ្ម។

លក្ខណៈវិនិច្ឆ័យ(៤)

ស្ថាបត្យកម្មខ្មែរបានវិវឌ្ឍន៍ចេញពីឧបទ្វីបឥណ្ឌា ប៉ុន្តែបានផ្តាច់ខ្លួនពីឥទ្ធិពលឥណ្ឌាយ៉ាងឆាប់រហ័ស នៅពេលដែលស្ថាបត្យកម្មនេះបានអភិវឌ្ឍន៍លក្ខណៈរបស់ខ្លួន។ លក្ខណៈខ្លះបានរីកធំជាត់ដោយឯករាជ្យ លក្ខណៈខ្លះទៀតជាកស្រង់គំនិតពីប្រពៃណីវប្បធម៌ប្រទេសជិតខាង។ ជាលទ្ធផលសិល្ប:ខ្មែរ មានលក្ខណៈដោយខ្លួនរបស់ខ្លួន ហើយប្រៀបធៀបនឹងសិល្ប: និងស្ថាបត្យកម្មនៃបណ្តាប្រទេសតំបន់ចូរគាំ។

ប្លាណាគាព

តំបន់អង្គរត្រូបដណ្តប់ដោយសំណង់ប្រាសាទសំខាន់ៗ បណ្តាញ ជាភាសាស្ត្រសម័យចក្រភពខ្មែរ បណ្តាបាយណ៍និងប្រឡាយទាំង ឡាយនៅតែបន្តមានអត្ថិភាព។ ទិដ្ឋភាពប្រាសាទនីមួយៗ ទិដ្ឋភាព ប្រព័ន្ធធារាសាស្ត្រនីមួយៗ ទុះបញ្ជាំងឱ្យឃើញនូវលក្ខណៈនៅតង់ វង្សល្អរបស់រមណីយដ្ឋាន ទុះបញ្ជាំងឱ្យឃើញនូវភាពរុងរឿងនៃ រាជធានីសម័យបុរាណ។ ប៉ុន្តែប្លាណាគាពរបស់រមណីយដ្ឋាននៅ ពេលបច្ចុប្បន្នកំពុងប្រឈមនឹងសម្ពាធពីរប្រភេទ៖

១. សម្ពាធកើតចេញពីក្នុងអង្គរ បង្កដោយប្រជាពលរដ្ឋ ១០០០០០នាក់រស់នៅក្នុងភូមិចំនួន១១២ ពាយប៉ាយ ក្នុងរមណីយដ្ឋានដែលមាននិន្នាការជាប្រចាំចង់ពង្រីក ដីធ្លី ផ្ទះសំបែងរបស់ខ្លួនៗ

២. សម្ពាធកើតចេញពីក្រៅ ដោយសារស្ថិតនៅជាប់និង ទីក្រុងសៀមរាប ទីរួមខេត្ត និងជាកន្លែងទទួល ទេសចរស្នាក់នៅ។

ភាពដើម

ការងារអភិរក្សសៀមរាប និងជួសជុលអង្គរ ដែលបានធ្វើឡើងនៅ ចន្លោះឆ្នាំ១៩០៧និង១៩៩៦ ជាពិសេសធ្វើឡើងដោយសាលាបារាំង ចុងបូព៌ាប្រទេស (EFEO) ក្រុមបុរាណវិទ្យាប្រទេសឥណ្ឌា (ASI) អង្គការអភិរក្សរបស់ប្រទេសប៉ូឡូញ (PKE) និងអង្គការមូលនិធិនៃ ប្រាង្គប្រាសាទពិភពលោក (WMF) ពុំបង្កផលប៉ះពាល់គួរឱ្យកត់ សម្គាល់ទៅលើភាពដើមរបស់បណ្តាប្រាសាទទាំងឡាយនៅតំបន់ អង្គរទេ ហើយក៏មិនបង្កផលប៉ះពាល់ដល់ចំណាប់អារម្មណ៍រួមអំពី ប្រាសាទនីមួយៗដែរ។

គោលការណ៍ទាំងឡាយដែលតម្រូវ ជាចាំបាច់ក្នុងការងារការពារ និងត្រប់ត្រង

សម្បត្តិបេតិកភណ្ឌអង្គរត្រូវបានការពារលើផ្នែកច្បាប់ ដោយព្រះរាជ ក្រឹត្យលេខ០០១នស ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៩៦ ស្តីពីការ កំណត់និងការចាត់ចែងត្រប់ត្រងតំបន់សៀមរាប-អង្គរ។ ច្បាប់ស្តីពីកិច្ច ការពារបេតិកភណ្ឌវប្បធម៌ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ នស/រកត/០១៩៦/៦៦ ចុះថ្ងៃទី៦៩ ខែមករា ឆ្នាំ១៩៩៦។ ព្រះរាជក្រឹត្យលេខ នស/រកត/០៦៩៥/១២ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរជាតិអប្សរា។ សេចក្តីសម្រេចរបស់ រាជរដ្ឋាភិបាលលេខ៣០សសរ ស្តីពីការកំណត់បទដ្ឋាននៃការប្រើ ប្រាស់ដីធ្លីនៅតំបន់១ និងតំបន់២ ក្នុងតំបន់រមណីយដ្ឋានសៀមរាប-អង្គរ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០០៤ ដែលកំណត់ថា ដីធ្លីទាំងអស់ ដែលស្ថិតក្នុងតំបន់១ និងតំបន់២ ក្នុងរមណីយដ្ឋានសៀមរាប-អង្គរ គឺជាដីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង អនុក្រឹត្យលេខ ៥០ អនក្រ.បក ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋាន នៃអាជ្ញាធរជាតិអប្សរា ចុះថ្ងៃទី ៨ ខែឧសភា ឆ្នាំ២០០៨ ដែលបាន ចែងច្បាស់អំពីការបង្កើតនាយកដ្ឋានមួយទទួលបន្ទុកចុះបញ្ជីដីធ្លី រៀបចំដែនដី និងត្រប់ត្រងលំនៅដ្ឋានក្នុងឧទ្យានអង្គរ។ ដើម្បី ពង្រឹងការងារត្រប់ត្រងដីធ្លី និងសំណង់ក្នុងតំបន់ការពារទី១ និង ទី២ បង្គោលកំណត់ព្រំប្រទល់តំបន់ការពារទី១ និងទី២ ត្រូវបានដាំ តាំងពីឆ្នាំ២០០៤មក រួចបន្តនៅឆ្នាំ២០០៨ និងបញ្ចប់នៅឆ្នាំ២០១៦។



តំបន់ដៅក្នុងបរិវេណរមណីយដ្ឋានអង្គរ និងខេត្តសៀមរាប

តាមព្រះរាជក្រឹត្យលេខ០០១នស ស្តីពីការកំណត់និងការចាត់ចែងគ្រប់គ្រងតំបន់សៀមរាប-អង្គរ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៩៦ តំបន់សៀមរាប-អង្គរទាំងមូល ត្រូវបានបែងចែកជាថតំបន់ដែលមានកម្រិតការពារខុសៗគ្នា៖


- តំបន់១ គឺជារមណីយដ្ឋានមានប្រាសាទ (ប្រាង្គប្រាសាទប្រវត្តិសាស្ត្រ និងស្ថានីយបុរាណវត្ថុកម្រិតជាតិ)។
- តំបន់២ គឺឧទ្យានបុរាណវត្ថុត្រូវការពារ(តំបន់ទ្រទាប់ដែលស្ថិតនៅជុំវិញរមណីយដ្ឋានមានប្រាសាទ)។
- តំបន់៣ គឺតំបន់ទេសភាពវប្បធម៌ត្រូវការពារ(បរិស្ថានដែលបង្កើតឡើងដោយអន្តរាគមន៍របស់មនុស្សឆ្លងកាត់ពេលវេលា)។
- តំបន់៤ គឺជាតំបន់ដែលមានសារប្រយោជន៍ខាងបុរាណវត្ថុវិទ្យា ឬប្រវត្តិសាស្ត្រ (រមណីយដ្ឋានដែលគេស្គាល់ទីតាំងឬត្រូវរកទីតាំងហើយដែលសារៈសំខាន់របស់តំបន់នេះ គឺអាចស្គាល់តែតាមរយៈការសិក្សាស្រាវជ្រាវនៅទីដែលនៅក្រោមដីប៉ុណ្ណោះ)។
- តំបន់៥ គឺជាបរិវេណសម្រាប់អភិវឌ្ឍសង្គម សេដ្ឋកិច្ច និងវប្បធម៌នៃតំបន់សៀមរាប-អង្គរ។

រមណីយដ្ឋានអង្គរ ដែលចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោក មានផ្ទៃដីចំហំ៦០១គីឡូម៉ែត្រក្រឡា (ពោលគឺប្រហែល ៦០១០០០ហិកតា) ហើយនៅកន្លែងខ្លះមានប្រជាជនរស់នៅ។ ទឹកដីអង្គរមាន៣ផ្នែក ផ្នែកទី១មានផ្ទៃដី៣៩១គីឡូម៉ែត្រក្រឡា (២៦គ.ម x ១៣គ.ម) គឺជារមណីយដ្ឋានអង្គរក្នុងន័យចង្អៀត។ ផ្នែកនេះរួមមានតំបន់១ រមណីយដ្ឋានមានប្រាសាទ និងតំបន់២ ឧទ្យានបុរាណវត្ថុត្រូវការពារស្ថិតនៅជុំវិញរមណីយដ្ឋានមានប្រាសាទ ស្របតាមបទដ្ឋានរបស់អនុសញ្ញានៃបេតិកភណ្ឌពិភពលោក។ បណ្តុំតំបន់១ និងតំបន់២នេះបង្កើតបានជាចតុកោណកែងធំជាមួយ គ្របដណ្តប់ចាកយណ៍ខាងលិច ចាកយណ៍ខាងជើង និងចាកយ៉ាណ៍ខាងកើត។ ចតុកោណកែងនេះភ្ជាប់ទៅតំបន់ការពាររមណីយដ្ឋានបន្ទាយស្រី (៦០គីឡូម៉ែត្រក្រឡា) នៅខាងជើងនិងភ្ជាប់ទៅរមណីយដ្ឋានរលួស(៣០គីឡូម៉ែត្រក្រឡា) នៅទិសអាគ្នេយ៍។ នៅក្នុងរមណីយដ្ឋានទាំងពីរខាងក្រោយនេះតំបន់១និងតំបន់២បានត្រួតស៊ីគ្នា។ ព្រះរាជក្រឹត្យលេខ០០១នស កំណត់តំបន់៣ ជាតំបន់ការពារទេសភាពវប្បធម៌មានលក្ខណៈបរមបុរាណ ដែលភ្ជាប់រវាងរមណីយដ្ឋានទាំងពីរខាងលើ ហើយការពារបរិវេណពិសេសដូចជាដងស្ទឹងរលួស ដងស្ទឹងសៀមរាប ដែលគ្របដណ្តប់តំបន់ក្រុងសៀមរាបទាំងមូល។

តំបន់៤ បម្រុងទុកសម្រាប់តំបន់នៅជាប់ឆ្ងាយពីគ្នា ឬតំបន់ដែលត្រូវធ្វើចំណាត់ថ្នាក់នៅខាងមុខ ដោយយោងតាមលទ្ធផលនៃការរកឃើញថ្មីៗ។ តំបន់នេះតម្រូវឱ្យមានការការពារកម្រិតប្រហាក់ប្រហែលនឹងតំបន់៦ដែរ។

តំបន់១ និងតំបន់២ ជាតំបន់ការពារកម្រិតខ្ពស់ពុំអនុញ្ញាតឱ្យសាងសង់អគារលំនៅដ្ឋានថ្មីឡើយ រីឯដីធ្លីជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ។ តំបន់១ ត្រូវបានបម្រុងទុកសម្រាប់កិច្ចការពារ និងការលើកតម្កើងរមណីយដ្ឋានមានប្រាសាទ។ ការសាងសង់ដែលអនុញ្ញាតបានតឹមតែការសាងសង់ទាំងឡាយផ្សារភ្ជាប់ជាមួយនឹងការរៀបចំការទស្សនារបស់ភ្ញៀវទេសចរប៉ុណ្ណោះ ការសាងសង់លំនៅដ្ឋានថ្មីរបស់ប្រជាពលរដ្ឋពុំអនុញ្ញាតទេ។ ក្នុងតំបន់២ គម្រោងអភិវឌ្ឍន៍ទាំងឡាយត្រូវបានកម្រិតត្រឹមកិច្ចការពារ ការលើកតម្កើងរមណីយដ្ឋានបុរាណវិទ្យា និង «ការអភិរក្សរបៀបរស់នៅរបស់ប្រជាពលរដ្ឋមូលដ្ឋាន» តែប៉ុណ្ណោះ។ ក្នុងតំបន់៦ អាចមានការអនុញ្ញាតឱ្យសាងសង់មជ្ឈមណ្ឌលសិប្បកម្មខ្នាតតូច។ ភូមិចាស់ទាំងឡាយរបស់ប្រជាពលរដ្ឋត្រូវថែរក្សា ប៉ុន្តែពុំអនុញ្ញាតឱ្យពង្រីកថែមទៀតឡើយ។

ប្លង់សិទ្ធិអាស្រ័យផលលើដីធ្លីរបស់ក្រុមហ៊ុនមីកាដូកាប៊ីនេសាក្នុងខេត្តព្រះវិហារ




អាជ្ញាធរជាតិអប្សរ

អាជ្ញាធរជាតិអប្សរ

អាជ្ញាធរជាតិអប្សរ ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលមានឈ្មោះថា «អាជ្ញាធរដើម្បីការពារ រមណីយដ្ឋាននិងរៀបចំតំបន់អង្គរ» ហៅជាភាសាបារាំងថា «Autorité pour la Protection du Site et l'Aménagement de la Région d'Angkor» និងហៅកាត់ជា ភាសាអង់គ្លេសថា «APSARA National Authority» ស្ថិតក្រោមអាណាព្យាបាលបច្ចេកទេសដោយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងស្ថិតក្រោមអាណាព្យាបាលហិរញ្ញវត្ថុដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

អាជ្ញាធរជាតិអប្សរា
APSARA



អាជ្ញាធរជាតិអប្សរាត្រូវបានបង្កើតឡើងនៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ១៩៩៥ ដើម្បីធ្វើយតបទៅនឹងលក្ខណៈមួយក្នុងចំណោមលក្ខណៈទាំងច្រើនដែលគណៈកម្មាធិការបេតិកភណ្ឌពិភពលោកសំណូមពរឱ្យប្រទេសកម្ពុជាបំពេញពេលដែលអង្គរបានចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោកនិងក្នុងបញ្ជីបេតិកភណ្ឌពិភពលោកប្រឈមនឹងគ្រោះថ្នាក់នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៩៦។

នៅក្នុងដំណាក់កាលដំបូងៗ នៃការចាប់ផ្តើមប្រតិបត្តិការការងាររបស់ខ្លួន អាជ្ញាធរជាតិអប្សរា បានកំណត់នូវផែនការយុទ្ធសាស្ត្រជាអាទិភាពជាក់លាក់ដើម្បីជំរុញផែនការឱ្យក្លាយជាលទ្ធផលសម្រេចជាក់ស្តែង។ ការងារអាទិភាពនៅពេលនោះ គឺប្រើប្រាស់នូវគ្រប់លទ្ធភាពឬធនធាន រួមទាំងយន្តការជាតិ និងអន្តរជាតិដើម្បីជួសជុលសង្គ្រោះបន្ទាន់ដល់ប្រាង្គប្រាសាទនានាដែលកំពុងប្រឈមនឹងគ្រោះថ្នាក់យ៉ាងខ្លាំងពីការខ្ទ្រានដោយព្រៃឈើ កន្លះខាតនៃការថែរក្សាដោយមូលហេតុសង្គ្រាមស៊ីវិល គ្រាប់មីន និងការលួចតាស់តកាយរកវត្ថុបុរាណជាដើមៗជាក់ស្តែង តាមរយៈអាយស៊ីស៊ី-អង្គរ មានស្ថាប័នអន្តរជាតិជាច្រើន ដែលជាតំណាងឱ្យរដ្ឋាភិបាលនៃប្រទេសទាំងនោះ បានបើកការដ្ឋានជួសជុលជាបន្តបន្ទាប់ដើម្បីជាទាយ ប្រាង្គប្រាសាទទាំងនោះនឹងលែងប្រឈមនឹងគ្រោះថ្នាក់ហើយរក្សាបានតរៀងទៅ។ ក្នុងបរិបទការងារដូចពេលខាងលើនេះហើយ ទើបរយៈពេល១០ឆ្នាំក្រោយ គឺនៅឆ្នាំ២០០៤ គណៈកម្មាធិការបេតិកភណ្ឌពិភពលោកប្រកាសជានិយ្យាភកថា រមណីយដ្ឋានអង្គរលែងជាបេតិកភណ្ឌពិភពលោកដែលប្រឈមនឹងគ្រោះថ្នាក់ទៀតហើយ។

ដោយសម្គាល់ឃើញការវិវឌ្ឍន៍ដ៏ធំធេងហើសនៃសកម្មភាពជួសជុលសង្គ្រោះបន្ទាន់នៃប្រាង្គប្រាសាទក្នុងរមណីយដ្ឋានអង្គរ សន្និសីទអន្តរដ្ឋាភិបាលដើម្បីអភិរក្សនិងអភិវឌ្ឍន៍រមណីយដ្ឋានអង្គរ បានរៀបចំជាលើកទី២ នៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៣ បានផ្តល់អនុសាសន៍សំខាន់ៗដោយផ្តោតជាពិសេសលើការរៀបចំផែនការត្រប់ត្រង់ រមណីយដ្ឋានអង្គរទាំងមូលព្រមទាំងយកចិត្តទុកដាក់លើការងារ ត្រប់ត្រងទឹក ព្រៃឈើ និង សហគមន៍។ ស្របតាមទិសការខាងលើ អាជ្ញាធរជាតិអប្សរា បានបង្កើតនាយកដ្ឋានជំនាញបន្ថែមទៀតដើម្បីពង្រីកវិសាលភាពការងារស្របតាមផែនការយុទ្ធសាស្ត្រ ជាអាទិភាពថ្មីពេលគឺ អភិរក្សដើម្បី



បាកយណ៌ាកជតាជាក ឬបាកយណ៌ាខាងជើង

អភិវឌ្ឍន៍ និងអភិវឌ្ឍន៍ដើម្បីអភិរក្ស។ ក្នុងន័យនេះ អាជ្ញាធរជាតិអប្សរាត្រូវរៀបចំ និងគ្រប់គ្រងរមណីយដ្ឋានអង្គរឱ្យបានកាន់តែល្អប្រសើរ ដើម្បីទាក់ទាញភ្ញៀវទេសចរ និងដើម្បីឱ្យរមណីយដ្ឋានអង្គរក្លាយជាប្រភពចំណូលយ៉ាងក្រាស់ក្រែលសម្រាប់អភិវឌ្ឍន៍រមណីយដ្ឋានអង្គរ ក៏ដូចជាសេដ្ឋកិច្ចតំបន់និងជាតិទាំងមូល។ ដូចគ្នាដែរ តាមរយៈការអភិវឌ្ឍប្រកបដោយចីរភាពនេះហើយ ទើបមានចរន្តនៃធនធានហិរញ្ញវត្ថុត្រូវបានត្រឡប់ទៅបម្រើដល់ការងារអភិរក្សជួសជុលជ្រាវជ្រាវនិងការពារវិញ។

ទន្ទឹមគ្នានេះដែរ ការសិក្សាអំពីសង្គមដោយផ្តោតលើប្រព័ន្ធពាក់ព័ន្ធសាស្ត្របុរាណ ប្រពៃណីជំនឿសាសនា ទំនៀមទម្លាប់ របៀបរបបរស់នៅរបស់អ្នកស្រុកអង្គរ ត្រូវបានអាជ្ញាធរជាតិអប្សរាសិក្សាស្រាវជ្រាវតាមបែបវិទ្យាសាស្ត្រផង បែបបុរាណវិទ្យាផង ដើម្បីឈ្វេងយល់ស៊ីជម្រៅនិងទូលំទូលាយអំពីប្រវត្តិសាស្ត្រ សង្គម និងលក្ខណៈអរូបីនៅរមណីយដ្ឋានអង្គរ ជាក់ស្តែង បាកយណ៌ាកជតាជាក ឬបាកយណ៌ាខាងជើងដែលជាសំណង់ប្រវត្តិសាស្ត្របុរាណធ្លាប់គោកវិនស្ងួតជាច្រើនរយឆ្នាំមកហើយ ត្រូវបានបំពេញទឹកជាថ្មីឡើងវិញកាលឆ្នាំ២០០៨។ ការបំពេញទឹកឡើងវិញនេះធ្វើឱ្យទេសភាពវប្បធម៌ នាសតវត្សរ៍ទី១៦ ដែលបានបាត់បង់អស់រយឆ្នាំទៅហើយនោះ ត្រូវបានរំលេចរូបភាពឡើងវិញយ៉ាងប្រចក្សចំពោះភ្នែកយើងរាល់គ្នាជាថ្មីម្តងទៀតនាសតវត្សរ៍ទី២១តាមរយៈការងារគ្រប់គ្រងទឹក។





បន្ថែមលើនេះ អាជ្ញាធរជាតិអប្សរា ក៏បានធ្វើសកម្មភាពអភិវឌ្ឍន៍សហគមន៍ជាច្រើនតាមរយៈ ការងារបណ្តុះបណ្តាលសមត្ថភាពជំនាញការបង្កើតមុខរបរចិញ្ចឹមជីវិត ការចេះគ្រប់គ្រង និងប្រើប្រាស់ដោយចីរភាពនូវធនធានជម្មជាតិ ការកសាងសហគ្រាសន៍សម្ព័ន្ធរបស់ខ្លួន ដើម្បីបម្រើដល់ផលប្រយោជន៍សេដ្ឋកិច្ចនិងសង្គម។

លើកតម្កើង និងថែរក្សាជារៀងរហូតមក។ ផែនការយុទ្ធសាស្ត្រជាអាទិភាពបន្ទាប់របស់ អាជ្ញាធរជាតិអប្សរា ត្រូវបានផ្តោតលើការរក្សាឱ្យបាននូវអត្តសញ្ញាណនៃរមណីយដ្ឋាន ដូចបានកំណត់ខាងលើ ពោលគឺត្រូវគិតគូរឱ្យបានហ្មត់ចត់ដោយមានការប្រុងប្រយ័ត្នឱ្យមានសុខដុមនីយកម្មគ្នារវាងប្រាង្គប្រាសាទ ទឹក ព្រៃឈើ និងការរស់នៅរបស់ប្រជាពលរដ្ឋក្នុងតំបន់រមណីយដ្ឋានអង្គរ។ លើសពីនោះ អាជ្ញាធរជាតិអប្សរា ក៏ត្រូវយកចិត្តទុកដាក់ចម្បងលើការងារបណ្តុះបណ្តាលកម្រិតជំនាញរបស់អ្នកជំនាញខ្មែរឱ្យកាន់តែមានសុក្រឹតភាព និងប្រកបដោយវិជ្ជាជីវៈ។

បើទោះបីជាអាជ្ញាធរជាតិអប្សរា សម្រេចបាននូវសមិទ្ធផលដ៏ធំធេងយ៉ាងណាក្តី ក៏មានការងារអាទិភាពផ្សេងៗទៀតដែលត្រូវយកចិត្តទុកដាក់ជាប្រចាំ។ សូមធ្វើការកត់សម្គាល់ថា យោងលទ្ធផលសន្និសីទអន្តរក្រសួងស្តីពីការអភិរក្ស និងអភិវឌ្ឍន៍រមណីយដ្ឋានអង្គរ លើកទី៣ ប្រព្រឹត្តទៅនៅថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០១៣ នាទីក្រុងសៀមរាប រមណីយដ្ឋានអង្គរត្រូវបានពិពណ៌នាថាជារមណីយដ្ឋានមានជីវិត ដោយមានសមាសធាតុផ្សំសំខាន់ៗដូចជា ប្រាង្គប្រាសាទ ធម្មជាតិ និងមនុស្ស។ ការសន្និដ្ឋានបែបនេះ ក៏ព្រោះតាំងពីសម័យបុរាណរហូតដល់បច្ចុប្បន្ន អង្គរពុំដែលត្រូវបោះបង់ចោលណានោះទេ ហើយអ្នកស្រុកដែលរស់នៅជុំវិញអង្គរក៏តែងតែប្រតិបត្តិយ៉ាងខ្ជាប់ខ្ជួននូវប្រពៃណីទំនៀមទម្លាប់ជូនតា ដោយថែរក្សាទុកធម្មជាតិជុំវិញ និងប្រាង្គប្រាសាទជាកន្លែងស័ក្តិសិទ្ធិ និងបានថែរក្សាការពារពីមួយជំនាន់ទៅមួយជំនាន់ឥតដាច់។ ជាតិកតាងប្រវត្តិសាស្ត្រ ជួរវិញ្ញាណ និង ព្រលឹងនៃអង្គរត្រូវបាន

ហេតុនេះហើយទើបឯកសារគោលចម្បង។ ដែលមានចរិតជាត្រីវិស័យកំណត់ជាគោលនយោបាយដឹកនាំ អនុវត្តការងារ ត្រូវបានបង្កើតឡើងជាបន្តបន្ទាប់។ ឯកសារធម្មនុញ្ញអង្គរ និងឯកសារក្របខណ្ឌគ្រប់គ្រងបេតិក-កណ្ឌអង្គរ ត្រូវបានទទួលស្គាល់យ៉ាងខ្ពស់-ខ្ពស់ថា ជាឯកសារគោលរួមដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយសម្រាប់ប្រតិបត្តិលើការងារអភិរក្សនិងអភិវឌ្ឍន៍ក្នុងរមណីយដ្ឋានអង្គរ។

បេសកកម្មក្នុងដំណាក់កាលផ្ទេរតាត់របស់អាជ្ញាធរជាតិអប្សរា

ដំណាក់កាលទី១ (១៩៩៥-២០០៧)

- ការពារ ថែរក្សា អភិរក្ស និងលើកតម្លៃរមណីយដ្ឋានប្រវត្តិសាស្ត្រអង្គរ។
- គិតគូរដឹកនាំការងារវៀបចំ និងអភិវឌ្ឍន៍ទេសចរណ៍នៃតំបន់ចំនួនប្រាំ ដែលកំណត់នៅក្នុងព្រះរាជក្រឹត្យលេខ ០០១.នស ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ១៩៩៦ ស្តីពីការកំណត់និងការចាត់ចែងតំបន់សៀមរាប-អង្គរ។

ដំណាក់កាលទី២ (២០០៧-២០១៧)

បន្ថែមលើបេសកកម្មនៅក្នុងដំណាក់កាលទី១ អាជ្ញាធរជាតិអប្សរាមានបេសកកម្ម៖

- សិក្សាវៀបចំ និងគ្រប់គ្រងប្រកបដោយចីរភាពនូវ ធនធានធម្មជាតិដែលចាំបាច់សម្រាប់ការអភិវឌ្ឍ និងតុល្យភាពបរិស្ថាន ទឹក ព្រៃឈើ និងគុណភាពជីវៈ
- រួមចំណែកក្នុងការអនុវត្តគោលនយោបាយគាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាលក្នុងតំបន់សៀមរាប-អង្គរ ជាពិសេសវៀបចំ និងអនុវត្តឱ្យបានសម្រេចនូវគោលការណ៍អភិវឌ្ឍន៍សេដ្ឋកិច្ចនិងសង្គម ដើម្បីជាគុណប្រយោជន៍ប្រជាពលរដ្ឋក្នុងន្យាន។

ដំណាក់កាលទី៣ (២០១៧-បច្ចុប្បន្ន)

បន្ថែមលើបេសកកម្មនៅក្នុងដំណាក់កាលទី១ និងដំណាក់កាលទី២ តាមអនុសាសន៍នៃកិច្ចប្រជុំអន្តរក្រសួងលើកទី៣នៅទីក្រុងសៀមរាប តម្រូវឱ្យអាជ្ញាធរជាតិអប្សរាបំពេញបេសកកម្មរបស់ខ្លួន ដោយប្រើប្រាស់បច្ចេកទេសទំនើប ដើម្បីស្រាវជ្រាវ អភិរក្សនិងអភិវឌ្ឍន៍ប្រកបដោយចីរភាព ដូចខាងក្រោម៖

- ប្រព័ន្ធព័ត៌មានភូមិសាស្ត្រនិងរូបភាពផ្កាយរណបឬយន្តហោះ (Remote Sensing and GIS)
- បច្ចេកវិទ្យាឡាស៊ែរ LIDAR
- Drone
- និងបច្ចេកវិទ្យាទំនើប (Modern Technology) ផ្សេងៗទៀតៗលៗ

ថ្នាក់ដឹកនាំនៃអាជ្ញាធរជាតិអប្សរា



ឯកឧត្តម ង្គឿ ម៉ូលីវណ្ណ

- *អតីតទេសរដ្ឋមន្ត្រីទទួលបន្ទុកការងារវប្បធម៌ ទេសចរណ៍ និងសំណង់*
- *ឆ្នាំ១៩៩៥-២០០១ ៖ ប្រធានក្រុមប្រឹក្សាអភិបាលអាជ្ញាធរជាតិអប្សរា និងជាប្រធានអាជ្ញាធរជាតិអប្សរា*



សម្តេចឪឧបាសិកាបញ្ញា សុខ ខេង

- *អតីតអនុប្រធានរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី*
- *ឆ្នាំ២០០៦-២០១៧ ៖ ប្រធានក្រុមប្រឹក្សាអភិបាលអាជ្ញាធរជាតិអប្សរា និងជាប្រធានអាជ្ញាធរជាតិអប្សរា*



លោកជំទាវបណ្ឌិតសភាចារ្យ ងៀម សុវណ្ណា

- *រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ*
- *ឆ្នាំ២០១៧-បច្ចុប្បន្ន ៖ ប្រធានក្រុមប្រឹក្សាអភិបាលអាជ្ញាធរជាតិអប្សរា*



ឯកឧត្តម ឱម ណារិទ្ធ

- *សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គម និង វប្បធម៌*
- *ឆ្នាំ២០០១-២០១៥ ៖ អគ្គនាយកអាជ្ញាធរជាតិអប្សរា*



ឯកឧត្តម ស៊ឺ ម៉ាច់

- *រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ*
- *ឆ្នាំ២០១៥-២០១៩ ៖ អគ្គនាយកអាជ្ញាធរជាតិអប្សរា*




ឯកឧត្តម ហាច់ ពៅ

- *ឆ្នាំ២០១៩-បច្ចុប្បន្ន ៖ អគ្គនាយកអាជ្ញាធរជាតិអប្សរា*

រចនាសម្ព័ន្ធរបស់អាជ្ញាធរជាតិអប្សរា

ស្របតាមកំណែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាលកម្ពុជា អាជ្ញាធរជាតិអប្សរាត្រូវបានដាក់ឱ្យស្ថិតនៅក្រោមសមត្ថកិច្ចនិងការទទួលខុសត្រូវរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ដោយព្រះរាជក្រឹត្យលេខ នស/រកត/០៣១៧/៣១៣ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៧។ ដើម្បីបន្តជានាវិការគ្រប់គ្រងតំបន់រមណីយដ្ឋានអង្គរឱ្យមានប្រសិទ្ធភាពខ្ពស់ **លោកជំទាវបណ្ឌិតសភាចារ្យ ភឿន សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈត្រូវបានតែងតាំងជាប្រធានក្រុមប្រឹក្សាកិច្ចរបស់អាជ្ញាធរជាតិអប្សរា។ ក្រុមប្រឹក្សាកិច្ចអាជ្ញាធរជាតិអប្សរាមានមកពីតំណាងក្រសួងពាក់ព័ន្ធមួយចំនួន និងមានអគ្គនាយកអាជ្ញាធរជាតិអប្សរាជាសេនាធិការ។ អាជ្ញាធរជាតិអប្សរា ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល គ្រប់គ្រងរដ្ឋបាលដោយអគ្គនាយក អមដោយអគ្គនាយករងមួយចំនួនទទួលបន្ទុកផ្នែកការងារផ្សេងៗ ទីប្រឹក្សា និងអ្នកទទួលបន្ទុកបេសកកម្មមួយចំនួន។



មុខងារចិន្តការទទួលខុសត្រូវ

- ការពារ ថែរក្សា អភិរក្ស គ្រប់គ្រង និង លើកតម្កើងបុរាណវិទ្យា វប្បធម៌ បរិស្ថាន និង ប្រវត្តិសាស្ត្រ នៃរមណីយដ្ឋានអង្គរ ព្រមទាំងរមណីយដ្ឋានផ្សេងទៀតដែលត្រូវបានប្រគល់ជូន
- សិក្សារៀបចំ និង គ្រប់គ្រងធនធានធម្មជាតិដែលចាំបាច់សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព និង រក្សាគុណភាពបរិស្ថាន ទឹក ព្រៃឈើ ដីធ្លី និងគុណភាពដីក្នុងតំបន់ទាំង៥ ដែលបានកំណត់ដោយបទប្បញ្ញត្តិនៃព្រះរាជក្រឹត្យលេខ ០០១ ន.ស ចុះ ថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៩៦ ស្តីពីការកំណត់ និង ការចាត់ចែងគ្រប់គ្រងតំបន់សៀមរាប-អង្គរ
- សិក្សាលើកតម្កៃ និង/ឬជាក់ឱ្យដំណើរការឡើងវិញនូវគោលការណ៍ប្រតិបត្តិអង្គរ និងលោដ្ឋារចនាសម្ព័ន្ធអង្គរ ដូចជាប្រព័ន្ធទឹកបុរាណ ផ្លូវបុរាណ និងសេតិកកណ្តាលបុរាណ
- សិក្សារៀបចំអនុវត្តឱ្យបានសម្រេចនូវគោលដៅនៃការសិក្សាគាត ព្រមមានកម្មវិធីនៃការរៀបចំមូលដ្ឋានទាំងសម្រាប់ការអភិវឌ្ឍ និងកម្មវិធីអភិវឌ្ឍន៍ទេសចរណ៍ប្រកបដោយចីរភាពក្នុងតំបន់ទាំង៥ ដែលបានកំណត់ដោយបទប្បញ្ញត្តិនៃព្រះរាជក្រឹត្យលេខ ០០១ ន.ស ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៩៦ ស្តីពីការកំណត់ និងការចាត់ចែងគ្រប់គ្រងតំបន់សៀមរាប-អង្គរ
- គ្រប់គ្រង និងចាត់ចែងតំបន់បុរីសណ្ឋាគារ ឬហៅម្យ៉ាងទៀតថាបុរីវប្បធម៌និងទេសចរណ៍ ឱ្យស្របតាមស្តង់ដារតំបន់ទ្រនាប់នៃខណ្ឌអង្គរ ដែលជាសេតិកកណ្តាលពិភពលោក
- ស្វែងរកប្រភពហិរញ្ញប្បទាន ទុនវិនិយោគសម្រាប់ការអភិរក្ស និងអភិវឌ្ឍតំបន់អង្គរ ស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន
- រួមចំណែកក្នុងការអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនក្នុងតំបន់សៀមរាប-អង្គរ ជាពិសេសរៀបចំ និងអនុវត្តឱ្យបានសម្រេចនូវគម្រោងអភិវឌ្ឍន៍សេដ្ឋកិច្ចនិងសង្គមកិច្ច ដើម្បីជាគុណប្រយោជន៍ប្រជាពលរដ្ឋក្នុងតំបន់ខណ្ឌអង្គរ
- សហការជាមួយអាជ្ញាធរខេត្ត មន្ទីរ ក្រសួង-ស្ថាប័ន ពាក់ព័ន្ធ គ្រប់វិស្ថាន មូលនិធិ អង្គការជាតិ និងអន្តរជាតិនានា ដែលមានគោលបំណងស្របនឹងទិសដៅរបស់អាជ្ញាធរជាតិអប្សរា
- សម្របសម្រួល និងសហការជាមួយអង្គភាពនានា ដែលបំពេញការកិច្ចក្នុងតំបន់អង្គរចំពោះកិច្ចការពារសេតិកកណ្តាល សន្តិសុខ សណ្តាប់ធ្នាប់ សុវត្ថិភាព និងការផ្តល់សេវាកម្មទេសចរណ៍ ក្នុងខណ្ឌអង្គរ និងតំបន់ពាក់ព័ន្ធផ្សេងៗទៀត ។



ទស្សនវិស័យអនាគត

- *សិក្សារៀបចំចាត់ចែងអនុវត្តន៍រយៈពេលមធ្យម និងរយៈពេលវែងលើការថែរក្សា អភិរក្ស ការពារ និងជួសជុលប្រាសាទខ្មែរបុរាណ រួមទាំងការងារថែទាំនិងទប់ទ្រ។*
- *ការងារអភិវឌ្ឍន៍ទេសចរណ៍វប្បធម៌។*
- *ការងារគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន ដីធ្លី និងសហគមន៍ជាពិសេសបង្កើតសួនច្បារ ថ្នាលបណ្តុះកូនឈើ ដាំដើមឈើឡើងវិញដើម្បីការពារបរិស្ថាននិងទេសភាពវប្បធម៌។*
- *បង្កើនការរៀបចំសាងសង់នូវហេដ្ឋារចនាសម្ព័ន្ធរូបវន្តផ្សេងៗ ចាំបាច់ ដូចជាផ្លូវ ថ្នល់ ស្ពាន លូ ប្រព័ន្ធជាតសាស្ត្រ។*
- *ការងារបណ្តុះបណ្តាល ស្រាវជ្រាវ ផ្សព្វផ្សាយ និងសហប្រតិបត្តិការជាតិ-អន្តរជាតិ។*
- *លើកកម្ពស់ជីវភាពតាមរយៈការបណ្តុះបណ្តាល។*
- *ការពារការពារលាស់សំណង់បុរាណក្នុងតំបន់សៀមរាប-អង្គរ រួមមានៈ វត្តដែលមានលក្ខណៈប្រវត្តិសាស្ត្រ លំនៅដ្ឋានបុរាណ និងការលាស់សំណង់ស្ថាបត្យកម្មបុរាណដែលមានតម្លៃបេតិកភណ្ឌ។*

ការអភិវឌ្ឍធនធានមនុស្ស

- *កៀរគរធនធានិងបច្ចេកទេសពីដៃគូអន្តរជាតិក្នុងការបណ្តុះបណ្តាលសមត្ថភាពបុគ្គលិកនិងសហគមន៍។ ការបណ្តុះបណ្តាលចំណេះដឹង គឺបានអនុវត្តជាក់ស្តែងតាមការដ្ឋានតែម្រាំងរបស់ដៃគូអន្តរជាតិជាច្រើនដែលកំពុងអនុវត្ត។*
- *អភិវឌ្ឍន៍ចំណេះដឹងបុគ្គលិកឱ្យស្របទៅតាមស្ថានភាពវិឌ្ឍន៍ដែលតម្រូវឱ្យមានជំនាញបច្ចេកទេស បច្ចេកវិទ្យា និងចំណេះដឹងពិតប្រាកដសម្រាប់ធ្វើការងារដោយខ្លួនឯងបាននៅពេលអនាគត*
- *ជ្រើសរើសបុគ្គលិកដែលមានគុណភាព ជាពិសេសផ្តល់ឱកាសជូនប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់បេតិកភណ្ឌអង្គរ ជាអាទិភាពដើម្បីជំរុញពួកគាត់ឱ្យចូលរួមក្នុងកិច្ចការពារបេតិកភណ្ឌពិភពលោក ជាកត្តាជួយលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅក្នុងសហគមន៍នៃឧទ្យានអង្គរ។*
- *រៀបចំកម្មវិធីបណ្តុះបណ្តាលដោយធ្វើការផ្ទាល់នៅការដ្ឋាន និងបណ្តុះបណ្តាលពីវិធីសាស្ត្រថ្មីៗ ដើម្បីអភិវឌ្ឍន៍ជំនាញឱ្យធ្វើយតបទៅនឹងការកែចម្រើននៅតំបន់អង្គរ។*
- *បង្កើតឱ្យមានកម្មវិធីផ្លាស់ប្តូរការសិក្សាដល់មន្ត្រី-បុគ្គលិកថ្នាក់ខ្ពស់សម្រាប់បណ្តុះបណ្តាលបន្ថែមលើជំនាញ ដូចជាៈ ផ្នែកបុរាណវិទ្យា ស្ថាបត្យកម្ម វិស្វកម្ម សំណង់ស៊ីវិល និង ការសិក្សាពីសង្គមជាដើម...។ល។*

នៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២២ អាជ្ញាធរជាតិអប្សរាបានដាក់ឱ្យដំណើរការទម្រង់គេហទំព័រថ្មីជាផ្លូវការ ដើម្បីអបអរខួប៦៧ឆ្នាំនៃការបង្កើតអាជ្ញាធរជាតិអប្សរា www.apsaraauthority.gov.kh *ក្នុងគោលបំណងផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធអាជ្ញាធរជាតិអប្សរា ឯកសារទិន្នន័យរបស់អាជ្ញាធរជាតិអប្សរា ព័ត៌មានអំពីប្រាសាទនានា កិច្ចសហប្រតិបត្តិការអន្តរជាតិ និងព្រឹត្តិការណ៍សំខាន់ៗនៅតំបន់រមណីយដ្ឋានអង្គរ។ ទន្ទឹមនឹងការដាក់ឱ្យដំណើរការគេហទំព័រទម្រង់ថ្មីនេះ អាជ្ញាធរជាតិអប្សរា ក៏បានបង្កើតបណ្តាញទំនាក់ទំនងសង្គមមួយចំនួនរួមមានៈ* Instagram, LinkedIn, Telegram Chanel, Tik Tok និង APSARA Newsletter *សម្រាប់ផ្សព្វផ្សាយព្រឹត្តិការណ៍ព័ត៌មានរបស់អាជ្ញាធរជាតិអប្សរាឱ្យកាន់តែមានភាពទូលំទូលាយបន្ថែមទៀត។*



កិច្ចសហប្រតិបត្តិការអន្តរជាតិ

ចាប់តាំងពីអង្គរបានក្លាយជាសម្បត្តិសកលរួមនៃមនុស្សជាតិ នាថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៩៦មក ប្រទេសជាច្រើនចាប់ផ្តើមចូលរួមក្នុងកិច្ចការអភិរក្ស និងជួសជុលស្ថារមៀងវិញនូវប្រាង្គប្រាសាទមួយចំនួនក្នុងរមណីយដ្ឋានអង្គរ។



សកម្មភាពក្រុមអ្នកជំនាញការ
ជប៉ុនជួសជុលនៅប្រាសាទបាយ័ន

ព្រះប្រធានកិត្តិយស

- **ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ** ព្រះមហាវីរក្សត្រ ព្រះវរាជបិតា ឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ «ព្រះបរមរតនកោដ្ឋ» (១៩៤៣-២០០៤)

- **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា (២០០៤-បច្ចុប្បន្ន)

អាជ្ញាធរជាតិអង្គរ

ប្រធាន		អគ្គនាយក	
១. ឯកឧត្តម វណ្ណ មូលីវណ្ណ	(១៩៩៥ - ២០០១)	១. ឯកឧត្តម ប៊ិន ណារិទ្ធ	(២០០១-២០១៥)
២. សម្តេចវិបុលបញ្ញា សុខ អាន	(២០០១ - ២០១៧)	២. ឯកឧត្តម ស៊ុំ ម៉ាប់	(២០១៥-២០១៩)
៣. លោកជំទាវបណ្ឌិតសភាចារ្យ គៀវ សកុណា	(២០១៧-បច្ចុប្បន្ន)	៣. ឯកឧត្តម ហង់ ពៅ	(២០១៩-បច្ចុប្បន្ន)

សហប្រធានកិច្ចប្រជុំពេញអង្គ

ឯកអគ្គរដ្ឋទូតបារាំង		ឯកអគ្គរដ្ឋទូតជប៉ុន	
1. Philippe COSTE	(1991-1994)	1. Yukio IMAGAWA	(1991-1996)
2. Gildas LE LIDEC	(1994-1998)	2. Shohei NAITO	(1996-1997)
3. André LIBOUREL	(1998-2003)	3. Masaki SAITO	(1997-2000)
4. Yvon ROE D'ALBERT	(2003-2007)	4. Gotaro OGAWA	(2000-2003)
5. Jean-François DESMAZIERES	(2007-2010)	5. Fumiaki TAKAHASHI	(2003-2007)
6. Christian CONNAN	(2010-2012)	6. Katsuhiro SHINOHARA	(2007-2009)
7. Serge MOSTURA	(2012-2014)	7. Masafumi KUROKI	(2009-2013)
8. Jean-Claude POIMBŒUF	(2012-2017)	8.Yuji KUMAMARU	(2013-2016)
9. Éva NGUYEN-BINH	(2017-2021)	9. Hidehisa HORINOUCHI	(2016-2019)
10. Jacques PELLET	(2022-now)	10. Mikami Masahiro	(2019-now)

សហប្រធានកិច្ចប្រជុំបច្ចេកទេស

ទីប្រឹក្សាកិច្ចសហប្រតិបត្តិការ និងកិច្ចការពារជាតិ

1. Gilles CARASSO	(1994-1998)
2. Jacques GERARD	(1998-2002)
3. Dominique DORDAIN	(2002-2006)
4. Dominique FRESLON	(2006-2010)
5. Catherine MANCIP	(2010-2012)
6. Romain LOUVET	(2012-2016)
7. Guillaume NARJOLLET	(2016-2020)
8. Christophe GIGAUDAUT	(2020-2022)
9. Pierre VINCENT	(2022-now)

រដ្ឋមន្ត្រីជប៉ុន

1. Kenji YAMAMOTO	(1997-1999)
2. Eiji YAMAMOTO	(1999-2001)
3. Katsuhiro SHINOHARA	(2001-2004)
4. Susumu INOUE	(2004-2006)
5. Norio MARUYAMA	(2006-2009)
6. Hiroshi KAWAMURA	(2009-2012)
7. Yoshiro HIGUCHI	(2012-2015)
8.Takahisa TSUGAWA	(2015-2017)
9. Kenichi BESSHO	(2017-2020)
10. Atsushi KARIMATA	(2020-2022)
11. Ichitomo TANINAI	(2022-now)

អ្នកជំនាញការ

1. Prof. Mounir BOUCHENAKI	(1993 - now)
2. Prof Stefano DE CARO	(2020 - now)
3. Prof. Eric PALLOT	(2017 - now)
4. Prof. Masaya MASUI	(2018 - now)
5. Prof. Jean-Marie FURT	(2008 - now)
6. Prof. Bernard HUBERT	(2010 - now)
7. Prof. Shinji TSUKAWAKI	(2012 - now)
8. Prof. Georgio CROCI	(1993 - 2016)
9. Prof. André LABLAUDE	(1993 - 2017)
10. Prof. Hiroyuki SUZUKI	(1996 - 2009)
11. Prof. François HOULLIER	(2007 - 2008)
12. Prof. Tetsuji GOTO	(2008 - 2012)
13. Prof. Kenichiro HIDAKA	(2011 - 2017)

លេខាធិការដ្ឋាន

1. Prof. Azedine Beschaouch	(1993 - now)	5. Mr. Sébastien CAVALIER	(1996 - 2003)	8. Ms. Keiko MIURA	(1992 - 1998)
2. HE. Dr. CHAU Sun Kerya	(2020 - now)	6. Ms.Tamara TENEISHVILI	(1999 - 2006)	9. Mr. Bun Hok LIM	(2006 - 2014)
3. Mr. Masanori NAGAOKA	(2019 - now)	7. Mr. Philippe DELANGHE	(2007 - 2019)	10. Mr. Blaise KILIAN	(2006 - 2015)
4. Mr. NOU Niran	(2015 - now)				

ឃ្លាំណាស្ត-ភ្នំពេញ

1. Mr. Richard Engelhardt	(1991 - 1994)	3. Mr. Bruno Lefèvre	(1997 - 1998)	5. Mr. Teruo Jinnai	(2005 - 2010)
2. Mr. Khamlène Nhouyvanisvong	(1994 - 1996)	4. Mr. Etienne Clément	(1998 - 2005)	6. Ms. Anne Lemaistre	(2010 - 2018)
		7. Mr. Sardar Umar Alam	(2019 - now)		


VINGT-SIXIÈME SESSION TECHNIQUE
TWENTY-SIXTH TECHNICAL SESSION
CO-PRÉSIDÉE PAR / CO-CHAIRED BY
Mme/Mrs. Pascale TURQUET
Attachée de coopération
Cooperation Attaché
AMBASSADE DE FRANCE
EMBASSY OF FRANCE
M. /Mr. Takahisa TSUGAWA
Ministre/Chef de mission adjoint
Minister/Deputy Chief of Mission
AMBASSADE DU JAPON
EMBASSY OF JAPAN
Siem Reap – 22 & 23 juin 2016 – Salle de conférence de L'Autorité nationale APSARA
Siem Reap – 22 & 23 June 2016 – APSARA National Authority Conference Hall
EXIT
កិច្ចប្រជុំ អាយស៊ីស៊ី-អន្តរ

គណៈកម្មាធិការអន្តរជាតិ អាយស៊ីស៊ី-អង្គរ

អាយស៊ីស៊ី (ICC) ជាពាក្យកាត់មកពីភាសាអង់គ្លេស International Coordination Committee for the Safeguarding and Development of Historic Site of Angkor ដែលមានន័យជាភាសាខ្មែរថា គណៈកម្មាធិការអន្តរជាតិសម្រាបសម្រួលកិច្ចគាំពារ និងអភិវឌ្ឍន៍តំបន់អង្គរ។

គណៈកម្មាធិការអាយស៊ីស៊ី (ICC) បានបង្កើតឡើងនៅឆ្នាំ១៩៩៣ ក្រោយសន្និសីទអន្តរជាតិលើកទី១ស្តីពីអង្គរនៅទីក្រុងតូក្យូ ប្រទេសជប៉ុន តាមសំណូមពររបស់គណៈកម្មាធិការបេតិកភណ្ឌពិភពលោក ពេលទទួលចុះអង្គរទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោក។

ការបង្កើតយន្តការអន្តរជាតិ ICC សម្រាប់អង្គរ ជាលក្ខណៈមួយក្នុងចំណោមលក្ខណៈទាំង៥ ដែលតម្រូវឱ្យអាជ្ញាធរកម្ពុជាបំពេញក្នុងរយៈពេល៣ឆ្នាំ(១៩៩៣-១៩៩៦)។ លក្ខណៈទាំង៥នោះគឺ ៖

១. រៀបចំបង្កើតនីតិក្រមសម្រាប់ការពារបេតិកភណ្ឌឱ្យបានសមស្រប
២. បង្កើតស្ថាប័នជាតិទទួលបន្ទុកការពារមណ្ឌលអង្គរដោយមានបុគ្គលិកគ្រប់គ្រាន់
៣. បង្កើតគ្រឹះការពារមណ្ឌលអង្គរជាអចិន្ត្រៃយ៍
៤. បង្កើតតំបន់ទ្រទាប់ឱ្យបានសមស្រប
៥. បង្កើតយន្តការត្រួតពិនិត្យ និងសម្របសម្រួលកិច្ចខិតខំរបស់អន្តរជាតិក្នុងការអភិរក្សរមណ្ឌលអង្គរ។

ក្នុងរយៈពេល៣ឆ្នាំ ពីឆ្នាំ១៩៩៣ ដល់១៩៩៦ ប្រទេសកម្ពុជាបានបំពេញលក្ខណៈទាំងអស់ ទោះបីជាសង្គ្រាមផ្ទៃក្នុងនៅពុំទាន់បញ្ចប់នៅឡើយក្តី៖

១. នៅថ្ងៃទី៦៩ ខែមករា ឆ្នាំ១៩៩៦ ច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌពិភពលោក ត្រូវបានប្រកាសឱ្យប្រើជាការជ្វើយតបនឹងលក្ខណៈទី១
២. ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៩៩ អាជ្ញាធរដើម្បីការពារមណ្ឌលដ្ឋាន និងរៀបចំតំបន់សៀមរាប-អង្គរ ហៅថាអាជ្ញាធរជាតិអប្សរា ត្រូវបានបង្កើតឡើងដោយព្រះរាជក្រឹត្យលេខ០០១ នស/រកត/០២៩៩/១២ ជាការបំពេញលក្ខណៈទី៦
៣. ថ្ងៃទី២៩ ខែឧសភា ឆ្នាំ១៩៩៦ ព្រះរាជក្រឹត្យលេខ ០០១ នស ស្តីពីការកំណត់ និងការចាត់ចែងគ្រប់គ្រងតំបន់សៀមរាប-អង្គរត្រូវបានឡាយព្រះហស្តលេខាដោយ**ព្រះមហាក្សត្រ ព្រះបាទសម្តេចព្រះនរោត្តម សីហនុ** ជាការបំពេញលក្ខណៈទី៣ និងទី៤។
៤. បង្កើតទូវគណៈកម្មាធិការ ICC បំពេញលក្ខណៈទី៥។

សមាជិកនៃអាយស៊ីស៊ី (ICC) មានចំនួន៣៣ប្រទេស មកពីទ្វីបទាំង៥ មានអង្គការអន្តរជាតិចំនួន១៣ទៀត ចូលរួមជាសមាជិកដែរ។ បណ្តាប្រទេសទាំងនោះមាន៖ បារាំង អាល្លឺម៉ង់ អូស្ត្រាលី បែលហ្សិក ប្រ៊ុយណេ កម្ពុជា កាណាដា ជាណីម៉ាក អេហ្ស៊ីប អេស្ប៉ាញ អាមេរិក រុស្ស៊ី ក្រិច ហុងគ្រី ឥណ្ឌា ឥណ្ឌូណេស៊ី អ៊ីតាលី ជប៉ុន ឡាវ លុចហ្សំបួរ ម៉ាឡេស៊ី ម៉ុរ៉ុក នីវែស នូវែលហ្សេឡង់ ហូឡង់ ហ្វីលីពីន ប៉ូឡូញ ចក្រភពអង់គ្លេសនិងអៀរឡង់ខាងជើង សាធារណរដ្ឋកូរ៉េ ចិន សិង្ហបុរី ស្រីលង្កា ស៊ុយអែត ស៊្វីស ថៃ ទុយណេស៊ី និងវៀតណាម។

ចំណែកអង្គការអន្តរជាតិមានដូចជា៖ អង្គការស្បៀងអាហារ និងកសិកម្ម (FAO) ធនាគារអភិវឌ្ឍន៍អាស៊ី សហភាពអឺរ៉ុប អង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ អង្គការICROM អង្គការICOM អង្គការICOMOS អង្គការទេសចរណ៍អន្តរជាតិ (UNWTO) អង្គការSEAMEO/SPAFA អង្គការយូណេស្កូ (UNESCO) អង្គការUNDP អង្គការUNV និងមូលនិធិប្រាថ្នាសាទពិភពលោក (WMF) ។

អាយស៊ីស៊ី (ICC) គឺជាយន្តការអន្តរជាតិសម្រាប់សម្រួលដល់បណ្តាប្រទេស និងអង្គការផ្សេងៗចូលរួមអភិរក្ស និងអភិវឌ្ឍន៍រមណីយដ្ឋានប្រវត្តិសាស្ត្រអង្គរ។ អាយស៊ីស៊ី (ICC) ជាវេទិកាមួយដែលស្ថាបត្យករ វិស្វករ បុរាណវិទូ អ្នកស្រាវជ្រាវ និងអ្នកបច្ចេកទេសជំនាញផ្សេងៗគ្នាអាចផ្លាស់ប្តូរបទពិសោធន៍ និងទស្សនៈរបស់ពួកគេសម្រាប់ការអភិរក្ស និងការអភិវឌ្ឍនៃនរណាងអង្គរ។

ការកិច្ចសំខាន់របស់អាយស៊ីស៊ី (ICC) គឺ ស្រាវជ្រាវ អភិរក្ស និងអភិវឌ្ឍន៍ប្រកបដោយចីរភាព នៅតំបន់រមណីយដ្ឋានសៀមរាបអង្គរ។ អាយស៊ីស៊ី (ICC) រៀបចំកិច្ចប្រជុំរបស់ខ្លួនពីរដងក្នុង១ឆ្នាំ ម្តងជាមួយសមាជិកគឺកិច្ចប្រជុំពេញអង្គ និងម្តងទៀតគឺកិច្ចប្រជុំបច្ចេកទេស។ កិច្ចប្រជុំពេញអង្គផ្តោតលើការតម្រង់ទិសគោលនយោបាយគ្រប់គ្រងអំពាវនាវស្វែងរកជំនួយថវិកា សុពលភាពនៃគម្រោងថ្មី និងការប្រកាសពីគម្រោងថ្មីៗនៅអង្គរ។ ជាធម្មតាសម័យប្រជុំពេញអង្គនេះតែងរៀបចំនៅចុងឆ្នាំ។



ព្រះករុណាព្រះបាទ សម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ក្នុងខួបជាឆ្នាំនៃអង្គការយូណេស្កូ

ចំណែកឯ សម័យប្រជុំបច្ចេកទេសតែងធ្វើឡើងនៅពាក់កណ្តាលឆ្នាំ ហើយអនុញ្ញាតឱ្យអ្នកជំនាញបច្ចេកទេសផ្លាស់ប្តូរបទពិសោធន៍របស់ពួកគេ ពិភាក្សាអំពីបញ្ហាបច្ចេកទេស និងដំណោះស្រាយសម្រាប់បញ្ហាជាក់លាក់ៗ ។ កាលសម័យប្រជុំពាំងអស់របស់អាយស៊ីស៊ី (ICC) ឯកអគ្គរដ្ឋទូតនៃប្រទេសជប៉ាន់ និងជប៉ុនទៅកម្ពុជាធ្វើជាសហប្រធាននៃកិច្ចប្រជុំនេះ និងផ្តល់ជំនួយហិរញ្ញវត្ថុដែលចាំបាច់ផ្សេងៗ រីឯអង្គការយូណេស្កូធ្វើជាលេខាធិការដ្ឋាន និងផ្តល់ចំណាយពាក់ព័ន្ធនឹងបេសកកម្មរបស់ក្រុមអ្នកជំនាញអាជីវកម្មសម្រាប់ការអភិរក្ស។ ចំណែកអាជ្ញាធរជាតិអប្សរាបានរួមចំណែកតាំងពីឆ្នាំ២០០៦ ផ្តល់ជាជំនួយហិរញ្ញវត្ថុក្នុងដំណើរការរបស់គណៈកម្មាធិការ ការចំណាយលើបេសកកម្មក្រុមអ្នកជំនាញអាជីវកម្ម និងចំណាយពាក់ព័ន្ធនឹងការរៀបចំកិច្ចប្រជុំ។



សហប្រធានជប៉ាន់ និងជប៉ុន ក្នុងកិច្ចប្រជុំ អាយស៊ីស៊ី-អង្គរ



ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា យាងសម្ពោធបិទការដ្ឋានជួសជុលប្រាសាទបាភ្នួន



លោកជំទាវបណ្ឌិតសភាចារ្យ កៀវ សុភណា រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងជាប្រធានក្រុមប្រឹក្សាភិបាលអាជ្ញាធរដោតិអប្សរ ជីកពាំសហប្រធាននិងអ្នកជំនាញការ នៃគណៈកម្មាធិការអាយស៊ីស៊ី-អង្គរ ទូលគាល់ក្រោមថ្វាយបង្គំព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា

ប្រទេសណាខ្លះដែលចាន់ជួយអង្គរ ក្រោយពេលដែលអង្គរ ត្រូវចាន់ដាក់បញ្ចូលជាបេតិកភណ្ឌពិភពលោក?

ក្នុងនាមជាស្ថាប័នគ្រប់គ្រងរមណីយដ្ឋានអង្គរ អាជ្ញាធរជាតិអប្សរា បានដើរតួយ៉ាងសំខាន់ក្នុងកិច្ចការអភិរក្សនិងអភិវឌ្ឍន៍រមណីយដ្ឋានអង្គរ ដោយមានការកិច្ចជាម្ចាស់ផ្ទះផង ជាអ្នកសម្របសម្រួលជាមួយស្ថាប័នអន្តរជាតិផង ដោយឆ្លងតាមក្រុមជំនាញនៃគណៈកម្មាធិការអាយស៊ីស៊ី-អង្គរ ដើម្បីជួសជុលអភិរក្សគេរមរតកជូនតា។

ចាប់តាំងពីអង្គរបានចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោករួចមកមានស្ថាប័នអន្តរជាតិជាច្រើនបានមកជួយក្រសោចស្រង់អង្គរ មានទាំងគម្រោងអភិរក្ស ជួសជុលប្រាសាទ ស្រាវជ្រាវ បណ្តុះបណ្តាល និងអភិវឌ្ឍន៍សហគមន៍។



កិច្ចប្រជុំ អាយស៊ីស៊ី-អង្គរ

និយាយពីគម្រោងអភិរក្សនិងជួសជុលប្រាង្គប្រាសាទ មានស្ថាប័នអន្តរជាតិចំនួន៦១ មកពី១៣ប្រទេស បានអនុវត្តគម្រោងអភិរក្សនិងជួសជុលប្រាសាទចំនួន៣១គម្រោង។ ប្រទេសទាំង១៣ នោះរួមមាន ចិន សាធារណរដ្ឋបែក បាកាំង អាល្លឺម៉ង់ ឥណ្ឌា ជប៉ុន អ៊ីតាលី សាធារណរដ្ឋកូរ៉េ ឥណ្ឌូណេស៊ី ស្វីស អាមេរិក អូស្ត្រាលី និងហុងគ្រី។ ក្នុងនោះមានប្រទេសចំនួន៦បានបញ្ចប់គម្រោងរបស់ខ្លួន ទាំងស្រុងគឺសាធារណរដ្ឋបែក ឥណ្ឌូណេស៊ី ស្វីស និងហុងគ្រី។ តាមរយៈគម្រោងទាំងនេះ ប្រាសាទដែលមានសភាពទ្រុឌទ្រោមក្បាច់ចម្លាក់ និងរចនាសម្ព័ន្ធជាច្រើនត្រូវបានជួសជុលស្តារឡើងវិញជាបន្តបន្ទាប់។


វេទិកាតុមូលនៃ អាយស៊ីស៊ី-អន្តរ


បន្ថែមពីលើគម្រោងអភិរក្ស និងជួសជុលប្រាសាទ មានស្ថាប័នចំនួន៣៤ មកពីប្រទេសចំនួន១១ រួមមាន អូស្ត្រាលី បារាំង ហុងគ្រី អាមេរិក ជប៉ុន ថៃ អង់គ្លេស ចិន សិង្ហបុរី និងអ៊ីតាលី បានផ្តោតលើការសិក្សាស្រាវជ្រាវ និងបណ្តុះបណ្តាលធនធានមនុស្ស។ គម្រោងទាំង៦៦នេះ បានផ្តោតយ៉ាងសំខាន់លើកិច្ចការស្រាវជ្រាវក្នុងន័យបណ្តុះបណ្តាលអ្នកជំនាញនៃអាជ្ញាធរជាតិអប្សរា ព្រមទាំងនិស្សិតមកពីសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈជាច្រើនរូបទៀតផងដែរ។

ក្រៅពីគម្រោងអភិរក្សជួសជុលប្រាសាទស្រាវជ្រាវ និងបណ្តុះបណ្តាលធនធានមនុស្ស ក៏នៅមានស្ថាប័នចំនួន១០ទៀតបានចូលរួមក្នុងកិច្ចអភិវឌ្ឍន៍សហគមន៍ក្នុងន័យអន្តរ និងភូមិឥណ្ឌាតំរុនតាឯក ដូចជាការអភិវឌ្ឍទេសចរណ៍សហគមន៍ កសិកម្ម ប្រព័ន្ធទឹកស្អាត និងអនាម័យការប្រើប្រាស់ថាមពលពន្លឺព្រះអាទិត្យ បរិស្ថាន និងការអប់រំជាដើម។ ស្ថាប័នដែលអនុវត្តគម្រោងខាងលើនេះ មានប្រទេសញ៉ូវហ្សេឡែន បារាំង ជប៉ុន អាមេរិក ចិន និងសាធារណរដ្ឋកូរ៉េ។



កិច្ចប្រជុំ អាយស៊ីស៊ី-អន្តរ

ស្ថាប័នអន្តរជាតិទាំងអស់ ដែលបានអនុវត្តគម្រោងរបស់ខ្លួននៅក្នុងរមណីយដ្ឋានអន្តរ ជាពិសេសគឺគម្រោងអភិរក្សជួសជុលនិងការសិក្សា ស្រាវជ្រាវ គឺសុទ្ធតែត្រូវធ្វើការត្រួតពិនិត្យនិងអនុម័តពីគណៈកម្មាធិការអាយស៊ីស៊ី-អន្តរ។ ត្រង់គម្រោងដែលអនុវត្តក្នុងរមណីយដ្ឋានអន្តរ តែងមានមន្ត្រីជំនាញអាជ្ញាធរជាតិអប្សរាចូលរួមអនុវត្ត។ តាមរយៈការចូលរួមនេះ មន្ត្រីជំនាញជាច្រើនបានពង្រឹងសមត្ថភាពរបស់ខ្លួនហើយអាចកាន់គម្រោងជាច្រើនបានដោយខ្លួនឯងនាពេលបច្ចុប្បន្ន ដែលនេះគឺជាទិសដៅដ៏សំខាន់សមនឹងពាក្យស្លោក ដែលគេតែងលើកឡើងថា **មានតកន្លែរ ធ្វើដោយកូនខ្មែរ និងដើម្បីកូនខ្មែរ**។ ជាក់ស្តែង បច្ចុប្បន្នមានគម្រោងអភិរក្សជួសជុលជាច្រើនដែលកំពុងអនុវត្តដោយមន្ត្រីជំនាញខ្មែរសុទ្ធសាធ។



បារាំង
(France)

អស់រយៈពេល៣០ឆ្នាំមកហើយ ដែលប្រទេសបារាំងបានធ្វើជាសហប្រធាននៃអាយស៊ីស៊ី-អង្គរ ព្រមទាំងបានរៀបចំសន្និសីទអន្តរជាតិបាលស្តីពីអង្គរ នៅទីក្រុងប៉ារីសកាលពីឆ្នាំ២០០៣។ ប្រទេសនេះបានអនុវត្តការងារជួសជុលទីលានទាំងពីរក្នុងក្រុងអង្គរធំ ប្រាសាទបាភួន និងប្រាសាទមេបុណ្យខាងលិច។ ទន្ទឹមនឹងនេះ កំបានដឹកនាំកម្មវិធីស្រាវជ្រាវជាបរទេសកម្មសិក្សាលើបុរាណវិទ្យា និងសិលាចារឹក ឬការរៀបចំដែនដីនៃរមណីយដ្ឋានអង្គរ ព្រមទាំងការវិវឌ្ឍន៍នៃទីក្រុងផងដែរ។ មិនតែប៉ុណ្ណោះកំបានបង្កើតកម្មវិធីបណ្តុះបណ្តាលសំខាន់ៗ បង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលតំបន់សម្រាប់វិជ្ជាជីវៈបេតិកភណ្ឌ (កម្ពុជា ឡាវ និងវៀតណាម) និងផ្តល់ជាអាហារូបករណ៍សិក្សានៅតាមវិទ្យាស្ថានបណ្តុះបណ្តាលវិជ្ជាជីវៈជំនាញផ្សេងៗនៃប្រទេសបារាំងដល់អ្នកអភិរក្សជំនាន់ថ្មី ព្រមទាំងអ្នកគ្រប់គ្រងរមណីយដ្ឋាន។ ក្នុងគម្រោងពង្រឹងផ្ទៃដីនៃអាកាសយានដ្ឋានអន្តរជាតិសៀមរាប ក្រុមហ៊ុនបានផ្តល់ទំនុកចិត្តប្រគល់ការងារស្រាវជ្រាវទៅ "វិទ្យាស្ថានជាតិស្រាវជ្រាវបុរាណវិទ្យាបង្គារ (INRAP)" ដោយមានកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរជាតិអប្សរា។លើកិច្ចការងារអភិវឌ្ឍន៍ទីភ្នាក់ងារបារាំងដើម្បីអភិវឌ្ឍន៍ (AFD) បានសាងសង់ផ្លូវក្នុងបុរីវប្បធម៌និងទេសចរណ៍និងបានរួមចំណែកក្នុងការលើកតម្ងៃខេត្តសៀមរាបតាមរយៈការងារកែលម្អប្រាំងស្ទឹងសៀមរាប។














ជប៉ុន
(Japan)

ប្រទេសជប៉ុនជាអ្នកចៀបចំសន្និសីទអន្តរជាតិបាលលើកទីមួយស្តីពីអង្គរនៅឆ្នាំ១៩៩៣ហើយបានធ្វើជាសហប្រធានអាយស៊ីស៊ី-អង្គរអស់រយៈពេល៣០ឆ្នាំមកហើយ។ សកម្មភាពការងារចម្បង គឺផ្តោតលើការអភិរក្សនិងការស្រាវជ្រាវ។ ទន្ទឹមនឹងនេះក៏មានវត្តមានមជ្ឈមណ្ឌលស្រាវជ្រាវលើសម្បត្តិវប្បធម៌នៃទីក្រុងតូក្យូនៅប្រាសាទ-តានែ ឬវិទ្យាស្ថានជាតិណាក៉ា (ការជួសជុលប្រាសាទតុបខាងលិច) ព្រមទាំងសាកលវិទ្យាល័យនីហុនតូទូ អូសាកា កាណាហ្សាវ៉ា យ៉ូកូហាម៉ា។

ស្ថាប័ន JSA បានប្តូរឈ្មោះទៅជា JASA (ក្រុមអភិរក្សអង្គរជប៉ុន-អប្សារ) ទទួលបន្ទុកការងារជួសជុល និងលើកតម្កើងប្រាសាទបាយ័ន បន្ទាប់ពីបញ្ចប់ការងារនៅប្រាសាទសួរព្រ៊ែត្រ និងបណ្ណាល័យខាងលើងប្រាសាទអង្គរវត្ត។ រីឯសាកលវិទ្យាល័យសូហ្វីយ៉ាបានធ្វើរបាគំហើញបុរាណវិទ្យាដ៏សំខាន់នៅប្រាសាទបន្ទាយក្តីបន្ទាប់មកបានទទួលភ៉ាប់រងការងារជួសជុលស្ពានហាលខាងលិចនៃប្រាសាទអង្គរវត្ត។

សាកលវិទ្យាល័យនេះ ក៏បានដឹកនាំកម្មវិធីស្រាវជ្រាវស្តីពីការអភិវឌ្ឍធនធានមនុស្ស (មជ្ឈមណ្ឌលសូហ្វីយ៉ាអាស៊ីសម្រាប់ការងារស្រាវជ្រាវ និងអភិវឌ្ឍន៍ធនធានមនុស្ស)។ ចំណែកឯកម្មវិធីមេសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពនៃតំបន់ស្ទឹមរាប-អង្គរ បានរៀបចំឡើងដោយអង្គការJICA (ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន) ។









ឥណ្ឌា
(India)

ឥណ្ឌាជាប្រទេសដំបូងគេបំផុតដែលបានបង្ហាញចំណងមិត្តភាពរបស់ខ្លួនចំពោះកម្ពុជាបន្ទាប់ពីមានជម្លោះប្រជាប់អាវុធប្រមាណពីទសវត្សរ៍តាមរយៈការងារអភិរក្ស និងជួសជុលប្រាសាទអង្គរវត្តដោយក្រុមស្រាវជ្រាវបុរាណវិទ្យាឥណ្ឌា(ASI) ចាប់ពីឆ្នាំ១៩៨៦មក។

នៅឆ្នាំ២០០៤ ការងារអភិរក្សនិងជួសជុលប្រាសាទតាព្រហ្មត្រូវបានចាប់ផ្តើម រុក្ខជាតិដុះនៅលើប្រាង្គប្រាសាទបានបង្កឱ្យមានផលលំបាកក្នុងការជានាទូនៃនិរន្តរភាពនៃមរតកដ៏អស្ចារ្យនេះ។ ម៉្យាងទៀត ASI ក៏បានផ្ញើបញ្ជីសារពើភណ្ឌដុំថ្ម និងវត្ថុផ្សេងៗទៀតដែលមាននៅក្នុងបរិវេណប្រាសាទ។ ជរម្មីសសម្រាប់ប្រាសាទនេះ គឺធ្វើការជួសជុសតែផ្នែកខ្លះ ហើយរក្សាទុកផ្នែកខ្លះទៀតនៅក្នុងស្ថានភាពដើម។

រុក្ខជាតិធំៗដែលដុះខ្ចាននលើប្រាសាទ បង្កើតបានជាទេសភាពប្លែកមិនមួយសម្រាប់ប្រជនីយដ្ឋាន។ នេះជាជាតុដ៏សំខាន់នៃព្រះពុទ្ធសាសនាដែលត្រូវបានគេប្រតិបត្តិនៅក្នុងរាជ្យព្រះបាទជ័យវរ្ម័នទី៧។
















អាល្លឺម៉ង់
(Germany)

ការអនុវត្តកម្មវិធីជារួម៖

- *ការស្រាវជ្រាវ៖ ឯកសារវិទ្យាសាស្ត្រស្តីពីរូបចម្លាក់សម្ភារៈសំណង់ ថ្មំងតំនូរតាមជញ្ជាំង សិលាចារឹក និងចម្លាក់ក្រឌោតតាបនៅតាមប្រាសាទ។*
- *ការអភិរក្ស៖ការព្យាបាលជំងឺរបស់ថ្ម និងការអភិរក្សបាយអរ ឥដ្ឋ តំនូរណោបពណ៌ (polycromy)។*
- *ការបណ្តុះបណ្តាល៖ការផ្ទេរចំណេះដឹងបច្ចេកទេសទៅអ្នកអភិរក្សខ្មែរជំនាន់ក្រោយ។*
- *ការអភិវឌ្ឍ៖ គម្រោងកសិកម្ម-ព្រៃឈើក្រវាត់បៃតង-នៅតំបន់អង្គរនិងការផ្ទេរចំណេះដឹងពីកសិករទៅកសិករដូចគ្នា។*
- *អ្នកអនុវត្តការជាវ៖ គម្រោងអាល្លឺម៉ង់ដើម្បីអភិរក្សចម្លាក់អប្សរ (GACP) ទីភ្នាក់ងារអាល្លឺម៉ង់សម្រាប់កិច្ចសហប្រតិបត្តិការអន្តរជាតិ (GIZ) សាកលវិទ្យាល័យបោន។*















ហុងគ្រី
(Hungary)

មូលនិធិកជាណាចក្រអង្គរ (Royal Angkor Foundation) គឺជាសមាជិកស្ថាបនិកនៃអាយស៊ីស៊ី-អង្គរ។ មូលនិធិនេះបានសហការជាមួយអង្គការយូណេស្កូ ក្នុងការបង្កើតប្រព័ន្ធព័ត៌មានភូមិសាស្ត្រ (SIG) ដំបូងគេបង្អស់សម្រាប់រមណីយដ្ឋានអង្គរ។ នៅឆ្នាំ១៩៩៥-១៩៩៦ មូលនិធិនេះបានលើកការស្រាវជ្រាវដោយសហការជាមួយអង្គការ Nasa/Jet Propulsion Laboratory និងអង្គការមូលនិធិប្រាង្គប្រាសាទពិភពលោក (WMF) ដើម្បីប្រមូលទិន្នន័យបានពីប្រព័ន្ធទទួលព័ត៌មានពីចម្ងាយ (remote sensing) នៃតំបន់អង្គរ ក្នុងគោលបំណងប្រើប្រាស់ទិន្នន័យសម្រាប់ការងារជួសជុលប្រាសាទព្រះគោ។ ចាប់ពីឆ្នាំ២០០៨មក Hunico (Hungarian Indochina Company) បានបំពេញការងារថែរក្សា ការពារ និងលើកតម្លៃតំបន់កោះកេរ ដែលបច្ចុប្បន្នស្ថិតនៅក្រោមការគ្រប់គ្រងរបស់អាជ្ញាធរជាតិព្រះវិហារ។







ឥណ្ឌូណេស៊ី
(Indonesia)

ពីឆ្នាំ១៩៩៦ដល់ឆ្នាំ២០០០ ក្រុម ITASA (Indonesian Team for Safeguarding Angkor) បានទទួលភារៈការងារជួសជុលខ្លោងទ្វារចំនួនបីនៃព្រះបរមាជភ័ព្តិមានអាកាសដែលការងារនេះផ្តោតលើគោលជើងម្បាង គឺការបណ្តុះបណ្តាលអ្នកបច្ចេកទេសខ្មែរ។






សាធារណរដ្ឋឆេក
(Czech Republic)

ពីឆ្នាំ២០០៧ដល់២០១១ សាលាអភិរក្សនិងជួសជុលឆេកបានធ្វើកិច្ចអន្តរាគមន៍នៅប្រាសាទភិមានអាកាសក្នុងគោលបំណងបណ្តុះបណ្តាលយុវជនកម្ពុជាលើផ្នែកអភិរក្សនិងការជួសជុលថ្មប្រាសាទ។





ចក្រភពអង់គ្លេស
(United Kingdom)

ចាប់តាំងពីឆ្នាំ២០០៨មក មូលនិធិបុកណាវិទ្យានិងអភិវឌ្ឍន៍ (ADF) បានទទួលបន្ទុកក្នុងការស្រាវជ្រាវបុកណាវិទ្យានិងការអភិវឌ្ឍនៅលើកំពូលែនៗ។ មូលនិធិនេះបានផ្តួចផ្តើមធ្វើយុទ្ធនាការផ្សព្វផ្សាយដល់ប្រជាជនក្នុងតំបន់ឱ្យជ្រួតជ្រាបក្នុងការដោះការពារបរិស្ថានធនធានតែកកណ្តាប្បធម៌។











សិង្ហបុរី
(Singapore)


សាកលវិទ្យាល័យសិង្ហបុរី បានចូលរួមធ្វើកំណាយបុកណាវិទ្យាជាច្រើននៅលើកំពូលែនៗ។ វិទ្យាស្ថានស្រាវជ្រាវអាស៊ី-អាគ្នេយ៍ (ISEAS) ទទួលបន្ទុកក្នុងការធ្វើកំណាយទីតាំងផលិតកុលាលភាជន៍ដែលមានស្រទាប់រលោងនៅតំបន់ទ័ពជ័យ។នៅឆ្នាំ២០១៣គម្រោងកំណាយទ្វេភាគីរវាងវិទ្យាស្ថានស្រាវជ្រាវអាស៊ីអាគ្នេយ៍និងអាជ្ញាធរជាតិអប្សរានៅប្រាសាទទន្ទេសួត បានរកឃើញឡើងវិញនូវវត្ថុសិល្បៈមួយចំនួនដែលក្នុងនោះមានបដិមាព្រះពុទ្ធគ្រួថ្នាំ(តែសផ្សគុក្ក)។











ប្រទេសថៃ
(Thailand)

គម្រោងសិក្សាទ្វេភាគីកម្ពុជា-ថៃ ដែលមានសមាសភាពចូលរួមពីសាកលវិទ្យាល័យជាច្រើននៃប្រទេសថៃ បានស្រាវជ្រាវបុរាណវិទ្យាឆ្លងកាត់ខ្សែបន្ទាត់ព្រំដែននៃប្រទេសទាំងពីរក្នុងក្របខណ្ឌគម្រោងស្រាវជ្រាវបណ្តាញគមនាគមន៍សម័យអង្គរ រួមទាំងមន្ទីរពេទ្យដែលបានកសាងឡើងក្នុងរាជ្យព្រះបាទជ័យវរ្ម័នទី៧។



កាណាដា
(Canada)

ក្នុងបរិបទអភិវឌ្ឍន៍ប្រកបដោយចីរភាព ប្រទេសកាណាដាបានចូលរួមបង្កើតឋានជំនេរុំមិនធម្មជាតិរុនតាឯកដែលជាការផ្តួចផ្តើមថ្មីមួយក្នុងការរៀបចំបង្កើតលំនៅដ្ឋានបែបធម្មជាតិ។











ញូវហ្សីឡែន
(New Zealand)

ដើម្បីលើកកម្ពស់សមត្ថភាពក្នុងការគ្រប់គ្រងរមណីយដ្ឋានអង្គរ ប្រទេសញូវហ្សីឡែនបានផ្តល់ជំនួយហិរញ្ញវត្ថុលើគម្រោងកែទម្រង់រចនាសម្ព័ន្ធផ្នែកក្នុងរបស់អាជ្ញាធរជាតិ-អប្សរា។ រចនាសម្ព័ន្ធថ្មីៗត្រូវបានបង្កើតឡើងដើម្បីជួយសហគមន៍ដែលរស់នៅក្នុងតំបន់អង្គរ ។







អូស្ត្រាលី
(Australia)

ប្រទេសអូស្ត្រាលី បានបង្កើតមូលនិធិដែលតម្កល់នៅអង្គការយូណេស្កូ ព្រមទាំងមានឋានៈជាបដិភាគីចូលរួមពីអាជ្ញាធរជាតិអប្សរា ក្នុងការរៀបចំចងក្រងឯកសារមានឈ្មោះថា "ក្របខ័ណ្ឌគ្រប់គ្រងបរិស្ថានអង្គរ" ដែលក្នុងឯកសារនេះមានដូចជា៖ ផែនការគ្រប់គ្រងទេសចរណ៍អង្គរ ផែនទីហានិភ័យ និងការបណ្តុះបណ្តាល។ លើសពីនេះទៀត គម្រោងស្រាវជ្រាវដែលដឹកនាំដោយសាកលវិទ្យាល័យស៊ីដនី (Greater Angkor Project) ក៏បានសិក្សាទៅលើប្រវត្តិនៃរូបនីយកម្មជាតិអង្គរនិងការចោះបង់ចោលរាជធានីលើប្រវត្តិនយោបាយសង្គម និងលើពាង់ជាដំបូងម្ភាក់ងាសម័យអង្គរ។










ស្វីស
(Switzerland)

ប្រាសាទបន្ទាយស្រីប្រៀបដូចជាគ្រឿងអលង្ការនៃសិល្បៈខ្មែរៗ ប្រាសាទមានទឿនរាបស្មើមួយនេះ សាងឡើងពីថ្មភក់ពណ៌ផ្កាឈូកនិងមានចម្លាក់ដ៏ប្រណីតៗ

រយៈពេល ៦០០៦-៦០០៨ បន្ទាប់ពីបញ្ចប់ការងារជួសជុលប្រព័ន្ធរំដោះទឹកនៅតូប័មកណ្តាលនៃប្រាសាទរួចមក ភ្នាក់ងារសហប្រតិបត្តិការស្វីស បានសម្រេចចូលរួមជាមួយអាជ្ញាធរជាតិអប្សរាក្នុងការសាងសង់ទីលានមុខប្រាសាទៗ ទីលានមុខប្រាសាទបន្ទាយស្រីត្រូវបានសាងសង់ឡើងដើម្បីលើកតម្លៃប្រាសាទដែលត្រូបដណ្តប់ដោយព្រៃធម្មជាតិនិងដើម្បីឱ្យភ្ញៀវទេសចរអាចតយតន់បរិស្ថានដ៏ស្រស់បំព្រងស្ងប់ស្ងាត់ ព្រមទាំងអាចទទួលបាននូវសេវាបដិសណ្ឋារកិច្ចផ្សេងៗនៅពេលពួកគាត់មកដល់ប្រាសាទ មជ្ឈមណ្ឌលបដិសណ្ឋារកិច្ចដែលមានកន្លែងអាចទទួលព័ត៌មានបឋមនៃការទស្សនាកន្លែងសក្តិសិទ្ធិបឋម កន្លែងផ្ញើអីវ៉ាន់ និងមជ្ឈមណ្ឌលបកស្រាយព័ត៌មានមួយៗអាជ្ញាធរជាតិអប្សរាបានបង្កើតទីលានមុខប្រាសាទនេះឡើង ដោយឈរលើគោលការណ៍ថែរក្សាបរិស្ថានឱ្យបានត្រឹមត្រូវ។

អ្នកអនុវត្តការងារ ៖ ការអភិរក្សនិងអភិវឌ្ឍន៍ប្រាសាទបន្ទាយស្រី ដោយអាជ្ញាធរជាតិអប្សរានិងភ្នាក់ងារស្វីសដើម្បីអភិវឌ្ឍន៍ និងសហប្រតិបត្តិការ។



ប្រាសាទបន្ទាយស្រី














ចិន
(China)

ចំណងមិត្តភាពកម្ពុជា-ចិនមានតាំងពីយូរលង់ណាស់មក ហើយដែលបញ្ជាក់ច្បាស់តាមរយៈកំណត់ហេតុដ៏ល្បីល្បាញ របស់បេសកទូត ជីវ តាក្វាន់ ១២៩៦ ស្តីពីទំនៀមទម្លាប់ ខ្មែរនាសម័យអង្គរ។ ដូច្នេះ នៅឆ្នាំ១៩៩៨ រដ្ឋាភិបាលចិន បានសម្រេចទទួលកិច្ចការអភិរក្ស និងជួសជុលប្រាសាទ ប៉ៃសាយខេវតា ដោយស្ថាប័នរដ្ឋាភិបាលចិនសម្រាប់ការ អភិរក្សអង្គរ (CSA) នៃបណ្ឌិត្យសភាបេតិកភណ្ឌវប្បធម៌ ចិន (CACH)។ បន្ទាប់មកទៀត ក្រុមការងារនេះបាន ទទួលបន្ទុកការងារអភិរក្សនិង ជួសជុលប្រាសាទតាកែវ ហើយបានខិតខំពុងសិក្សាជួសជុលរាជភ័ពអង្គរធំ និង ត្រៀមក្នុងការផ្តល់ជំនួយបច្ចេកទេសសម្រាប់ការងារ អភិរក្ស និងជួសជុលប្រាសាទបន្ទាយមាលានាពេលខាងមុខ។












សាធារណរដ្ឋកូរ៉ែ
(Republic of Korea)

ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃសាធារណរដ្ឋកូរ៉ែ (KOICA) បានផ្តល់ជំនួយក្នុងការអភិវឌ្ឍស្របពេលដែលអង្គការនេះកំពុងអនុវត្តការងារអភិរក្សនៅតំបន់រមណីយដ្ឋានអង្គរ។

មិនត្រឹមតែប៉ុណ្ណោះ KOICA បានផ្តល់ហិរញ្ញប្បទានសម្រាប់ការងារសាងសង់ផ្លូវវង់តំបន់អង្គរ ដែលមានប្រវែង៣៦.៥ គីឡូម៉ែត្រ។ ចាប់តាំងពីឆ្នាំ២០១៥មក អង្គការនេះបានធ្វើការងារជួសជុលក្រុមប្រាសាទព្រះពិឃរ និងកំពុងសិក្សាជួសជុលព្រះលានជល់ដំរី ដោយប្រើប្រាស់មូលនិធិការពារបេតិកភណ្ឌវប្បធម៌ KOCHEF និង KOICA ។


















អ៊ីតាលី
(Italy)

ចាប់ពីឆ្នាំដំបូងៗនៃការចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោករបស់អង្គរ អង្គការ IGeSបានធ្វើការងារអភិរក្សពង្រឹងតួប៉ម សំខាន់ៗចំនួន១០របស់ប្រាសាទប៉ែរួប ដោយប្រើប្រាស់មូលនិធិរដ្ឋាភិបាលអ៊ីតាលីតម្កល់នៅអង្គការយូណេស្កូ។

តាំងពីឆ្នាំ២០០១មក អង្គការ IGeS បានអនុវត្តគម្រោងជួសជុលជាច្រើននៅតាមទីតាំងផ្សេងៗគ្នា នៃប្រាសាទអង្គវត្ត។ ប្រទេសអ៊ីតាលី កំបានចូលរួមផងដែរក្នុងការលើកកម្ពស់ជនជាតិមនុស្សរបស់កម្ពុជាតាមរយៈសកម្មភាពបណ្តុះបណ្តាល។

ដូច្នេះអ្នកបច្ចេកទេសខ្មែរវ័យក្មេងត្រូវបានទទួលការបណ្តុះ-បណ្តាលដោយសាស្ត្រាចារ្យ និងអ្នកជំនាញការពីសាកល-វិទ្យាល័យដែលមានកិត្យានុភាពបំផុត នៅក្នុងប្រទេសអ៊ីតាលី លើជំនាញអភិរក្សនិងជួសជុលវត្ថុសិល្បៈអំពីថ្ម អំពីឈើ និង លោហៈ។











សហរដ្ឋអាមេរិក
(USA)


អង្គការមូលនិធិប្រាសាទពិភពលោក (WMF) ដែលជាអង្គការឯកជនបានទទួលបន្ទុកការងារអភិរក្សនិងជួសជុលប្រាសាទមួយចំនួនក្នុងតំបន់រមណីយដ្ឋានអង្គរចាប់ពីឆ្នាំ១៩៩៨មក។

ប្រាសាទព្រះខ័ន (១៩៩៨-២០១៣) ៖ បានធ្វើឱ្យប្រាសាទមានស្ថិរភាព ការបើកបង្ហាញចម្លាក់ពិសេសៗល្អឯក និងការអភិរក្សចម្លាក់រូបត្រុនៅលើជញ្ជាំងកំពែងខាងក្រៅ។


ប្រាសាទតាសោម (១៩៩៩-២០០៦) ៖ ការដ្ឋានបង្រៀនជំនាញអភិរក្សដល់អ្នកអភិរក្សកម្ពុជា។

ប្រាសាទភ្នំបាខែង (ចាប់តាំងពីឆ្នាំ២០០៦) ៖ បាននិងកំពុងធ្វើឱ្យរចនាសម្ព័ន្ធប្រាសាទភ្នំនេះមានស្ថិរភាពការងារស្រាវជ្រាវផ្នែកបុរាណវិទ្យា និងការត្រួតត្រាលំហូរភ្ញៀវទេសចរដើម្បីការពារផ្នែកបផ្នែកខាងលើនៃប្រាសាទពីភ្ញៀវទេសចរដែលមកទស្សនាថ្ងៃលិច។

ប្រាសាទអង្គរវត្ត (ចាប់តាំងពីឆ្នាំ១៩៩៧) ៖ ញាបាលរូបចម្លាក់ខ្ទះៗនិងចម្លាក់ក្រឡោតពាបនៅលើថែវក្រៅសមុទ្រទឹកដោះ ព្រមទាំងចម្លាក់ពិតានឈើ។ លើសពីនេះទៀតសាកលវិទ្យាល័យកាលីហ្វ័រញ៉ា ឈីកាហ្គោ និងហ្វ្លរីដា បានចូលរួមសហការស្រាវជ្រាវទីតាំងមន្ទីរពេទ្យព្រះបាទជ័យវរ្ម័នទី៧មួយកន្លែងនៅប្រាសាទតាមួង ។











ក្រុមការងារតម្រង់ទិសដើម្បីដោះស្រាយបញ្ហាសំណង់ខុសច្បាប់ និងដីធ្លីក្នុងតំបន់រមណីយដ្ឋានអង្គរ និងតំបន់ដទៃទៀត ស្ថិតក្រោមការគ្រប់គ្រងរបស់អាជ្ញាធរជាតិអប្សរា

ក្រុមការងារតម្រង់ទិស ដើម្បីដោះស្រាយបញ្ហាសំណង់ខុសច្បាប់ និងដីធ្លីក្នុងតំបន់រមណីយដ្ឋានអង្គរនិងតំបន់ដទៃទៀតស្ថិតក្រោមការគ្រប់គ្រងរបស់អាជ្ញាធរជាតិអប្សរា ដែលមាន **ឯកឧត្តម ង៉ា សុផាំង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជាប្រធាន បានប្រកាសបើកយុទ្ធនាការចុះរាស់ដែងកំណត់និយាមការក្បាលដី និងអត្តសញ្ញាណអ្នកកាន់កាប់ក្បាលដី និងសំណង់ខុសច្បាប់ក្នុងតំបន់រមណីយដ្ឋានអង្គរនិងតំបន់ដទៃទៀត ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់អាជ្ញាធរជាតិអប្សរា ចាប់ពីថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២២។

យុទ្ធនាការចុះរាស់ដែងកំណត់និយាមការក្បាលដី និងអត្តសញ្ញាណអ្នកកាន់កាប់ក្បាលដី និងសំណង់ខុសច្បាប់ បានប្រព្រឹត្តទៅក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ង៉ា សុផាំង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងជាប្រធានក្រុមការងារតម្រង់ទិស **លោកជំទាវបណ្ឌិតសភាចារ្យ ឡើង សាវុឌា** រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។

ប្រមុខរាជរដ្ឋាភិបាល បានសម្រេចបង្កើតសមាសភាពក្រុមការងារតម្រង់ទិស ដើម្បីដោះស្រាយបញ្ហាសំណង់ខុសច្បាប់ និងដីធ្លី ក្នុងតំបន់រមណីយដ្ឋានអង្គរ និងតំបន់ដទៃទៀត ស្ថិតក្រោមការគ្រប់គ្រងនៃអាជ្ញាធរជាតិអប្សរា ដែលមានសមាសភាពមកពីក្រសួងពាក់ព័ន្ធមួយចំនួនរួមមាន ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងផែនការ អាជ្ញាធរវេត្តសៀមរាប និងអាជ្ញាធរជាតិអប្សរា ព្រមទាំងមានកិច្ចសហការពីក្រសួងការពារជាតិ ក្រសួងបរិស្ថាន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងរៃប្រសណីយ៍ និងទូរគមនាគមន៍ ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងទេសចរណ៍ កីឡា សាស្ត្រា បច្ចេកវិទ្យា និងនវានុវត្តន៍ ដើម្បីអនុវត្តដោះស្រាយបញ្ហាសំណង់ និងដីធ្លីក្នុងតំបន់រមណីយដ្ឋានអង្គរ និងតំបន់ដទៃទៀត ស្ថិតក្រោមការគ្រប់គ្រងរបស់អាជ្ញាធរជាតិអប្សរានេះ ឱ្យមានប្រសិទ្ធភាព និងស្អាតភាព។




ពិធី
ថ្ងៃពុធ ៨រោច ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
ត្រូវនឹងថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២២









ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ២៤០ សសរ

សេចក្តីសម្រេច
ស្តីពី
ការកំណត់តំណែងសមាសភាពក្នុងគណៈកម្មាធិការជាតិ ដើម្បីដោះស្រាយបញ្ហាអំពីអនីតិជនក្នុងគំនិតមនសិការរដ្ឋនិងអន្តរ និងគំនិតអំពីនៃឆ្នើត ស្ថិតក្រោមការគ្រប់គ្រងរបស់រាជរដ្ឋាភិបាលកម្ពុជា

រាជរដ្ឋាភិបាល

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/០៩១៤/៤២៥ ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពី ការតែងតាំងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកស/០៣២៧/៤២៩ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពី ការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៤/០៤ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩៩៦/០២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី និងវិនិច្ឆ័យសិល្បៈ
- បានឃើញក្រុមព្រះរាជក្រមលេខ នស/រកម/០៩៩៦/២៦ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌
- បានឃើញព្រះរាជក្រឹត្យលេខ០០១/ នស ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៩៨ ស្តីពីការកំណត់និងឈរចាត់តែងត្រាប់ត្រងតំបន់សៀមរាប-អង្គរ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកស/០៣១៧/៣១៣ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៧ ស្តីពី ការផ្ទេរអាជ្ញាធរ តណៈកម្មាធិការ តណៈកម្មការ និងក្រុមប្រឹក្សាដែលស្ថិតនៅក្រោមសមត្ថកិច្ច និងការទទួលខុសត្រូវរបស់ទីស្តីការគណៈរដ្ឋមន្ត្រីឱ្យស្ថិតនៅក្រោមសមត្ថកិច្ច និងការទទួលខុសត្រូវរបស់ក្រសួងមានសមត្ថកិច្ចពាក់ព័ន្ធ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកស/០២៦៧/២០៣ ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២០ ស្តីពី ការបង្កើតអាជ្ញាធរជាតិអប្សរាជាក្រឹះស្ថានសាធារណៈរដ្ឋបាល



- បានដឹកនាំកិច្ចប្រជុំលើកទី២២ នៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៤ ស្តីពីការប្រែក្លាយ និងការត្រួតពិនិត្យការប្រើប្រាស់ដីសង្គមកិច្ច និងសំណង់
- បានដឹកនាំកិច្ចប្រជុំលើកទី២៤ នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការប្រែក្លាយ និងការត្រួតពិនិត្យការប្រើប្រាស់ដីសង្គមកិច្ច និងដីវិទ្យាល័យ
- បានដឹកនាំកិច្ចប្រជុំលើកទី២៥ នៅថ្ងៃទី៨ ខែមីនា ឆ្នាំ២០១៥ ស្តីពីការប្រែក្លាយ និងការត្រួតពិនិត្យការប្រើប្រាស់ដីសង្គមកិច្ច និងដីវិទ្យាល័យ
- បានដឹកនាំកិច្ចប្រជុំលើកទី២៦ នៅថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៥ ស្តីពីការបង្កើតក្រុមការងារចុះមើលទីតាំង ដើម្បីពិនិត្យរកឃើញបញ្ហាដីសង្គមកិច្ច និងដីវិទ្យាល័យ ក្នុងគោលបំណងស្វែងរកដំណោះស្រាយ និងដាក់ជូនសម្តេចតេជោនាយករដ្ឋមន្ត្រី និងគណៈរដ្ឋមន្ត្រីពិនិត្យ ស៊ើបអង្កេតរកដីវិទ្យាល័យដែលមានបញ្ហាជាក់ស្តែង
- បានដឹកនាំកិច្ចប្រជុំលើកទី២៧ នៅថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការបង្កើតក្រុមការងារចុះមើលទីតាំង ដើម្បីពិនិត្យរកឃើញបញ្ហាដីសង្គមកិច្ច និងដីវិទ្យាល័យ ក្នុងគោលបំណងស្វែងរកដំណោះស្រាយ និងដាក់ជូនសម្តេចតេជោនាយករដ្ឋមន្ត្រី និងគណៈរដ្ឋមន្ត្រីពិនិត្យ ស៊ើបអង្កេតរកដីវិទ្យាល័យដែលមានបញ្ហាជាក់ស្តែង
- បានបោសសំអាតទីលានសាលាខេត្ត

បទបញ្ជា

ប្រការ ១.

ត្រូវបានដឹកនាំដោយសម្តេចតេជោនាយករដ្ឋមន្ត្រី ដើម្បីពិនិត្យរកឃើញបញ្ហាដីសង្គមកិច្ច និងដីវិទ្យាល័យ និងដាក់ជូនសម្តេចតេជោនាយករដ្ឋមន្ត្រី ស៊ើបអង្កេតរកដីវិទ្យាល័យដែលមានបញ្ហាជាក់ស្តែង ដូចមានរៀបរាយក្នុងប្រការ ២ ខាងក្រោម៖

១. ឯកឧត្តម ង៉ា សុផល	អនុប្រធានក្រុមប្រឹក្សាខេត្ត	ប្រធាន
២. លោកជំទាវ ប្រុង ស្រីមុំ	សមាជិកក្រុមប្រឹក្សាខេត្ត	អនុប្រធាន
៣. ឯកឧត្តម ឡៃ ចាន	ស្នងការនគរបាលខេត្ត	អនុប្រធាន
៤. ឯកឧត្តម ស៊ឹម ម៉ាត់	អនុរដ្ឋលេខាធិការក្រសួងបរិស្ថាន	សមាជិក
៥. ឯកឧត្តម ឈួក ជាមួត	អនុរដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់	សមាជិក
៦. ឯកឧត្តម ម៉ី ឈឿ	អនុរដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់	សមាជិក
៧. ឯកឧត្តម ឈេង សុភាព	អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ	សមាជិក
៨. ឯកឧត្តម ថុង ម៉ាឯកវុធ	អនុរដ្ឋលេខាធិការក្រសួងដែនដី	សមាជិក
៩. ឯកឧត្តម ហេង សុផាន	អនុរដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់	សមាជិក
១០. ឯកឧត្តម ម៉ក់ ពេជ	អនុរដ្ឋលេខាធិការក្រសួងការពារជាតិ	សមាជិក
១១. ឯកឧត្តម ទេពបច្ចុប សុជាតិវង្សទៅ	អនុរដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ	សមាជិក
១២. ឯកឧត្តម ឃឹម ចន្ធីដារ៉ូ	អនុរដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ	សមាជិក
១៣. ឯកឧត្តម ឈួក ភក្តវរ	អនុរដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ	សមាជិក

ប្រការ ២.

ក្រុមការងារខេត្ត មានភារកិច្ចដូចតទៅនេះ៖ ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៥ ស៊ើបអង្កេតរកដីវិទ្យាល័យដែលមានបញ្ហាជាក់ស្តែង ដើម្បីធ្វើរបាយការណ៍ស្តីពីលទ្ធផលនៃការចុះស៊ើបអង្កេតជូនសម្តេចតេជោនាយករដ្ឋមន្ត្រី និងគណៈរដ្ឋមន្ត្រីពិនិត្យ

ប្រការ ៣.

ក្រុមគ្រឹះស្ថានសាធារណៈ ក្រុមប្រឹក្សាខេត្ត អភិបាលខេត្ត ស្នងការនគរបាលខេត្ត មន្ទីរពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់ និងបុគ្គលពាក់ព័ន្ធ ត្រូវអនុវត្តបទបញ្ជានេះដោយការយកចិត្តទុកដាក់ខ្ពស់ ។

ថ្ងៃទី ខែ ឆ្នាំ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៥៩
ធ្វើនៅភ្នំពេញ ថ្ងៃទី ខែ ឧសភា ឆ្នាំ ២០១៥

សម្តេចតេជោ ហ៊ុន សែន

ទន្ទឹមនេះជូន៖
- ក្រុមប្រឹក្សាខេត្ត
- អគ្គលេខាធិការដ្ឋាន
- អគ្គលេខាធិការដ្ឋាន
- អគ្គលេខាធិការដ្ឋាន
- ឯកឧត្តម លោកជំទាវ
- ឯកឧត្តម លោក
- ឯកឧត្តម លោក
- ឯកឧត្តម លោក



សកម្មភាពជួបជជែកជាមួយក្រុមការងារតម្រង់ទិសចុះជាប់ជាមូលដ្ឋានជាមួយអាជ្ញាធរមូលដ្ឋាន















សកម្មភាពថ្នាក់ដឹកនាំក្រុមការងារឆ្លងដែនចុះពិនិត្យទីតាំងចាប់ក្បាលដី















ប្រាសាទបន្ទាយក្តី

អភិរក្សប្រពៃណីកម្ពុជា

ច្បាប់ច្បាស់លាស់


កិច្ចការអភិរក្សច្បាប់ច្បាស់លាស់ ត្រូវបានយកចិត្តទុកដាក់ថែទាំ ការពារដោយច្បាប់ពីសំណាក់អាជ្ញាធរជាតិ អប្សរា និងពីស្ថាប័នអន្តរជាតិ ក្នុងនោះតម្រាងអភិរក្សខ្លះបានបញ្ចប់ ការងារមួយចំនួនទៀតកំពុងបន្តរហូតដល់សព្វថ្ងៃ។ ការសិក្ខាសាលាអភិរក្សនានា គឺសុទ្ធសឹងស្ថិតក្រោមអនុសាសន៍ណែនាំរបស់គណៈកម្មាធិការ អាយស៊ីស៊ី-អង្គរ នៅអំឡុងពេលប្រជុំប្រចាំឆ្នាំម្តងៗ។

កិច្ចការអភិរក្សនិងជួសជុល
នៅប្រាសាទអង្គរវត្ត

*អង្គរជាប្រាសាទដ៏ល្អត្រកាលនិងធំជាងគេនៅក្នុងចំណោមប្រាសាទ
របស់ខ្មែរទាំងអស់ បានសាងឡើងនៅចំកណ្តាលរាជធានីអង្គរនៅ
រាងពាក់កណ្តាលទី១នៃសតវត្សរ៍ទី១៦ ក្នុងរាជព្រះបាទសូរ្យវរ្ម័នទី៦។*

*ទម្រង់នៃប្រាសាទទាំងមូលរួមនិងកសិន្ទុមានទទឹង១៨០ម៉ែត្រព័ទ្ធ
ជុំវិញផងនោះបណ្តើតបានជាកន្ទបតុកោណដ៏ធំមួយមានទំហំ១៩០០
ម៉ែត្រគុណនិង១៣០០ម៉ែត្រគ្របដណ្តប់លើផ្ទៃដីប្រមាណ
ជា២០០ហិកតា។*

*លក្ខណៈសំខាន់របស់ប្រាសាទអង្គរវត្ត គឺសំណង់ជាកន្ទសាជីថ្នេរ
មួយតូចមួយធំខ្វែងគ្នាដែលស្ថិតនៅចំកណ្តាលរោងទន្ទព័ទ្ធជុំវិញ
ជាច្រើនជាន់។ ការជារជួសជុល និងពង្រឹងឡើងវិញត្រូវបាន
ដំណើរការឡើងនៅក្នុងគម្រោងអន្តរជាតិ ដែលទាក់ទងនិងក្រុម
អ្នកបច្ចេកទេសខ្មែរពីអាជ្ញាធរជាតិអប្សរា ក្រុមការងារមកពី
សហរដ្ឋអាមេរិក អាល្លឺម៉ង់ អ៊ីតាលី និងជប៉ុន។*





គម្រោងអភិរក្សរូបចម្លាក់ខេពអប្សរ ប្រាសាទអង្គរវត្ត

ចាប់តាំងពីឆ្នាំ១៩៩៧មក គម្រោងអភិរក្សរូបចម្លាក់ខេពអប្សរបស់ប្រទេសអាល្លឺម៉ង់ (GACP) បានខិតខំពុះពារអនុវត្តដើម្បីអភិរក្សរូបចម្លាក់ខេពអប្សរ និងត្រឿងលម្អនៅតាមផ្នែកផ្សេងៗទៀតរបស់ប្រាសាទ។ រូបចម្លាក់ទេវតាប្រមាណជា៦០តាងរយ ស្ថិតក្នុងស្ថានភាពខូចខាតខ្លាំងបណ្តាលមកពីសំណើមក្រូសព័ន្ធកាយនិងការជួសជុលមិនបានប្រសើរនៅពេលអតីតកាលដែលប្រការទាំងអស់នេះ បានធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំងទៅលើរូបចម្លាក់ទាំងនោះ។

ក្នុងការអនុវត្តការងារដ៏ប៉ិនប្រសប់ និងល្បាកនេះអង្គការគម្រោងអភិរក្សរូបចម្លាក់ខេពអប្សរបស់ប្រទេសអាល្លឺម៉ង់បានផ្ញើការវិភាគដ៏ជាក់លាក់ដោយប្រើវិធីសាស្ត្រព្យាបាល និងជួសជុលដែលអាចជួយឱ្យចម្លាក់ទាំងនោះ រួចផុតពីការប្រឈមបានទាន់ពេលវេលា។



ការអភិរក្សនិងជួសជុល
បណ្ណាល័យខាងជើងទ្រនាប់ព្រះអង្គវត្ត

ស្ថាប័ន ហៅកាត់ថា JSA របស់រដ្ឋាភិបាលជប៉ុន ដែលជាជំនួយសម្រាប់កិច្ចការអភិរក្សនិងជួសជុលប្រាសាទមានវត្តមាននៅអង្គរនាឆ្នាំ ១៩៩៦។ គម្រោងនេះស្ថិតនៅក្រោមកិច្ចសហប្រតិបត្តិការរវាងអង្គការអន្តរជាតិយូណេស្កូ-ជប៉ុន-អាជ្ញាធរជាតិអប្សរា។ បណ្ណាល័យនេះបានជួសជុលរួចរាល់នៅក្នុងឆ្នាំ២០០០ នៃគម្រោងដំណាក់កាលទី៦ ។



កំពុងជួសជុល



ក្រោយជួសជុល







ការជួសជុលកោងឆត្រ
ក្បាលសមុទ្រទឹកដោះគ្រែថាសាទអង្គរវត្ត

ឆ្នាំ២០០៨ គម្រោងមូលនិធិជ្រាសាទពិភពលោក (WMF)របស់សហរដ្ឋអាមេរិក សហការជាមួយអាជ្ញាធរជាតិអប្សរា បានទទួលភ៉ាប់រង ជួសជុលដំបូលកោងឆត្រក្បាលសមុទ្រទឹកដោះក្នុងបំណងធំ ដើម្បីការពារជម្រាបទឹកដែលហូរស្រក់ពីផ្នែកដំបូលកោងឆត្រជាប្រចាំមកលើជញ្ជាំង ព្រោះថា ទឹកនឹងនាំឲ្យមានសំណើម បង្កើតជាកំណើនជាតិអំបិលច្រើនស្ថិតជាប់ នៅលើក្បាច់ចម្លាក់ពឿងក្បាលសមុទ្រទឹកដោះនៅលើជញ្ជាំង ហើយក្បាច់ចម្លាក់នឹងទទួលរងការពុកផុយលើផ្ទៃថ្មយ៉ាងរហ័សៗ









តម្រាវនេះ មានរយៈពេល៦ខ្នាំសម្រាប់ការជួសជុលផង និង បណ្តុះបណ្តាលដល់អ្នកបរិក្ខេរទេសខ្មែរជំនាញវិស្វកម្មផង ជាពិសេស ដល់ពលករ ទទួលខុសត្រូវបទពិសោធន៍ត្រប់ត្រាន់លើផ្នែកអភិរក្ស និង ជួសជុលបេតិកភណ្ឌ។

គម្រោងជួសជុលចម្រឹងបង្ហួច និងការដាស្រង្កែះបង្ហាន់

ស្ថានភាពចម្រឹងបង្ហួចទាំងអស់នៅប្រាសាទអង្គរវត្ត ពុំមានភាពរឹងមាំឡើយ ជាក់ស្តែងចម្រឹងខ្លះពុកផុយ និងសឹករិចរិលរលេះខ្លាក់ដោយអន្ទឹង។ ខ្លះទៀតបាក់ ឬបាត់បង់ទាំងស្រុង។ នៅកោដ្ឋទី៦(ផ្នែកខាងក្នុង) មានស៊ុមបង្ហួចសរុបចំនួន១៦៩ស៊ុមដែលមានចម្រឹង ១០៣៩ចម្រឹង ក្នុងនោះចម្រឹងបានបាត់បង់ចំនួន៦៥០ ចម្រឹង។ ក្រុមអ្នកជំនាញខ្មែរនៃអាជ្ញាធរជាតិអប្សរា បានយកចិត្តទុកដាក់ជួសជុលរួចនៅចម្រឹង បង្ហួចស្ថិត នៅកោដ្ឋទី៦ខាងក្នុងប៉ែកខាងត្បូងកាល ពីខែមីនា ឆ្នាំ២០១៩កន្លងទៅ។













សកម្មភាពសង្គ្រោះបន្ទាន់នៅប្រាសាទអង្គរវត្តដែលជាកិច្ចការចាំបាច់ជាមុន ទល់នឹងការគំរាមកំហែងប្រឈមនឹងហានិភ័យខ្ពស់ សាងសង់កម្រាលការពារ សង់ជណ្តើរឈើដើម្បីសម្រួលដល់ដំណើរទស្សនារបស់ភ្ញៀវទេសចរ ធ្វើរបាការពារចម្លាក់នានា ជួសជុលកម្រាលថ្មផ្លូវដើរស្ថិតនៅតាមរួតនីមួយៗ ដោយបំពេញបំណែកថ្មកក់ថ្មី រៀបរយសណ្តាប់ធ្នាប់ថ្មពុយប៉ាយ សង់ជើងទម្រឈើដើម្បីតម្កល់បំណែកព្រះពុទ្ធរូបស្ថិតនៅជុំវិញកោដ្ឋទីមួយៗ ចុះបញ្ជីវត្ថុសិល្បៈដែលរាយប៉ាយ សង់សំណាញ់ការពារសត្វប្រចៀវ សម្អាតសត្វល្អិត ស្មាមប្រឡាក់ និងស្មាមគំនូរលើជញ្ជាំង។

គម្រោងអភិរក្សជិនជួសជុលស្រះទាជជើងច្រាសាធអង្គរវត្ត

ស្រះទាជជើង ប្រឈមនឹងលំហូរទឹងរបស់កំណកដីចាក់បង្គរទៅក្នុងស្រះជារៀងរាល់ឆ្នាំដោយបង្កឱ្យមានជម្រៅទឹកតាក់ ជាពិសេស រចនាសម្ព័ន្ធថ្មកាំជណ្តើរនៃប្រាំងស្រះបានអស់លេញពីតន្ទងដើមចូលទៅក្នុងបាតស្រះ និងបាត់បង់ថ្មមួយចំនួន។

ស្របនឹងតម្រូវការអភិវឌ្ឍន៍ ផ្នែកវិស័យទេសចរណ៍នាពេលខាងមុខ។ ការជួសជុលសាកល្បងមានចំនួន១៥ម៉ែត្រ ធ្វើឡើងនៅជ្រុងនិរតីនៃស្រះ និងជួសជុលបន្តបន្ទាប់ឆ្នាំ២០២០ប្រវែង២០ម៉ែត្រ និងឆ្នាំ ២០២១ ប្រវែង ៦៥ម៉ែត្រ។





គម្រោងអភិរក្សដំបូងក្នុងឆ្នាំ២០១៤ របស់អាជ្ញាធរជាតិអប្សរបានកំណត់ទូរកម្មវិធីលើកតម្លៃស្រះខាងជើងនេះឡើងវិញតាមរយៈ ប្រតិបត្តិខាងផ្នែកជួសជុលទៅលើរចនាសម្ព័ន្ធថ្មគឺក្នុងគោលបំណងបង្ហាញទ្រង់ទ្រាយស្រះខាងជើង ឱ្យបានច្បាស់លាស់ឡើងវិញ ដោយឡែក កិច្ចការប្រតិបត្តិផ្នែកបច្ចេកទេស អាជ្ញាធរជាតិអប្សរបានយកចិត្តទុកដាក់ខ្ពស់លើគ្រប់សកម្មភាពខាងអភិរក្សថ្មចាំងការ ធ្វើកំណាយស្រាវជ្រាវ ជុះបញ្ជីវត្ថុសិល្បៈ ការរុះរើថ្ម និងរៀបចំកាំប្រាំងឡើងវិញស្របទៅតាមទម្រង់នៃស្ថាបត្យកម្មដើម។







ប្រវត្តិនៃការជួសជុលតាផ

ជាព្រះបដិមាមានដៃប្រាំបីដ៏ធំសម្បើមមួយនេះ គឺជាព្រះដែលអ្នកស្រុកទូទៅគោរពខ្លាំងជាងគេបង្អស់ ក្នុងចំណោមព្រះទាំងអស់នៅអង្គរវត្ត ក៏ដូចជាតំបន់អង្គរទាំងមូល។ អ្នកស្រុកហៅបដិមានេះថា «តាផ»។ តាមទំនៀមអ្នកអង្គរ «តាផ» មានកិត្តិនាមល្បីល្បាញខ្លាំងដោយសារតែបារមីដ៏ខ្លាំងពូកែស័ក្តិសិទ្ធិរបស់ព្រះអង្គ។ មានអ្នកប្រាជ្ញជាច្រើនយល់ថា រូបតាផ ជាព្រះនារាយណ៍ ជាព្រះដ៏ជំនួយអង្គរបស់ព្រហ្មញ្ញសាសនា ដែលមានតួនាទីថែរក្សាលោក។ រីឯអ្នកប្រាជ្ញមួយចំនួនទៀតយល់ថា ជារូបព្រះលោកេស្វរ ជាព្រះពោធិសត្វនៅក្នុងព្រះពុទ្ធសាសនាមហាយាន ដែលតំណាងឲ្យសេចក្តីមេត្តាករុណា។


រូបតាផដ៏ធំនេះជាផ្នាក់ឡើងនៅរវាងពីចុងសតវត្សទី១២ ដល់ដើមសតវត្សទី១៣ ហើយអ្នកស្រុកបានគោរពបូជារូបនេះតាំងពីពេលនោះរហូតរៀងមក។ សព្វថ្ងៃនេះ ប្រជាជនកម្ពុជានៅគ្រប់ទីកន្លែង នៅតែប្រាថ្នាមកអង្គរវត្ត ដើម្បីសំពះតាផ។

ទោះជាយ៉ាងដូច្នេះក៏ដោយ ក៏តាផមិនមានគេគោរពកោតខ្លាចគ្រប់ៗគ្នានោះទេ។ នៅឆ្នាំមួយនាឆ្នាំ១៩៩៥ មានចោរមួយក្រុមបានមកលួចជាប់កាត់ព្រះកេសរបស់តាផ។ នៅពេលនោះ មានអព្ភូតហេតុដ៏អស្ចារ្យមួយ គឺធ្វើមិនឲ្យក្រុមចោរលួចយកព្រះកេសចេញទៅបាន ហើយបានទុកព្រះកេសនោះចោលនៅក្បែរបល្ល័ង្ក។

ដើម្បីថែរក្សាព្រះកេសនេះឲ្យបានគង់វង្សល្អ រាជរដ្ឋាភិបាលកម្ពុជាបានយកមករក្សាទុកនៅក្នុងឃ្លាំងនៃអគារក្សដ្ឋានអង្គរក្នុងខេត្តសៀមរាប។ ក្រោយពីព្រឹត្តិការណ៍ចោរចូលឆ្នាំ អគារក្សដ្ឋានអង្គរនៅឆ្នាំ១៩៩៣មក ព្រះកេសតាផត្រូវបានដឹកយកទៅរក្សាទុកក្នុងសារមន្ទីរជាតិកម្ពុជានៅឯរាជធានីភ្នំពេញ។ ចាប់ពីពេលនោះមក ព្រះកេសតាផត្រូវបានជំនួសដោយព្រះកេសធ្វើពីស៊ីម៉ងត៍។

នៅឆ្នាំ២០០៤ មានក្រុមអ្នកអគារក្សមួយក្រុមរបស់អាជ្ញាធរជាតិអប្សរាបានរួមគ្នាជាមួយក្រុមអគារក្សឯកទេសអាល្លឺម៉ង់បានជួសជុលរូបតាផដែលបាក់បែក។ កិច្ចការជួសជុលរូបនេះ មិនគ្រាន់តែធ្វើតាមលក្ខណបច្ចេកទេសទេ គឺមុននឹងចាប់ផ្តើមធ្វើកិច្ចការអ្វីទីមួយ។ ក្រុមកម្ពុជានិងអាល្លឺម៉ង់ទៅប្រាស្រ័យទាក់ទងពិភាក្សា និងពិគ្រោះយោបល់ជាមួយនិងអ្នកគូមិនានា និងជាមួយរូបស្នងរបស់តាផ ដើម្បីរកវិធីធ្វើយ៉ាងណាឲ្យការជួសជុលរូបធ្វើទៅបានល្អ និងទៅតាមទំនៀមដែលតែងតែគេគោរពបូជាជាទីបំផុត។





ការជួសជុល បានប្រើប្រាស់វត្ថុធាតុធម្មជាតិដែលមានក្នុងស្រុកដូចជា ជ័រឈើដែលអាចរកបាននៅក្នុងស្រុកៗ ប្រជាជនកម្ពុជាមានជំនឿថា សម្ភារៈទាំងអស់នោះជាតំណាងឱ្យព្រលឹងនៃបុព្វបុរសរបស់គេៗ ដំណើរការជួសជុលរូបនេះ បានជួបប្រទះនឹងឧបសគ្គខ្លះៗ ដែលត្រូវការពេលវេលាមួយចំនួនៈ ល្អដូចជាដែលរុំជាប់បដិមាកប់សតវត្សរ៍ បន្ទាប់ពីលាងសំអាត បានលេចចេញនូវសន្ទឹកមាសដ៏ល្អប្រណិត ដែលបានយកមកទឹបដោយអ្នកគោរពបូជាជាតិ និងអ្នកជើងមួយគ្រានៅទូទាំងតំបន់អាស៊ីអាគ្នេយ៍។ ប្រជាជនកម្ពុជាខ្លះទៀត មានសេចក្តីរីករើបយ៉ាងខ្លាំងចំពោះការជួសជុលរូបតារាជ។ ក្នុងរយៈពេលបីឆ្នាំនៃដំណើរការជួសជុល ប្រជាជនកម្ពុជានៅតែមកសំពះ និងគោរពបូជាតារាជមិនដែលដាច់។

អ្វីដែលគួរឱ្យរំភើបជាទីបំផុតនៅក្នុងរយៈពេលនៃការជួសជុលនោះគឺ ការនាំយកព្រះកេសដើមរបស់តារាជមកតភ្ជាប់វិញ។ ក្រៅតែអំពីការការពារសន្តិសុខតឹងរឹងនោះ គឺមានផ្នើកិច្ចពិធីយ៉ាងអធិកអធមមួយ នៅពេលដែលព្រះកេសរបស់តារាជនាំយកមកដល់អង្គរវត្ត។ ពេលនោះ អ្នកស្រុកយ៉ាងច្រើនបានមកចូលរួមជង្គែព្រះកេស និងមកប្រជុំគ្នានៅអង្គរវត្តព្រមៗគ្នាដោយមិនបានកព្រឹងទុកមុន ដើម្បីចូលរួមពិធីតាមទំនៀមមួយ មុននឹងចាប់ផ្តើមការងារតភ្ជាប់ព្រះកេសដើមឡើងវិញ។ អ្នកស្រុកជាច្រើននាក់ នៅតាមជានសកម្មភាពការងារបស់ក្រុមអ្នកអភិរក្ស ប្រកបដោយទឹកមុខរីករាយនិងមានសង្ឃឹម។ ពេលដែលការងារតភ្ជាប់ព្រះកេសដើមនឹងព្រះកាយរបស់តារាជឡើងវិញនោះ ក្រុមការងារអភិរក្សទាំងអស់គ្នាហាក់ដូចជាមិនបានជឿថា គេបានបំពេញកិច្ចការនេះតាមបច្ចេកទេសនោះទេ តែមានជំនឿហាក់បីដូចជាអំណាចនៃបារមីរបស់តារាជបានជួយដឹកដៃសម្រេចការងារនេះទៅវិញ។

ជួសជុលស្ពានហាលខាងលិចច្រាសាទអង្គរវត្ត

ស្ពានហាលមានបណ្តោយប្រវែង៦០០ម៉ែត្រទទឹង១៦ម៉ែត្រ។
ចន្លោះឆ្នាំ១៩៩៦ដល់ឆ្នាំ២០០៧ សាគលវិទ្យាល័យសូហ្វីយ៉ានិងអជ្ញាធរជាតិអប្សរាក៏បានជួសជុល
ស្ពានហាលនៅពាក់កណ្តាលខាងជើងផ្នែកខាងកើតរួចរាល់ប្រវែង១០០ម៉ែត្រ ។















មុនជួសជុល


ក្រោយជួសជុល

នៅឆ្នាំ ២០១៦ អាជ្ញាធរជាតិអប្សរា និងសាកលវិទ្យាល័យសូហ្វីយ៉ា នៃប្រទេសជប៉ុនបានចុះអនុស្សរណៈនៃការយោគយល់គ្នា ដើម្បីបន្តគម្រោងកិច្ចសហប្រតិបត្តិការជួសជុលបញ្ចប់ផ្នែកដែលនៅសេសសល់ នៃស្ពានហាលខាងលិចប្រាសាទអង្គរវត្ត គឺត្រឹមពាក់កណ្តាលខាងលើផ្នែកខាងលិចដែលមានប្រវែង១០៣ម៉ែត្រ និងលានកំពង់ទឹកនៅប៉ែកកណ្តាលស្ពានហាលៗ កាលដំណើរការជួសជុលទាំងអស់គឺស្ថិតនៅក្រោមថវិការជរដ្ឋាភិបាលខ្មែរទាំងស្រុងសម្រាប់ចំណាយលើការផ្គត់ផ្គង់សម្ភារៈដល់ការដ្ឋាន ចំណាយលើប្រាក់បៀវត្សដល់មន្ត្រីបច្ចេកទេសបុគ្គលិក ពលករជំនាញនិងការដឹកជញ្ជូនជាដើមៗ ចំណែកស្ថាប័នសូហ្វីយ៉ា កំពុងផ្តល់នូវជំនួយជាសម្ភារៈគ្រឿងចក្រមួយចំនួនរួមមាន៖ ឡានស្នូចថ្ម ឡានដឹកជញ្ជូនថ្ម ម៉ាស៊ីនកៀង ម៉ាស៊ីនកាត់ថ្មនិងសម្ភារៈប្រើប្រាស់ដទៃទៀតៗ




កំពុងជួសជុល


មុនជួសជុល


ក្រោយជួសជុល

គម្រោងជួសជុលពន្លឿនច្រាំងកសិទ្ធ ច្រាសាទអង្គរវត្ត

ប្រទេសឥណ្ឌាបានជួសជុលពន្លឿន ច្រាំងកសិទ្ធច្រាសាទអង្គរវត្ត ប្រវែង១៦៣ ម៉ែត្រស្ថិតនៅត្រើយខាងកើតប៉ែកខាងជើងនៃស្ពានហាលខាងលិចច្រាសាទអង្គរវត្ត។ ចំណែកប្រទេសអ៊ីតាលី (I.Ge.S) ក៏បានចូលរួមផងដែរក្នុងការជួសជុលច្រាំងកសិទ្ធប្រវែង៦០ម៉ែត្រ ស្ថិតនៅត្រើយខាងកើតប៉ែកខាងត្បូងនៃស្ពានហាលក្នុងឆ្នាំ២០០១ ដល់ ២០០៤ និងជួសជុលប្រវែង៣០ម៉ែត្រទៀតស្ថិតនៅត្រើយខាងលិចប៉ែកខាងជើងនៃស្ពានហាលអង្គរវត្ត។

ចាប់ពីឆ្នាំ២០១៣មកអាជ្ញាធរជាតិអប្សរាបានអនុវត្តគម្រោងជួសជុលច្រាំងកសិទ្ធច្រាសាទអង្គរវត្តប្រវែងសរុប៦០៣ម៉ែត្រ ដែលមានភ្ជាប់នឹងជំណាក់កាល។


មុនជួសជុល





ក្រោយជួសជុល



កំពុងជួសជុល



ក្រោយជួសជុល

កិច្ចការអភិរក្សលើជួសជុល
ប្រាសាទចាយក្អែក

ប្រាសាទចាយក្អែក ជាសំណង់អំពីថ្មកក់និងឥដ្ឋបាយក្រៀមមានទំហំតូច ស្ថិតនៅប៉ែកខាងលិចនៃប្រាសាទអង្គរវត្ត។ ឥដ្ឋដែលជាក់វាយប៉ាយ ពាំងអស់នោះប្រមាណ៤០ដុំ សុទ្ធសឹងជាចំណែករបស់សសរពេជ្រ ចំណែកចង្រឹងបង្ហួច បល្ល័ង្ក និងចំណែកស៊ុមទ្វារជាដើម គឺគេអាចប្រមូលសម្រង់យកទៅផ្គុំឡើងវិញបានមួយផ្នែក និងគេអាចយល់បានដោយបង្ហាញនូវទម្រង់ព្រាលៗរបស់រចនាសម្ព័ន្ធប្រាសាទ។

តាមរយៈលទ្ធផលពីកំណាយស្រាវជ្រាវឆ្នាំ២០១១ ដែលធ្វើនៅលើប៉មប្រាសាទចាយក្អែក និងទួលបុកាណលេខCP.417បង្ហាញថា ប្រាសាទចាយក្អែកនៅសេសសល់ត្រឹមតែខឿនប៉ុណ្ណោះ (កម្ពស់៣០ ស.ម) ហើយស្ថិតក្នុងកម្រិតខ្ទង់ខាតជួនច្រេះដោយសារមូលហេតុចម្បងពីរគឺ មានផលប៉ះពាល់ខ្លាំងពីការរីកដុះដាលនៃរុក្ខជាតិនៅលើប៉ម ប្រាសាទ និងភាពវិនាសរបស់មនុស្ស។



ក្រោយជួសជុល

កិច្ចអភិរក្សនិងជួសជុលប្រាសាទបាយក្រែក


មុនជួសជុល


មុនជួសជុល


កំពុងជួសជុល


កំពុងជួសជុល

ការអភិរក្សនិងជួសជុលប្រាសាទភ្នំបាខែង

អង្គការមូលនិធិប្រាសាទពិភពលោក WMF របស់រដ្ឋាភិបាលអាមេរិក សហការជាមួយអាជ្ញាធរជាតិអប្សរា បានផ្តល់នូវថវិកា និងជំនួយបច្ចេកទេសសម្រាប់អភិរក្សប្រាសាទភ្នំបាខែងដែលមានរយៈពេលកំណត់ៗ ជាំហានទី១ចាប់ពីឆ្នាំ២០០៦ ដល់ ២០០៨ ផ្តោតទៅលើការសិក្សា រៀបចំផែនការគោល និងគម្រោងសាកល្បងដើម្បីជួសជុលថ្ម ជ្រុងនិងតីនៃប៉មធំពីរ៉ាមីតៗ



មុនជួសជុល



ក្រោយជួសជុល


ក្រោយជួសជុល

ជំហ៊ានទី៦(២០០៩-២០១៦) បានធ្វើការជួសជុលប្រាសាទឥដ្ឋលេខ១០ រួចរាល់ដោយក្រុមការងារបច្ចេកទេសនៃអាជ្ញាធរជាតិអប្សរា។ លទ្ធផលផ្នែកអភិរក្ស និងជួសជុលប្រាសាទភ្នំបាខែង បានបញ្ចប់ការជួសជុលលើរចនាសម្ព័ន្ធថ្មនៃប៉មពីរ៉ាមីតគិតត្រឹមពាក់កណ្តាលផ្នែកខាងកើត ហើយសព្វថ្ងៃកំពុងបន្តជួសជុលទីតម្លៃនខ្វះខាតនៃប៉មពីរ៉ាមីតនៅពាក់កណ្តាលខាងលិច។


កំពុងជួសជុល


មុនជួសជុល



ខ្លោងទ្វារទន្លេអ៊ុំ

ការជួសជុលចម្លាក់ថាញ់ត្រីតែជៅខ្លោងទ្វារទន្លេអ៊ុំ



ថ្មចម្លាក់ក្បាលនាគនៅខ្លោងទ្វារទន្លេអ៊ុំ បានរងការខូចខាតដោយសារដើមឈើជួលរលំសង្កត់អំឡុងពេលភ្លៀងកាលពីខែសីហា ឆ្នាំ២០១៣កន្លងទៅ និងធ្វើឲ្យថ្មចម្លាក់ខ្លះរំកិលចេញពីទម្រង់ដើមនិងបម្រុងថ្លាក់ដី។ ស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់នេះ ក្រុមអ្នកជំនាញខ្មែរនៅអគិរក្សថ្មនៃអាជ្ញាធរជាតិអប្សរ SCU ដែលបានទទួលការបណ្តុះបណ្តាលផ្នែកអគិរក្សថ្មពីអ្នកជំនាញបរទេសមកពីស្ថាប័ន GIZ នៃប្រទេសអាឡឺម៉ង់បានរៀបចំគម្រោងជួសជុលឡើងវិញក្នុង



ខែកញ្ញា ឆ្នាំ២០១៦ ដោយបញ្ចប់រួចរាល់នៅខែមេសា ឆ្នាំ២០១៩។ រចនាសម្ព័ន្ធទាំងមូលនៃប្រាសាទត្រូវបានជួសជុលពង្រឹងតាមរយៈការរុះរើថ្មដោយផ្នែកដែលអស្ថេរភាព និងបន្ថែមថ្មថ្មីត្រង់ចំណែកបាត់បង់ ជាពិសេសស្វានបញ្ចូលស្នូលនិងប្រើដែកតាមដើម្បីពង្រឹងរចនាសម្ព័ន្ធឬបង្កាន់ដៃឲ្យរឹងមាំ។

ដោយឡែកនៅក្នុងឆ្នាំ២០១៦ អាជ្ញាធរជាតិអប្សរាបានធ្វើកិច្ចការអភិរក្សបម្លាក់ទេពនៅខ្នងទ្វារទន្ទេរ៉ុំដោយសង់ព្រះកេសទៅតាថ្មីចំនួន៣ព្រះកេសក្រោមជំនួយថវិកាពីសប្បុរសជន និងយកទៅដំឡើងភ្ជាប់ជាមួយដងខ្លួនទៅតាវិញ។









ជួសជុលចម្ងាក់ឯវចនាសម្ព័ន្ធថ្ម
ជៅខ្ញាងទ្វារតាគាវ

លើពិនិត្យលើរចនាសម្ព័ន្ធថ្មនៅខ្ញាងទ្វារនេះក្នុងឆ្នាំ១៩៣៦ដែលជា រូបឯកសារចាស់ៗរបស់សាលាបារាំងចុងបូព៌ា(EFEO) បង្ហាញថា ស្ថានភាពខ្លះធ្ងន់ធ្ងរមខ្លាំង ក្នុងនោះរចនាសម្ព័ន្ធថ្មត្រូវបានបំផ្លាញ ដោយសារដើមឈើដុះពីលើ បណ្តាលឱ្យថ្មជាច្រើនដុំរលុះឆ្ងាក់ កយប៉ាយដោយផ្នែកៗ រួមទាំងថ្មរបចម្ងាក់ខាញត្រីត្រនៅសងខាង ផ្នែកខាងលិចខ្ញាងទ្វារ បាក់ធ្លាក់ទាំងស្រុង។



ក្រាយជួសជុល

ក្នុងឆ្នាំ២០២១អាជ្ញាធរជាតិអប្សរាបានផ្តើមអនុវត្តជួសជុលពង្រឹងខ្លោងទ្វារទាំងមូលឡើងវិញក្រោមជំនួយថវិកាពីសប្បុរសជននៅក្នុងស្រុក ដើម្បីជួសជុលរចនាសម្ព័ន្ធថ្មដំបូលខ្លោងទ្វារនិងច្រកចូលជួសជុលរូបចម្លាក់ដំរីក្បាលបីទាំងបួនទិស ជួសជុលជញ្ជាំងថ្មបាយក្រៀមអមខ្លោងទ្វារ និងជួសជុលបង្គាន់ដៃរូបចម្លាក់ទាញព្រ័ត្រទាំងសងខាងនៅផ្នែកខាងលិចប្រវែង១០ម៉ែត្រៗនៅដើមឆ្នាំ២០២២ អាជ្ញាធរជាតិអប្សរាកំពុងប្រតិបត្តិកិច្ចការបច្ចេកទេសមួយចំនួនដោយរៀបចំបញ្ចូលត្រង់ទីតាំងដើមវិញផ្នែកដំបូលខាងលិច បន្តជួសជុលពង្រឹងរូបចម្លាក់ថ្មដំរីក្បាលបីនៅជ្រុងពាយ័ព្យនិងនៅជ្រុងអាគ្នេយ៍ និងជួសជុលរូបចម្លាក់ទាញព្រ័ត្រខាងលិចរួមទាំងពង្រឹងថ្មក្រាំងកសិន្ទុ។


ពិធីប្រុងពលីដំណើរការជួសជុលខ្លោងទ្វារនាពេលវេ


មុនជួសជុល


កំពុងជួសជុល


ក្រោយជួសជុល

កិច្ចការអភិរក្សលើជញ្ជាំងជួសជុលកំពែងក្រុងអង្គរធំ

ជញ្ជាំងកំពែងថ្មបាយក្រៀមក្រុងអង្គរធំ មានប្រវែងសរុប១៦គ.ម ដោយគិតរួមលើទំហំបួនជ្រុងស្មើៗ

គម្រោងអភិរក្សនិងជួសជុលឡើងវិញសម្រាប់រយៈពេលជិត៣០ឆ្នាំកន្លងមកនេះ អាជ្ញាធរជាតិអប្សរាបានទិតទំលើកតម្លៃ និងជួសជុលរួចរាល់រចនាសម្ព័ន្ធសំណង់បុរាណនេះបានសរុប១៦៣ ម៉ែត្រដែលស្ថិតនៅត្រង់ទីតាំងខុសៗគ្នារួមមាន៖កំពែងប្រវែង៣៩ម៉ែត្រ ស្ថិតនៅស្ទាបខាងកើតខ្នោងទ្វារដីឆ្នាំងបានជួសជុលរួចកាលពីក្នុងចន្លោះឆ្នាំ ២០១៦ ដល់ឆ្នាំ២០១៩។ កំពែងជ្រុងឦសានក្រុងអង្គរធំប្រវែង៨ម៉ែត្រជួសជុលរួចក្នុងឆ្នាំ២០១៦។ កំពែងប្រវែង៣៦ម៉ែត្រស្ថិតនៅស្ទាបខាងលិចខ្នោងទ្វារទន្ទេអ៊ុំជួសជុលរួចចន្លោះឆ្នាំ ២០១៦ ដល់ឆ្នាំ២០១៨។

កិច្ចអភិរក្សនិងជួសជុលកំពែងប្រវែង១៦ម៉ែត្រស្ទាបខាងកើតខ្នោងទ្វារដីឆ្នាំង



មុនជួសជុល



ក្រោយជួសជុល


កិច្ចអភិរក្សនិងជួសជុលកំពែងរលំបាក់ប្រវែង៦៥ម៉ែត្រស្ទាបខាងកើត-ខាងលិចខ្នោងទ្វារដីឆ្នាំង



មុនជួសជុល



ក្រោយជួសជុល


មុនជួសជុល


ក្រោយជួសជុល

កិច្ចអភិរក្សនិងជួសជុលកំពែងប្រវែង៨ម៉ែត្រជ្រុងឦសាន


មុនជួសជុល


ក្រោយជួសជុល

កិច្ចអភិរក្សនិងជួសជុលកំពែងប្រវែង១៦ម៉ែត្រខាងលិចខ្លោងទ្វារទន្លេអ៊ុំ

ការងារអភិរក្សនិងជួសជុលប្រាសាទបាយ័ន

ហេដ្ឋារចនាសម្ព័ន្ធប្រាសាទបាយ័នច្រើនកន្លែងបានជួលរលំនិងស្ថិតក្រោមការគ្រុនក្រាមខ្លាំង ហើយចំណុចហានិភ័យទាំងអស់ច្រើនតែងកើតមានឡើងនៅត្រង់ផ្នែកខ្លះនៃដំបូលកោងទងនីមួយៗ ត្រង់រចនាសម្ព័ន្ធខ្លោងទ្វារ ជញ្ជាំង សសរ និងកម្រាលថ្ម។ គម្រោងកិច្ចសហប្រតិបត្តិការរវាងអាជ្ញាធរជាតិអប្សរា ជាមួយប្រទេសជប៉ុន (APSARA-JSA/JASA)តាំងពីឆ្នាំ ១៩៩៦ រហូតដល់បច្ចុប្បន្នមាន ៦ដំណាក់កាល។ ស្ថាប័នJSA (Japanese governement team for Safeguarding Angkor)នៃរដ្ឋាភិបាលជប៉ុន គឺជាជំនួយបច្ចេកទេសសម្រាប់អភិរក្ស និងជួសជុលប្រាសាទដោយស្ថិតនៅក្រោមកិច្ចសហប្រតិបត្តិការរវាងអង្គការអន្តរជាតិ យូណេស្កូ-ជប៉ុន-អាជ្ញាធរជាតិ-អប្សរា។



ប្រាសាទបាយ័ន

គោលដៅផ្នែកអភិរក្សរបស់គម្រោងនេះនាចន្លោះឆ្នាំ១៩៩៥ ដល់ឆ្នាំ១៩៩៩ បានសម្រេចលទ្ធផលជួសជុលហោត្រៃខាងជើង និងខ្នោងទ្វារខាងកើតរបស់ប្រាសាទបាយ័ន។ ឆ្នាំ២០១១ បានបញ្ចប់ការជួសជុលហោត្រៃខាងត្បូង។ ឆ្នាំ២០១៦ បានជួសជុលកែលម្អប៉ម លេខ៣៥ ត្រង់ជញ្ជាំងកោងខងខាងក្រៅនៃខ្នោងទ្វារខាងត្បូង បានធ្វើកំណាយស្រាវជ្រាវលើរចនាសម្ព័ន្ធកាំជណ្តើរខាងកើត ជួសជុលបង្គាន់ដៃនាគ ជួសជុលចម្លាក់តោខាងត្បូងនិងខាងជើងប៉មលេខ៣៥ និងបញ្ចប់ការងារជួសជុលប៉មលេខ៣៧។ ឆ្នាំ២០១៩ ធ្វើកំណាយស្រាវជ្រាវនៅទីតាំងកនហាលខាងកើតនៃប្រាសាទបាយ័នព្រមទាំងជួសជុលចម្លាក់តោចំនួន៤ នៅកនហាលនេះ។





កំពុងជួសជុល

កិច្ចអភិរក្សនិងជួសជុលបង្គាន់ដៃនាគនិងចម្លាក់តោ



ក្រោយជួសជុល

ឆ្នាំ២០១៦ ជួសជុលកែលម្អកាដទង់ខាងកើតស្ថាបនាដើងនៃប៉ម លេខ៥៦។ ឆ្នាំ ២០១៨ រហូតដល់បច្ចុប្បន្ន ជួសជុលបង្កាន់ដៃនាគ ខាងកើត ជួសជុលកាដទង់ខាងក្រៅត្រង់បរិវេណទី១ នៃប៉ម លេខ៦៨ និងកំពុងបន្តជួសជុលពង្រឹងប៉ម លេខ៦៨ ត្រង់បរិវេណទី២ និង ជួសជុលចម្លាក់ក្រឡេតខាងៗ

ចាប់ពីខែ មេសា ឆ្នាំ២០២២តទៅ តម្រាវសហប្រតិបត្តិការរួមរវាង អាជ្ញាធរជាតិអប្សរា និងប្រទេសជប៉ុននឹងត្រូវបន្តអនុវត្តកិច្ច អន្តរាគមន៍ចំនួន០៤ ទីតាំងបន្ថែមទៀតដែលទាក់ទងទៅនឹងតម្រាវ សិក្សា ជួសជុលពង្រឹងគ្រឹះប៉ម ចំកណ្តាលប្រាសាទបាយ័ន រួមទាំង រចនាសម្ព័ន្ធថ្មផ្នែកខាងលើ អភិរក្សចម្លាក់លើជញ្ជាំងកាដទង់ខាង ក្នុង ជួសជុលជំហ្លួកាដទង់ខាងក្នុង និងតម្រាលថ្ម ជួសជុលបង្កាន់ ដៃនាគនៅប៉មកណ្តាល និងរៀបចំបរិវេណកាដទង់ខាងក្រៅជ្រុង ឦសានឆ្ពោះទៅតាមបណ្តោយផ្លូវច្បាល។


មុនជួសជុល


ក្រោយជួសជុល



មុនជួសជុល

កិច្ចអភិរក្សនិងជួសជុលជួសជុលសហគ្រាសាង់ស្វង



ក្រោយជួសជុល

កិច្ចការអភិរក្ស និងជួសជុល ប្រាសាទតុបខាងលិច

ស្ថាប័ណាក៏នៃប្រទេសជប៉ុនកំពុងយកចិត្តទុកដាក់ជួសជុលសព្វថ្ងៃៗបន្ទាន់ទៅលើប្រាសាទតុបខាងលិចនេះ ដោយសហការជាមួយអាជ្ញាធរជាតិអប្សរា ក្រោមគម្រោងរយៈពេល១០ឆ្នាំ។

ពីឆ្នាំ២០១១ ដល់ ឆ្នាំ២០១៥ បានបញ្ចប់រុះរើឬ និងរៀបចំឡើងវិញត្រង់រចនាសម្ព័ន្ធប៉មខាងត្បូង និងប៉មខាងជើងរឹងដំណាក់កាលទី២ ពីឆ្នាំ២០១៦ ដល់ឆ្នាំ២០២២កំពុងបន្តជួសជុលពង្រឹងប៉មជំកណ្តាល។





ក្រោយជួសជុល





មុនជួសជុល



កំពុងជួសជុល



កំពុងជួសជុល

ការងារអភិរក្សនិងជួសជុល
ប្រាសាទបាគូន

ក្រោមការដឹកនាំដោយលោក B. P.Grosleir បុរាណវិទូនៃសាលាបារាំងចុងបូព៌ា (EFEO) និងលោក Jacques Dumarcay ជាស្ថាបត្យករបានជួសជុលប្រាសាទបាគូនដោយប្រើប្រាស់វិធីសាស្ត្រអាណាស្ទីឡូដើម្បីពង្រឹងគ្រឹះប្រាសាទដ៏ធំនេះ បន្ទាប់មកក៏បានជួសជុលថ្មកក់យកមកដាក់ឱ្យដូចនឹងស្ថានភាពដើមរបស់វាចនាសម្ព័ន្ធសំណង់។



ប្រាសាទបាគូន

កិច្ចការនេះបានបន្តអនុវត្តអស់រយៈពេល១៦ឆ្នាំ ដោយលោក Pascal Royere ជាស្ថាបត្យករមកពីសាលាបារាំងចុងបូព៌ា ដែលបានធ្វើឱ្យប្រាសាទទាំងមូលមានលំនឹងឡើងវិញព្រមទាំងបានអភិរក្សទុកនូវដំណាក់កាលសំខាន់ៗ ទាំងពីរបស់ប្រវត្តិប្រាសាទគឺសម័យកាលទាក់ទងនឹងព្រហ្មញ្ញសាសនា ជាពិសេសគឺរូបចម្លាក់នៅតាមជញ្ជាំងរៀបរាប់ពីរឿងរាមកេរ្តិ៍និងសម័យកាលពុទ្ធសាសនាមានរូបព្រះពុទ្ធចូលព្រះនិព្វាន។









ជួសជុលថ្មត្រួបកឈូក ដៅព្រះលានដល់ដី

ក្នុងឆ្នាំ២០១៥កន្លងទៅ ថ្មត្រួបកឈូកចំនួន១១ដុំ បានរលុះធ្លាក់បាក់ដោយសារភាពពុកផុយនៃដែកទាមថ្ម ដែលបានប្រើប្រាស់អំឡុងពេលជួសជុល។ ក្រុមអភិរក្សថ្មនៃអាជ្ញាធរជាតិអប្សរាបានសិក្សា និងអន្តរាគមន៍បន្ទាន់ ដោយប្រមូលបំណែកថ្មទាំងអស់យកទៅជួសជុលពង្រឹង តភ្ជាប់និងរៀបដំឡើងនៅត្រង់ទីតាំងដើមវិញរួចរាល់ក្នុងឆ្នាំ២០១៦។



ក្រាយជួសជុល



កំពុងជួសជុល



មុនជួសជុល

ជួសជុល ព្រះបរមរាជភិន កិមានអាកាស អង្គរធំ

នៅឆ្នាំ១៩៩៦ រហូតដល់ឆ្នាំ២០០០ ក្រោមជំនួយបច្ចេកទេសសម្រាប់អភិរក្សអង្គរហៅ (ITASA) នៃរដ្ឋាភិបាលប្រទេសឥណ្ឌូនេស៊ី ដោយសហការជាមួយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈកម្ពុជា អាជ្ញាធរជាតិអប្សរាបានជួសជុលរួចរាល់ខ្នោងទ្វារចំនួនបី គឺខ្នោងទ្វារខាងជើង ខ្នោងទ្វារខាងត្បូង និងខ្នោងទ្វារធំកណ្តាលខាងកើតនៃព្រះបរមរាជភិនអង្គរធំ។



គម្រោងអភិរក្សដោយឡែកមួយទៀត គឺជាគម្រោងតាំទ្រថែរក្សាពីក្រសួងហិរញ្ញវត្ថុ និងសភាចិនផ្នែកបេតិកភណ្ឌវប្បធម៌ហៅ CACH (Chinease Academy of Cultural Heritage) បានពង្រីកកម្មវិធីជួសជុលប្រាសាទកិមានអាកាសនៃព្រះបរមរាជភិន អង្គរធំសម្រាប់ឆ្នាំ២០១៨ ដល់ឆ្នាំ២០២៥។



មុនជួសជុល



ក្រោយជួសជុល

កិច្ចការអភិរក្ស និងជួសជុល ក្រុមប្រាសាទព្រះពិហារ

គម្រោងស្តារឡើងវិញសម្រាប់អភិរក្ស និងជួសជុលក្រុមប្រាសាទព្រះពិហារ រយៈពេលវែងនាដំណាក់កាលទី១សម្រាប់ឆ្នាំ២០១៥ ដល់ឆ្នាំ២០១៧ គឺស្ថិតក្រោមជំនួយអភិវឌ្ឍន៍ផ្លូវការរបស់ (ODA) នៃរដ្ឋាភិបាលកូរ៉ៃ ដែលត្រូវបានគ្រប់គ្រងដោយភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉ៃ KOICAៗ គម្រោងនេះបានអនុវត្តរួមគ្នារវាងមូលនិធិសិប្បកម្មវប្បធម៌កូរ៉ៃ (KCHEF) និងអាជ្ញាធរជាតិអប្សរាដោយជួសជុលរួចរាល់លើលានភ្លឺកាកបាទស្ថិតនៅខាងលិចផ្លូវចូលប្រាសាទ នៅក្នុងឆ្នាំ២០១៨ៗ



ប្រាសាទព្រះពិហារ


កំពុងជួសជុល


មុនជួសជុល




មុនជួសជុល


ក្រោយជួសជុល

ការអភិរក្សនិងជួសជុលប្រាសាទតាព្រហ្ម

ស្ថាប័នASIបាននិងកំពុងសហការយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរជាតិ-អប្សរក្រោមការសម្របសម្រួលរបស់គណៈកម្មាធិការអន្តរជាតិសម្រាប់កិច្ចការអភិរក្សតំបន់ប្រវត្តិសាស្ត្រអង្គរ (ICC-Angkor)។

រហូតមកដល់បច្ចុប្បន្នការងារអភិរក្ស និងជួសជុលសម្រេចបានដោយជោគជ័យលើការងារចំនួនប្រាំ ក្នុងចំណោមទីតាំងគម្រោងចាំងប្រាំបី ពោលគឺ ថៅរទីបី ប៉ែកខាងកើតស្ថាបនាខាងត្បូង ស្ពានហាលខាងលិចតភ្ជាប់កំពែងទីបីនិងទីបួន ខ្ទោងទ្វារកំពែងទីបួនខាងលិច ខ្ទោងទ្វារខាងលិចកំពែងទីប្រាំ រួមទាំងជញ្ជាំងថ្មបាយក្រៀមនៅសងខាងនិងផ្នែកខ្លះនៃសាលរចាំ។



ប្រាសាទតាព្រហ្ម



ក្រោយជួសជុល

កិច្ចអភិរក្សនិងជួសជុលសាលាចាំ



កំពុងជួសជុល



ក្រោយជួសជុល



មុនជួសជុល



ក្រោយជួសជុល



មុនជួសជុល

កិច្ចអភិរក្សនិងជួសជុលថែវធីបី ប៉ែកខាងកើតស្ថាបនាងត្បូង






កិច្ចអភិរក្សនិងជួសជុលខ្នងផ្លូវខាងលិចកំពែងទីប្រាំ រួមទាំងជញ្ជាំងថ្មបាយក្រៀម







មុនជួសជុល



មុនជួសជុល



កំពុងជួសជុល

កិច្ចការអភិរក្សជំនួសជុលប្រាសាទតាឆៃ

គម្រោងសហប្រតិបត្តិការរួមរវាងអាជ្ញាធរជាតិអប្សរា និងវិទ្យាស្ថានជាតិស្រាវជ្រាវ មរតកវប្បធម៌នៃទីក្រុងតូក្យូប្រទេសជប៉ុន (INRCP,TOKYO) ស្តីពីកិច្ចការស្រាវជ្រាវអំពីកម្រិតខ្ជះខ្ជាតថ្មប្រាសាទ ដែលបណ្តាលមកពីជីវសាស្ត្រចម្រុះបានបញ្ចាប់នៅក្នុងខែមករា ឆ្នាំ២០១៣។



កំពុងជួសជុល



ក្រោយជួសជុល

កម្មវិធីអភិរក្សប្រាសាទតានៃបានធ្វើកិច្ចការអន្តរាគមន៍ជាច្រើន ដូចជា៖ រៀបចំបុះបញ្ចីសារពើភណ្ឌថ្មនិងវត្ថុសិល្បៈ ទស្សន្ទ្រវនាសម្ព័ន្ធប្រាសាទចំនួន៦០កន្លែងដែលមានកម្រិតហានិភ័យខ្ពស់ សិក្សានិងសម្រង់ប្លង់ប្រាសាទដោយធ្វើការរួមគ្នារវាងអាជ្ញាធរជាតិ-អប្សរា ជាមួយអ្នកជំនាញជប៉ុនមកពីស្ថាប័ន INRCP,TOKYO ក្នុងនោះបានរៀបចំធ្វើកំណាយស្រាវជ្រាវនៅតាមបណ្តោយច្រកចូលខ្វោងទ្វារខាងកើត និងជួសជុលពន្រ្លឹងរួចរាល់ខ្វោងទ្វារខាងកើតនៅក្នុងឆ្នាំ៦០២០។




កំពុងជួសជុល




កំពុងជួសជុល

កិច្ចការអភិរក្សនិងជួសជុល
ប្រាសាទខនទេស្វូត

អាជ្ញាធរជាតិអប្សរា បានកំណត់គម្រិតជួសជុលប្រាសាទនេះដោយ តម្រូវឲ្យរុះរើថ្មប៉ម ប្រាសាទទាំងស្រុងចាប់ពីខឿនហូតដល់កំពូល និងរៀបឡើងវិញស្របតាមទម្រង់ដើមរបស់ប្រាសាទ និងអនុវត្តតាម អនុសាសន៍ណែនាំនៃគណៈកម្មាធិការអាយស៊ីស៊ី-អង្គរ។ ប៉ម ប្រាសាទខនទេស្វូតត្រូវបានរៀបដំឡើងរួចរាល់ជាស្ថាពរនៅ ក្នុងឆ្នាំ២០២០។



ប្រាសាទខនទេស្វូត





ក្រោយជួសជុល


មុនជួសជុល


កំពុងជួសជុល

កិច្ចអភិរក្សនិងជួសជុលប៉មប្រាសាទទន្ទេស្ងួត ត្រូវបានរៀបដំឡើងរូបភាងឡើងវិញ


កំពុងជួសជុល


មុនជួសជុល

កិច្ចការអភិរក្ស
ប្រាសាទព្រះខ័ន

អាជ្ញាធរជាតិអប្សរា បានសហការជាមួយអង្គការមូលនិធិប្រាសាទពិភពលោក World Monuments Fund (WMF) ធ្វើសម្រង់ប្លង់និងសិក្សាយ៉ាងហ្មត់ចត់ពីស្ថានភាពគ្រោះថ្នាក់ រួមទាំងការធ្វើកំណាយបុរាណវិទ្យា ដើម្បីពិនិត្យស្ថានភាពគ្រឹះរបស់ប្រាសាទ។

ពង្រឹងរចនាសម្ព័ន្ធខួចខាតបន្ទាន់ៗចំនួន ៣០ កន្លែង ទល់ប្រប្រាសាទរួចរាល់ចំនួន១៦កន្លែង បន្ថែមផែនការទល់ប្រ២០កន្លែងទៀត ជួសជុលខ្ទោងទ្វារទី៣នៃប៉មកណ្តាលប៉ែកខាងកើតនិងខាងលិច ជួសជុលស៊ុមទ្វារខាងជើងនៃអគារតាប្រហ្ម ជួសជុលចម្លាក់ត្រុងចំនួន៣០ត្រុង ទល់ប្រខ្ទោងទ្វារទី៣ខាងត្បូង ទល់ប្រជំបូលរោងឧបទី៦ខាងត្បូង រួមទាំងចងគ្រឹបរចនាសម្ព័ន្ធប្រាសាទមួយចំនួនទៀត។


ប្រាសាទព្រះខ័ន


មុនជួសជុល


ក្រោយជួសជុល


មុនជួសជុល


ក្រោយជួសជុល

កិច្ចអភិរក្សនិងជួសជុលខ្ទោងទ្វារខាងកើត អគារព្រះឥសូរ


កំពុងជួសជុល


ក្រោយជួសជុល

កិច្ចអភិរក្សនិងជួសជុលគ្រុឌ

អភិរក្សជួសជុលប្រាសាទតាសោម

នៅឆ្នាំ២០០៧ គម្រោងអភិរក្សរបស់អង្គការមូលនិធិប្រាសាទពិភពលោក(WMF) ក្រោមកិច្ចសហការជាមួយអាជ្ញាធរជាតិអប្សរា ប្រាសាទតាសោម បានធ្វើការអភិរក្សបន្ទាន់មួយចំនួនលើរចនាសម្ព័ន្ធថ្មជុំវិញប្រាសាទ។ ដំណាក់កាលដំបូង ក្បឿបចំថ្មដែលធ្លាក់រាយប៉ាយ ផ្តុំថ្មឡើងវិញ តំរឿបថ្មដាក់ឲ្យមានសណ្តាប់ធ្នាប់ដើម្បីការពារថ្មបាត់បង់ដោយប្រការណាមួយ និងជឿសាងការខូចខាតផ្សេងៗ។ ក្រុមជួសជុលប្រាសាទរបស់អង្គការ WMFបានបញ្ចប់គម្រោងជួសជុលខ្នងទ្វារទី១ ប៉ែកខាងកើត ខាងជើង និងខ្នងទ្វារទី៦ប៉ែកខាងលិច។ អង្គការនេះក៏បានសហការផ្នែកបច្ចេកទេសជាមួយអាជ្ញាធរជាតិអប្សរាដើម្បីសិក្សារកទីតាំងផ្តល់លទ្ធភាពរឿបចំបញ្ចៀសប្រព័ន្ធទឹកចូលប្រាសាទតាសោមនៅរដូវភ្លៀង។





ប្រាសាទតាសោម









កិច្ចការអភិរក្សលើផ្នែកស្ពានឆ្លងទន្លេនិងប្រាសាទជាតព័ទ្ធ



ប្រាសាទខាងជើង

ប្រាសាទនាគព័ទ្ធមានទន្លេទឹកចំនួន៤ នៅតាមទិសធំៗទាំងបួន ហើយនៅតាមរន្ធបង្ហូរទឹកនីមួយៗលម្អដោយរូបចម្លាក់ខុសៗ គ្នា និងមានសង់ជំបូលគ្របពីលើអំពីថ្មកក់ ក្នុងនោះ ទន្លេបង្ហូរទឹកខាងកើតលម្អរូបក្បាលមនុស្ស ខាងលិចលម្អរូបក្បាលសេះ ខាងជើងលម្អរូបដំរី និងខាងត្បូងលម្អរូបក្បាលនាគ។ បច្ចុប្បន្ន ជំបូលទន្លេបង្ហូរទឹកទាំងបួនមានស្ថានភាពទ្រុឌទ្រោម ជាពិសេសរចនាសម្ព័ន្ធជំបូលនៃទន្លេទឹកខាងត្បូងខូចខាតខ្លាំងជាងគេ ដោយសារមានសម្ពីន្ធថ្មប្រេះ ឆៀកជាច់ពីគ្នាចន្លោះពី៥ស.ម ទៅ១៥ស.ម។ ក្នុងខែតុលា ឆ្នាំ ២០១៦ កន្ទុយទៅ ថ្មកំពូលហោជាងផ្នែកខាងជើងនៃជំបូលទន្លេបង្ហូរទឹកខាងត្បូងចំនួន១ជុំបានធ្លាក់ពីកន្លែងដើម។ រីឯខែកុម្ភៈ ឆ្នាំ២០១៧ ក៏មានថ្មជណ្តើរចំនួនពីរដុំស្ថិតនៅខាងកើតជ្រុងខាងត្បូង ស្រះទឹកខាងលិចប្រាសាទនាគព័ទ្ធបានរអិលចេញពីទីតាំងដើម រួមទាំងថ្មនៅទីនេះមានស្ថានភាពស្រុតចុះដោយផ្នែកៗត្រង់ថ្មកម្រាលជុំវិញមាត់ស្រះ។


កំពុងជួសជុល


កំពុងជួសជុល


មុនជួសជុល


ក្រោយជួសជុល

ប្រវត្តិខាងអភិរក្សរបស់សាលាបារាំងចុងបូព៌ា (EFEO) គឺ ធ្លាប់បានធ្វើការជួសជុលដំបូលទេបង្គួរទឹកខាងត្បូងនេះរួចម្តងហើយ ប៉ុន្តែសម្ភារៈពន្លឺដូចជា ដែកខាមឬដុំបេតុងត្រូវបានពុកផុយទាំងស្រុង ដូច្នេះ ការជួយស្រួយលើសម្ភារៈដែលបានអន្តរាគមន៍ទាំងនោះ តួបផ្សំកន្លាជាច្រើនទៀតពាក់ព័ន្ធទៅនឹងកម្រិតប្រែប្រួលដីបាតគ្រឹះរបស់សំណង់ចុះខ្សោយ វាជាកត្តាដើមហេតុនាំមកទៅវិញ្ញាយនឹងបន្តរលុះបាក់នាពេលខាងមុខៗ នៅចុងឆ្នាំ ២០២១ ក្រុមជំនាញរបស់អាជ្ញាធរជាតិអប្សរាបានបញ្ចាប់គម្រោងជួសជុលទេបង្គួរទឹកខាងត្បូងប្រាសាទនាគព័ន្ធខ្សែរវិញក្រោមចំណាយថវិការដ្ឋទាំងស្រុង។

ការងារអភិរក្សនិងជួសជុល ប្រាសាទថៅសាយទេវតា

គម្រោងអភិរក្ស និងជួសជុលឡើងវិញគឺស្ថិតនៅក្រោមការគ្រប់គ្រង ថវិកា និងបច្ចេកទេសពីរដ្ឋាភិបាលចិន (CSA) ដោយសហការជាមួយអាជ្ញាធរជាតិអប្សរា។



ប្រាសាទថៅសាយទេវតា

គម្រោងជួសជុលប្រាសាទថៅសាយទេវតារយៈពេល៨ឆ្នាំដោយផ្តើមក្នុងឆ្នាំ២០០០ បានបែងចែកការងារជាបួនទីតាំង រួមមាន៖ ជួសជុលប៉មកណ្តាល ជួសជុលបណ្ណាល័យខាងជើង និងខាងត្បូង ជួសជុលរចនាសម្ព័ន្ធថ្មស្ពានហាលផ្នែកខាងកើត។

កិច្ចអភិរក្សនិងជួសជុលប៉មកណ្តាល


ក្រោយជួសជុល


មុនជួសជុល

កិច្ចអភិរក្សនិងជួសជុលបណ្ណាល័យខាងជើង


ក្រោយជួសជុល


មុនជួសជុល

កិច្ចអភិរក្សនិងជួសជុលបណ្ណាល័យខាងត្បូង


ក្រោយជួសជុល


មុនជួសជុល



បង្ហាន់ដៃនាគ ជ្រុងនិរតីប្រាសាទបន្ទាយសម្រែ

ការអភិរក្សជួសជុលប្រាសាទបន្ទាយសម្រែ

ជាទូទៅប្រាសាទបន្ទាយសម្រែគេឃើញកម្រិតខូចខាតច្រើន តែងកើតមាននៅលើសម្ភារៈតុបតែងលម្អនានាដូចជា៖ បម្អាក់ទោល បម្អាក់លើជញ្ជាំង សសរពេជ្រ ផ្ដែរ លោជាង ធ្នឹម បម្រើងបង្ហូច ក្រឿងបង្គុំ សំណង់ស្ថាបត្យកម្មជាទៃទៀត ជាពិសេសថ្មបង្ហាន់ដៃនាគគាន់ច្រើនធ្ងាក់ចាក់ជាកំណាត់ៗ និងរាយប៉ាយនៅជុំវិញបរិវេណខាងក្នុង។

ស្ថិតក្រោមជំនួយផ្នែកបច្ចេកទេសរបស់អង្គការ GIZ នៃរដ្ឋាភិបាលអាល្លឺម៉ង់ ក្រុមអភិរក្សថ្ម SCU នៃអាជ្ញាធរជាតិអប្សរាសម្រាប់ប្រាសាទបន្ទាយសម្រែ គឺបានស្ដែងចេញនូវលទ្ធផលសន្ធឹកសន្ធាប់រួមមាន៖ ជួសជុលពង្រឹងរួចរាល់ថ្មបម្អាក់បង្ហាន់ដៃនាគនៅបរិវេណខាងក្នុងប្រាសាទសរុបប្រវែង៣០ម៉ែត្រគិតត្រឹមចុងឆ្នាំ២០២១ ជួសជុលថ្មមឈូសបុកណារួចរាល់នៅក្នុងខែកញ្ញា ឆ្នាំ២០១៩ និងពង្រឹងក្បាច់បម្អាក់ផ្ដែរចំនួន៦ផ្ដែរ។



កំពុងជួសជុល

ក្រោយជួសជុល

មុនជួសជុល

ការអភិរក្ស និងជួសជុលប្រាសាទមេបុណ្យខាងលិច

ប្រាសាទមេបុណ្យខាងលិច ត្រូវបានអភិរក្ស ជួសជុល និងស្តារឡើងវិញដោយគម្រោងសហការរវាងអង្គុជរជាតិអប្សរានិងរដ្ឋាភិបាលជប៉ុន តាមរយៈសាលាជប៉ុនចុងបូព៌ា។



ប្រាសាទមេបុណ្យខាងលិច



មុនជួសជុល



មុនជួសជុល

កិច្ចអភិរក្សនិងជួសជុលថែរក្សាជើងកើត


កំពុងជួសជុល


កំពុងជួសជុល


កំពុងជួសជុល

កិច្ចអភិរក្សនិងជួសជុលខឿនស្រះរបស់ប្រាសាទ


កំពុងជួសជុល


កំពុងជួសជុល


មុនជួសជុល



ប្រាសាទបន្ទាយស្រី



កិច្ចការអភិរក្សជួសជុលប្រាសាទបន្ទាយស្រី

គម្រោងអភិរក្សប្រាសាទបន្ទាយស្រីហៅកាត់ថា (BSCP) នៃសហព័ន្ធស៊ីស បានសហការជាមួយអាជ្ញាធរជាតិអប្សរា ជួសជុលពង្រឹងកម្រាលដោយផ្ទៃក។ សិក្សារចនាសម្ព័ន្ធប្រព័ន្ធទឹកបុរាណ រៀបចំប្រព័ន្ធថ្មីដើម្បីរំដោះទឹក ចុះបញ្ជីថ្មនិងវត្ថុសិល្បៈដែលបានពីកំណាយ រៀបរយសណ្តាប់ធ្នាប់ថ្មប្រាសាទដែលស្ថិតនៅកយច៉ាយក្នុងបរិវេណប្រាសាទ និងរៀបចំទីលានបដិសណ្ឋារកិច្ច និងចំណតនៅផ្នែកខាងកើតប្រាសាទ។


មុនជួសជុល


ក្រោយជួសជុល

លើសពីនេះជួសជុលកំពែងទី៣ជ្រុងនិរតីប្រវែង៧ម៉ែត្រ ជួសជុលខ្នោងទ្វារខាងកើតស្ថាបខាងជើង កំពែងទី៣ ជួសជុលពង្រឹងជញ្ជាំងកំពែងទី៣ ខាងកើតប្រវែង១១ម៉ែត្រ ជួសជុលកំពែងខាងត្បូងនិងខាងលិច ចំនួន៣កន្លែង និងជួសជុលពង្រឹងរចនាសម្ព័ន្ធឥដ្ឋនៅខ្នោងទ្វារទី១ខាងលិច។



មុនជួសជុល


ក្រោយជួសជុល



ប្រាសាទមេបុណ្យខាងកើត

អភិរក្សដិនជួសជុលប្រាសាទមេបុណ្យខាងកើត

គិតត្រឹមឆ្នាំ២០១១ រហូតមកដល់បច្ចុប្បន្ន ដំណើរការអភិរក្សលើរចនាសម្ព័ន្ធប្រាសាទមេបុណ្យខាងកើតបានអន្តរាគមន៍បន្ទាន់ត្រង់ចំណុចដែលមានកម្រិតហានិភ័យខ្ពស់ ក្នុងនោះមានទីតាំងចំនួន១៦កន្លែងបានជួសជុលរួចរាល់ដូចជា៖ ជួសជុលពង្រឹងរចនាសម្ព័ន្ធជណ្តើរខាងលិចនិងខាងជើង ជួសជុលពង្រឹងជញ្ជាំងខឿនខាងក្រោមទាំងបួនជ្រុង ជួសជុលប្រព័ន្ធទទឹកបង្ហូរទឹកបុកណាចំនួន៦កន្លែង ជួសជុលពង្រឹងចំណែកថ្មស៊ីកត្រចៀកដំរីស្ថិតនៅជ្រុងឦសាន ខឿនទី១។



កំពុងជួសជុល

កិច្ចអភិរក្សនិងជួសជុលពង្រឹងជញ្ជាំងរឿនខាងក្រោមទាំងបួនជ្រុង


ក្រោយជួសជុល


មុនជួសជុល

កិច្ចអភិរក្សនិងជួសជុលពង្រឹងរចនាសម្ព័ន្ធជណ្តើរខាងជើង


ក្រោយជួសជុល


មុនជួសជុល

កិច្ចអភិរក្សនិងជួសជុលពង្រឹងរចនាសម្ព័ន្ធជណ្តើរខាងលិច


ក្រោយជួសជុល


កំពុងជួសជុល

គម្រោងអភិរក្ស និងជួសជុលប្រាសាទតាកែវ

កិច្ចអន្តរាគមន៍ផ្នែកសង្គ្រោះបន្ទាន់របស់អាជ្ញាធរជាតិអប្សរាកន្លងមក បានយកចិត្តទុកដាក់ទៅលើ ផែនការទល់ទ្រទៅលើគ្រប់រចនាសម្ព័ន្ធប្រាសាទតាកែវដែលរងការខូចខាតយ៉ាងខ្លាំង ហើយការងារនេះ ជាដំណោះស្រាយបណ្តោះអាសន្នសម្រាប់ទប់ស្កាត់គ្រោះថ្នាក់របស់ប្រាសាទ។



ក្រោយជួសជុល

ល្បាយថ្មដុំរួម

ឆ្នាំ ២០២៤ សិក្ខាសាលាអភិវឌ្ឍន៍វិជ្ជាជីវៈអភិរក្សបេតិកភណ្ឌ
ISBN 978-9924-500-00-6



ក្រោយជួសជុល



មុនជួសជុល



ក្រោយជួសជុល



មុនជួសជុល

កាលសកម្មភាពទប់ទ្រខនាសម្ព័ន្ធប្រាសាទតាកែវ បានផ្ញើឡើងនៅតាមខ្នោងទ្វារទីមួយៗ ជញ្ជាំងដែលច្រេតនិងពង្រឹងថ្មនៅរួតទី៦ជ្រុងពាយ័ព្យៗ ដោយខ្សែកគម្រោងកិច្ចសហប្រតិបត្តិការអន្តរជាតិសម្រាប់

អភិរក្សប្រាសាទតាកែវ គឺមានការចូលរួមពីគម្រោងអភិរក្សអង្គរបស់រដ្ឋាភិបាលចិន(CSA) និងសាកាថិនផ្នែកបេតិកភណ្ឌវប្បធម៌បានន័យថាគម្រោងជួសជុលប្រាសាទតាកែវចាប់ផ្តើមជាផ្លូវការនៅក្នុងខែវិច្ឆិកា




ក្រោយជួសជុល

ឆ្នាំ២០១១ ក្នុងទឹកប្រាក់ចំនួន៦០លានយ៉ន់សម្រាប់ជួសជុលជ្រុងកែងនិរតី ជួសជុលជ្រុងអាគ្នេយ៍ ជ្រុងឦសានវត្តទី៦ ជួសជុលបណ្ណាល័យខាងជើង ជួសជុលបណ្ណាល័យខាងត្បូងនិងរចនាសម្ព័ន្ធថ្មដទៃទៀត។ ក្នុងឆ្នាំ ២០១៦ គម្រោងនេះបានបន្តជួសជុលផ្នែកសេសសល់នៅខ្នងទ្វារខាងជើង ខ្នងទ្វារខាងលិច និងកោនទល់វត្តទី៦ ក្នុងនោះបន្ថែមកម្មវិធីកំណាយស្រាវជ្រាវនៅជ្រុងអាគ្នេយ៍នៃប៉មពីរាំមីត រួមទាំងអភិរក្សក្បាច់ចម្លាក់លើជញ្ជាំងជ្រុងឦសានវត្តទី១។ ពេលវេលាសម្រាប់ជួសជុលប្រាសាទតាកែវដោយក្រុមអភិរក្សអង្គរបស់រដ្ឋាភិបាលចិន (CSA) បានបញ្ចប់បេសកកម្មជួសជុលប្រាសាទតាកែវនៅក្នុងឆ្នាំ២០១៨។



មុនជួសជុល



ប្រាសាទតាកែវ

កិច្ចអភិរក្សនិងជួសជុលជ្រុងឆ្ពិសានៃខឿនជាន់ទី៦



ក្រោយជួសជុល



មុនជួសជុល



កិច្ចអភិរក្សនិងជួសជុលជ្រុងឦសានខាងលើនៃខឿនជាន់ទី៣



ក្រោយជួសជុល



មុនជួសជុល

កិច្ចអភិរក្សនិងជួសជុលជ្រុងពាយ័ព្យនៃខឿនជាន់ទី៦



ក្រោយជួសជុល



មុនជួសជុល



ប្រាសាទប្រែរូប

កិច្ចការអភិរក្សជំនួសជុលប្រាសាទប្រែរូប

អង្គការ I.Ge.S នៃប្រទេសអ៊ីតាលីបានយកចិត្តទុកដាក់ទៅលើបច្ចេកទេសពង្រឹងប៉មដោយស្វានដាក់ស្នូលដើម្បីត្រឹមប៉ម និងជួសជុលឥដ្ឋដោយផ្នែកៗ លើប្រាង្គឥដ្ឋធំៗចំនួន១០ ស្ថិតនៅជុំវិញបរិវេណប្រាសាទប្រែរូប ដោយសហការជាមួយអាជ្ញាធរជាតិអប្សរា។






ក្រោយជួសជុល




មុនជួសជុល


មុនជួសជុល


កំពុងជួសជុល

ដោយឡែកគម្រោងរបស់GIZនៃប្រទេសអាឡឺម៉ង់ក៏បានចូលរួមផ្នែកបច្ចេកទេសលើកម្មវិធីអភិរក្សថ្មដែលស្ថិតក្រោមចំណាយថវិកា និងមន្ត្រីបច្ចេកទេសខ្មែរពីអាជ្ញាធរជាតិអប្សរា។ បដិមាព្រះពុទ្ធរូបពីរអង្គនៅប៉ែមកណ្តាលប្រាសាទប្រែរូបបានជួសជុល ផ្តុំនិងតភ្ជាប់បំណែកជង្គង់ព្រះពុទ្ធឡើងវិញរួចរាល់ក្នុងខែតុលា ឆ្នាំ២០១៨។ កិច្ចការសំខាន់ផ្នែកជួសជុលព្រះពុទ្ធរូបនេះគឺ យកចិត្តទុកដាក់អភិរក្សខ្មុកម្រ័ក្សដែលជាបច្ចេកទេសបុរាណបានប្រើប្រាស់លាបលើផ្ទៃថ្មព្រះពុទ្ធរូប ដោយសហការជាមួយអ្នកជំនាញមកពីស្ថាប័នអន្តរជាតិ(EFEO) ។

ក្រុមអភិរក្សថ្ម (SCU) នៃអាជ្ញាធរជាតិអប្សរាបានប្រមូលបំណែករូបបដិមាគោចំនួន៥ដើម្បីផ្គុំតភ្ជាប់ និងជួសជុលឡើងវិញរួចរាល់ក្នុងឆ្នាំ២០១៦ និងឆ្នាំ២០១៨។

បដិមាគោចំនួន ៥មានទីតាំងស្ថិតនៅឯុសៗគ្នា (ចំនួន១ស្ថិតនៅវត្តទី៣ជណ្តើរឡើងខាងត្បូង ចំនួន១នៅវត្តទី១ជណ្តើរខាងជើង និងចំនួន៣នៅប៉មជ័យគណ្ឌាលា ប្រាសាទប្រែរូប។

កម្រិតនៃការជួសជុលបដិមាគោនេះគឺ តភ្ជាប់បំណែកដងខ្លួនឡើងវិញ បំពេញបន្ថែមដុំថ្មកក់ថ្មីមួយចំនួនត្រង់ផ្នែកដែលបាត់បង់រួមមាន៖ បន្ថែមប្រអប់ជើងថ្មី និងមួយភាគនៃថ្មដងខ្លួន។


កំពុងជួសជុល


ក្រោយជួសជុល


មុនជួសជុល


មុនជួសជុល


មុនជួសជុល


ក្រោយជួសជុល


មុនជួសជុល


មុនជួសជុល

គម្រោងជួសជុលខ្នងថ្ងាទី៦នាងកើតប្រាសាទប្រែរូប តិបានធ្វើឡើងនៅត្រង់ចំណុចប្រឈមនឹងហានិភ័យខ្ពស់ចំនួន៦០កន្លែងនៃស្ថាបនាងស្ទួង ជាដំណាក់កាលទី១ ក្នុងឆ្នាំ២០២១ ហើយបានបញ្ចប់ការជួសជុលឥដ្ឋជាស្ថាពរនាចុងឆ្នាំ២០២១ ផងដែរ។




ក្រោយជួសជុល

កិច្ចការអភិរក្សលើផ្នូរជុល
ប្រាសាទគោកចក



ក្រោយជួសជុល



មុនជួសជុល



ក្រោយជួសជុល

គម្រោងអភិរក្សក្នុងឆ្នាំ២០១៦ បានជួសជុលប៉មខាងត្បូងដោយចំណាយថវិកាទាំងស្រុងរបស់អាជ្ញាធរជាតិអប្សរា ចំណែកលទ្ធផលនៃកិច្ចការសង្គ្រោះឡើងវិញ គឺបានកាត់បន្ថយការគ្រោះថ្នាក់របស់ប្រាសាទជាពិសេសរចនាសម្ព័ន្ធឥដ្ឋនៅខ្ទោងទ្វារខាងកើត ជញ្ជាំងខាងជើងនិងខាងត្បូងដោយទទួលទ្វេភាពវិញមាំបន្ទាប់ពីជួសជុលរួច។



កំពុងជួសជុល



ក្រោយជួសជុល

កិច្ចការអភិរក្សដ៏ធំជួសជុលទ្រង់សាធចាតជុំ



មុនជួសជុល



កំពុងជួសជុល



កំពុងជួសជុល

ប័មឥដ្ឋទាំងបីនៃប្រាសាទបាតដុំ ត្រូវបានអភិរក្ស និងជួសជុលឡើងវិញតាំងពីឆ្នាំ២០០៦ តាមរយៈការធ្វើកំណាយស្រាវជ្រាវ សំអាត ចងគ្រឹប និងទល់ទ្រដោយអាជ្ញាធរជាតិអប្សរា សហការជាមួយបាក់ង (FSP_ACCPR) ។ ដោយឡែកប័មឥដ្ឋខាងជើង ប័មកណ្តាល និងប័មខាងត្បូងបានពង្រឹងរចនាសម្ព័ន្ធឥដ្ឋដោយផ្នែកៗ ក្នុងចន្លោះឆ្នាំ២០១៩ ដល់ ឆ្នាំ២០២២។




ក្រោយជួសជុល

កិច្ចការអភិរក្សជួសជុល
ប្រាសាទអកយំ



ក្រោយជួសជុល

ទម្រង់សំណង់ប្រាសាទឥដ្ឋព្រាលៗដែលនៅសល់ពីការលំបាក់ជាច្រើនឆ្នាំមក ត្រូវបានអាជ្ញាធរជាតិអប្សរាយកចិត្តទុកដាក់ជួយសង្គ្រោះឡើងវិញតាមរយៈអនុវត្តកិច្ចការជួសជុលឥដ្ឋដោយផ្នែក។ តាំងពីឆ្នាំ២០១៨ ដល់ឆ្នាំ២០២០។



កំពុងជួសជុល



មុនជួសជុល

លើសពីនោះក៏មានកម្មវិធីធ្វើកំណាយបុរាណវិទ្យាផងដែរ ដោយសហការជាមួយស្ថាប័នសាលាបារាំងចុងបូព៌ា (EFEO) នាអំឡុងឆ្នាំ២០១៨។

កិច្ចការអភិរក្ស ប្រាសាទត្រពាំងផុង




គម្រោងថែទាំនិងអភិរក្សប្រាសាទឡើងវិញ តឹមានការចូលរួមពីការដ្ឋានជាតិនិងអន្តរជាតិ ក្នុងនោះស្ថាប័នអន្តរជាតិ (GACP)នៃប្រទេសអាល្លឺម៉ង់ បានផ្តល់នូវការយកចិត្តទុកដាក់លើផ្នែកអភិរក្ស និងជួសជុលពង្រឹងកំពោរបាយអដែលស្ថិតនៅសួចស្តើងលើជញ្ជាំងឥដ្ឋរបស់ប្រាសាទ។ ដោយឡែក ស្ថិតក្រោមចំណាយថវិកាមូលនិធិអភិរក្សនិងអភិវឌ្ឍន៍អន្តរឆ្នាំ២០១៨ អាជ្ញាធរជាតិអប្សរាផ្តើមអនុវត្តគម្រោងជួសជុលបន្ទាន់លើរចនាសម្ព័ន្ធឥដ្ឋត្រង់ចំណុចដែលមានហានិភ័យនៅប្រាង្គជំកណ្តាលប្រាសាទត្រពាំងផុង។ លទ្ធផលក្នុងឆ្នាំ២០២០-២០២១ តឹបានជួសជុលពង្រឹងសសរពេជ្រនៅខ្នងទ្វារខាងកើត ជួសជុលជញ្ជាំងខាងលិចពីខឿនរហូតដល់រួតកំពូលប្រាសាទ។



កំពុងជួសជុល



ក្រោយជួសជុល



មុនជួសជុល

កិច្ចការអភិរក្សលើផ្នែកជណ្តើរ
ប្រាសាទព្រៃមធ្មឹរ


ប្រាសាទព្រៃមធ្មឹរ

កម្រិតអន្តរាគមន៍នៅប្រាសាទព្រៃមធ្មឹរ ធ្វើឡើងត្រង់ចន្លោះសម្រាប់ផ្នែកជណ្តើរដែលកំពុងទទួលរងហានិភ័យខ្ពស់ជួចនេះ ផ្នែកខ្លះៗនៃប៉មទាំងបីអាជ្ញាធរជាតិអប្សរាបានរៀបចំអនុវត្តកិច្ចការសង្គ្រោះបន្ទាន់ ដោយប្រើប្រាស់បច្ចេកទេសទាល់ច្រ ចងគ្រឹប និងជួសជុលពង្រឹងឥដ្ឋត្រង់ក្បាលសសរជ្រោង នៃប៉មឥដ្ឋធំកណ្តាលក្នុងខែកុម្ភៈ ឆ្នាំ២០២០។


មុនជួសជុល


កំពុងជួសជុល


ក្រោយជួសជុល

កិច្ចការអភិរក្សប្រាសាទបាគង



ប្រាសាទបាគង

ទីនេះ ដើមឡើយគឺច្រកចូលខាងកើត ប្រាសាទបាគងស្ថិតក្នុងស្ថានភាពដីចាក់បន្ថែរសម្រាប់ធ្វើចរាចរណ៍រថយន្តគ្រប់ប្រភេទចូលបរិវេណប្រាសាទ។ ក្នុងឆ្នាំ២០១៤ អាជ្ញាធរជាតិអប្សរាផ្តើមរៀបចំជួសជុលកែលម្អច្រកចូលនេះឡើងវិញ ដោយបានកាយយកចេញនូវកំណកដី ដើម្បីធ្វើការជួសជុលរចនាសម្ព័ន្ធឬឡើងវិញ និងបង្ហាញអំពី ទម្រង់ពិតរបស់ខ្លោងទ្វារកំពែងប្រាសាទបាគង។



មុនជួសជុល



ក្រោយជួសជុល

ជួសជុលពង្រឹងប៉មឥដ្ឋលេខ៦ ប្រាសាទបាគង កិច្ចការសង្គ្រោះបន្ទាន់នៅលើប៉មឥដ្ឋលេខ៦នេះមានពីរផ្នែកក្រោមកិច្ចការសហការរួមរវាងអាជ្ញាធរជាតិ-អប្សរា និងអង្គការGACPនៃប្រទេសអាល្លឺម៉ង់។ បានន័យថា អាជ្ញាធរជាតិ-អប្សរាបានជានាក់ប់រងទាំងស្រុងលើផ្នែកបច្ចេកទេសជួសជុលរចនាសម្ព័ន្ធឥដ្ឋទាំងមូល និងរួចរាល់ពុងឆ្នាំ២០១៧។

ចំណែកអង្គការGACP មានការកិច្ចទទួលសង្គ្រោះបន្ទាន់លើចម្លាក់កំបោរបាយអស្ថិតនៅតាមជញ្ជាំងប្រាសាទ។



ក្រោយជួសជុល



កំពុងជួសជុល



មុនជួសជុល

ជួសជុលពង្រឹងប៉មឥដ្ឋលេខ៨ ប្រាសាទបាគង ជាប៉មស្ថិតនៅជ្រុងឆ្វេងនៃប៉មពីរ៉ាមីត។ ដើមឡើយប៉មនេះបានជួលរលំបាក់ ផ្នែករចនាសម្ព័ន្ធខ្វោងខ្លាំងខាងកើតក្នុងខែតុលា ឆ្នាំ២០០៩។


មុនជួសជុល


កំពុងជួសជុល


ក្រោយជួសជុល


កំពុងជួសជុល

ចាប់ពីពេលនោះមក កិច្ចការអន្តរាគមន៍បន្ទាន់បាននិងកំពុងអនុវត្តរហូតដល់សព្វថ្ងៃ នាចុងឆ្នាំ២០២២ ដោយធ្វើកិច្ចការជួសជុលពង្រឹងឥដ្ឋពង្រឹងខឿនជុំវិញ និងជួសជុលសម្ភារៈសំណង់។ល។



ក្រោយជួសជុល

ជួសជុលពង្រឹងឥដ្ឋបណ្ណាល័យជ្រុងអាគ្នេយ៍(ប៉ែកខាងជើង) ប្រាសាទបាតដ៏។ បណ្ណាល័យជ្រុងអាគ្នេយ៍បានជួសជុលពង្រឹងឡើងវិញសម្រាប់ដំណាក់កាលទី១ក្រោមការចំណាយថវិការដ្ឋឆ្នាំ២០១៩ ដូចនេះផ្នែកមួយចំនួនស្ថិតនៅជញ្ជាំងខាងជើង ជញ្ជាំងខាងលិចចាប់ពីខឿនរហូតដល់រូតទី១ ជញ្ជាំងខ្ទោងទ្វារខាងលិចនិងស៊ុមបង្ហួចខាងកើត បានជួសជុលរួចរាល់ក្នុងឆ្នាំ២០២០។



មុនជួសជុល


ក្រោយជួសជុល


កំពុងជួសជុល

ជួសជុលជញ្ជាំងថ្មកក់ជ្រុងអាគ្នេយ៍នៃជាន់ទី១ ប៉មពីរ៉ាមីត ប្រាសាទបាតដី។

ថ្មជញ្ជាំងនៅជ្រុងនេះប្រវែង១៦.៩០ម៉ែត្របានរលុះបាក់ ទាំងស្រុងនាអំឡុងឆ្នាំ ១៩៧៣ ដោយសារកម្ទិតចុះខ្សោយ នៃដីបង្គាប់ខឿនទិដការហូរច្រោះដីចេញប្រចាំឆ្នាំ។

គម្រោងសង្គ្រោះបន្ទាន់បានផ្តើមសម្រង់ថ្មរយៈប៉ាយទាំងនោះ យកទៅជួសជុល ដោយបានរៀបដំឡើងថ្មជាក់បញ្ជូល នៅត្រង់ទីតាំងដើមវិញរួចរាល់នៅចុងខែធ្នូ ឆ្នាំ២០២១ កន្លងទៅ។


មុនជួសជុល


កំពុងជួសជុល

គម្រោងចងក្រឹប និងទល់ទ្រុសផ្ដោះបន្ទាប់ ប្រាសាទថាតង



ប្រាសាទបាតង

ជាខ្ទមៅរចនាសម្ព័ន្ធឥដ្ឋនៅប្រាសាទបាតងកំពុងប្រឈមទៅនឹងហានិភ័យខ្លាំងជាងរចនាសម្ព័ន្ធថ្ម ហើយផ្នែកខ្លះរបស់ប្រាង្គឥដ្ឋបានស្រុត ទ្រេតនិងរលុះឥដ្ឋជាប្រចាំ។ កិច្ចការសង្គ្រោះបន្ទាន់កន្ទុយមកបានអនុវត្តន៍ជូរបច្ចេកទេសចងក្រឹប និងទល់ទ្រុបណ្ដោះអាសន្នដោយប្រើប្រាស់ខ្សែកាបវែត ប្រើទ្រុនឈើ និងទ្រុនដែកជាដើម។

ជាលទ្ធផលលើសកម្មភាពសង្គ្រោះបន្ទាន់គឺសម្រេចបានចំនួន ១០ ទីតាំងរួមមាន៖ ទល់ទ្រប៉មឥដ្ឋលេខ១៧ ប៉មឥដ្ឋលេខ៣១ស្ថិតនៅក្នុងឆ្នាំ២០១៩-២០២០ ដោយប្រើប្រាស់ទ្រុនដែកទល់ទ្របណ្ដាលយ ជ្រុងអាគ្នេយ៍ទាំងពីរអំពីទ្រុនឈើ និងទល់ទ្រប៉មឥដ្ឋលេខ២៦ និងប៉មឥដ្ឋលេខ២៦។ ក្រៅពីនោះ ចងក្រឹបបណ្ដោះអាសន្នលើចនាសម្ព័ន្ធប៉មឥដ្ឋលេខ៣ក្នុងឆ្នាំ២០១៩។ល។











ប្រាសាទព្រះគោ

អភិរក្សនិងជួសជុលប្រាសាទព្រះគោ

គម្រោងឈ្មោះ RAF (The Royal Angkor Foundation) គឺជាជំនួយផ្នែកបរិកា និងបច្ចេកទេសដែលបានផ្តើមកិច្ចការអភិរក្ស និងជួសជុលប៉មប្រាសាទព្រះគោនៅក្នុងខែមករា ឆ្នាំ១៩៩៦ រហូតដល់ឆ្នាំ១៩៩៦។ នៅអំឡុងឆ្នាំ១៩៩៨ ដល់ឆ្នាំ១៩៩៩អង្គការអន្តរជាតិរបស់ប្រទេសអាល្លឺម៉ង់ GACP កំបានបន្តកិច្ចការជួសជុលរួមមាន៖ ជួសជុលថ្មគម្រាលខឿន ពង្រឹងសសរផ្តោបលើប៉មទាំងប្រាំមួយ សង់សសរផ្តោបថ្មីនៅប៉មជំកណ្តាលខាងកើត និងខាងលិច និងជួសជុលពង្រឹងកំបោរបាយអលើជញ្ជាំងនៃប៉មជ្រុងពាយ័ព្យនិងប៉មកណ្តាល



ក្រោយជួសជុល



មុនជួសជុល



កំពុងជួសជុល


ក្រោយជួសជុល


មុនជួសជុល

ខាងកើត។ ក្នុងខែសីហា ឆ្នាំ២០២១ អាជ្ញាធរជាតិអប្សរាបានជួសជុលប៉មធំកណ្តាលខាងកើត សង់សសរពេជ្រថ្មី១ដើមនៅខ្វែងខ្វាងខាងកើតនៃប៉មជ្រុងពាយ័ព្យ ពង្រឹងសសរពេជ្រចាស់ចំនួន៦ដើមនៅខ្វែងខ្វាងខាងកើតនៃប៉មកណ្តាលខាងលិច សង់សសរពេជ្រថ្មី១ដើមនៅខ្វែងខ្វាងបញ្ចោតខាងត្បូងនៃប៉មជ្រុងអាគ្នេយ៍ ជួសជុលឥដ្ឋជ្រុងនិរតីនៃប៉មអាគ្នេយ៍ ពង្រឹងសសរពេជ្រឥដ្ឋនៅប៉មកណ្តាលខាងលិច និងប៉មជ្រុងពាយ័ព្យ។ ក្នុងឆ្នាំ២០១៩ ជួសជុលពង្រឹងឥដ្ឋនៅបណ្ណាល័យជ្រុងអាគ្នេយ៍ និងជួសជុលខ្វែងខ្វាងទី៣ ច្រកចូលខាងកើតក្នុងឆ្នាំ២០២១។


ក្រោយជួសជុល


មុនជួសជុល

កិច្ចការអភិរក្សនិងផ្សព្វផ្សាយប្រាសាទលលៃ



ប្រាសាទលលៃ



លលៃ ជាកោះមួយស្ថិតនៅកណ្តាលបាកយណ៍តន្ទ្រែតដាក់ដែលព្រះបាទយសោវរ្ម័នសាងឡើងចប់ជាស្ថាពរនៅ គ.ស៩៩៣។ ប្រាង្គសង់អំពីឥដ្ឋពាំងបួនមានស្ថាបត្យកាពន្ទ្រុះព្រមទាំងខូចខ្ទេចខ្ទី ជាក់ស្តែងប្រាង្គឥដ្ឋអាគ្នេយ៍រលុះបាក់ស្ទើរតែពាំងស្រុងក្នុងឆ្នាំ១៩៦៧ ។ ចំណែកប្រាង្គដទៃទៀត ក៏កំពុងប្រឈមនឹងរលុះបាក់ផងដែរប្រសិនបើពុំមានវិធានការណាមួយដើម្បីជួយសង្គ្រោះបន្ទាន់។ តម្រាងវៃពាំនិងអភិរក្សប៉មឥដ្ឋពាំងបួនប្រាសាទលលៃធ្វើឡើងជាភ្ជាប់រាល់ឆ្នាំក្រោមបទដ្ឋានបច្ចេកទេសដោយខ្សែកៗដូចជា៖ ចាប់ពីឆ្នាំ២០០៦ ដល់២០១០មានការទប់ទ្រសង្គ្រោះបន្ទាន់ត្រង់ចំណុចប្រឈមនឹងហានិភ័យខ្ពស់នៅប៉មនិរតី ប៉មពាយ័ព្យនិងប៉មអាគ្នេយ៍ រួមទាំងបន្ថែមការចង់ត្រឹបរចនាសម្ព័ន្ធប៉មឥដ្ឋសាន។ សម្រាប់តម្រាងជួសជុលប៉មឥដ្ឋរយៈពេលវែង ចាប់ផ្តើមឡើងដំបូងនៅប៉មឥដ្ឋសានក្នុងឆ្នាំ២០១៦និងមានតម្រាងបន្តបន្ទាប់សម្រាប់ជួសជុលប៉មពាយ័ព្យនិងប៉មអាគ្នេយ៍។ ប៉មឥដ្ឋសាននិងប៉មអាគ្នេយ៍ជួសជុលរួចរាល់នាចុងឆ្នាំ ២០៦១ រីឯប៉មពាយ័ព្យក្រោមចំណាយថវិការដ្ឋឆ្នាំ២០១៩ និងឆ្នាំ២០៦០ បានជួសជុលរួចរាល់ជញ្ជាំងខាងជើងនិងខាងកើត។ បច្ចុប្បន្ន ឆ្នាំ២០៦២កំពុងជួសជុលប៉មឥដ្ឋថ្ម្រុងនិរតី។



ក្រោយជួសជុល



មុនជួសជុល



មុនជួសជុល



ក្រោយជួសជុល

រហាត់ទឹកអង្គរ

រហាត់ទឹកអង្គរ ត្រូវបានអាជ្ញាធរជាតិអប្សរា សហការជាមួយវិស័យឯកជនធ្វើការជួសជុលឡើងវិញ។ រហាត់ទឹកនេះស្ថិតនៅសួនបណ្តុះកូនឈើប្រាសាទតាកែវ ជាអត្តសញ្ញាណមួយរបស់ខេត្តស្ទឹមរាប ដែលជាប្រយោជន៍ក្នុងការទាក់ទាញភ្ញៀវទេសចរជាតិ និងអន្តរជាតិ។



ពិធីសម្ពោធ និងដាក់ឱ្យដំណើរការផ្លូវរហាត់ទឹក នៅស្ថានីយបណ្តុះកូនឈើប្រាសាទតាកែវ



ពិធីសម្ពោធបញ្ចប់ការជួសជុលប្រាសាទកណ្តាលស្រះស្រង់



មុនជួសជុល



ក្រោយជួសជុល

កិច្ចការអភិរក្សនិងជួសជុល ប្រាសាទកណ្តាលស្រែះស្រង់

ប្រាសាទកណ្តាលស្រះស្រង់ (ការអភិរក្ស និងស្រាវជ្រាវអស់រយៈពេលជាច្រើនឆ្នាំ) អាជ្ញាធរជាតិអប្សរាបានបញ្ចប់ការជួសជុលដោយមូលនិធិវិស័យឯកជន ការជួសជុលប្រាសាទដែលឈរនៅទីនោះ (នៅកណ្តាលស្រះស្រង់) យោងតាមការសិក្សាសិលាចារឹក និងបុរាណវិទ្យានៃសាលាចាក់ឌុងបូព៌ា។ ប្រាសាទនេះត្រូវបានសម្ពោធដាក់ឱ្យប្រើប្រាស់ដោយ **លោកជំទាវកិត្តិសង្គហបណ្ឌិត ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី និង **លោកជំទាវបណ្ឌិតសភាចារ្យ ឡើង សាវុឌា** រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។

អភិរក្សនិងជួសជុលប្រាសាទអូរផ្គុង

នៅខែឧសភា ឆ្នាំ២០១៣ ក្រុមការងារបច្ចេកទេសវិស្វកម្ម និងក្រុមអភិរក្សប្រចាំការនៅភ្នំគូលែន បានចុះពិនិត្យស្ថានភាពនៅប្រាសាទអូរផ្គុងឃើញមានវុក្ខជាតិដុះនៅលើកំពូលប្រាសាទ ជញ្ជាំងខាងក្រៅមានស្នាមប្រេះហែកចំនួន៦កន្លែងនៅជ្រុងខាងលិច តួប៉មបង្រួមនៅវួតទី១ និងវួតទី២ ខ្ទុះច្រាម ជញ្ជាំងខាងលើនៃខ្នោងទ្វារខាងកើតបម្រុងជ្រុះធ្លាក់។



នៅថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៣ ក្រុមការងារបច្ចេកទេសអាជ្ញាធរជាតិអប្សរា ចាប់ផ្តើមជួសជុលប្រាសាទនេះជារលើកដំបូងរហូតដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៦ ទើបបានបញ្ចប់។ ការជួសជុលនេះផ្ញើនែផ្នែកណាដែលប្រឈមខ្លាំងគឺរៀបក្តិតស្នាមប្រេះជញ្ជាំងក្រៅខាងលិច និងជញ្ជាំងក្រៅខាងត្បូង ជួសជុលពង្រឹងតួប៉មបង្រួមវួតទី១ និងវួតទី២ ទល់ទ្រវួតទី៣ និងទល់ទ្រផ្នែកខាងលើនៃខ្នោងទ្វារខាងកើតដោយប្រើរនាំដែក។

ស្ថានភាពមុនជួសជុល



ជញ្ជាំងប្រេះហែក



ឥដ្ឋខាងលើខ្នោងទ្វារបម្រុងធ្លាក់

ស្ថានភាពក្រោយជួសជុល







អភិរក្សនិងជួសជុលប្រាសាទគ្រែហាម

នៅថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៧ ក្រុមការងារបច្ចេកទេសវិស្វកម្ម បានចុះពិនិត្យឃើញថា នៅជញ្ជាំងខាងកើតមានតំនរដើលុបពាក់កណ្តាលស៊ុមទ្វារ និងស៊ុមទ្វារក្នុងបម្រុងរលំដួល ជញ្ជាំងខាងត្បូង និងខាងលិចមានស្នាមប្រេះជាច្រើនកន្លែង។

នៅថ្ងៃទី៣ ខែតុលា ដល់ថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៨ ក្រុមការងារបច្ចេកទេសអាជ្ញាធរជាតិអប្សរាបានជួសជុលលើកដំបូងដោយសម្អាតតំនរដី សម្អាតនិងចាក់ថ្នាំសម្លាប់រុក្ខជាតិដែលដុះលើជញ្ជាំងប្រាសាទ ជួសជុលពង្រឹងជញ្ជាំងប្រេះស្រាក និងពុកផុយ ជួសជុលខ្នងទ្វារខាងកើត និងវត្ថុសិល្បៈ។

មុនជួសជុល



ស្ថានភាពមើលពីខាងកើត



ស្ថានភាពមើលពីខាងលើ



ស្ថានភាពជញ្ជាំងប្រេះស្រាក



ស្ថានភាពមេទ្វារខាងកើត





ស្ថានភាពវត្ថុសិល្បៈ



ក្រោយជួសជុល



ឃោនី លិង្គក្រោយជួសជុល

អភិរក្សនិងជួសជុលប្រាសាទខ្នាឃ្មុំ

នៅថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៧ ក្រុមវិស្វកម្មបានចុះពិនិត្យឃើញថា ជ្រុងកែងខាងជើងជញ្ជាំងប្រេះហែក រួតទី១ពុកផុយ និងមានរុក្ខជាតិដុះនៅត្រប់រួត និងដំបូល។

នៅថ្ងៃទី៣ ខែតុលា ដល់ថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៨ ក្រុមការងារបច្ចេកទេសអាជ្ញាធរជាតិអប្សរាបានជួសជុលដោយសម្អាតគំនរដី សម្អាតនិងចាក់ថ្នាំសម្លាប់រុក្ខជាតិដែលដុះលើជញ្ជាំងនិងដំបូលប្រាសាទ ជួសជុលពង្រឹងជញ្ជាំងប្រេះ និងពុកផុយ។



រាយជួសជុលមើលពីកើត



រាយជួសជុលមើលពីជើង

មុនជួសជុល



រូបភាពមើលពីខាងកើត



រូបភាពមើលពីខាងជើង



ជួសជុលរួតដែលពុកផុយ



រៀបចំដីតជញ្ជាំងប្រេះហែក



ស្ថានភាពក្រោយការងារ

អភិរក្សជួសជុលប្រាសាទដំរីគ្រាប (ប្រាង្គកណ្តាល) ជៅភ្នំគូលែន

នៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៧ ក្រុមការងារបច្ចេកទេសវិស្វកម្មបានចុះពិនិត្យឃើញថាខឿនពុកផុយ ស៊ុមទ្វារខាងលើបម្រុងជ្រុះធ្លាក់ ប្រាសាទជ្រុងនៅរួតទី១ និងរួតទី៦ពុកផុយ នៅតាមរួតនីមួយៗមានរុក្ខជាតិដុះ និងដំបូលពុកផុយ។

នៅថ្ងៃទី២៧ ខែកក្កដាដល់ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២០ ក្រុមការងារបច្ចេកទេសអាជ្ញាធរជាតិអប្សរាបានជួសជុលដោយសម្អាតគំនរដើ សម្អាតនិងចាក់ថ្នាំសម្លាប់រុក្ខជាតិ(SC480)ដែលដុះលើជញ្ជាំងរួតទាំង៣ថ្នាក់ និងដំបូលប្រាសាទ ជួសជុលពង្រឹងខឿនដែលពុកផុយ និងរៀបក្តិតជញ្ជាំងប្រៈលែក ជួសជុលខ្នងទ្វារ និងជណ្តើរខាងកើត ជួសជុលដំបូលប្រាសាទ និងគ្របបន្ទះដែក លុបថ្នាក់ទឹក និងជីកចង្ករដោះទឹកភ្លៀង។

រូបភាពមុនជួសជុល



រូបភាពមើលពីជ្រុងឦសាន



ក្រោយជួសជុល



ជញ្ជាំងជ្រុងខាងឆ្នេង



ជញ្ជាំងជ្រុងខាងលិច



ក្រោយជួសជុល

អភិរក្សដិនជួសជុលស្ពានបុរាណតាអោង



នៅថ្ងៃទី៦៧ ខែមីនា ឆ្នាំ២០១៩ ក្រុមការងារបច្ចេកទេសវិស្វកម្មបានចុះពិនិត្យនិងថ្វៃផែនទីហានិភ័យឃើញថា សសរខាងជើងរលំខ្លាក់ចំនួន៦កន្លែងជាកន្លែងដែលមានគ្រោះថ្នាក់ខ្លាំង បង្គាន់ដៃនាគជ្រុះខ្លាក់នៅកាយប៉ាយលើកម្រាលស្ពាន និងនៅខាងក្រោមស្ពាន មានរុក្ខជាតិដុះនៅស្ទាបជញ្ជាំងស្ពាន។

នៅថ្ងៃទី១៩ ខែមករាដល់ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២១ក្រុមការងារបច្ចេកទេសអាជ្ញាធរជាតិអប្សរាបានជួសជុលស្ពានផ្នែកខាងជើងដោយសម្អាតគំនរដីដែលកកស្ទះសម្អាត និងចាក់ថ្នាំសម្លាប់រុក្ខជាតិ (SC480) ដែលដុះនៅលើថ្មស្ពាន ជួសជុលរៀបបំពេញសសរស្ពានដែលរលំខ្លាក់និងពុកផុយ ជួសជុលនិងតម្លើងបង្គាន់ដៃនាគផ្នែកខាងជើងប្រាសាទ និងត្រួបបន្ទះដែក លុបថ្នក់ទឹក និងជីកចង្ហុរដោះទឹកភ្លៀង។





អភិរក្សជួសជុលខ្នងផ្ទាំងច្រាសាទចៅស្រីវិបុល

រូបភាពមុនជួសជុល





ខ្នងផ្ទាំងប្រាសាទចៅស្រីវិបុលក្រោយជួសជុល



សកម្មភាពជួសជុល













នៅថ្ងៃទី០៧ ខែមេសាដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ ក្រុមការងារបច្ចេកទេសអាជ្ញាធរជាតិអប្សរាបានជួសជុលដោយធ្វើសម្រង់ ប្ងន់ ចុះបញ្ជី រឹ ផ្ដុំ និងទុកដាក់ថ្មដែលជ្រុះធ្លាក់ ថ្កកប់ក្នុងដី ចុះបញ្ជី រឹតួប្រាសាទ និងផ្ដុំសាកល្បងជាផ្នែកហោជាងជំហូល កំពូល និងជញ្ជាំងជើងក្រោម។

អគារកណ្ដាលនិងជួសជុលច្រាប្ដូរខាងត្បូងច្រាសាធរដ៏ត្រកាមភ្នំគូលែន

នៅថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៧ ក្រុមការងារបច្ចេកទេសវិស្វកម្ម បានចុះពិនិត្យ និងធ្វើផែនទីហានិភ័យ។ ប្រាង្គខាងត្បូងនេះមានរុក្ខជាតិ និងដើមឈើដុះនៅជញ្ជាំងផ្នែកខាងលើ ជញ្ជាំងមានស្នាមប្រេះលែកជាកន្លែងថ្នែង បង្គាន់ដៃជណ្ដើរខាងកើតពុកផុយ និងជញ្ជាំងខ្ទង់ទ្វារខាងកើតប្រេះលែក នាំឲ្យប្រាង្គនេះស្ថិតក្នុងគ្រោះថ្នាក់មធ្យម ចំណែកប្រាង្គកណ្ដាលគ្រោះថ្នាក់ខ្លាំងដែលបានជួសជុលកាលពីឆ្នាំ២០២០។

នៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២១ដល់ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២២ បានជួសជុលដោយធ្វើសម្រង់ចម្លង់ សម្អាតដី និងចាក់ថ្នាំកម្ចាត់រុក្ខជាតិ ជួសជុលពង្រឹងជញ្ជាំងទាំងខាងក្នុងនិងក្រៅទាំង០៤ជ្រុង ជួសជុលខ្ទង់ទ្វារខាងកើត។



ជ្រុងខាងកើតមុនជួសជុល



ជ្រុងខាងត្បូងមុនជួសជុល



ជ្រុងខាងត្បូងក្រោយជួសជុល



ជ្រុងខាងកើតក្រោយជួសជុល

ការដាក់ចោះបង្គោលព្រំការពារខេត្តប្រាសាទ

នៅឆ្នាំ២០១៣ បានចោះបង្គោលព្រំចំនួន១៧ដើម ដើម្បីការពារខេត្តប្រាសាទកោះកែរដោយមានការចូលរួមពីអាជ្ញាធរឃុំស្រយ៉ង់ ស្រុកគូលែន មន្ទីរវៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី និងមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តព្រះវិហារ។










នៅឆ្នាំ២០១៣ បានចោះបង្គោលព្រំចំនួន១៦ដើម ដើម្បីការពារខេត្តប្រាសាទលង-មាលាដោយមានការចូលរួមពីអាជ្ញាធរភូមិ-ឃុំបឹងមាលា និងសាលាស្រុកស្វាយលើ។

នៅថ្ងៃទី៦០ ខែមិថុនា ឆ្នាំ២០១៩ បានសហការជាមួយអាជ្ញាធរភូមិឃុំនិងស្រុក ចុះចោះបង្គោលព្រំចំនួន១៧ដើម ដែលបង្គោលនីមួយៗមានទំហំ ០,៥០ម៉ែត្រ x ០,៥០ម៉ែត្រ x កំពស់១,៨០ម៉ែត្រ ពីដីដល់កំពូល ដើម្បីការពារតំបន់ប្រាសាទក្បាលបី ស្ថិតក្នុងភូមិស្វែងស្ពាន ឃុំស្វែងស្ពាន ស្រុកស្រីស្នំ ខេត្តសៀមរាប។



នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ បានសហការជាមួយអាជ្ញាធរដែនដី សាលាស្រុក សាលាឃុំប្រាសាទបាតង និងភូមិបាលស្រុក ចុះផ្ទៀងផ្ទាត់និងចោះបង្គោលព្រំបានចំនួន៥៣ដើមដែលបង្គោលនីមួយៗ មានទំហំ ០,២៦ម៉ែត្រ x ០,២៦ម៉ែត្រ x កំពស់ ១,១០ម៉ែត្រ ដើម្បីការពារផ្នូរបុរាណពីបាតងទៅអង្គរ។





ការងារទប់ទ្រ និងសង្គ្រោះបន្ទាន់

បានទប់ទ្រនិងសង្គ្រោះបន្ទាន់ប្រាសាទធំនៅតំបន់ប្រាសាទកោះកេរ ប្រាសាទស្រុត ប្រាសាទលិង្គ ប្រាសាទសេង ប្រាសាទក្រចាប់ ប្រាសាទអណ្តូងគុក ប្រាសាទដំរី ប្រាសាទបន្ទាយពីរជាន់ ប្រាសាទសេងមាលា ប្រាសាទចៅស្រីវិបុល ប្រាសាទបន្ទាយស្រីជាដែកៗ













ការដាក់ស្លាកឈ្មោះស្ពានបុរាណ

បានដាក់ស្លាកឈ្មោះស្ពានបុរាណចំនួន១១នៅតាមផ្លូវជាតិលេខ ៦A ពីវត្តស ទៅដល់ស្ពានបុរាណកំពង់ក្តីស្ពានព្រះទិស និងដាក់ស្លាកបម្រាមផ្សេងៗ ស្លាកបង្ហាញស្ពាន និងរបារការពារស្ទាបទាំងសងខាងនៃស្ពានព្រះទិស ដើម្បីលើកតម្កៃស្ពាន។









ការដាក់ស្លាកបំរាម និងស្លាកគ្រោះថ្នាក់ប្រតិបត្តិអង្គរដៅថ្មាសាធបេងមាលា

បានដាក់ស្លាកបំរាមចំនួន៣៥ផ្ទាំងរួមមាន៖

- ហាមឡើង ហាមប៉ះក្បាច់ ចំនួន១០ផ្ទាំង
- ហាមអង្គុយលើបង្គាន់ដៃនាគ ចំនួន០៥ផ្ទាំង
- ប្រយ័ត្នគ្រោះថ្នាក់ ប្រយ័ត្នប៉ះក្បាល ចំនួន១០ផ្ទាំង
- ក្រមប្រតិបត្តិអង្គរចំនួន ១០ផ្ទាំង












អភិរក្សបេតិកភណ្ឌ

សំណង់សាសនា

នៅក្នុងតំបន់រក្សាទុកអង្គរទាំងមូលមានវត្តអារាមចំនួន៣៥វត្ត ក្នុងនោះមានទីអារាមមួយចំនួនមានសំណង់បេតិកភណ្ឌសាសនា ដែលមានអាយុកាលដ៏យូរលង់ និងមានតម្លៃផ្នែកស្ថាបត្យកម្មល្អឯកឥតដែរ។ ដើម្បីរួមចំណែកក្នុងការអភិរក្ស និងអភិវឌ្ឍសំណង់សាសនាឱ្យមានប្រសិទ្ធភាព ត្រូវមានការចូលរួមពីស្ថាប័នពុទ្ធចក្រជាចាំបាច់ ហេតុនេះនៅឆ្នាំ២០១៣ រដ្ឋបាលខេត្តសៀមរាបបានសម្រេចបង្កើត «ក្រុមប្រឹក្សាកិច្ចការវត្តអារាមក្នុងតំបន់រក្សាទុកអង្គរ» ហៅកាត់ថា CoMAPA (Council of Monk In Angkor Park Pagoda Affairs) ក្រោមការសម្របសម្រួលពីគម្រោងអភិវឌ្ឍន៍សេដ្ឋកិច្ចសហគមន៍ និងបេតិកភណ្ឌអង្គរ (ACHA)។ សមាសភាពនៃក្រុមប្រឹក្សានេះមកពី អាជ្ញាធរជាតិអប្សរា មន្ទីរធម្មការ និងសាសនាខេត្តសៀមរាប មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តសៀមរាប និងព្រះមេគណទាំង២គណៈ។ ក្រុមប្រឹក្សានេះមានការកិច្ចដូចជា សម្របសម្រួលកិច្ចការសាង់សង់ក្នុងតំបន់រក្សាទុកអង្គរ ផ្តល់យោបល់ពាក់ព័ន្ធលើបញ្ហាទាក់ទងនឹងវត្តអារាម និងកិច្ចការសាសនា ជួយទប់ស្កាត់ការសាង់សង់ដោយគ្មានច្បាប់អនុញ្ញាត និងថែរក្សាបេតិកភណ្ឌវប្បធម៌។



ឯកឧត្តម ហង់ ពៅ អគ្គនាយកអាជ្ញាធរជាតិអប្សរាចូលបង្គំគាល់
សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី ទេព វង្ស ទូលថ្វាយពីកិច្ចការ
អភិរក្សបេតិកភណ្ឌនិងកិច្ចការវត្តអារាមក្នុងតំបន់រមណីយដ្ឋានអង្គរ



ព្រះវិហារវត្តបាគង

ការជួសជុល និងអភិរក្សព្រះវិហារវត្តបាគង

វត្តបាគងស្ថិតនៅភូមិវីរខ្មោក ឃុំបាគង ស្រុកប្រាសាទបាគង ខេត្តសៀមរាប។ ព្រះវិហារសាងសង់ក្នុងរវាងឆ្នាំ១៩៣៩ ដែលបង្ហាញនូវតម្លៃស្ថាបត្យកម្ម សាសនា គំនូរ និងប្រវត្តិសាស្ត្រ។ ចាប់ពីឆ្នាំ២០០៧ដល់ឆ្នាំ២០១១ ក្រោមគម្រោងហិរញ្ញប្បទានហុលស៊ីម-អប៊ូក ព្រះវិហារវត្តបាគងបានត្រូវជួសជុល និងអភិរក្ស ដោយចាប់ផ្តើមសង្គ្រោះបន្ទាន់នូវគំនូរ១១ផ្ទាំង ដែលស្ថិតនៅជែរបស់ព្រះវិហារដែលរងនូវការគំរាមពីការជាប់ឆ្លាក់អន្តរាយរួមនឹងការសិក្សាលម្អិតដើម្បីកំណត់នូវវិធីសាស្ត្រត្រឹមត្រូវសម្រាប់ការជួសជុលពង្រឹងគ្រឹះ និងដំបូល។ ដំណាក់កាលនេះក៏បានសាងសង់ដំបូលបណ្តោះអាសន្នពីលើព្រះវិហារ ដើម្បីការពារផ្ទាំងគំនូរនៅក្នុងព្រះវិហារពីការខូចខាតជាបន្តដោយទឹកភ្លៀងផងដែរ។ បន្ទាប់មក ក្រុមអ្នកជំនាញបានពង្រឹង និងជួសជុលហេដ្ឋារចនាសម្ព័ន្ធសំណង់ និងជួសជុលដំបូលព្រះវិហារទាំងស្រុង។ ដំណាក់កាលចុងក្រោយ ការជួសជុលស្តារផ្ទាំងគំនូរជាប់ជញ្ជាំងឡើងវិញ។





សម្តេចវិបុលបញ្ញា សុខ អាន ក្នុងពិធីបញ្ចប់ការដ្ឋាន
ថែរក្សាជួសជុលព្រះវិហារវត្តបាគង



កំពុងជួសជុល



កំពុងជួសជុល



មុនជួសជុល



ក្រោយជួសជុល

ការជួសជុល និងអភិរក្ស ព្រះវិហារ និងសាលាធាន់វត្តរាជបូណ៌ិ

ក្នុងទីធ្លាអារាមនេះ មានព្រះវិហារចាស់ដែលមានគំនូរបុកណាំងរាមកេរ្តិ៍ដ៏ល្អវិចិត្រ នៅលើផ្ទៃជញ្ជាំងខាងក្នុង ចំណែកនៅលើបង្ហួចខាងក្រៅនីមួយៗមានចម្ងាក់លៀន ជកស្រស់ចេញពីរឿងរាមកេរ្តិ៍ដ៏រស់រវើកដូចគ្នា។ ព្រះវិហារចាស់នេះទំនងជាបានសាងសង់ឡើងនៅរាងដើមសតវត្សរ៍ទី២០។ កត្តាអាយុកាល អាកាសធាតុ សត្វស្លាប និងវិញ្ញើរដី បានធ្វើឱ្យសំណង់ព្រះវិហារវត្តរាជបូណ៌ដែលមានតម្លៃពុំអាចកាត់ថ្លៃបាននេះ មានសភាពទ្រុឌទ្រោមប្រឈមនឹងហានិភ័យខ្ពស់ ហើយដែលចាំបាច់ត្រូវមានការអភិរក្សឱ្យទាន់ពេលវេលា។

នៅរាងឆ្នាំ២០១៤-២០១៦ អជ្ញាធរជាតិអប្សរាសហការជាមួយអ្នកជំនាញអ៊ីតាលី ចាប់ផ្តើមជួសជុលព្រះវិហារ ដោយផ្តោតលើការជួសជុលរចនាសម្ព័ន្ធសសរ បល្ល័ង្ក សន្ទឹកទ្វារ បង្ហួច និងព្រះពុទ្ធរូប។ នៅឆ្នាំ២០១៧ ព្រះវិហារមានការសិក្សាគម្រោងសម្រង់ប្លង់ចាស់ និងធ្វើដំបូលដែកត្រួបពីលើ ដោយប្រើប្រាស់ថវិការបស់ពុទ្ធបរិស័ទក្រោមការផ្តួចផ្តើមពី ព្រះមហាវិមលធម្ម ពិន សែម សិរីសុវណ្ណោ ។ បន្ទាប់មកទៀត អ្នកជំនាញធ្វើការជួសជុលដោយផ្តោតលើគ្រឿងបង្គុំដំបូល ដើម្បីរក្សាលំនឹងរបស់ដំបូល សម្ងាប់មេរោគ និងសត្វល្អិតស៊ីសាច់ឈើ ជួសជុលសម្ភតរហាជាដ៏ដែលមានចម្ងាក់ក្បាច់ និងគ្រឿងលម្អដំបូលដែលធ្វើអំពីកំបោរចុយអាំងអស់ឡើងវិញ រួចរាល់ ១០០%នៅឆ្នាំ២០១៩។ នៅឆ្នាំ២០២០ ការជួសជុលតួព្រះវិហារ រួមមានជញ្ជាំង ក្បាច់ជើងជញ្ជាំង កាំជណ្តើរ ការ៉ូ ក្បាច់លើទ្វារបង្ហួច ជាំងសាច និងខឿនព្រះវិហារ ព្រមទាំងពង្រឹងសំណង់រូបចម្ងាក់ដែលចាស់ទ្រុឌទ្រោមឱ្យបានរឹងមាំឡើងវិញ។






មុនជួសជុល


ក្រោយជួសជុល


សន្ទឹកទ្វារ


កំពុងជួសជុល


ក្រោយជួសជុល


ក្រោយជួសជុល


កំពុងជួសជុល


ក្រោយជួសជុល



ក្រោយជួសជុល

នៅវត្តពពប្អូណ៌ដដែលនេះ អាជ្ញាធរជាតិអប្សរ
ក៏បានជួសជុលសាលាឆាន់ចាស់ដែលមាន
អាយុកាលប្រមាណ៩០ឆ្នាំ ហើយដែលស្ទើរតែ
បាត់បង់មុខងារពាំងស្រុងទៅហើយ។



មុនជួសជុល



មុនជួសជុល


មុនជួសជុល


មុនជួសជុល


កំពុងជួសជុល


កំពុងជួសជុល



កុដិឈើក្រោយជួសជុល

ការជួសជុល ចំពោះកុដិវត្តព្រហ្មវ័ន្ត



កុដិឈើមុនជួសជុល

នៅក្នុងអាគមមួយនេះមានសំណង់កុដិឈើពីរខ្នង សង់ខ្ពស់ផុតពីដីជាប់ប្រក់ក្បឿង ដែលមានទម្រង់ស្ថាបត្យកម្មពីរផ្សេងគ្នា មួយជាទម្រង់កុដិដំបូលខ្មែរ និងមួយទៀតជាទម្រង់កុដិដំបូលប៉ិតៗ ស្ថាបត្យកម្មទាំងពីរនេះ ត្រូវបានសាងសង់ក្នុងដំណាក់កាលពីរផ្សេងគ្នា កុដិដែលមានដំបូលខ្មែរ ឬកឹង ត្រូវបានសាងសង់ក្នុងអំឡុងទសវត្សរ៍ ១៩៦០ ហើយកុដិដែលមានដំបូលប៉ិតត្រូវបានសាងសង់ក្នុងអំឡុងទសវត្សរ៍១៩៥០ៗ ស្ថាបត្យកម្មនៃសំណង់ឈើនេះ មានតុណតម្លៃដ៏ពិសិដ្ឋ និងយ៉ាងល្អឯក ទាំងរូបរាង បច្ចេកទេស និងភាពប្រណិតនៃសិល្បៈដែលស្តែងឡើងតាមរយៈស្ថាបត្យកម្មមួយនេះ។


ក្រោយជួសជុល


កំពុងជួសជុល


កំពុងជួសជុល


មុនជួសជុល


ក្រោយជួសជុល


មុនជួសជុល

ដោយស្មារតីចង់រក្សាឱ្យបាននូវគុណតម្លៃនៃស្ថាបត្យកម្មមួយនេះ អ្នកបច្ចេកទេសរបស់អាជ្ញាធរជាតិអប្សរា បានទិតទំប្រើដៃប្រឹងក្នុងការសង្គ្រោះសំណង់ឈើនេះ ដោយប្រើបច្ចេកទេស និងសម្ភារៈដូចដើមទាំងស្រុង ធ្វើយ៉ាងណាឱ្យសំណង់នេះស្ថិតស្ថិរតទៅមុខទៀតៗ

ការជួសជុល អភិរក្សព្រះវិហារវត្តលៃលៃ

ព្រះវិហារនៅលើខឿនប្រាសាទលៃលៃ ក៏ទទួលបានការអភិរក្សថែទាំពីអ្នកជំនាញអាជ្ញាធរជាតិអប្សរា។ សំណង់ព្រះវិហារនោះមានសភាពចាស់ទ្រុឌទ្រោម ដោយហេតុអាយុកាល គុណភាពសំណង់ និងការបំផ្លាញដោយសត្វល្អិត ដែលចាំបាច់ត្រូវមានការជួសជុលអភិរក្សក្នុងន័យរក្សាតម្លៃដើម និងទេសភាពវប្បធម៌របស់សម្បត្តិបេតិកភណ្ឌ។ ព្រះវិហារនៃវត្តប្រាសាទលៃលៃជាសម្បត្តិបេតិកភណ្ឌមានអាយុកាលជិត១០០ឆ្នាំ ដែលមានតម្លៃប្រវត្តិសាស្ត្រ និងសិល្បៈស្ថាបត្យកម្ម។ ក្នុងគោលបំណងថែរក្សាមរតកសំណង់សាសនាដ៏វែរវែកនេះឱ្យនៅបិតថែរបន្តទៅមុខទៀត អាជ្ញាធរជាតិអប្សរាបានធ្វើការជួសជុល និងអភិរក្សព្រះវិហារនេះក្នុងឆ្នាំ២០២២ ដោយប្រើប្រាស់បច្ចេកទេសជួសជុល និងសម្ភារៈដូចដើមតាំងស្រុង ។





ក្រោយជួសជុល


ក្រោយជួសជុល


ក្រោយជួសជុល


មុខជួសជុល


កំពុងជួសជុល


មុខជួសជុល

រចនាសម្ព័ន្ធសំណង់ឈើ ស្ថិតនៅចំកណ្តាល
ស្រះខាងលើឥដ្ឋប្រាសាទអន្តរវត្ត

កំណាយស្រាវជ្រាវ

ក្រៅពីការកិច្ចការអភិរក្ស ជួសជុលប្រាសាទ និងអភិវឌ្ឍន៍ អាជ្ញាធរជាតិអប្សរាក៏បានយកចិត្តទុកដាក់លើការស្រាវជ្រាវពីអារ្យធម៌អង្គរៗ កន្លងមកនេះ អាជ្ញាធរជាតិអប្សរាបានស្រាវជ្រាវ និងសហការស្រាវជ្រាវជាមួយដៃគូជាតិ និងអន្តរជាតិជាច្រើន ដើម្បីសិក្សាស្វែងយល់បុរេប្រវត្តិសាស្ត្រ ប្រវត្តិសាស្ត្រ រមណីយដ្ឋានអង្គរ រួមទាំងការស្រាវជ្រាវពីរចនាសម្ព័ន្ធប្រាសាទមួយចំនួន តាមរយៈសាស្ត្រផ្សេងៗ ក្នុងនោះក៏មានការធ្វើ«កំណាយបុរាណវិទ្យា» ដែរ។ ការសម្រាំងស្រាវជ្រាវនៅក្នុងរមណីយដ្ឋានអង្គរត្រូវមានការអនុញ្ញាត និងការចុះកិច្ចព្រមព្រៀងជាមួយអាជ្ញាធរជាតិអប្សរា ដើម្បីជានាថាការសិក្សាលក្ខណៈនៃការអនុវត្តគម្រោងធ្វើយតបទៅតាមតម្រូវការរបស់ស្ថានគ្រប់គ្រងនិងក្រមប្រតិបត្តិដែលបានកំណត់ ក៏ដូចជារួមចំណែកក្នុងការពង្រឹងសមត្ថភាពជនជាតិមនុស្សតាមរយៈកិច្ចសហការនិងបណ្តុះបណ្តាល។

បន្ថែមពីលើកិច្ចការស្រាវជ្រាវតាមរយៈការធ្វើកំណាយ បុរាណវិទូនៃអាជ្ញាធរជាតិអប្សរាក៏តែងធ្វើ«កំណាយសង្គ្រោះ» ដើម្បីសិក្សាវាយតម្លៃ និងមានវិធានការធ្វើយតបទៅនឹងផលប៉ះពាល់ផ្សេងៗមុននឹងសម្រេចជ្រើសរើសទីតាំងណាមួយអនុវត្តគម្រោង ដូចជាការសាងសង់សំណង់ហេដ្ឋារចនាសម្ព័ន្ធមួយដែលជាកម្មវិធីអភិវឌ្ឍន៍ប្រកបដោយចីរភាពនៅក្នុងរមណីយដ្ឋានអង្គរ។

កំណាយស្រាវជ្រាវប្រាសាទទន្លេស្ងួត

ប្រាសាទទន្លេស្ងួតគឺជាហោរបន់នៃមន្ទីរពេទ្យមួយ ក្នុងចំណោមហោរបន់នៃមន្ទីរពេទ្យទាំង១០៦ ដែលបានកសាងក្នុងរាជព្រះបាទជ័យវរ្ម័នទី៧ និងជាហោរបន់នៃមន្ទីរពេទ្យមួយក្នុងចំណោមហោរបន់មន្ទីរពេទ្យទាំង៤ដែលស្ថិតនៅខាងក្រៅក្រុងអង្គរធំតាមផ្លូវចូលក្រុង។ ក្រុមអ្នកស្រាវជ្រាវអាជ្ញាធរជាតិអប្សរាបានសហការជាមួយអ្នកស្រាវជ្រាវមកពីវិទ្យាស្ថានបច្ចេកវិទ្យាជាន់ខ្ពស់កម្ពុជា និងអ្នកស្រាវជ្រាវមកពីវិទ្យាស្ថានអាស៊ីអាគ្នេយ៍នៃប្រទេសសឹង្ហបុរី បានចាប់ផ្តើមធ្វើកំណាយស្រាវជ្រាវចាប់ពីថ្ងៃទី៦៨ ខែកក្កដា រហូតដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៧។ ក្នុងការស្រាវជ្រាវនោះផងដែរអ្នកស្រាវជ្រាវបានរកឃើញរូបចម្លាក់ព្រះពុទ្ធរូបចំនួន៦ បំណែកកុលាលភាជន៍ខ្មែរ ថ្មត្បាំលៀ និងបំណែកគ្ឌីងសត្វចតុប្បាទ។



ចម្លាក់ព្រះពុទ្ធរូប



បំណែកព្រះពុទ្ធរូប



ថ្មត្បាំលៀ



បំណែកគ្ឌីងសត្វចតុប្បាទ



បំណែកកុលាលភាជន៍

ស្ពានីយស្វែកបុរាណដៅតំបន់អង្គរ

ក្រុមអ្នកស្រាវជ្រាវនៃអាជ្ញាធរជាតិអប្សរាបានរកឃើញស្ពានីយស្វែកបុរាណមួយនៅភូមិសាលាក្រវ៉ាន់ ឃុំរំចេក ស្រុកបន្ទាយស្រី ខេត្តសៀមរាប។ នៅដើមឆ្នាំ២០១៦ និងឆ្នាំ២០១៧ ផ្នែកស្រាវជ្រាវនៃមជ្ឈមណ្ឌលអង្គរជាតិស្រាវជ្រាវ និងតម្កល់ឯកសារអង្គរបានធ្វើកំណាយក្នុងគោលបំណងស្វែងយល់ថា តើសំណល់អាចម៍ស្វែក និងបំណែកដីដុត ដែលប្រទះឃើញនៅលើផ្ទៃដីពិតជារបស់ស្ពានីយស្វែកមែន ឬមិនមែន? បើមែនតើមានសំណល់ចង្រ្កានស្វែកដែរឬទេ? តើចង្រ្កានមានទ្រង់ទ្រាយដូចម្តេច? តើវិសាលភាពផលិតនោះ មានទំហំប៉ុន្មានដែលអាចផ្គត់ផ្គង់លោហៈដល់តម្រូវការរបស់អង្គរបានដែរទេ?




បំណែកចង្រ្កាន ស្លាមជាក់ច័ពដំខ្យល់នៅជាប់ជញ្ជាំងមូល និងបំណែកច័ពដំខ្យល់



បំណែកដីដែក

ឃ្មុង្ហារដីឆ្នាំងនៃអង្គរធំ

ក្រោយពីបានចុះពិនិត្យផ្ទៀងផ្ទាត់ និងស្រង់ទិន្នន័យបុរាណវិទ្យា ដោយក្រុមអ្នកស្រាវជ្រាវនៃមជ្ឈមណ្ឌលអន្តរជាតិស្រាវជ្រាវនិងតម្កល់ឯកសារអង្គរបានរកឃើញខ្ទួលខ្សាច់នៅស្ថានីយនេះមានចំនួន៦៥ខ្ទួលខ្សាច់ ចែកជា១៦ក្រុម ដែលក្រុមនីមួយៗមានទម្រង់ខ្ទួលខ្សាច់សាស្ត្រាខុសៗគ្នា។ តាំងពីមុនមកពុំទាន់មានការធ្វើកំណាយដើម្បីបញ្ជាក់ថាទីនេះជាអ្វីពិតប្រាកដនៅឡើយទេ គ្រាន់តែមានអ្នកស្រាវជ្រាវមួយចំនួនបានពីសយកអំបែងគាជន៍យកទៅសិក្សាតែប៉ុណ្ណោះ។ ដូច្នេះហើយទើបក្រុមបុរាណវិទូនៃមជ្ឈមណ្ឌលអន្តរជាតិស្រាវជ្រាវ និងតម្កល់ឯកសារអង្គរនៃអាជ្ញាធរជាតិអប្សរាបានធ្វើកំណាយនៅទីនោះ ដើម្បីអាចដឹងព័ត៌មានវែងឆ្ងាយទៅទៀត ដោយបានជ្រើសរើសយកខ្ទួលឈ្មោះ ខ្ទួលត្រពាំងប៉ុះមានលេខសម្គាល់TDCK1 និងខ្ទួលTDCK7a ធ្វើកំណាយដើម្បីបញ្ជាក់ឱ្យច្បាស់ថា ទីនេះជាស្ថានីយខ្សាច់ដុតគាជន៍សម័យបុរាណដែរឬទេ។



ជាលទ្ធផល ក្រុមស្រាវជ្រាវបានរកឃើញរចនាសម្ព័ន្ធឃ្មុង្ហារដីឆ្នាំង TDCK1 និង TDCK7a មានភាពកំប៉ោង ហើយមានទំហំតូចពុំដូចខ្សាច់ដុតកុលាលគាជន៍មានស្រទាប់រលោងពណ៌ងងឹតដែលរកឃើញនៅតាមស្ថានីយមួយចំនួនក្នុងប្រទេសកម្ពុជា ជាពិសេសនៅក្នុង និងក្រៅតំបន់អង្គរ ដែលជាទូទៅតួខ្សាច់ដុតកុលាលគាជន៍មានភាពធំទ្រវែងសណ្តកលើខ្ទួលដែលមានប្រវែងពី៥,៥ម៉ែត្រទៅ៨ម៉ែត្រ និងទទឹង១,៣ម៉ែត្រទៅ៣ម៉ែត្រ ដូចជាៈ ខ្សាច់ម្រាម ខ្សាច់ស៊ី ខ្សាច់ពោជ ខ្សាច់តានី និងខ្សាច់ផ្តៅ។ លើសពីនេះខ្សាច់ដុតកុលាលគាជន៍ ស្រទាប់រលោងពណ៌ត្នោត ដែលបានរកឃើញនៅក្នុងភូមិសាស្ត្រស្រុកជីក្រែង គឺមានការរីរាលន៍ពាំងផ្នែកបច្ចេកទេស និងទំហំខ្សាច់ដុតកុលាលគាជន៍នៅឃ្មុង្ហារដីឆ្នាំងនៃអង្គរធំ អ្នកស្រាវជ្រាវបានហៅថាខ្សាច់ប្រភេទ Up-draught។







កំណាយស្រាវជ្រាវដៅទួល១០០ នៃច្រាសាទឧ

ទិន្នន័យ LiDAR បានបង្ហាញឱ្យយើងដឹងពីរចនាសម្ព័ន្ធនៃក្រុមទួលនៅផ្នែកជ្រុងឦសានបារាយណ៍យសោធរបុរ (បារាយណ៍ខាងកើត)។ ក្រុមទួល ១០០នេះរៀបចំឡើងនៅក្នុងរចនាសម្ព័ន្ធដីទួលមួយមានរាងចតុកោណ និងមាន១០ជួរ លើយក្នុងមួយជួរមាន១០ទួល (រត់ពីលិចទៅកើត និងពីជើងទៅត្បូង) មកដល់សព្វថ្ងៃនេះ ពុំទាន់មានការសិក្សាស្រាវជ្រាវណាមួយមកបញ្ជាក់ពីប្រវត្តិ និងតួនាទីនៃរចនាសម្ព័ន្ធទួល១០០ទាំងនេះឡើយ។ ក្នុងគោលបំណងស្វែងយល់ពីតួនាទី និងការលើកទួល១០០នេះ ក្រុមការងារបច្ចេកទេសនៃអាជ្ញាធរជាតិអប្សរាបានធ្វើកំណាយស្រាវជ្រាវទីតាំងខាងលើដោយជ្រើសរើសទួលមួយក្នុងចំណោមទួលជាច្រើនធ្វើកំណាយស្រាវជ្រាវ។









គោលបំណងធ្វើកំណាយស្រាវជ្រាវទីតាំងទួល១០០ ដើម្បីស្វែងយល់ពីប្រវត្តិរៀបចំរចនាសម្ព័ន្ធទួលទាំងនោះធ្វើនៅពេលណា? និងក្នុងគោលបំណងអ្វី? ឧទាហរណ៍ អាចមានទំនាក់ទំនងទីជំនឹកិច្ចពិធីអ្វី? ឬជាផ្នែកនៃរចនាសម្ព័ន្ធនគរូបនីយកម្មរបស់ព្រះរាជាសម័យអង្គរ។ល។ ដោយយើងសង្ឃឹមថា ទិន្នន័យដែលទទួលបានពីការសិក្សាស្រាវជ្រាវនេះនឹងផ្តល់ចំណេះដឹងបន្ថែមស្តីពីអារ្យធម៌អង្គរបន្ថែមទៀត។





បញ្ជូលព័ត៌មានវត្តបុកណាក្នុងប្រព័ន្ធគ្រប់គ្រង



ការចុះបញ្ជីសារពើភណ្ឌ

ជាទូទៅស្ថាប័នជាតិ និងអន្តរជាតិទាំងអស់ដែលកំពុងបំពេញការងារជួសជុលប្រាសាទ និងសិក្សាស្រាវជ្រាវ នៅតំបន់អង្គរតែងប្រគល់វត្ថុបុកណាដែលបានរកឃើញមកអាជ្ញាធរជាតិអប្សរាក្រោយពេលសិក្សារួច។ ក្រៅពីនោះ នៅមានវត្ថុបុកណាមួយចំនួនទៀតទទួលបាន ពីប្រជាជន ដែលគាត់បានប្រទះឃើញដោយចៃដន្យពេលរៀបចំដីដាំដំណាំ ឬធ្វើស្រែចម្ការ។ វត្ថុបុកណាទាំងនោះមានដូចជា៖ កាជន៍ ឬបំណែកកាជន៍ (មានស្រទាប់រលោង និងពុំមានស្រទាប់រលោង) បំណែកចម្លាក់ថ្មភក់ និងចម្លាក់ថ្មភក់ បំណែករលោហធាតុ (មាស ដែក ស្ពាន់លង្ហិន) និងសិលាចារឹកៗលៗ ដោយឡែក ក្នុងករណីស្ថាប័នដែលបានប្រគល់វត្ថុបុកណាទាំងនោះមានចំណងមកសិក្សាពីវត្ថុបុកណាទាំងនោះបន្ថែមទៀត គឺអាជ្ញាធរជាតិអប្សរាតែងតែអនុញ្ញាតតាមការស្នើសុំ។

ដើម្បីងាយស្រួលថែរក្សា និងគ្រប់គ្រងតាមស្តង់ដារឱ្យបានត្រឹមត្រូវចាំបាច់យើងត្រូវរៀបចំចុះបញ្ជីសារពើភណ្ឌវត្ថុបុកណាទាំងនោះដោយផ្តោតលើអត្តសញ្ញាណសំខាន់ៗរបស់វត្ថុដូចជា៖ សម័យកាលរចនាប័ទ្ម ប្រភព វត្ថុធាតុដើម ទំហំ ទម្ងន់ ពណ៌នា កាលបរិច្ឆេទរកឃើញ ប្រវត្តិនៃការអភិរក្ស ស្ថាប័នប្រគល់ កាលបរិច្ឆេទប្រគល់ លេខបញ្ជីចាស់ លេខបញ្ជីថ្មី និងទីតាំងរក្សាវត្ថុជាដើម។ បញ្ជីសារពើភណ្ឌនេះ គឺជាជំរើរការស្រង់ព័ត៌មានវត្ថុបុកណាដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់អាជ្ញាធរជាតិអប្សរា ព្រោះបញ្ជីសារពើភណ្ឌមានព័ត៌មានត្រប់ត្រាន់ អាចឱ្យយើងដឹងនូវ៖

- វត្ថុបុកណាអ្វីខ្លះដែលយើងមាន
- វត្ថុបុកណាទាំងនោះរក្សាទុកនៅកន្លែងណា
- ពីចំនួនសមុច្ច័យដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់យើង
- ងាយស្រួលរក្សាទុក និងផ្ទេរពីទីតាំងមួយទៅទីតាំងមួយ
- ងាយស្រួលក្នុងការផ្សព្វផ្សាយ
- ជាឯកសារសំខាន់ដែលជួយសម្រួលដល់ការតាមដានត្រឡប់មកវិញក្នុងករណីមានវត្ថុបុកណាណាមួយបានបាត់បង់



ទទួលវត្ថុបុរាណពីវិទ្យាស្ថានសាលាបារាំង (EFEO)



ព័ត៌មានក្នុងបញ្ជីសារពើភណ្ឌ

ក្រោយពីបំពេញព័ត៌មានវត្ថុបុរាណទាំងនោះរួចរាល់ ក្រុមចុះបញ្ជីត្រូវបញ្ចូលព័ត៌មានទាំងនោះទៅក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យអេឡិចត្រូនិច ព្រោះប្រព័ន្ធគ្រប់គ្រងទិន្នន័យនេះជួយឱ្យយើងងាយរៀបចំឯកសារ និងងាយស្រួលរកៗ ក្រៅពីនេះ ការរៀបចំបញ្ជីសារពើភណ្ឌក្នុងទម្រង់ជាព័ត៌មានឌីជីថលបែបនេះ គឺងាយស្រួលក្នុងការផ្សព្វផ្សាយ ងាយស្រួលបញ្ជូនទិន្នន័យវត្ថុបុរាណទៅអ្នកស្រាវជ្រាវ ប៉ូលីស និងអង្គការអន្តរជាតិ ដូចជាអង្គការយូណេស្កូជាដើមៗ

រហូតមកដល់បច្ចុប្បន្ននេះ ក្រុមការងារចុះបញ្ជីសារពើភណ្ឌវត្ថុបុរាណនៅតែបន្តចុះបញ្ជីវត្ថុបុរាណ ព្រោះស្ថាប័នជាដៃគូតែងតែផ្តល់វត្ថុបុរាណមកអាជ្ញាធរជាតិអប្សរាជាបន្តបន្ទាប់ៗ ជាក់ស្តែងរហូតមកដល់ពេលនេះ មជ្ឈមណ្ឌលអន្តរជាតិស្រាវជ្រាវ និងតម្កល់ឯកសារអង្គរ បានចុះបញ្ជីសារពើភណ្ឌវត្ថុបុរាណដែលបានមកពី៖

- តម្រាំងមូលនិធិបុរាណវិទ្យា និងអភិវឌ្ឍន៍កម្មវិធីក្តីគូលែន (ADF) បានចំនួន៨៦ដុំ
- តម្រាំងជួសជុលប្រាសាទមេបុណ្យខាងលិច ដោយសាលាបារាំងចុងបូព៌ា (EFEO) បានចំនួន៥១ដុំ
- តម្រាំងមហានគរនៃសាកលវិទ្យាល័យស៊ីដនីចំនួន៤៧០ដុំ
- នាយកដ្ឋានចំណុះអាជ្ញាធរជាតិអប្សរាចំនួន១១១ដុំ



បញ្ជីសារពើភណ្ឌ

បច្ចុប្បន្នវត្ថុបុរាណដែលចុះបញ្ជីសារពើភណ្ឌរួច បានរក្សាទុកនៅក្នុងឃ្លាំងរបស់នាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងផ្សព្វផ្សាយ។ កិច្ចការចុះបញ្ជីសារពើភណ្ឌវត្ថុបុរាណ គឺតម្រូវឱ្យមានការពិនិត្យ អង្កេតហ្មត់ចត់ និងប្រើពេលវេលា រួមទាំងអ្នកជំនាញ។ សព្វថ្ងៃវត្ថុបុរាណនៅក្នុងឃ្លាំងរបស់មជ្ឈមណ្ឌលមានចំនួនច្រើន ដូច្នេះការចុះបញ្ជីវត្ថុបុរាណត្រូវការពេលវេលាយូរបន្តទៀតៗ





ដោយឡែក ក្រុមការងារចុះបញ្ជីបេតិកណ្ឌរូបីនៃនាយកដ្ឋានអភិរក្សប្រាសាទ និងបុរាណវិទ្យា បានចុះបញ្ជីបំណែកចម្លាក់ព្រះពុទ្ធរូប រូបចម្លាក់ផ្សេងៗ និងសិលាចារឹកនៅតាមប្រាសាទទាំង៩១ ដែលបានចុះបញ្ជីជាបេតិកភណ្ឌពិភពលោក នៅទីតាំងប្រវត្តិសាស្ត្រ និងវត្តនានាក្នុងរមណីយដ្ឋានអង្គរ ដូចខាងក្រោម៖

- ចុះបញ្ជីបំណែកចម្លាក់នៅតាមប្រាសាទ បានចំនួន៦៧៨៦ដុំ
- ចុះបញ្ជីវត្ថុបុរាណបានចំនួន៨៦៨ប្រភេទ (រក្សាទុកនៅសារមន្ទីរព្រះនរោត្តមសីហនុ-អង្គរ)
- ចុះបញ្ជីវត្ថុបុរាណទូលពីកន្លែងផ្សេងៗ បានចំនួន១៧៤ដុំ (ចំនួន៨៦ដុំបញ្ជូនទៅរក្សាទុកនៅនាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងផ្សព្វផ្សាយ)
- ចុះបញ្ជីចម្លាក់នៅប្រាសាទអង្គរវត្ត បានចំនួន៩៣១ដុំ (រក្សាទុកនៅឃ្លាំងនាយកដ្ឋានអភិរក្សប្រាសាទ និងបុរាណវិទ្យា)





ប្រគល់ទទួលវត្ថុបុរាណ





ប្រគល់ទទួលវត្ថុបុរាណ

ក្រៅពីកិច្ចការចុះបញ្ជីវត្ថុបុរាណ ដែលស្ថាប័នជាតិ និងអន្តរជាតិប្រគល់មកអាជ្ញាធរជាតិអប្សរ និងចុះបញ្ជីវត្ថុបុរាណនៅតាមទីតាំងប្រវត្តិសាស្ត្រនានាក្នុងមណ្ឌលអង្គរ ក្រុមចុះបញ្ជីសារពើភណ្ឌវត្ថុបុរាណនៃសារមន្ទីរព្រះនគរតួមសីហនុ-អង្គរ និងសារមន្ទីរកុលាលភាជន៍អង្គរ នៅភូមិតានី ក៏បានចុះបញ្ជីពាល់សមុច្ច័យដែលបានតាំងបង្ហាញ និងវត្ថុក្នុងឃ្លាំងតាំងអស់ដើម្បីងាយត្រប់ត្រង។ មកដល់បច្ចុប្បន្ននេះ សារមន្ទីរព្រះនគរតួម សីហនុ-អង្គរ មានសមុច្ច័យសរុបតាំងអស់ចំនួន ១,៧៣៦ ដែលទទួលបានពីសាកលវិទ្យាល័យសូហ៊ីយ៉ានៃប្រទេសជប៉ុន ដែលរកឃើញក្នុងពេលធ្វើកំណាយស្រាវជ្រាវនៅប្រាសាទបន្ទាយក្តីក្នុងឆ្នាំ២០០០ និងឆ្នាំ២០០១ អាជ្ញាធរជាតិអប្សរ សាលាបាក់ឌុងបូព៌ា គម្រោងមូលនិធិអភិវឌ្ឍន៍ភ្នំគូលែន អគ្គភាពនគរបាលការពារសតិកគណៈទន្តសៀមរាប ប្រជាពលរដ្ឋ ព្រះសង្ឃ និងក្រុមហ៊ុនផងដែរ។



ការរៀបចំទុកជាគំរូនូវបុកណាដែលបានចុះបញ្ជីសារពើភណ្ឌរួច

សារមន្ទីរបុរាណវត្ថុ សិរីសុភ័ណ្ឌ

លេខបញ្ជីវត្ថុ	ព្រះពុទ្ធបដិមាកែង	រូបភាព
លេខបញ្ជីថ្មី	NSAM.2007.3	
លេខបញ្ជីចាស់	(BKS) NSAM.2008.167	
ប្រភេទវត្ថុ	ទូទៅ / លោហៈ / ប្រាង្គ	
ទំហំ (ស.ម)	៨៣×៤៥.៥	
ទំងន់ (ក.ក)	៥៦	
សម័យកាល	ឥណ្ឌូ / ក.ស.វ / ចុងសតវត្សទី ១៦-១៧	
ប្រភព	ព្រះសាទបន្ទាយឆ្មារ	
ចំណែកវត្ថុ	ទម្រាំលាក	
ទីកន្លែងរក្សារ	ជាន់ទី១ បន្ទប់ក្រុងអង្គរ	
ស្ថានភាពកាយ	ស្អាតប្លឹង	
ស្ថានភាពបច្ចុប្បន្ន	ស្អាតប្លឹង	
ការចងក្រងចុងក្រោយ	ថ្ងៃទី ៦ ខែតុលា ឆ្នាំ២០០៨	
ពណ៌នា	ព្រះពុទ្ធបដិមាបានតាំងនៅលើទម្រាំលាកមួយបានផ្គុំពីរ។ ចេញពីព្រះភក្ត្រព្រះ... ព្រះនេត្រទាំងសងខាង ស្លាកបាត់ខ្លះ។ ដៃស្តាំព្រះអង្គបាត់... ព្រះភក្ត្រព្រះពុទ្ធរូបនេះ... ប្រាង្គរាងជ្រលក់ទាំងស្តើង... ដែលមានរាងដូចផ្កាឈូក...	
ប្រវត្តិសង្ខេប	...	
ឯកសារយោង	...	
ការចងក្រងចុងក្រោយ	ថ្ងៃទី ... ខែ... ឆ្នាំ...	


ចំណែកសារមន្ទីរកុលាលកាជន៍អង្គរនៅភូមិតានី ដែលជាសារមន្ទីរបុរាណវិទ្យា មានទីតាំងនៅទីជម្ពុជកុលាលកាជន៍សម័យអង្គរ បានចុះសមុច្ច័យដែលបានតាំងបង្ហាញ ដែលបានរកក្នុងពេលធ្វើកំណាយស្រាវជ្រាវដោយភាគីជប៉ុន និងអាជ្ញាធរជាតិអប្សរា។ សព្វថ្ងៃសារមន្ទីរនេះមានសមុច្ច័យសរុបទាំងអស់ចំនួន១១៧ ជាកុលាលកាជន៍ ដែលបានពីការធ្វើកំណាយស្រាវជ្រាវនៅឡមានលេខសម្គាល់ A6, B1 និង B4។ ដោយសាកលវិទ្យាល័យ SOPHIA និងវិទ្យាស្ថានជាតិ NARA ប្រទេសជប៉ុន សហការជាមួយអាជ្ញាធរជាតិអប្សរា។



សារមន្ទីរក្នុងកិច្ចអភិរក្ស

សារមន្ទីរ ជាស្ថាប័នមិនរកប្រាក់ចំណេញក្នុងការបម្រើសង្គមនិងការអភិវឌ្ឍតាមរយៈការតាំងបង្ហាញ ជាអចិន្ត្រៃយ៍ ឬបណ្តោះអាសន្ននូវសម្បត្តិវប្បធម៌រូបី អរូបីនៃមនុស្សជាតិ ដែលមានសារៈសំខាន់ផ្នែកសិល្បៈវប្បធម៌ ប្រវត្តិសាស្ត្រ ឬវិទ្យាសាស្ត្រ ជាសាធារណៈក្នុងគោលបំណងផ្សព្វផ្សាយ អប់រំ ស្រាវជ្រាវ បណ្តុះបណ្តាល ការកម្សាន្ត និងអភិរក្ស ព្រមទាំងជាកន្លែងថែរក្សាវត្ថុបុរាណ ស្នាដៃសិល្បៈ ស្នាដៃវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ព្រមទាំងវិស័យផ្សេងៗទៀតដែលទាក់ទងបុរេប្រវត្តិសាស្ត្រ ប្រវត្តិសាស្ត្រ និងសកម្មភាពមនុស្សៗលៗ សារមន្ទីរមានច្រើនប្រភេទ៖ សារមន្ទីរសិល្បៈ សារមន្ទីរបុរាណវិទ្យា សារមន្ទីរប្រវត្តិសាស្ត្រជម្មជាតិ សារមន្ទីរវិទ្យាសាស្ត្រ សារមន្ទីរសង្គ្រាម និងសារមន្ទីរកុមារៗលៗ

បច្ចុប្បន្ន សារមន្ទីរចំនួន៣ ត្រូវបានគ្រប់គ្រងដោយអាជ្ញាធរជាតិអប្សរា ក្នុងនោះមានសារមន្ទីរព្រះនរោត្តម សីហនុ-អង្គរ សារមន្ទីរកុលាលភាជន៍អង្គរនៅភូមិតានី និងសារមន្ទីរវាយនភណ្ឌប្រពៃណីអាស៊ីៗ



ពិព័រណ៌វាលគប់សពកោះតាមាស

សារមន្ទីរព្រះនរោត្តមសីហនុ-អង្គរ



សារមន្ទីរព្រះនរោត្តមសីហនុ-អង្គរ ជាសារមន្ទីរបុរាណវិទ្យាដំបូងគេបង្អស់នៅក្នុងខេត្តសៀមរាប។ រាល់វត្ថុសិល្បៈដែលជាក់តាំងពិព័រណ៍នៅក្នុងសារមន្ទីរនេះសុទ្ធសឹងតែបានមកពីការធ្វើកំណាយបុរាណវិទ្យាក្នុងភូមិសាស្ត្រខេត្តសៀមរាប ជាពិសេសប្រាសាទបន្ទាយក្តី។ សារមន្ទីរនេះកសាងឡើងក្រោមកិច្ចសហប្រតិបត្តិការរវាងអាជ្ញាធរជាតិអប្សរា និងសាកលវិទ្យាល័យសូហ្វីយ៉ា ដោយមូលនិធិនៃក្បិប ១% របស់ក្រុមហ៊ុនអ៊ីអុង ក្នុងគោលបំណងដើម្បីថែរក្សា និងដាក់តាំងបង្ហាញវត្ថុបុរាណដែលរកឃើញក្នុងពេលសិក្សាស្រាវជ្រាវរបស់សាកលវិទ្យាល័យសូហ្វីយ៉ាកាលពីឆ្នាំ២០០០ និង២០០១។ សារមន្ទីរនេះបានកសាងរួចរាល់នៅក្នុងឆ្នាំ២០០៧ និងបានយោងសម្ពោធក្រោមព្រះរាជធិបតីភាពដ៏ខ្ពង់ខ្ពស់ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា។



















ក្នុងឆ្នាំ២០៦០ និង២០៦១កន្លងមកនេះ សារមន្ទីរបានរៀបចំ ពិព័រណ៌ចំនួន២បន្ថែមទៀតរួមមាន៖ ពិព័រណ៌ចម្ងាក់សត្វអណ្តើក និងពិព័រណ៌ចម្ងាក់ទ្វារបាលក្រោយទទួលបានអនុសាសន៍ណែនាំពី **ឧកញ៉ាឧត្តមបណ្ឌិតអស្សាចារ្យ ង៉ែត សុភណ** រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងជាប្រធានក្រុមប្រឹក្សាភិបាលអាជ្ញាធរជាតិអប្សរា ក្នុងឱកាសដែលលោកជំទាវបានអញ្ជើញចូលទស្សនាអគារកន្សែងអន្តរ និងសារមន្ទីរបូចមក នៅឆ្នាំ២០៦៦នេះ សារមន្ទីរក៏បានរៀបចំពិព័រណ៌ពុទ្ធបដិមាឈើ និងពុទ្ធបាទថ្ម ចំនួន៧ សម្មុខ្ញ័យបន្ថែម។


ការរៀបចំពិព័រណ៌នេះ ក្នុងគោលបំណងចូលរួមចំណែកក្នុងការអភិវឌ្ឍសារមន្ទីរ និងផ្សព្វផ្សាយវប្បធម៌ សាសនា សិល្បៈ ប្រវត្តិសាស្ត្រខ្មែរឱ្យកាន់តែទូលំទូលាយដល់សាធារណៈជនទូទៅ សិស្ស និស្សិត ជាពិសេសអ្នកស្រាវជ្រាវជាតិ អន្តរជាតិ ។





តិត្ថវណ៌ព្រះពុទ្ធបដិមា (ប្រាសាទបន្ទាយក្តី)

នៅឆ្នាំ២០០០ និង២០០១ សាកលវិទ្យាល័យសូហ្គីយ៉ា និងបុរាណវិទូខ្មែរ បានធ្វើកំណាយសិក្សាស្រាវជ្រាវនៅប្រាសាទបន្ទាយក្តី ហើយបានប្រទះឃើញរូបចម្លាក់ចំនួន៦៧៩បំណែក ដែលកប់ក្នុងរណ្តៅតែមួយៗ រូបចម្លាក់ទាំងនេះជាកម្មសិទ្ធបញ្ជាក់ពីព្រឹត្តិការណ៍ដ៏គួរឱ្យកត់សម្គាល់មួយទាក់ទងនឹងព្រះពុទ្ធសាសនាសម័យអង្គរៗ ពុទ្ធបដិមាទាំងនេះមានសម័យកាលខុសៗគ្នា ហើយធ្លុះបញ្ចាំងពីការវិវឌ្ឍន៍នៃសិល្បៈព្រះពុទ្ធសាសនាខ្មែរៗ







ពិព័រណ៌កាលកប់សព
(កោះតាមាស ឯងព្រៃភ្នែង)

កោះតាមាសជាទីខ្ពស់ធំមួយ ដែលមានផ្ទៃកបស្មើស្ថិតនៅចម្ងាយ ១៣០០ម៉ែត្រខាងលិចប្រាសាទមេបុណ្យក្នុងបានបាត់យណ៍ទឹកថ្ងាដ៏ធំល្វឹងល្វើយ។ ដំណើរការសិក្សានៅកោះតាមាសនេះ នាំឱ្យគេរកឃើញតឹកតាងនៃការតាំងភូមិករនៅយុគសំរឹទ្ធ ក៏ដូចជាសម្គាល់ឃើញទីកប់សពបុរាណមួយដែលមានអាយុកាលប្រហែល៣០០០ឆ្នាំមុន។ ការជីកំណាយក្នុងឆ្នាំ២០០៦-២០០៩ ដែលមានការចូលរួមពីក្រុមកំណាយបុរាណវិទូខ្មែរ និងបារាំង បានរកឃើញកុលាលភាជន៍ល្អវិចិត្រ គ្រឿងអលង្ការ ឧបករណ៍ប្រើប្រាស់ ឆ្អឹងសត្វចតុប្បាទ និងឆ្អឹងត្រី ដែលកប់នៅជាមួយសពជាច្រើន។ ឯព្រៃភ្នែងជាឈ្មោះប្រាសាទតូចមួយនៅក្បែរទំនប់ខាងលិចនៃបារាយណ៍ទឹកថ្ងា ដែលនៅទីនោះគេបានរកឃើញកន្លែងកប់សពបុរាណនិងភូមិករបុរាណ។







ពិព័រណ៌ភាជន៍ដាក់ជាតុ
(ប្រាសាទគោកចាន់ត្រី)

ក្នុងឆ្នាំ២០០៩ ក្រុមការងាររបស់អាជ្ញាធរជាតិអប្សរា បានជីកំណាយនៅប្រាសាទគោកចាន់ត្រីបានរកឃើញភាជន៍ជាង៦០ ព្រមទាំងវត្ថុសិល្បៈផ្សេងៗទៀត។ កុលាលភាជន៍ដែលកំណាយបានជាប្រភេទវត្ថុ ដែលអ្នកស្រុកប្រើប្រាស់អចិន្ត្រៃយ៍។ ភាជន៍ខ្លះនាំចូលពីប្រទេសចិន ជប៉ុន និងថៃ ហើយខ្លះទៀតជាភាជន៍ក្នុងស្រុក។

តាមការវិភាគកាលបរិច្ឆេទវិទ្យុសកម្មភាពបួន ភាជន៍ទាំងនេះមានអាយុកាលចាប់ពីសតវត្សរ៍ទី១៥-១៧នៃគ.ស. ប៉ុន្តែការប្រើប្រាស់ភាជន៍ទាំងអស់ មានអាយុកាលចាប់ពីចុងសតវត្សរ៍ទី១៥-១៩នៃគ.ស.។





សារមន្ទីរវាយនកណ្តាប្រពៃណីអាស៊ី



ក្រោមកិច្ចសហប្រតិបត្តិការតំបន់ទន្លេមេគង្គ-គង្គាបានបើកដំណើរការក្នុងឆ្នាំ២០១៦ ដែលបង្ហាញពីលក្ខណៈដូច និងស្រដៀងគ្នានៃវប្បធម៌របស់ប្រទេសឥណ្ឌា កម្ពុជា ឡាវ មីយ៉ាន់ម៉ា ថៃ និងវៀតណាម តាមរយៈការប្រើប្រាស់វាយនកណ្តា និងសម្លៀកបំពាក់។ សារមន្ទីរបង្ហាញនូវលក្ខណៈពិសេសនៃអត្តសញ្ញាណ និងវប្បធម៌ក្នុងតំបន់ក៏ដូចជាឥទ្ធិពលនៃវប្បធម៌ចម្រុះ ដែលកើតឡើងដោយការច្រាស្រ័យទាក់ទងគ្នា ការធ្វើពាណិជ្ជកម្ម ការតាំងទីលំនៅ និងការចែករំលែកនូវជំនឿរួមគ្នា តាមរយៈវាយនកណ្តា សម្លៀកបំពាក់ និងដំណើរការផលិត។ គោលបំណងនៃការកសាងសារមន្ទីរនេះគឺ ដើម្បីថែរក្សាប្រពៃណីនៃការផលិតវាយនកណ្តា ក៏ដូចជាបង្ហាញពីទំនាក់ទំនងរវាងអរិយធម៌ វប្បធម៌ និងពាណិជ្ជកម្ម របស់ប្រទេសជាសមាជិកដែលមានរយៈពេលជាច្រើនសតវត្សរ៍មកហើយ។



សារមន្ទីរមានអាសយដ្ឋាននៅភូមិបឹងជួនប៉ា (ផ្លូវ៦០ម៉ែត្រ) សង្កាត់ស្វាយក្រម ក្រុងសៀមរាប ដែលបើកជូនសាធារណជនចូលទស្សនាពីថ្ងៃពុធដល់ថ្ងៃចន្ទ ចាប់ពីម៉ោង៨:៣០នាទីព្រឹក ដល់ម៉ោង៤:០០នាទីល្ងាច ជាពិសេសមិនគិតថ្លៃចំពោះព្រះសង្ឃ ជូនជី តាជី និងកុមារក្រោមអាយុ១៦ឆ្នាំ។ សារមន្ទីរក៏មានមគ្គុទ្ទេសក៍ជំនាញនៅចាំធ្វើការពន្យល់ បកស្រាយជូនភ្ញៀវជាតិ និងអន្តរជាតិទាំងអស់ដោយឥតគិតថ្លៃផងដែរ។






Mahatma Gandhi
and
Khadi Fabric of India











សារមន្ទីរកុលាលភាជន៍អង្គរកូមិតាធី



កុលាលភាជន៍ បានបម្រើឱ្យការរស់នៅប្រចាំថ្ងៃរបស់មនុស្សតាំងពីសម័យបុរាណប្រវត្តិសាស្ត្រ រហូតមកដល់បច្ចុប្បន្ននេះ។ នៅសម័យអង្គរឿងកុលាលភាជន៍ ក៏ជាគ្រឿងសម្គាល់យសមន្ត្រីក្រមការ ក្នុងរាជការខៀតផង មានន័យថាកុលាលភាជន៍បម្រើឱ្យសង្គមមនុស្សគ្រប់ស្រទាប់ថ្នាក់។ នាយុគសម័យចំនើបនេះ កុលាលភាជន៍នឹតតែមានសារសំខាន់ចំពោះមនុស្សជាតិ។ ឧទាហរណ៍ ជ្រុងមួយនៃការប្រើប្រាស់កុលាលភាជន៍ក្នុងវិស័យឧស្សាហកម្មលោហៈ កុលាលភាជន៍ជាឧរំលាយលោហៈ ដែលអាចជន់នីងសីតុណ្ហភាព លើសពីកម្រិតរលាយ នៃលោហៈជាតុគ្រប់ប្រភេទ។ នេះយើងមិនទាន់និយាយអំពីក្បឿង ការ៉ូរៀបផ្ទះ ជុំឥដ្ឋសាងសង់អាគារគ្រប់ប្រភេទ និងផលិតផលផ្ទះបាយមួយចំនួនទៀតផង។









សារមន្ទីរកុលាលកាជន៍អង្គរភូមិតានី ជាសារមន្ទីរកុលាលកាជន៍សម័យអង្គរ ដែលសាងសង់នៅទីតាំងស្ថានីយ៍ឧប្បុកណភូមិតានីផ្ទាល់តែម្តង។ ពិព័រណ៌អចិន្ត្រៃយ៍នៅសារមន្ទីរនេះ មានសមុច្ច័យសរុបចំនួន១១៧ ដែលបានមកពីរណ្តៅកំណាយបុកណាវិទ្យា ពីបណ្តុំឧប្បុកណានៅជុំវិញតំបន់អង្គរ។ ពិព័រណ៌នេះកំពុងតាំងបង្ហាញជូនម្ចាស់សិក្សាស្រាវជ្រាវផ្នែកកុលាលកាជន៍ ភ្ញៀវទេសចរជាតិនិងអន្តរជាតិដើម្បីសិក្សាស្វែងយល់អំពីកុលាលកាជន៍ខ្មែរ ក៏ដូចជាការរួមចំណែកផ្សព្វផ្សាយជ្រុងមួយនៃអារ្យធម៌អង្គរ ដែលកូនខ្មែរត្រូវបន្តរួមតែសិក្សាស្វែងយល់។

សម័យអង្គរជាសម័យកាលដ៏រុងរឿង នៃប្រវត្តិសាស្ត្រខ្មែរ កុលាលកាជន៍ក៏ដើរតួនាទីសំខាន់ដូចគ្នាចំពោះបុព្វបុរសខ្មែរៗ ម្ល៉ោះហើយ ទើបបណ្តុំឧប្បុកណាជាច្រើន បានរកឃើញនៅជុំវិញតំបន់អង្គរ និងតួទាំងអតីតអាណាចក្រខ្មែរសម័យបុកណា ដែលបុកណាវិទូបានរកឃើញ និងអាចបន្តរកឃើញថ្មីៗទៀតៗ។ បណ្តុំឧប្បុកណានៅតំបន់អង្គរ មានដូចជាឧត្តានីទ័ពជ័យ សារសី អន្ទង់ធំ ខ្នារពោធិ បង្គោង ឧប្បុតកាជន៍ទ្វារដីឆ្នាំងនៃក្រុងអង្គរធំដែលទើបរកឃើញ។


ប្រព័ន្ធជារ
Angkor Hydr
Tonlé Sgnuot
PREAH KHAN
NEAK P
ANGKOR THOM
WEST MEBON
TA KEO
Pourk River
PHNOM BAKENG
SRAH SR
TA PROHM
BANTEAY KDE
Siem Reap River
ANGKOR WAT
PREAH KO
PHNOM KROM
BAKO
Tonlé Sap Lake


aulic Network
BANTEAY SREI
Phnom Kulen
Phnom Dei
EAST MEBON
PHNOM BOK
CHAO SREI VIBOL
LOLEI
Roluos River
© HANG PEOU

អភិវឌ្ឍន៍ប្រកបដោយចីរភាព

ប្រព័ន្ធធារាសាស្ត្រសម័យបុរាណ

ការស្តារឱ្យប្រសើរឡើងវិញនូវប្រព័ន្ធធារាសាស្ត្រសម័យបុរាណ គឺជាការងារប្រឈមដ៏ឧឡារិកមួយក្នុងចំណោមការងារប្រឈមដទៃទៀតក្នុងរមណីយដ្ឋានអង្គរ។ កិច្ចការនេះមិនត្រឹមតែជាកត្តល់សម្រាប់ការអភិរក្សប្រាង្គប្រាសាទ និងការអភិវឌ្ឍប្រកបដោយចីរភាពនៃរមណីយដ្ឋានអង្គរប៉ុណ្ណោះទេ តែក៏ជាបញ្ហាប្រឈមក្នុងការរក្សាតុល្យភាពទឹកនៅក្នុងតំបន់សៀមរាបទាំងមូល ព្រោះតំណើនដ៏ឆាប់រហ័សនៃចំនួនភ្ញៀវទេសចរ និងប្រជាជន។ ដំណោះស្រាយគន្លឹះជាចាំបាច់ក្នុងការធ្វើយតបតម្រូវការក្នុងការប្រើប្រាស់ទឹកប្រចាំថ្ងៃ និងការជានាឱ្យមានស្ថិរភាពចំពោះប្រាង្គប្រាសាទ ដែលសាងសង់នៅលើគ្រឹះខ្សាច់ គឺពង្រីកលទ្ធភាពរក្សាទឹកនៅតាមទីតាំងរក្សាទុកសំខាន់ៗក្នុងរមណីយដ្ឋានអង្គរ។



ទ្វារទឹកភូមិប្រាសាទបាយ



អាជ្ញាធរជាតិអប្សរាបានសិក្សាស្រាវជ្រាវជាក់ស្តែងអំពីប្រព័ន្ធ ធារាសាស្ត្របុរាណដោយបង្ហាញថា ផ្នែកខាងជើងធៀងខាងកើត បារាយណ៍ខាងជើងមានទំនប់មួយដែលគេសង់ក្នុងទិសពីកើតទៅលិច និងមានស្ពានបុរាណមួយធ្វើពីថ្មបាយក្រៀម ដែលមានប្រហោងបង្ហូរទឹកជាច្រើន សង់លើស្ទឹងសៀមរាប អាចត្រូវបានប្រើប្រាស់សម្រាប់លំហូរទឹកនិងគ្រប់គ្រងទ្វារទឹក។ ដោយសារប្រព័ន្ធខែកចាយនិងអូរប្រមាក់ក្រឡាន្ទាជាច្រើននេះហើយ ទើបការបង្វែរទឹកទៅទិសខាងលិច (បារាយណ៍ខាងជើង បារាយណ៍ខាងលិច និងស្ទឹងពួក) ទៅទិសខាងកើត (ស្ទឹងរលួស) និងទិសខាងត្បូង (កសិន្ទទឹកទីក្រុងអង្គរធំ កសិន្ទទឹកប្រាសាទអង្គរវត្ត និងស្ទឹងសៀមរាប) អាចធ្វើឡើងបានដោយរលូនពុំមានឧបសគ្គអ្វីទាំងអស់។

ទ្វេកាត់ការកែតាគទិន្នន័យជំហ៊ន និងការសន្និដ្ឋានវិទ្យាសាស្ត្រនៃទឹកជំនន់ឆ្នាំ២០០៩ឆ្នាំ២០១០ និងឆ្នាំ២០១១ អាជ្ញាធរជាតិអប្សរា បានអនុវត្តនូវការងារជាក់ស្តែងចាំបាច់មួយចំនួនដូចជា ការជួសជុលនិងស្តារប្រព័ន្ធធារាសាស្ត្របុរាណសម័យអង្គរឱ្យដំណើរការឡើងវិញជាស្ថាពរ។ ជាពិសេស នៅឆ្នាំ២០១៦ ផ្នែកដ៏សំខាន់នៃប្រព័ន្ធធារាសាស្ត្របុរាណសម័យអង្គរត្រូវបានស្តារឡើងវិញ ដែលការស្តារនេះធ្វើឱ្យរមណីយដ្ឋានអង្គរនិងទីក្រុងសៀមរាបទាំងមូលបានចៀសផុតពីការរងគ្រោះទឹកជំនន់។ ចំណុចនេះបញ្ជាក់យ៉ាងច្បាស់ថា ប្រព័ន្ធធារាសាស្ត្របុរាណសម័យអង្គរមិនត្រឹមតែអាចគ្រប់គ្រងទូវ ធនធានទឹកបានយ៉ាងល្អប៉ុណ្ណោះទេ តែថែមទាំងអាចគ្រប់គ្រងទឹកជំនន់បានទៀតផង។





ការស្ពានប្រឡាយផ្ដន់ផ្ដង់ទឹក



ការសម្ពាធប្រឡាយសហគមន៍ក្បឹប្រាស់ទឹក

កសិទ្ធិទឹកទីក្រុងអង្គរជំ

កសិទ្ធនេះជាអាងស្តុកទឹកដ៏ធំមួយ ដែលមានប្រវែង១៦គីឡូម៉ែត្រ ព័ទ្ធជុំវិញទីក្រុងអង្គរជំ និងអាចផ្ទុកទឹកបានជិត៦លានម៉ែត្រគូបៗ កាលពីពេលមុន មានតែផ្នែកខាងត្បូងធៀងខាងលិចប្រវែងប្រមាណ ៣គីឡូម៉ែត្រប៉ុណ្ណោះដែលអាចរក្សាទឹកបាន ខណៈផ្នែកខាងត្បូងធៀងខាងកើតពុំមានទឹកទាល់តែសោះក្នុងរដូវប្រាំងៗ បន្ទាប់ពីជួសជុលលើកទី១ កំណាត់កសិទ្ធផ្នែកខាងត្បូងធៀងខាងកើតប្រវែង ៣គីឡូម៉ែត្រ អាចរក្សាទឹកបានពេញមួយឆ្នាំ ទាំងរដូវប្រាំង និងរដូវវស្សា។ ក៏ប៉ុន្តែចាប់ពីឆ្នាំ២០១៦មក កសិទ្ធទឹកទីក្រុងអង្គរជំទាំងមូលប្រវែង១៦គីឡូម៉ែត្រ ត្រូវបានជួសជុលរួចរាល់ទាំងស្រុង និងអាចរក្សាទឹកបានពេញក្នុងមួយឆ្នាំជាប្រចាំឡើងវិញ។



កសិទ្ធិទឹកប្រាសាទអង្គរវត្ត

មុនឆ្នាំ២០១០ ប្រព័ន្ធបង្ហូរទឹកបំពេញកសិទ្ធទឹកប្រាសាទអង្គរវត្ត គឺមានប្រឡាយមួយដែលគេសាងឡើងនៅចន្លោះកសិទ្ធទឹកទីក្រុងអង្គរជំខាងត្បូងធៀងខាងលិចរហូតដល់ត្រពាំងសេសទ្ធជាប់ខាងក្រោយកន្លែងបន្លោះបាឡុងក្នុងសម័យថ្មីនេះ។ បច្ចុប្បន្នយើងបានស្តារប្រព័ន្ធបុរាណឡើងវិញ ដោយភ្ជាប់កសិទ្ធទឹកទីក្រុងអង្គរជំផ្នែកខាងត្បូងធៀងខាងកើតទៅកសិទ្ធទឹកប្រាសាទអង្គរវត្តផ្នែកខាងជើងធៀងខាងលិចផ្ទាល់ ដោយទ្វេជាន់តាមកសិទ្ធទឹកភ្នំបាខែង និងអូរសំពៅលូនៗ។ ប្រព័ន្ធនេះបានជ្រើសរើសកម្រិតទឹកក្នុងកសិទ្ធអង្គរវត្តកើនបានកម្ពស់១ម៉ែត្របើធៀបទៅនឹងកម្រិតទឹកអតិបរមាពេលមុនៗ





ស្រះស្រង់

ស្រះស្រង់មានទឹកដោយសារទឹកភ្លៀងនិងទឹកជ្រាបពីក្រោមដី ចេញពីបាកយណ៍ខាងកើតនិងទឹកក្រោមដីដែលនៅជុំវិញស្រះនោះ។ ប៉ុន្តែដោយសារបាកយណ៍ខាងកើតរលីងស្ងួតហួតហែងអស់ទៅហើយនិងដោយសារកម្ទិតទឹកក្រោមដីបានស្រកចុះទឹកក្នុងស្រះស្រង់ក៏បានចាប់ផ្តើមរលីងស្ងួតដែរនៅរដូវប្រាំង រហូតដល់គ្មានទឹកទាល់តែសោះនៅខែមេសា ឆ្នាំ២០០៦។ នៅខែមីនា ឆ្នាំ២០០៩ អាជ្ញាធរជាតិអប្សរាបានរៀបចំបង្កើតប្រព័ន្ធបន្ថែមមួយដើម្បីបង្ហូរទឹកចូលក្នុងស្រះស្រង់ដោយយកទឹកចេញពីភ្នំបូកនិងរលួស។



អាង‌ស្តុកទឹក‌ច្រាស‌ាទ‌ជាត‌ព្រ

នៅជុំវិញប្រាសាទនាគព័ទ្ធមានអាងចំនួន៩ ដែលត្រូវបានរលីងស្ងួតអស់ពេញមួយឆ្នាំ លើកលែងតែអាងកណ្តាលដែលមានទឹកក្នុងរយៈពេលប៉ុន្មានខែប៉ុណ្ណោះក្នុងមួយឆ្នាំនៅរដូវវស្សា។ ប៉ុន្តែចាប់តាំងពីបាកយណ៍ខាងជើងមានទឹកសាជាថ្មីឡើងវិញមក អាងទាំង៩នេះក៏មានទឹកពេញឡើងវិញគ្រប់រដូវដែរ។




ក‌សិន្ទុ‌ទឹក‌ច្រាស‌ាទ‌ព្រះ‌ខ័ន

នៅក្នុងសម័យបុរាណជួចស្រះស្រង់ដែរ កសិន្ទុទឹកប្រាសាទព្រះខ័នគ្មានប្រព័ន្ធទឹកបង្ហូរចូលបំពេញនោះទេ។ នៅសម័យបច្ចុប្បន្ន កសិន្ទុនេះមានទឹកតែមួយរយៈពេលប៉ុណ្ណោះក្នុងមួយឆ្នាំ ប៉ុន្តែតាំងពីបាកយណ៍ខាងជើងមានទឹកឡើងវិញមក កសិន្ទុប្រាសាទព្រះខ័នក៏មានទឹកឡើងវិញពេញមួយឆ្នាំដែរ។ បាតុភូតនេះបង្ហាញថាបាកយណ៍ខាងជើងនិងប្រាសាទព្រះខ័នមានទំនាក់ទំនងគ្នាតាមរយៈទឹកក្រោមដី។

ចាកយណ៍ខាងជើង


ចាកយណ៍នេះមានបណ្តោយ៣៦០០ម៉ែត្រនិង១ទឹង៩៣០ម៉ែត្រ មានសមត្ថភាពផ្ទុកទឹកពីដំបូងរហូតដល់ថ្ងៃនម៉ែត្រគូបៗ ទឹកនៅក្នុងចាកយណ៍មិនត្រូវបានគេប្រើដើម្បីយកទៅស្រោចស្រពដំណាំដូចទឹកចាកណ៍ផ្សេងទៀតនៅក្នុងតំបន់នេះឡើយ ប៉ុន្តែគេរក្សាទឹកចាកយណ៍នេះសម្រាប់ប្រើនៅក្នុងទីក្រុងអង្គរធំ ប្រាសាទព្រះខ័ន និងនាគព័ន្ធ។ ចាកយណ៍នេះបានវិលសួតហួតហែងអស់ជាង៩០០ឆ្នាំមកហើយ ម្យ៉ាងទៀតអ្នកស្រាវជ្រាវមួយចំនួនគិតថាការធ្វើឱ្យចាកយណ៍ខាងជើងមានទឹកសាជាថ្មីឡើងវិញមិនអាចទៅរួចនោះឡើយ។ ប៉ុន្តែនៅឆ្នាំ២០០៧ អ្នកស្រាវជ្រាវខ្មែរបានជួសជុលប្រព័ន្ធបង្ហូរទឹកដែលគេបានរកឃើញនៅឆ្នាំ២០០៥ ហើយនៅឆ្នាំ២០០៨ ទឹកក៏ចាប់ផ្តើមហូរចូលក្នុងចាកយណ៍នេះវិញ។ ការបង្ហូរទឹកចូលចំពេញក្នុងចាកយណ៍ខាងជើងបានធ្វើឡើងដូចតទៅនេះ៖

- ចំនួន៣០០.០០០ម៉ែត្រគូបនៅឆ្នាំ២០០៧
- ចំនួន៣.០០០.០០០ម៉ែត្រគូបនៅឆ្នាំ២០០៨
- ចំនួន៣.៦៧៤.០០០ម៉ែត្រគូបនៅឆ្នាំ២០១០
- ចំនួន៥.០០០.០០០ម៉ែត្រគូបនៅឆ្នាំ២០១១ និង២០១៦។



ទាក់ទងនឹងបាតុកម្ម

នៅក្នុងទសវត្សរ៍ទី៦០ ដើម្បីចំពេញទឹកក្នុងបាកយណ៍ខាងលិច ទឹកស្ទឹងសៀមរាបត្រូវបានគេបង្វែរទៅនៅត្រង់ច្រកខាងជើងឆៀងខាងកើតនៃក្រុងអង្គរធំតាមរយៈប្រឡាយមួយដែលគេជីកនៅកសិន្ទ ទីក្រុងអង្គរធំតែម្តង (កសិន្ទខាងជើងនិងខាងជើងឆៀងខាងលិច) មានបណ្តោយប្រវែង៤៩០០ម៉ែត្រ ភ្ជាប់ទៅបាកយណ៍តាមបណ្តោយផ្លូវចូលខ្ញែងទ្វារតាកាវ ដែលជាខ្ញែងទ្វារខាងលិចទីក្រុងអង្គរធំ។ ប្រឡាយទាំងនេះបានធ្វើឱ្យកសិន្ទនិងផ្នែកខាងកើតបាកយណ៍ខាងលិចគោកគ្មានទឹកដែលធ្វើឱ្យគេគិតថាការគោកនេះគឺបណ្តាលមកពីដីកកនៅក្នុងបាតបាកយណ៍។ ឆ្នាំ២០១០ អាជ្ញាធរជាតិអប្សរាបានរកឃើញប្រព័ន្ធបង្ហូរទឹកនៅក្នុងបាកយណ៍ខាងលិចពីសម័យដើមដែលក្នុងនោះមានអាងរក្សាទុកទឹកបុកណាមួយ និងអូរមួយលាតសន្ធឹងដល់ច្រកខាងជើងឆៀងខាងលិចកសិន្ទទីក្រុងអង្គរធំ។ នៅឆ្នាំ២០១១ អាជ្ញាធរជាតិអប្សរាបានបើកអូរសម័យបុកណាបង្ហូរទឹកបាកយណ៍ខាងលិចដើម្បីស្រូបយកទឹកជំនន់ និងការពារភូមិអ្នកស្រុក។ នៅឆ្នាំ២០១៦ អាជ្ញាធរជាតិអប្សរាបានស្តារប្រព័ន្ធបង្ហូរទឹកចំពេញបាកយណ៍នេះទាំងមូលឡើងវិញហើយសព្វថ្ងៃបាកយណ៍ខាងលិចអាចមានទឹកពេញផ្នែកក្នុងគម្រិតអតិបរមា និងបានដើរតួយ៉ាងពេញទំហឹងនៅក្នុងការគ្រប់គ្រងទឹកជំនន់។







ប្រព័ន្ធទឹកប្រាសាទថៅស្រីវិបុល

ប្រព័ន្ធទឹកនៅប្រាសាទថៅស្រីវិបុលត្រូវបានស្ដារឡើងវិញក្នុងឆ្នាំ២០១៥និងបានសាងសង់សំណង់ចំនួន០៤កន្លែងសម្រាប់គ្រប់គ្រងប្រព័ន្ធទឹកនេះ ដោយអាជ្ញាធរជាតិអប្សរាដែលមានការជួយពីប្រទេសញូហ្សីឡែន តាមរយៈគម្រោងអភិវឌ្ឍន៍សេដ្ឋកិច្ចសហគមន៍ និងបេតិកភណ្ឌអង្គរ (Angkor Community Heritage and Economic Advancement, ACHA) ដែលជាគម្រោងមួយជួយផ្តល់លទ្ធភាពក្នុងការអភិវឌ្ឍសហគមន៍។









ប្រព័ន្ធទឹកនេះបានផ្តល់ផលប្រយោជន៍យ៉ាងក្រៃលែងដល់ប្រជាជននៅក្នុងតំបន់នេះ ជាពិសេសប្រជាជននៅក្នុងភូមិចំនួន០៣ គឺភូមិព្រំកុដិ ភូមិបល្ល័ង្ក និងភូមិក្រពើ ឃុំបល្ល័ង្ក ស្រុកប្រាសាទបាគង ដូចជា៖

- សម្រាប់ប្រើប្រាស់ប្រចាំថ្ងៃ សម្រាប់សត្វចិញ្ចឹមរបស់ពួកគាត់ និងសម្រាប់ស្រោចស្រពស្រែចម្ការ ជាពិសេសនៅរដូវប្រាំងដែលអាចជានាបានទទួលប្រាក់ចំណូលក្នុងការផ្គត់ផ្គង់ជីវភាពគ្រួសារ។
- ផ្តល់នូវទឹកផ្នែងសម្រាប់ទេសាទដូចបានឃើញខាងលើ។
- ការជួសជុលឡើងវិញនៃទេសភាពវប្បធម៌ ដែលអាចទាក់ទាញភ្ញៀវទេសចរមកទស្សនាឱ្យកាន់តែច្រើនធ្វើឱ្យប្រជាពលរដ្ឋក្នុងតំបន់នេះទទួលបានប្រាក់ចំណូលក្នុងការផ្គត់ផ្គង់ជីវភាពគ្រួសារ។
- អាចការពារនៅពេលដែលមានទឹកជំនន់ គឺអាចស្រូបយកផ្នែកដែលលើសបណ្តោះអាសន្ន ដើម្បីកុំឱ្យមានការលិចគ្រួស។



ក្រៅពីផលប្រយោជន៍ទាំងនេះ អាជ្ញាធរជាតិអប្សរាបានស្តារប្រព័ន្ធទឹកឡើងវិញដោយមានគោលគំនិតសំខាន់មួយទៀតគឺ បង្រៀនដល់សិស្សនិស្សិត និងអ្នកអភិរក្សជំនាន់ក្រោយៗ ឱ្យយល់ពីតួនាទីរបស់ទឹក ការគ្រប់គ្រងទឹកជាមួយប្រាសាទ និងសហគមន៍។




ប្រព័ន្ធស្រោចស្រពភូមិថ្មាសាធចារ្យ

សំណង់ប្រព័ន្ធស្រោចស្រពនេះ សាងសង់លើប្រឡាយរំដោះទឹកទៅស្រុកពួក ដែលបម្រើផលប្រយោជន៍ដល់ប្រជាពលរដ្ឋចំនួន៦ភូមិ គឺភូមិថ្មាសាធចារ្យ ភូមិគោកពោធិ៍ ភូមិល្បើក ភូមិពាម ភូមិតាស្នេហ៍ ឃុំជួនកែវ ស្រុកពួក និងភូមិគោកស្នោត សង្កាត់គោកឧកញ៉ា ក្រុងសៀមរាប អាចស្រោចស្រពលើផ្ទៃដីជាង១.០០០ហិកតាក្នុងរដូវប្រាំង និងជាង៦.០០០ហិកតាក្នុងរដូវវស្សា។

ក្នុងរដូវប្រាំងប្រព័ន្ធស្រោចស្រពនេះ ក្លាយជាប្រភពធនធានទឹកយ៉ាងសំខាន់សម្រាប់ឃុំជួនកែវ ដោយទឹកទាំងនោះអាចជួយឱ្យប្រជាពលរដ្ឋដាំដំណាំរួមផ្សំជាច្រើនដើម្បីលក់នៅទីផ្សារនានាក្នុងខេត្តសៀមរាប។

ប្រព័ន្ធស្រោចស្រពនេះមានទ្វារទឹកចំនួន៥កន្លែង រួមនឹងទំនប់អាងសង៊ាតប្រវែង១.៣០០ម៉ែត្រ កម្ពស់១,៩ម៉ែត្រ ដើម្បីលើកកម្ពស់ទឹកឱ្យបានត្រប់ត្រាន់សម្រាប់ការប្រើប្រាស់របស់ប្រជាពលរដ្ឋសហគមន៍។













សំណង់ទ្វារទឹកអូរកាកុះ






សំណង់បញ្ចូលទឹកបាកយណ៍ខាងលិច



សំណង់បញ្ជៀសទឹកជំនន់ចំនួនបួនសោម



ទ្វារទឹកបាកយណ៌ពេជាក




សំណង់ទ្វារទឹកអន្លង់ធ្នក

ប្រព័ន្ធស្រោចស្រពជៅភូមិគោកស្នាត

សំណង់ប្រព័ន្ធស្រោចស្រពនេះ សាងសង់លើប្រឡាយរំដោះទឹកទៅស្ទឹងពួក ដែលបង្កើនផលប្រយោជន៍ដល់ប្រជាពលរដ្ឋភូមិគោកស្នាត ភូមិគោកបេង ភូមិនគរក្រៅ សង្កាត់គោកចក ក្រុងសៀមរាប និងភូមិប្រាសាទចារ្យ ឃុំជួនកែវ ស្រុកពួក។

ប្រព័ន្ធស្រោចស្រពនេះក៏មានទ្វារទឹកចំនួន៣កន្លែង រួមនឹងការជួសជុលទំនប់ប្រវែង១៥០ម៉ែត្រ កម្ពស់១,៩ម៉ែត្រ ដើម្បីលើកកម្ពស់ទឹកឱ្យបានគ្រប់គ្រាន់សម្រាប់ការប្រើប្រាស់របស់ប្រជាពលរដ្ឋសហគមន៍។





សំណង់ទ្វារទឹក លូឆ្លុង លូម្ងូល

សំណង់ទាំងនេះ សម្រាប់រំដោះទឹកចេញពីភូមិភរម្អកស្រុកក្នុងរដូវវស្សា និងស្រោចស្រពក្នុងវិស័យកសិកម្ម ដែលស្ថិតលើផ្លូវ១១គម ក្នុងឃុំជួនកែវ ស្រុកពួកវ។










ទ្វារទឹកខំនប់អូរគោជាប់




ទ្វារទឹកលើផ្លូវដីសពីភូមិនគរក្រៅទៅសាលាឃុំជួនកែវ



ទ្វារទឹកស្ពឹងព្រះស្រុក


ទ្វារទឹកថ្មីកូមិឯព្រាក្មេង


ទ្វារទឹកអូរតោប្រាក់


ទ្វារទឹកកូមិស្ទឹង



ទ្វារទឹកខ្នោងទ្វារជើងឆ្នាំង



ទ្វារទឹកខ្នោងទ្វារខ្មោច



ទ្វារទឹកកសិឧស្សាហ៍កម្មរំដេះ



ទ្វារទឹកខ្នាតធំទ្វារតាកាវ



ទ្វារទឹកបូលខនេះស្ពួត



ទ្វារទឹកខាងលើជិតប្រាសាទព្រះខ័ន




ទ្វារទឹកកសិន្ទុក្រាសាទអង្គវត្ត




សំណង់បង្ហូរទឹកឃុំជួនកៅ



អាងហ្លោះស្បាប់កសិន្ទុក្រាសាទអង្គវត្ត


សំណង់បង្ហៀរទឹកភូមិប្រាសាទបាវ


ទ្វារទឹកភូមិបង្គោល


ទ្វារទឹកភូមិល្បើក





ស្ពានស្ថិតព្រះស្រុក ស្ថិតក្នុងភូមិស្ថិតព្រះស្រុក ឃុំល្វា ស្រុកពួក ចុះទៅវាលបឹងទន្លេសាប ប្រវែង ៦០០០ម៉ែត្រ ដើម្បីការពារទឹកជំនន់កុំឱ្យលិចទីរួមស្រុកពួក និងឃុំល្វា ដែលមានចភូមិ នៅតាមបណ្តោយប្រឡាយបុកណដែលបញ្ចៀសទឹកជំនន់ពីស្ថិតសៀមកប។





ស្ពានប្រឡាយអូរដំរីស្ងាប់ និងអូរលុះ ដើម្បីទាញយកទឹកជំនន់ពីស្ថិតសៀមកបទៅស្ថិតពួក និងស្ថិតព្រះស្រុក ការពារកុំឱ្យទឹកជន់ក្នុងតំបន់អង្គរ និងក្រុងសៀមកប ព្រមទាំងទីរួមស្រុកពួកផងដែរ។





ស្ពានប្រឡាយបុកណ និងអូរកា ស្ថិតក្នុងភូមិនគរក្រៅ សង្កាត់គោកចក ក្រុងសៀមកប ដើម្បីទាញយកទឹកពីស្ថិតសៀមកបតាមរយៈអូរខ្នុត ចូលទៅបាយណ៍ខាងលិច និងស្ថិតពួកតាមអូរដំរីស្ងាប់ ប្រវែងពាក់ខ្លួម៉ែត្រ។





ស្ពានប្រឡាយអូរខ្ទួត ស្ថិតក្នុងភូមិនគរក្រៅ សង្កាត់គោកឧកញ៉ា ក្រុងសៀមរាប រហូតដល់ភូមិរហាល ឃុំជួនកែវ ស្រុកពួក ប្រវែង ១៣គីឡូម៉ែត្រ ដើម្បីទាញយកទឹកជំនន់ពីស្ទឹងសៀមរាបទៅស្ទឹងពួក និងស្ទឹងព្រះស្រុក ការពារកុំឱ្យទឹកជន់ក្នុងតំបន់អន្លង់ និងក្រុងសៀមរាប។





ទំនប់សង់ខាងប្រឡាយអូរខ្ទួតប្រវែង៦៦០០ម៉ែត្រស្ថិតក្នុងភូមិប្រាសាទចារ្យ ឃុំជួនកែវ ស្រុកពួកដើម្បីលើកកម្ពស់ទឹកក្នុងប្រឡាយសម្រាប់បញ្ជូលស្រែប្រជាកសិករ។





ស្ពានប្រឡាយប្រវែង៩០០០ម៉ែត្រ របស់ប្រព័ន្ធស្រោចស្រពបាកយណ៍ខាងលិច ក្នុងគោលបំណងបង្កើនប្រសិទ្ធភាពផ្គត់ផ្គង់ទឹកជូនប្រជាកសិករសម្រាប់បង្កបង្កើនផល។



ទិដ្ឋភាពពីលើវត្តថ្មីព្រះសីហនុ

អភិវឌ្ឍន៍ប្រកបដោយចីរភាព

ការថែរក្សាធនធានព្រៃឈើ

ព្រៃឈើជាធាតុមួយដែលមិនអាចខ្វះបានទិដ្ឋភាពយ៉ាងសំខាន់ក្នុងការលើកកម្ពស់តម្លៃជាសកលនៃរមណីយដ្ឋានអង្គរ ពោលគឺព្រៃឈើបានរួមត្រជាប់បញ្ចូលគ្នាជាមួយប្រាង្គប្រាសាទនិងសហគមន៍មនុស្សក្បាយជាអត្តសញ្ញាណកំណត់សម្គាល់នៃរមណីយដ្ឋានអង្គរ។ តាមការសង្កេតនៅឆ្នាំ២០០៦ ព្រៃឈើក្នុងរមណីយដ្ឋានអង្គរមានទំហំតែ៤៩៨ហិកតាតែប៉ុណ្ណោះ ប៉ុន្តែដោយមានការយកចិត្តទុកដាក់ក្នុងការថែទាំនិងជាំជុះជាបន្តបន្ទាប់របស់អាជ្ញាធរជាតិអប្សរា ព្រៃឈើបានកើនឡើងចំនួន១,៨៦០ហិកតានៅឆ្នាំ២០១៦ ស្មើនឹង ៦៥០ហិកតា។

ព្រៃឈើក្នុងតំបន់រមណីយដ្ឋានអង្គរមានដើមឈើជាង៦០០ប្រភេទ។ ព្រៃឈើទាំងនេះមានដុះពាយប៉ាយគ្របទឹកដែន បង្កើតបានជាទេសភាពបៃតងដ៏មានសោភ័ណភាព និងបានក្លាយជាចំណុចទាក់ទាញយ៉ាងខ្លាំងសម្រាប់ភ្ញៀវទេសចរជាតិនិងអន្តរជាតិ។ លើសពីនេះទៀត ព្រៃឈើក៏បានបំពេញការកិច្ចផ្សេងៗទៀតក្នុងការងារអភិរក្សនិងអភិវឌ្ឍន៍ប្រកបដោយចីរភាពរមណីយដ្ឋានអង្គរនោះគឺជារបាំងខ្យល់ជួយទប់ការសឹករលាយនៃថ្មតាមរយៈការរក្សាបាននូវសំណើម ឬកម្តៅថ្មឱ្យស្ថិតក្នុងស្ថានភាពមួយប្រសើរជារបាំងនៃការទប់ការហូរច្រោះនៃទឹកភ្លៀង ជាប្រភពចំណូលរបស់អ្នកស្រុកអង្គរ និងជាជម្រកសត្វព្រៃច្រើនប្រភេទ។





ការបណ្តុះកូនឈើ

ការបណ្តុះកូនឈើសម្រាប់ដាំឡើងវិញ ជាការកិច្ចដ៏ចម្បងដែលអាជ្ញាធរជាតិអប្សរាកំពុងតែអនុវត្តជារៀងរាល់ឆ្នាំៗ កូនឈើជាង ១,២២៦,០០០ដើម ត្រូវបានបណ្តុះនិងបានចែកចាយដល់គ្រប់តម្រូវការសម្រាប់ដាំឡើងវិញ ទាំងក្នុងនិងក្រៅរមណីយដ្ឋានអង្គរ។







ក្នុងមួយឆ្នាំៗ អាជ្ញាធរជាតិអប្សរាបានរៀបចំផែនការបណ្តុះកូនឈើមានចំនួន៧៦,០០០ដើម នៅតាមស្ថានីយ៍បណ្តុះកូនឈើចំនួនបីគឺ៖

១. ស្ថានីយ៍បណ្តុះកូនឈើប្រាសាទតាកែវ មានបណ្តុះពូជឈើជួចជា ដើមតគឹរ ដើមឈើទាល ដើមត្រសេក ដើមអង្កាញ់ ដើមកកោះ ដើមផ្លៀកៗ

២. ស្ថានីយ៍បណ្តុះកូនឈើមណ្ឌលបី មានបណ្តុះពូជឈើហូបផ្លែជួចជា ម៉ាក់ច្រាផ្ត សិរមោន់ ក្បៀវ វល្លិតុយ និងពូជឈើលម្ហជួចជា ត្របែកព្រៃ លៀងរាជ ក្រោកដំ ក្រោកតួច រំដួល អំពិលបាក់ង កន្ទុំថេតៗ

៣. ស្ថានីយ៍បណ្តុះកូនឈើ០៨ហិកតា មានប្រភេទឈើប្រណិតជួចជា ត្រញ៉ង់ នាងនួន បេង ជ្លង់ ច្រេសៗ





ការដាំដើមឈើឡើងវិញ

ក្នុងមួយឆ្នាំៗ អាជ្ញាធរជាតិអប្សរាបានដាំកូនឈើលើផ្ទៃដីទំនេរ ក្នុងរមណីយដ្ឋានអង្គរបានប្រមាណជាង ៦០ ០០០ ដើម និងបានចែកចាយកូនឈើដល់សាធារណជនគ្រប់ទិសទីប្រមាណជាង ១០០ ០០០ ដើម ។ បើគិតតាំងពីឆ្នាំ២០០៤មក អាជ្ញាធរជាតិអប្សរា បានដាំដើមឈើបន្ថែមសរុបជាង ៦ ០០០ ០០០ ដើមមកហើយក្នុងតំបន់រមណីយដ្ឋានអង្គរក្នុងគោលបំណងសំខាន់គឺដើម្បីឱ្យរមណីយដ្ឋានអង្គរមានភាពបៃតង និងបំផុសស្មារតីប្រជាពលរដ្ឋឱ្យស្រឡាញ់ និងការពារបរិស្ថាន ។









ការគ្រប់គ្រងហានិភ័យដើមឈើក្នុងរមណីយដ្ឋានអង្គរ

ក្រុមការងារអាជ្ញាធរជាតិអប្សរា បានកាត់ដកហូតដើមឈើ កាត់ក្រឹមែកឈើដែលមានហានិភ័យខ្ពស់ ដើមឈើរលំដួល កាត់ក្រឹមែកឈើជាប់និងរស់ ដើម្បីធានាដល់សុវត្ថិភាពភ្ញៀវទេសចរ សាធារណជន ក៏ដូចជាដើម្បីលើកកម្ពស់សោភ័ណភាពនៅតាមដងផ្លូវ និងនៅតាមបរិវេណប្រាសាទក្នុងរមណីយដ្ឋានអង្គរ និងតំបន់ដែលគ្រប់គ្រងដោយអាជ្ញាធរជាតិអប្សរាជាប្រចាំ។ មុននឹងចុះអនុវត្តសកម្មភាពកាត់ដកហូត កាត់ក្រឹមែកឈើជាប់និងរស់ អាជ្ញាធរជាតិអប្សរាតែងតែជូនដំណឹងដល់ស្ថាប័នសមត្ថកិច្ចពាក់ព័ន្ធ ភ្ញៀវជាតិ-អន្តរជាតិ មគ្គុទ្ទេសក៍ទេសចរណ៍ ព្រមទាំងសាធារណជនទាំងអស់ជ្រាបជាព័ត៌មានជាមុន។

ការងារទាំងនេះគឺធ្វើតាមតំបន់ប្រាសាទ ក្នុងភូមិ សាលារៀន និងតាមតំបន់ផ្សេងៗដែលស្ថិតនៅក្នុងរមណីយដ្ឋានអង្គរ ក្នុងនោះរួមមាន កសិន្នអង្គរវត្ត ប្រាសាទព្រះខ័ន ប្រាសាទបាយ័ន ប្រាសាទបាភួន ខ្នោងទ្វារជើងឆ្នាំង ខ្នោងទ្វារទន្លេអ៊ុំ ប្រាសាទតាព្រហ្ម ប្រាសាទក្នុងបាឆៃង កំពែងអង្គរធំ និងកំពែងប្រាសាទអង្គរវត្តជាដើម។ល។





សកម្មភាពកាត់ស្មៅនិងដំណាលដើមឈើតាល
មានអាយុកាលជាង១០០ឆ្នាំជាប់ប្រាសាទបាយ័ន្ត

ការព្យាបាលជំងឺដើមឈើ

ដើមឈើបានធ្វើឱ្យរមណីយដ្ឋានអង្គរមានសោភ័ណភាពស្រស់ស្អាត និងជារនាំងការពារប្រាសាទផងដែរ ប៉ុន្តែដោយសារកត្តាធម្មជាតិនិងមនុស្ស បានធ្វើឱ្យដើមឈើធំៗខ្លះមានជំងឺដែលចាំបាច់ត្រូវព្យាបាលឱ្យទាន់ពេលវេលា ដើម្បីឱ្យដើមឈើលូតលាស់ល្អ មានសុខភាពរឹងមាំឡើងវិញ។ ដើមឈើក៏ដូចមនុស្សដែរ វាត្រូវការអុកស៊ីសែន ការសម្រាក ចំណីអាហារ ទឹក និងការព្យាបាលដូចគ្នា។

ជំងឺដែលតែងតែកើតមានលើដើមឈើ បណ្តាលពីកត្តាដូចជា៖

- របួសដោយការកាប់ ចាំង ជំនែកគោល ឬសរសៃអក្សរពីលើដែលធ្វើឱ្យទ្វេដមរោគ។
- ជំពៅដែលបង្កឡើងដោយផ្សិត ការពុកឆ្អូដើមឈើ និងពុកគល់ ។
- ដើមឈើដែលជំពៅឬសដោយសកម្មភាពមនុស្សជាន់ពីលើជារឿងកាល់ថ្លែឬមានវត្ថុធ្ងន់ៗសង្កត់លើ។
- ដើមឈើជំពៅគល់ដោយការចោះយកជ័រ។
- ដើមឈើដែលមានក្រណាត់រុំជុំវិញដើម។

ជំងឺទាំងនេះបង្កឡើងដោយការចាក់ដីហាប់ណែន ចាក់បេតុងពីលើ ឬចាក់ដីលុបគល់ដែលមានជម្រៅក្រៅ និងការដោត់ពន្ធឺក្តើងអគ្គិសនីខ្លាំងជិតដើមឈើជារឿងកាល់ថ្លែ ដែលបង្កផលប៉ះពាល់ដល់ជំណែករបស់ដើមឈើ។


























វិធីសាស្ត្រក្នុងការព្យាបាល ត្រូវអនុវត្តទៅតាមប្រភេទជំងឺផ្សេងៗ ដូចជា៖

- ចំពោះឈើដែលពុកគល់ឬដើម ត្រូវកោសនិងលាងសម្អាតសាច់ឈើពុកឬដុះផ្សិតឱ្យស្អាត បន្ទាប់មកបាញ់ឬលាបជ័រទឹកទៅលើផ្ទៃដែលបានសម្អាតហើយនោះ។
- ជំងឺខ្ទុះ ត្រូវបិទប្រហោងតូចៗដោយប្រើល្បាយដីដំបូកឬក្រមួន ហើយត្រូវជ្រើចផ្លូវបង្ហូរទឹកនិងជ័រចេញផង។
- ចំណែកដើមឈើខ្ទុះខៀត ដែលមានឫសធំៗចេញផុតពីដី ជាពិសេសក្នុងតំបន់ប្រាសាទដែលមានក្បៀវទស្សនាច្រើនដើរកាត់ អង្គុយពីលើ ហើយបង្កឱ្យមានជំងឺនោះត្រូវជ្រើតម្រាលឈើ ឬជណ្តើរឈើកុំឱ្យមនុស្សឈរ ឬដើរពីលើតទៅទៀត។
- ចំណែកជំងឺពុស្តសវិញ ត្រូវព្យាបាលដោយយកពន្ធឹអគ្គិសនីចេញឬបន្តយពន្ធឹឱ្យមកនៅកម្រិតទាប។
- ឈូសឆាយជ្រើឱ្យដីជូរឬតាស់យកសត្វដងចេញជាក់ដី ដាំស្មៅពីលើ ។ល។ កាប់រណ្តៅជុំវិញគល់ឈើ ស្រោចទឹកជាក់ដី។

គួរបញ្ជាក់ផងដែរថា បច្ចេកវិទ្យាដ៏វិសេសនេះត្រូវបានបង្ហាត់បង្រៀនដោយអ្នកជំនាញមកពីប្រទេសឥណ្ឌា ។

គម្រោងដោះលែងសត្វព្រៃក្នុងឧទ្យានអង្គរ

រមណីយដ្ឋានអង្គរក្រៅពីមានប្រាង្គប្រាសាទដ៏មហាអស្ចារ្យ ក៏មានព្រៃជាដែនជម្រកសត្វព្រៃដ៏មានសុវត្ថិភាពក្រោមកិច្ចសហការរវាង អាជ្ញាធរជាតិអប្សរា រដ្ឋបាលព្រៃឈើភ្នំពេញ និងអង្គការ Wildlife Alliance បានដោះលែងសត្វចូលក្នុងព្រៃធម្មជាតិនៃឧទ្យានអង្គរវត្តឯជា សត្វទោទមកុជចំនួន១៥ក្បាល(កើតកូនបានចំនួន៣ក្បាល) សត្វឈ្លូសចំនួន៥ក្បាល សត្វស្វាព្រាមចំនួន១៦ក្បាល សត្វសំពោចក្រអូបចំនួន៥ក្បាល សត្វកេចំនួន៥ក្បាល សត្វថ្មាដា១គូ កេងកងតូច៦ក្បាល កេងកងធំ៦ក្បាល ព្រាំង៤ក្បាល ក្អែក៨ក្បាល និងប្រភេទសត្វមួយចំនួនទៀត។





















ការរៀបចំសោភ័ណភាពខាងមុខច្រាសាទអង្គរវត្ត











អង្គភាពប្រព័ន្ធគ្រប់គ្រងបរិស្ថានអង្គរ

នៅថ្ងៃទី៦៣ ខែធ្នូ ឆ្នាំ២០០៣ អាជ្ញាធរជាតិអប្សរាបានចុះអនុស្សរណៈយោគយល់គ្នាស្តីពីការបង្កើតប្រព័ន្ធគ្រប់គ្រងបរិស្ថាន ជាមួយស្ថាប័នជប៉ុនចំនួន៤ រួមមាន៖

- JQA (Japan Quality Assurance Organization)
- Sophia University
- ISRI (International Standard Research Institute)
- JQAI (Japan Quality Assurance Institute)

ក្នុងគោលបំណងពន្យល់បកស្រាយស្តង់ដារអន្តរជាតិ ISO 14001 ហ៊ឹកហឺនអ្នកជំនាញការងារបរិស្ថានប្រចាំនាយកដ្ឋានទីមួយៗនិងបណ្តុះបណ្តាលសាខាការផ្ទៃក្នុង។










ក្នុងរយៈពេលចាប់ផ្តើម ក្រុមការងារបរិស្ថានអង្គរ ក្រោមការបង្ហាត់បង្ហាញបច្ចេកទេសពីស្ថាប័នជប៉ុនចម្រុះចាំង៤ ក៏បានរៀបចំប្រព័ន្ធគ្រប់គ្រងបរិស្ថានអង្គរ ដែលអនុលោមតាមស្តង់ដារអន្តរជាតិ ISO 14001។ លក្ខណៈពិសេសនៃប្រព័ន្ធស្តង់ដារនេះ (P:Plan, D:Do, C:Check, A:Act) គឺតម្រូវឱ្យបុគ្គលិកបច្ចេកទេសអាជ្ញាធរជាតិអប្សរា នៅតាមនាយកដ្ឋានទីមួយៗចេះបង្កើតចរន្តការងារល្អាស់លាស់ ពោលគឺចេះរៀបចំផែនការអនុវត្ត (Plan) យកផែនការមកអនុវត្ត ដោយមានវិធីអនុវត្តការងារល្អាស់លាស់ ចេះធ្វើការជាក្រុម (Do) ចេះត្រួតពិនិត្យវាយតម្លៃផ្ទៀងផ្ទាត់លទ្ធផលជាក់ស្តែងទៅនឹងផែនការដែលបានត្រាងទុក (Check) បើក្នុងករណីលទ្ធផលមិនដូចតាមផែនការ គឺអាចចេះរកវិធានការកែតម្រូវឬបង្ការខុតជាមុននូវកំហុសឆ្គងជាលើកទី២ ថែមទាំងចេះរកវិធីដោះស្រាយប្រព័ន្ធការងារឱ្យមានភាពប្រសើរជាប្រចាំ (Act)។



ISO 14001
Management System Certificate
វិញ្ញាបនប័ត្រប្រព័ន្ធគ្រប់គ្រងបរិស្ថាន

JQA-EM5246

អាជ្ញាធរអប្សរា

ISO 14001 :2015 / JIS Q 14001 :2015

JAPAN QUALITY ASSURANCE ORGANIZATION

JQA



ISO 14001
Appendix
ឧបសម្ព័ន្ធ

JQA-EM5246 1 / 1

អាជ្ញាធរអប្សរា

JAPAN QUALITY ASSURANCE ORGANIZATION


JQA

ចាប់ពីឆ្នាំ២០០៦មក អាជ្ញាធរជាតិអប្សរាបានទទួលវិញ្ញាបនបត្រស្តង់ដារ ISO 14001:2004 ចំនួន៤លើក។ ក្នុងនោះ លើកទី១ ឆ្នាំ២០០៦ ដោយមានស្ថាប័នជប៉ុនចាំដណ្តើមតែ៤ខែ បន្តជួយជាបច្ចេកទេសដើម្បីជំរុញការងារប្រព័ន្ធគ្រប់គ្រងបរិស្ថានឱ្យដំណើរការជាប្រក្រតី។ លើកទី៦ឆ្នាំ២០០៩ លើកទី៧ ឆ្នាំ២០១២ និងលើកទី៨ ឆ្នាំ២០១៥ តាមរយៈការវាយតម្លៃនិងផ្តល់វិញ្ញាបនបត្រដោយស្ថាប័ន JQA ។

ទៅឆ្នាំ២០១៧ អង្គភាពប្រព័ន្ធគ្រប់គ្រងបរិស្ថានអង្គរ បានរៀបចំចងក្រងសៀវភៅប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងបរិស្ថានថ្មី អនុលោមតាមស្តង់ដារថ្មី ISO 14001:2015។ សៀវភៅប្រើប្រាស់នេះមានប្រមាណជា១០០ទំព័រ ដែលរួមមានៈ គោលការណ៍ណែនាំទូទៅ វិធីបង្កើតផែនការ វិធីអនុវត្តវិធីវាយតម្លៃ និងវិធីសាស្ត្រកែលម្អ។ សៀវភៅប្រើប្រាស់នេះ ត្រូវបានយកមកអនុវត្តក្នុងក្របខណ្ឌការងារអាជ្ញាធរជាតិអប្សរាទៅដើមខែសីហា ឆ្នាំ២០១៧តែម្តង។

នៅឆ្នាំ២០១៨ អាជ្ញាធរជាតិអប្សរា បានទទួលវិញ្ញាបនបត្រស្តង់ដារ ISO ជាលើកទី៥ និងលើកទី៦ នៅឆ្នាំ២០២១។ វិញ្ញាបនបត្រលើកទី៥ និងទី៦នេះ មានលក្ខណៈពិសេស ដោយមានការផ្ទាស់ប្តូរស្តង់ដារថ្មីពី ស្តង់ដារ ISO14001:2004 មកជា ស្តង់ដារ ISO14001:2015 វិញ។

ស្ថាប័ន JQA ជប៉ុន តែងតែចុះធ្វើ សវនកម្មប្រព័ន្ធគ្រប់គ្រងបរិស្ថាន របស់អាជ្ញាធរជាតិអប្សរាជារៀងរាល់ ឆ្នាំ ដើម្បីបញ្ជាក់នូវភាពអនុលោម ជាប្រចាំថ្ងៃនៃប្រព័ន្ធគ្រប់គ្រងបរិស្ថាន នៅក្នុងរយៈពេលនៃសុពលភាព ៣ឆ្នាំ។



គោលនយោបាយបរិស្ថានរបស់អាជ្ញាធរអប្សរា

ឧទ្យានៈបរិស្ថាន

តំបន់អង្គរៈសៀមរាប គឺជាចីតាំងនៃក្រុមប្រាសាទសិលា-និទ្ទេស នៃប្រទេសជាតិយើង និងជាបេតិកភណ្ឌប្លែកមិនពិភពលោក ហើយក៏ជាតំបន់ដែលរក្សានូវទំនៀមទម្លាប់ថ្លាល់របស់អ្នកស្រុក ព្រមទាំងជាតំបន់ដែលគ្របដណ្តប់ដោយព្រៃព្រឹក្សាស្ទឹង បឹងបួ សម្បត្តិធម្មជាតិដ៏ល្អប្រណិត។

យើងខ្ញុំ *-អាជ្ញាធរដើម្បីការការពារតំបន់អង្គរ និងរៀបចំតំបន់អង្គរ-* ហៅថា *-អាជ្ញាធរអប្សរា-* ដែលជាគ្រឹះស្ថានសាធារណៈដ៏ថាល ទទួលបន្ទុកគ្រប់គ្រងតំបន់អង្គរ ឃ្លាំមើលដំណើរការស្តារបានសង្គមមួយ ឈរលើមូលដ្ឋានអភិវឌ្ឍន៍ សិចច្នាក់ព្នាវាង *-ធម្មជាតិ ប្រាសាទ និងអ្នកស្រុក-* ពោលគឺវាង *-បរិស្ថាន វប្បធម៌ និងសេដ្ឋកិច្ច-* ដើម្បីជានានូវការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព សម្រាប់អ្នកជំនាន់ក្រោយ តាមរយៈសកម្មភាពជួសជុលថែរក្សាប្រាសាទ និងសកម្មភាពអភិវឌ្ឍន៍តំបន់ ដោយសហការជិតស្និទ្ធជាមួយ ស្ថាប័នជាតិ-អន្តរជាតិ អាជ្ញាធរពាក់ព័ន្ធនានា និងជាមួយប្រជាជនក្នុងតំបន់ទាំងមូល។

គោលនយោបាយបរិស្ថាន

១. ជំរុញនិងលើកកម្ពស់ការថែរក្សាបរិស្ថានដោយផ្តែកទៅលើឧទ្យានៈខាងលើ

យើងខ្ញុំនឹងខិតខំខ្លះខ្ជែងបង្ការផលប៉ះពាល់ទៅលើបរិស្ថាន តាមរយៈការអនុវត្តន៍យ៉ាងសកម្មនូវវិធានការថែរក្សាបរិស្ថានតំបន់ ឱ្យស្របទៅតាមកំណើនភ្ញៀវទេសចរណ៍ និងការកើនឡើងក្នុងរដូវទេសចរណ៍។

២. ចូលរួមធ្វើសកម្មភាពថែរក្សាបរិស្ថានទាំងអស់គ្នាឆ្ពោះទៅលើ

- ការរៀបចំទីតាំងអង្គរ ឱ្យបានស្អាតល្អ និងបង្កើតប្រព័ន្ធគ្រប់គ្រងសំរាមមួយ ដើម្បីកាត់បន្ថយសំរាម
- ការសម្អាត និងថែរក្សា ទឹកស្ទឹង បឹងបួ បាយណ៍ កសិឧស្សាហកម្ម នៅក្នុងតំបន់ឱ្យបានប្រសើរឡើងវិញ
- ការលើកកម្ពស់ការការពារជាតុអាកាសឱ្យបានល្អជាប្រចាំ
- ការលើកកម្ពស់ការការពារព្រៃឈើ-សម្បត្តិធម្មជាតិដ៏មានតម្លៃនៅក្នុងតំបន់ឱ្យបានគង់វង្ស

៣. ធ្វើការអប់រំផ្សព្វផ្សាយអំពីបរិស្ថានចំពោះប្រជាជនក្នុងតំបន់

យើងខ្ញុំនឹងធ្វើការអប់រំផ្សព្វផ្សាយអំពីបរិស្ថានចំពោះប្រជាជនក្នុងតំបន់ ក៏ដូចជាចំពោះបុគ្គលិករបស់ខ្លួនដែរ ដើម្បីបង្កើនចំណេះ និងការយល់ដឹងនូវសារៈសំខាន់នៃការថែរក្សាបរិស្ថានក្នុងតំបន់។

៤. គោរពច្បាប់បច្ចុប្បន្ន និងតម្រូវការនានានៃទៀតផ្នែកបរិស្ថាន

យើងគោរពច្បាប់បច្ចុប្បន្ន ព្រមទាំងការសន្យាទាំងឡាយរបស់ខ្លួនដែលពាក់ព័ន្ធនឹងបរិស្ថាន ហើយជួយណែនាំប្រជាជនក្នុងតំបន់ឱ្យគោរពច្បាប់បច្ចុប្បន្ន និងវិធានការទាំងនេះ។

៥. ជំរុញឱ្យមានការកែលម្អប្រសិទ្ធិភាពជាប្រចាំ

យើងខ្ញុំនឹងស្វែងយល់នូវផលប៉ះពាល់ទៅលើបរិស្ថាន ដែលវាគឺសកម្មភាព និងចេញពីវិធានការការងារបស់ខ្លួនឯង ហើយយើងខ្ញុំនឹងរៀបចំប្រព័ន្ធគ្រប់គ្រងបរិស្ថានមួយ ដោយកំណត់យ៉ាងជាក់លាក់នូវគោលបំណង គោលដៅ និងផែនការគោរពបរិស្ថាន ដោយពិនិត្យឡើងវិញជាប្រចាំ ដើម្បីធ្វើឱ្យមានភាពប្រសើរជានិច្ច ជានាទទួលបានឡើងវិញនូវបណ្ណ ISO14001 ហើយគឺជាកត្តាសំខាន់មួយក្នុងចំណោមកត្តាទាំងឡាយ ដែលនាំទៅដល់ឧទ្យានអង្គរទទួលស្គាល់ដោយសកលលោកថាជាតំបន់ដ៏មួយក្នុងចំណោមតំបន់ទេសចរណ៍។

៦. គោលនយោបាយបរិស្ថាននេះ គឺបម្រុងផ្សព្វផ្សាយឱ្យបានទូលំទូលាយទៅគ្រប់មុខតំណែងអាជ្ញាធរអប្សរាទាំងអស់ គឺនឹងមិនចំណាយសោះ។

ថ្ងៃ សុក្រ ១០រោច ខែមាឃ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
សៀមរាប, ថ្ងៃទី ០១ ខែ មីនា ឆ្នាំ២០១៩

អគ្គនាយកអាជ្ញាធរអប្សរា

ហាន់ រៅ



សវនកម្មប្រព័ន្ធគ្រប់គ្រងបរិស្ថានអង្គរ

ការធ្វើសវនកម្ម ត្រូវយកចិត្តទុកដាក់ទៅលើ៥ចំណុចៈ

- *ទី១ ប្រសិទ្ធភាពនៃប្រព័ន្ធគ្រប់គ្រងបរិស្ថានទាំងមូលធ្វើយ តបនឹងសភាពការប្រែប្រួលផ្ទៃក្រៅនិងផ្ទៃក្នុង។*
- *ទី២ ភាពទាក់ទងគ្នាជាប្រចាំ ព្រមទាំងលក្ខណៈអាចអនុវត្ត បាននៃប្រព័ន្ធគ្រប់គ្រងបរិស្ថានធ្វើយតបនឹងវិសាលភាព នៃវិញ្ញាបនបត្រ។*
- *ទី៣ ប្រសិទ្ធភាពនៃប្រព័ន្ធគ្រប់គ្រងបរិស្ថាន ព្រមជាមួយការ ចាត់ចែងបន្តការកែលម្អ។*
- *ទី៤ អំណោយផលនៃការអនុវត្តប្រព័ន្ធគ្រប់គ្រងទៅលើ ការសម្រេចគោលនយោបាយបរិស្ថាន និងគោលដៅ បរិស្ថានរបស់ស្ថាប័ន។*
- *ទី៥ ពិនិត្យអំពីស្ថានភាពកែលម្អជាប្រចាំតាមរយៈការបង្វិល កង់ PDCA (Plan, Do, Check, Act)។*

ការធ្វើសវនកម្មម្តង។ តែងមានការចូលរួមនិងយកចិត្តទុកដាក់ពី មន្ត្រីជំនាញដែលជាសេនាធិការតាមនាយកដ្ឋាននីមួយៗរបស់ អាជ្ញាធរជាតិអប្សរា ដែលធ្វើឱ្យការងារនេះទទួលបានលទ្ធផលល្អ។







អភិវឌ្ឍប្រកបដោយចីរភាព

ហេដ្ឋារចនាសម្ព័ន្ធ

ដោយពិនិត្យឃើញភាពចាំបាច់និងតម្រូវការប្រើប្រាស់ប្រចាំថ្ងៃរបស់បងប្អូនប្រជាពលរដ្ឋ អាជ្ញាធរជាតិអប្សរាបានកសាងផ្លូវថ្នល់ ស្ពាន លូទឹក ប្រឡាយទឹក តូចធំជាច្រើនកន្លែង។ ក៏ហេដ្ឋារចនាសម្ព័ន្ធរូបវន្តបានបង្កើតជាឱកាសដ៏ល្អប្រសើរសម្រាប់ប្រជាពលរដ្ឋក្នុងតំបន់រមណីយដ្ឋានអង្គរ ដើម្បីទទួលផលប្រយោជន៍ពីការរីកចម្រើននៃវិស័យទេសចរណ៍ ហើយអាចធ្វើដំណើរនិងការប្រាស្រ័យទាក់ទងរវាងសហគមន៍ ប្រជាពលរដ្ឋកាន់តែល្អប្រសើរ ដែលកត្តាទាំងនោះបាននាំមកនូវលទ្ធភាពជាច្រើនជូនប្រជាពលរដ្ឋអាចស្វែងរកឱកាសក្នុងការពង្រីកមុខរបរ និងជំនួញដោយសមរម្យព្រមទាំងអាចដឹកជញ្ជូនផលិតផលកសិកម្មជម្មជាតិ សិប្បកម្មរបស់ខ្លួនមកផ្គត់ផ្គង់ទីផ្សារ។



ព្រះលានជល់ដំរី ក្រុងអង្គរធំ


មុនកែលម្អ

រូបភាពមុន និងក្រោយ
ការកែលម្អបរិវេណមុខ
ព្រះលានដល់ជិត
ក្រុងអង្គរធំ


មុនកែលម្អ



ក្រោយកែលម្អ



ក្រោយកែលម្អ

ជាប្រភេទផ្លូវក្រោះ ដោយមានរៀបចំសួនច្បារនិងប្រឡាយទឹកអមសងខាងផ្លូវ សាងសង់នៅក្នុងឆ្នាំ២០០៦លាតសន្ធឹងពីត្បូងទៅជើងចំណុចផ្លូវជាតិលេខ៦ (ខាងកើតផ្សារលើ) មកទល់នឹងផ្លូវវង់តូចចូលរមណីយដ្ឋានអង្គរ និងពីលិចមកកើតត្រង់ចំណុចមុខមន្ទីរពេទ្យគន្ធបុប្ផាមកទល់នឹងផ្លូវបត់ចូលភូមិបន្ទាយ។







ផ្លូវនេះមានសារៈសំខាន់យ៉ាងខ្លាំងក្នុងការបញ្ជៀសការកកស្ទះចិត្តគ្រោះថ្នាក់ចរាចរណ៍នៅតាមដងផ្លូវជាតិលេខ៦ ជាពិសេសនោះគឺបានជួយកាត់បន្ថយពេលវេលាក្នុងការធ្វើដំណើរពីទីក្រុងសៀមរាបមកស្រុកប្រាសាទបាគងចិត្តស្រុកបន្ទាយស្រី។



















គម្រោងកែលម្អហេដ្ឋារចនាសម្ព័ន្ធផ្លូវរវាងជំ-រវាងតូច៖

- ការងារកែលម្អផ្លូវពីខាងជើងកសិទ្ធអង្គរទៅដល់ផ្លូវជុំវិញប្រាសាទបាយ័ន ជាប្រភេទផ្លូវ DBST ប្រវែង៣៣៩០ម៉ែត្រ ទទឹង៩ម៉ែត្រ
- ការងារកែលម្អផ្លូវជុំវិញប្រាសាទបាយ័ន (G) ប្រវែង១,០៦៤ម៉ែត្រ ទទឹង ម៉ែត្រ ដោយគ្រាន់តែអ៊ិតបេតុងកៅស៊ូ AC ពីលើផ្លូវមានស្រាប់ DBST
- ការងារកែលម្អផ្លូវ (G-H) ប្រវែង១,៦៦៧ម៉ែត្រ ទទឹង៦ម៉ែត្រ ជាប្រភេទអ៊ិតបេតុងកៅស៊ូ AC ភ្ជាប់ពីខាងជើងប្រាសាទបាយ័នដោយវាងព្រះលានដល់ដំរីទៅដល់ខ្នោងទ្វារដែផ្នាំង
- កែលម្អផ្លូវរវាងជំ ប្រវែង១៣,៣៣៦ម៉ែត្រ ទទឹង៦-៩ម៉ែត្រ ជាប្រភេទអ៊ិតបេតុងកៅស៊ូ AC
- កែលម្អផ្លូវរវាងតូច ប្រវែង៧,០៩៩ម៉ែត្រ ទទឹង៦ម៉ែត្រ ជាប្រភេទអ៊ិតបេតុងកៅស៊ូ AC ពីលើផ្លូវមានស្រាប់ DBST
- ការងារកែលម្អផ្លូវប្រវែង៩៣៦៩ម៉ែត្រ ទទឹង៩-៩ម៉ែត្រ ចាប់ពីជ្រុងកសិទ្ធខាងលិចឆៀងខាងស្ទូងរហូតដល់ស្រះស្រង ជាប្រភេទអ៊ិតបេតុងកៅស៊ូ AC ពីលើផ្លូវមានស្រាប់ DBST
- ការងារកែលម្អផ្លូវវាងមុខប្រាសាទអង្គរវត្ត ប្រវែង១៦៦៧ម៉ែត្រ ទទឹង៩ម៉ែត្រ ជាប្រភេទផ្លូវ DBST
- ការងារកែលម្អផ្លូវចាប់ពី វិថីព្រះនភគ្គមសីហមុនី អតីតផ្លូវក្ងម៉ែត្រចំណុចត្រួតពិនិត្យសំបុត្រ ដល់ចំណតរថយន្តខាងមុខប្រាសាទអង្គរវត្ត ប្រវែង១០៩៩ម៉ែត្រ ជាប្រភេទអ៊ិតបេតុងកៅស៊ូ (AC) ទទឹង ៦ម៉ែត្រ និងទទឹង៩ម៉ែត្រ មានខឿនបេតុងការពារចាក់តែមផ្លូវកៅស៊ូ
- ការងារកែលម្អផ្លូវ បរិវេណជុំវិញត្រពាំងសេសខាងមុខប្រាសាទអង្គរវត្ត ទៅដល់ប្រាសាទព្រហ្មកិល ប្រវែងសរុប៦៣៩ម៉ែត្រ ជាប្រភេទអ៊ិតបេតុងកៅស៊ូ (AC) ទទឹង៩ម៉ែត្រ និងមានខឿនបេតុងការពារចាក់តែមផ្លូវកៅស៊ូ





ការងារកែលម្អផ្លូវចាប់ពីចំណតរថយន្តខាងមុខប្រាសាទអង្គរវត្ត កាត់តាមព្រលានយន្តហោះអន្តរជាតិសៀមរាប រហូតទៅដល់ផ្លូវជាតិលេខ៦ ប្រវែង៦,២៣៧ម៉ែត្រ ទទឹងចាប់ពី៩-១០ម៉ែត្រ ជាប្រភេទអ៊ីតបេតុងកៅស៊ូ AC



ការងារកែលម្អវិថីព្រះនរោត្តមសីហមុនី អតីតផ្លូវក្រម៉ែ ចំណុចសួនរុក្ខជាតិអង្គរទៅជួបផ្លូវជុំវិញកសិទ្ធប្រាសាទអង្គរវត្ត ប្រវែង៦,៣៦០ ម៉ែត្រ ទទឹង៩.៦ម៉ែត្រ ជាប្រភេទអ៊ីតបេតុងកៅស៊ូ AC



ការងារកែលម្អផ្លូវ ប្រវែង៩៨៥ម៉ែត្រ ទទឹង៦ម៉ែត្រ ជាប្រភេទអ៊ីតបេតុងកៅស៊ូ AC និងមានខ្សែបេតុងការពារបាក់គែមផ្លូវកៅស៊ូ ចាប់ពីខាងកើតប្រាសាទតាព្រហ្ម ភ្ជាប់ទៅខាងលិចប្រាសាទបន្ទាយក្តី



កែលម្អផ្លូវនគរក្រៅ ប្រវែង៨០០ម៉ែត្រទទឹង៧ម៉ែត្រ ជាប្រភេទអ៊ីតបេតុងកៅស៊ូ AC និងមានខ្សែការពារបាក់គែមផ្លូវកៅស៊ូ ចាប់ពីផ្លូវបំបែកខ្ទោងខាងជើងផ្នាំង



ការងារកែលម្អផ្លូវ ប្រវែង១,៨៨៦ម៉ែត្រ ទទឹង៦ម៉ែត្រ ជាប្រភេទអ៊ីតបេតុងកៅស៊ូAC និងមានខ្សែបេតុងការពារបាក់គែមផ្លូវកៅស៊ូ ចាប់ពីខាងលិចប្រាសាទបាយ័ន ដល់ផ្លូវវង់ភូជ័

កែលម្អផ្លូវជុំវិញប្រាសាទបាគង ប្រវែង៦,៧៨១ម៉ែត្រ ទទឹង៥-៦ម៉ែត្រ
ជាប្រភេទបេតុងកៅស៊ូ AC ចេញទៅភ្ជាប់ផ្លូវជាតិលេខ៦A





សាងសង់ផ្លូវបេតុងចំនួន០១ខ្សែប្រវែង៣១គីឡូម៉ែត្រទទឹង៦ម៉ែត្រដែលក្រាលបេតុងស៊ីម៉ង់ត៍គ្មានតំណរចាប់ពីចំណុចផ្លូវឡើងភ្នំគូលែនស្រុកបន្ទាយស្រី កាត់តាមចំណុចព្រះអង្គជំពុះទៅកាន់ឃុំស្វាយលើ ស្រុកស្វាយលើ ខេត្តសៀមរាបฯ



កែលម្អផ្លូវ (K-L) ចាប់ពីផ្លូវបំបែកវត្តធំឃុំព្រះដាក់ កាត់តាមប្រាសាទបន្ទាយសម្រែ
ភ្ជាប់ទៅជួបផ្លូវជាតិលេខ៦៧ ជាប្រភេទបេតុងកៅស៊ូ AC ប្រវែង១៦,៦១៦ម៉ែត្រ ទទឹង៦ម៉ែត្រ





កែលម្អផ្លូវ(E-F) ចាប់ពីដើមផ្លូវមិត្តភាពកម្ពុជា-ភូព័ជំហានទី១ខាងកើត រហូតដល់ចុងផ្លូវ
មិត្តភាពកម្ពុជា-ភូព័ជំហានទី២(ភ្នំដំរី) ជាប្រភេទបេតុងកៅស៊ូ AC
ប្រវែង១៤,៦៣៩ម៉ែត្រ ទទឹង៧ម៉ែត្រ









ផ្លូវកាយ

ផ្លូវកង់ប្រវែងប្រមាណ៦៣គីឡូម៉ែត្រ ស្ថាបនាឡើងដើម្បីជួយសម្រួលចរាចរណ៍ និងសុខសុវត្ថិភាពដល់ប្រជាពលរដ្ឋ សិស្សានុសិស្ស ទាក់ទាញទេសចរអ្នកជិះកង់កម្សាន្ត និងរីករាយនឹងការដើរធ្វើដំណើរកាត់ព្រៃក្នុងរមណីយដ្ឋានអង្គរ។









ស្ពានឈើភូមិគោកបង



ស្ពានបេតុងភូមិគោកឆ្នេត



ស្ពានបេតុងភូមិជាម



ស្ពានបេតុងភូមិស្ទឹងព្រះស្រុក



ស្ពានបេតុងភូមិនគរក្រៅ



ស្ពានបេតុងភូមិស្ទឹង



ស្ពានបេតុងភូមិស្ទឹង



ស្ពានបេតុងភូមិស្ទឹងព្រះស្រុក



ស្ពានបេតុងភូមិរហាស



ស្ពានបេតុងភូមិបណ្តោង



ផ្លូវក្រួសក្រហម ភូមិតាកុយ ឃុំបល្ល័ង្ក ស្រុកជ្រោយចង្វារ



ផ្លូវក្រួសក្រហម ភូមិលាជ័ដែ
ឃុំលាជ័ដែ ស្រុកអង្គរជុំ



ផ្លូវក្រួសក្រហម ភូមិគោកស្រុក ឃុំចាន់ដ ស្រុកជ្រោយចង្វារ





ផ្លូវក្រួសក្រហមជាកយណ៍ខាងលិច



ផ្លូវដីសងាមបណ្តោយស្ទឹងព្រះស្រុក



ភ្ញៀវទេសចរទស្សនាថ្ងៃរះ
នៅប្រាសាទអង្គរវត្ត

ការអភិវឌ្ឍទេសចរណ៍

កំណើនភ្ញៀវទេសចរមកកាន់ប្រទេសកម្ពុជា បានបង្ហាញអំពីសក្តានុពលទេសចរណ៍នៅក្នុងប្រទេស គួបផ្សំជាមួយនឹងសន្តិសុខ និងសុវត្ថិភាពក្នុងប្រទេសផងដែរ។ ទាំងនេះគឺជាសមិទ្ធផលដែលបានកើតចេញពីការដឹកនាំដ៏ឈ្លាសវៃ និងត្រឹមត្រូវរបស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា ដែលមាន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** *នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។*

ការអភិវឌ្ឍវិស័យទេសចរណ៍មកដល់ពេលនេះ គឺចាប់ផ្តើមពីការដាក់ចេញនូវគោលនយោបាយ "បើកច្រកទ្វារអាកាសចរណ៍ដោយសេរី" នៅឆ្នាំ១៩៩៣ និង គោលនយោបាយ "ឈ្នះ ឈ្នះ" នៅឆ្នាំ១៩៩៩។

រដ្ឋាភិបាលកម្ពុជាបានចំណាយថវិកាប្រមាណ ១៦០លានដុល្លារអាមេរិក ដើម្បីរៀបចំកែលម្អហេដ្ឋារចនាសម្ព័ន្ធសម្រាប់ត្រៀមទទួលភ្ញៀវទេសចរក្រោយវិបត្តិជំងឺកូវីដ-១៩។ ការរៀបចំកែលម្អហេដ្ឋារចនាសម្ព័ន្ធទាំងអស់នេះអនុញ្ញាតមិនត្រឹមតែជីវភាពប្រជាពលរដ្ឋទទួលបានផលក្នុងៗទេ តឹសម្រាប់ការអភិវឌ្ឍ អភិរក្ស និងការការពារទៅដល់តំបន់រមណីយដ្ឋានអង្គរដូចគ្នា។ មុនពេលការស្ថាបនាកែលម្អផ្លូវទាំង៣៨ខ្សែនេះ ក្រុងសៀមរាបទាំងមូលពុំមានផ្លូវសម្រាប់ថ្មើរជើងនិងផ្លូវកង់ទេ តែចាប់ពីពេលនេះក្រុងសៀមរាបមានផ្លូវសម្រាប់កង់ដែលចាប់ពីក្រុងសៀមរាបភ្ជាប់ទៅដល់តំបន់រមណីយដ្ឋានអង្គរតែម្តង ដែលអាជ្ញាធរជាតិអប្សរាបានស្ថាបនាផ្លូវកង់រួចរាល់ក្នុងឆ្នាំ២០១៩។



ការអភិវឌ្ឍទេសចរណ៍ក្នុងវិមណីយដ្ឋានអង្គរ

ដើម្បីចូលរួមលើកតម្កើងវិមណីយដ្ឋានអង្គរ អាជ្ញាធរជាតិអប្សរាបាន និងកំពុងខិតខំប្រឹងប្រែងរិះរកមធ្យោបាយនានា ដើម្បីអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងផ្តល់សេវាកម្ម និងបទពិសោធន៍ល្អៗ សម្រាប់ភ្ញៀវទេសចរ។ អាជ្ញាធរជាតិអប្សរា បានអនុវត្តផែនការគ្រប់គ្រងទេសចរណ៍ដោយស្មារតីទទួលខុសត្រូវខ្ពស់ក្នុងគោលបំណងចូលរួមការអភិរក្ស និងអភិវឌ្ឍន៍វិមណីយដ្ឋានអង្គរឱ្យមានចីរភាព។ ផែនការគ្រប់គ្រងទេសចរណ៍នេះ បានរៀបចំឡើងសមស្របនឹងគោលនយោបាយជាតិនិងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍ ២០១៦-២០២០ របស់ក្រសួងទេសចរណ៍ ដើម្បីចូលរួមទាក់ទាញភ្ញៀវទេសចរឱ្យបានឥសានទាក់ក្នុងឆ្នាំ២០២០។



ដោយសារមានទស្សនវិស័យច្បាស់លាស់ក្នុងការដឹកនាំ និងអនុវត្ត បានល្អវិមណីយដ្ឋានអង្គរ បានទទួលជ័យលាភីផ្នែកៗគួរជាទីមោទកភាព ដូចជា៖

Archaeo Madness

នៅឆ្នាំ២០១៦ប្រាសាទអង្គរវត្តត្រូវបានវិទ្យាស្ថានបុរាណវិទ្យារបស់សហរដ្ឋអាមេរិក (Archaeological Institute of America) ផ្តល់ចំណាត់ថ្នាក់លេខ១ ជើងឯក ArchaeoMadness ដែលបានរៀបចំឡើងនៅក្នុងវិនិសាសប្រារព្ធទិវាបុរាណវិទ្យាអន្តរជាតិ។

Ultimate Travelist (Lonely Planet)

នៅឆ្នាំ២០១៥ ប្រព័ន្ធផ្សព្វផ្សាយ Lonely Planet ក៏បានសម្រេចជាក់អង្គរវត្តក្នុងបញ្ជី Ultimate Travel List ជាគោលដៅសម្រាប់ភ្ញៀវទេសចរទស្សនាក្នុងចំណាត់ថ្នាក់លេខ១ ក្នុងចំណោមគោលដៅទស្សនាចាំង ១០លើពិភពលោកផងដែរ។

Tripadvisor

នៅឆ្នាំ២០១៥ ២០១៧ និង២០១៨ អង្គរវត្តត្រូវបានបណ្តាញផ្សព្វផ្សាយ TripAdvisor ផ្តល់ចំណាត់ថ្នាក់លេខ១ ក្នុងចំណោមគោលដៅទស្សនាល្បីៗចាំងគ្បាយលើពិភពលោក។

ផែនការគ្រប់គ្រងទេសចរណ៍ជាមូលដ្ឋាន


ក្រុមការងារអនុវត្តផែនការគ្រប់គ្រងទេសចរណ៍ (TMP)

យោងតាមការស្នើសុំរបស់គណៈកម្មាធិការអន្តរជាតិសម្រាបសម្រួលដើម្បីការអភិរក្ស និងអភិវឌ្ឍន៍រមណីយដ្ឋានអង្គរ ហៅកាត់ថា អាយស៊ីស៊ី-អង្គរ ICC-Angkor នៅចុងឆ្នាំ២០១០ បានតម្រូវឱ្យអាជ្ញាធរជាតិអប្សរា រៀបចំជាផែនការគ្រប់គ្រងទេសចរណ៍ (Tourism Management Plan, TMP) ដែលជាផ្នែកមួយរួមបញ្ចូលក្នុងក្របខ័ណ្ឌគ្រប់គ្រងលេខាធិការអង្គរ (Angkor Heritage Management Framework, AHMF)។ ផែនការគ្រប់គ្រងទេសចរណ៍បានសិក្សា និងចងក្រងឡើងក្រោមកិច្ចសហការរវាងអាជ្ញាធរជាតិអប្សរា ជាមួយក្រសួងទេសចរណ៍ ដែលតាំទ្រដោយភាគីរដ្ឋាភិបាលកម្ពុជា រដ្ឋាភិបាលអូស្ត្រាលី និងអង្គការយូណេស្កូ នៅឆ្នាំ២០១៣ ផែនការគ្រប់គ្រងទេសចរណ៍នេះ ត្រូវបានចុះហត្ថលេខា និងដាក់ឱ្យប្រើប្រាស់ជាផ្លូវការដោយ **សម្តេចតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរជាតិអប្សរា ហើយនៅចុងឆ្នាំ២០១៣ ថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរា បានចេញសេចក្តីសម្រេចលេខ៣៦សរបង្កើតក្រុមការងារអនុវត្តផែនការគ្រប់គ្រងទេសចរណ៍ ដើម្បីអនុវត្តផែនការគ្រប់គ្រងទេសចរណ៍នៅរមណីយដ្ឋានអង្គរឱ្យមានប្រសិទ្ធភាពខ្ពស់។

ការងាររៀបចំផែនការមេអភិវឌ្ឍន៍តំបន់ទេសចរណ៍សៀមរាប-អង្គរ (TDP)

យោងតាមអនុសាសន៍នៃគណៈកម្មាធិការ អាយស៊ីស៊ី-អង្គរ នាកិច្ចប្រជុំបច្ចេកទេសលើកទី៦១ កាលពីថ្ងៃទី១១-១៦ ខែមិថុនា ឆ្នាំ២០១៤ គណៈកម្មាធិការនេះបានតម្រូវឱ្យក្រុមការងារជំនាញ នៃអាជ្ញាធរជាតិអប្សរា ធ្វើការសិក្សាវិភាគឱ្យបានច្រប់ជ្រុងជ្រោយ ដើម្បីដាក់ចេញនូវផែនការមេសម្រាប់ការអភិវឌ្ឍទេសចរណ៍ដោយចីរភាពក្នុងតំបន់អង្គរ។ ធ្វើយតបនឹងអនុសាសន៍នេះ ក្រុមការងារក៏បានរៀបចំផែនការអភិវឌ្ឍន៍តំបន់ទេសចរណ៍សៀមរាប-អង្គរ (TDP) និងបានធ្វើការប្រជុំពិភាក្សាជាមួយវិស័យឯកជនចំនួន១៦លើក ចាប់ពីថ្ងៃទី១៦ ខែកញ្ញា រហូតដល់ថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៤ ដែលមានទាំងសមាគមសណ្ឋាគារ ផ្ទះសំណាក់ សមាគមពុងឆៅ ប្រតិបត្តិការទេសចរណ៍ មគ្គុទ្ទេសក៍ទេសចរណ៍ ភ្ញៀវទេសចរប្រជាពលរដ្ឋ ព្រះសង្ឃ យុវជន ការដ្ឋានអន្តរជាតិដែលកំពុងបំពេញការងារអភិរក្សក្នុងតំបន់អង្គរ និងស្ថាប័នរដ្ឋពាក់ព័ន្ធជាច្រើនទៀត។

ធ្វើតាមកិច្ចប្រជុំពិភាក្សា និងការវិភាគទិន្នន័យនេះ ក្រុមការងារបានចងក្រងឯកសារដែលមានឈ្មោះថា TOURISM DEVELOPMENT PLAN FOR THE DESTINATION SIEM REAP-ANGKOR ដែលឯកសារនេះស្ទើរតែរួចរាល់ហើយ ប៉ុន្តែដោយវិបត្តិកូវីដ-១៩ ក្រុមការងារ ត្រូវសិក្សាបន្ថែមនូវចំណុចបន្ទាន់មួយចំនួនដើម្បីត្រៀមខ្លួនទាក់ទាញនិងទទួលភ្ញៀវទេសចរ ក្រោយចប់វិបត្តិកូវីដ១៩។ ក្រុមការងារបានបង្ហាញផែនការមេ និងទទួលបានការអនុម័តក្នុងកិច្ចប្រជុំបច្ចេកទេសលើកទី៣៩ និងកិច្ចប្រជុំពេញអង្គលើកទី៦៩ នៃគណៈកម្មាធិការ អាយស៊ីស៊ី-អង្គរ កាលពីថ្ងៃទី៦-២៩ ខែមីនា ឆ្នាំ២០២២។





សមិទ្ធផលទេសចរណ៍ក្នុងរមណីយដ្ឋានអង្គរ

ដើម្បីសម្រួលដល់ការធ្វើចរាចរ និងកាត់បន្ថយការកកស្ទះយានយន្ត ការពារញើរ កំដៅចេញពីយានយន្តប៉ះពាល់ដល់រមណីយដ្ឋានអង្គរ អាជ្ញាធរជាតិអប្សរាបានសិក្សាអំពីចំនួនយានយន្ត និងប្រភេទមធ្យោបាយធ្វើដំណើរក្នុងរមណីយដ្ឋាន រួចបានដាក់ផែនការ និង បានអនុវត្តការងារមួយចំនួនដូចខាងក្រោម៖

- ហាមឃាត់រថយន្តលើសពី២៥កៅអី មិនឱ្យចរាចរតាមវង់តូច និងវង់ធំក្នុងរមណីយដ្ឋានអង្គរ។
- កាត់បន្ថយការកកស្ទះនៅត្រង់ខ្នោងទ្វារទន្ទេរ៉ាំនៅពេលព្រឹក តាមរយៈការអនុញ្ញាតតែចរាចរឯកទិសពីស្ទឹងទៅជើង ចាប់ពីម៉ោង៧:៣០នាទីព្រឹក ដល់ម៉ោង១១:៣០នាទីព្រឹក។
- លើកទឹកចិត្តអ្នកប្រើប្រាស់មធ្យោបាយធ្វើដំណើរដោយកង់ តាមរយៈការរៀបចំឱ្យមានផ្លូវជិះកង់។

ក្នុងគោលបំណងកាត់បន្ថយភាពកកស្ទះជៀសវាងផលប៉ះពាល់អវិជ្ជមានដល់ប្រាសាទ លើកតម្លៃប្រាសាទ បង្កើនគុណភាពក្នុងការទស្សនា និងសុវត្ថិភាពភ្ញៀវទេសចរ អាជ្ញាធរជាតិអប្សរា បានសិក្សានិងអនុវត្តការគ្រប់គ្រងលំហូរភ្ញៀវទេសចរទៅតាមប្រាសាទមួយចំនួនដូចជា៖

រូបភាពកាណានៃប្រាសាទអង្គរវត្ត

បានកំណត់ចំនួនភ្ញៀវទេសចរដែលអាចទស្សនាមានត្រឹមតែ១០០នាក់ប៉ុណ្ណោះក្នុងពេលតែមួយ។ ដូច្នេះដើម្បីទស្សនារូបភាពកាណានេះភ្ញៀវទេសចរត្រូវតម្រង់ជួរហើយទទួលយកប័ណ្ណទស្សនាពីភ្នាក់ងារទេសចរណ៍។

ប្រាសាទភ្នំបាខែង

បានកំណត់ចំនួនភ្ញៀវទេសចរដែលអាចឡើងទៅកាន់ប្រាសាទភ្នំបាខែងមានត្រឹមតែ៣០០នាក់ប៉ុណ្ណោះក្នុងពេលតែមួយ។ ដូច្នេះ





ដើម្បីឡើងទៅកាន់ប្រាសាទភ្នំបាខែងបានក្បៀវទេសចរត្រូវតម្រង់ជួរគ្នាហើយទទួលបណ្ណទស្សនាពីភ្នាក់ងារទេសចរណ៍។ អាជ្ញាធរជាតិអប្សរា បានរៀបចំកន្ទុយទស្សនាចំនួន០៤កន្ទែង នៅលើភ្នំបាខែង ដើម្បីសម្រួលឱ្យក្បៀវដែលមិនបានឡើងដល់លើប្រាសាទអាចបានទស្សនាទិដ្ឋភាពជុំវិញភ្នំបាខែង។

ប្រាសាទតាព្រហ្ម

ក្បៀវទេសចរអាចទស្សនាប្រាសាទតាព្រហ្មស្វែងយល់ពីប្រវត្តិសាស្ត្រ រចនាសម្ព័ន្ធ និងតុណតម្លៃប្រាសាទប្រកបដោយគុណភាពខ្ពស់ និងទទួលបានខ្លួវបទពិសោធន៍ល្អ។ ដោយមិនប៉ះពាល់ជាអវិជ្ជមានដល់ប្រាសាទ អាជ្ញាធរជាតិអប្សរាបានរៀបចំវង់ទស្សនាក្នុងប្រាសាទតាព្រហ្ម ដោយធ្វើការលើកទឹកចិត្តឱ្យមគ្គុទ្ទេសក៍ទេសចរណ៍ និងក្បៀវទេសចរចូលទស្សនាតាមច្រកខាងកើត។

ប្រាសាទបន្ទាយស្រី

ឆ្នាំ២០០៤ជាក់ដំណើរការទីលានបដិសណ្ឋារកិច្ចក្បៀវទេសចរ (Parvis បន្ទាយស្រី) និងបានកែសម្រួលបន្ថែមនៅឆ្នាំ២០២២។

ប្រាសាទតាយ័ន

នៅដើមឆ្នាំ២០២០ ដោយផ្អែកលើស្ថានភាពទ្រុឌទ្រោមបង្ករការគ្រោះថ្នាក់ដល់ក្បៀវទេសចរ នៅជាន់ទី៣ដែលមានប្រាង្គកណ្តាលនៃប្រាសាទបាយ័ន្តបានបិទការឡើងទស្សនា។ នៅឆ្នាំ២០២២ អាជ្ញាធរជាតិអប្សរាបានជាក់ដំណើរការវង់ទស្សនានៅជាន់ទី១ និងទី២ តាមរយៈការជាក់រនាំងបិទផ្លូវឡើងទស្សនាជាន់ទី៣រៀបចំឱ្យមានបង្ហោលរបារ ផ្ទាំងព័ត៌មានប្រវត្តិសាស្ត្រ និងស្លាកសញ្ញាចង្អុលទិស។ល។



ការលើកតម្កើងមណីយដ្ឋានអប្សរ តាមរយៈក្រមប្រតិបត្តិអប្សរ


*ក្រមប្រតិបត្តិអប្សរ ត្រូវបានអាជ្ញាធរជាតិអប្សរសហការជាមួយស្ថាប័នជាតិ-អន្តរជាតិ និងដៃគូពាក់ព័ន្ធក្នុងវិស័យឯកជនចង់ក្រង និងផ្សព្វផ្សាយដល់សាធារណជនដើម្បីចូលរួមក្នុងកិច្ចការពារ ថែរក្សា អភិរក្សលើតកណ្តាប់ឬជម៌ កាត់បន្ថយផលប៉ះពាល់ដល់រមណីយដ្ឋានអង្គរ និងផ្តល់បទពិសោធន៍ក្នុងការទស្សនាដល់ភ្ញៀវទេសចរ។ ក្រមប្រតិបត្តិអង្គរនេះ បានដាក់សម្ពោធជាផ្លូវការកាលពីថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៥ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចតិបុលមហាសេនា ។***



ផែនទីទេសចរណ៍អង្គរ

ដើម្បីងាយស្រួលដល់ភ្ញៀវទេសចរ និងលើកតម្លៃទស្សនាវបស់ភ្ញៀវដែលមកទស្សនាមណ្ឌលអង្គរ អាជ្ញាធរជាតិអប្សរាបានផលិត និងបោះពុម្ពផែនទីទេសចរណ៍អង្គរដែលមានឈ្មោះថា ANGKOR World Heritage Site Visitor Map *ចំនួន ៩៣០ ០០០ច្បាប់ ដែលមានពីរភាសាគឺ ភាសាអង់គ្លេស និងភាសាចិន ដើម្បីចែកជូនភ្ញៀវទេសចរដោយមិនគិតថ្លៃ។*









ទិដ្ឋភាពរួមសួនវត្ថុជាតិអង្គរ

សួនវត្ថុជាតិអង្គរ

សួនវត្ថុជាតិអង្គរជាប្រភេទរមណីយដ្ឋានកែច្នៃមួយរបស់អាជ្ញាធរជាតិអប្សរា មានទំហំផ្ទៃដីប្រមាណជាង១ថហិកតា ស្ថិតក្នុងក្រុងសៀមរាប ត្រូវបានបើកសម្ពោធជាផ្លូវការនៅព្រឹកថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២៦ ក្រោមអធិបតីភាព **ឯកឧត្តម ជា សុផារ៉ា** *ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងមានការអញ្ជើញចូលរួមពី* **លោកជំទាវបណ្ឌិតសភាចារ្យ ឡើង សកុណា** *រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងជាប្រធានក្រុមប្រឹក្សាភិបាលអាជ្ញាធរជាតិអប្សរា។*













សួនរុក្ខជាតិអន្តរជាសមិទ្ធផលទេសចរណ៍ថ្មីមួយ នៅក្នុងក្រុងសៀមរាប ដែលមានជាំរុក្ខជាតិចម្រុះកប់ម៉ឺនដើមនៃពូជជាង ៩០០ប្រភេទ ដូចជា ដើមក្ដា ស្មៅ ឈើហូបផ្លែ ដោយអាចចាត់ទុកថា ជាសួនមានលក្ខណៈពិសេសលើសសួនកម្សាន្តជាទៃ ដោយសារតែសួននេះ ស្ថិតក្នុងរចនាប័ទ្មបែបខ្មែរ មានជាំបន្លែចម្រុះជាច្រើនមុខ មានសួនរុក្ខជាតិផ្នើនិសថ សួនគ្រឿងទេស សួនអម្បុរផ្ការីត សួនលំនៅដ្ឋានខ្មែរ និងសួនព្រៃឈើ បន្ថែមលើនេះ ក៏មានសត្វជាច្រើនប្រភេទ ដូចជាអណ្ដើក ក្អែក ព្រាប ទន្សាយ និងសត្វស្វាបប្រកាំងជាដើម។





ពិធីសម្ពោធស្ពានអណ្តែតទឹកមុខប្រាសាទអង្គវត្តក្រោមអធិបតីភាព
លោកជំទាវបណ្ឌិតសភាចារ្យ កៀវ សភុណា រដ្ឋមន្ត្រីក្រសួងវប្បធម៌
និងវិចិត្រសិល្បៈ និងជាប្រធានក្រុមប្រឹក្សាភិបាលអាជ្ញាធរជាតិអប្សរា









ស្ពានអណ្តែតទឹកមុខប្រាសាទអង្គរវត្ត

ស្ពានអណ្តែតទឹកត្រូវបានកសាងឡើងសម្រាប់ភ្ញៀវទេសចរធ្វើដំណើរជាបណ្តោះអាសន្នចូលទស្សនាប្រាសាទអង្គរវត្ត ក្នុងអំឡុងពេលដែលស្ពានហាលកំពុងទទួលការជួសជុលនោះត្រូវបានជាក់សម្តែងបើកជូនភ្ញៀវទេសចរជាតិ និងអន្តរជាតិប្រើប្រាស់ជាផ្លូវការ កាលពីព្រឹកថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧។ ដោយឡែក ស្ពានហាលនៃប្រាសាទអង្គរវត្តនឹងត្រូវបិទផ្លាកការធ្វើដំណើរចាប់ពីពេលនេះ រហូតដល់ឆ្នាំការជួសជុលរួចរាល់ ដើម្បីបញ្ចៀសគ្រោះថ្នាក់ជាយថាហេតុដល់ភ្ញៀវទេសចរនិងបង្កលទ្ធភាពងាយស្រួលដល់ក្រុមការងារជួសជុល។

ស្ពាននេះមានប្រវែងបណ្តោយ១៣០ម៉ែត្រ ទទឹង៨ម៉ែត្រ ស្មើនឹង ១៣៦០ម៉ែត្រក្រឡា ដោយប្រើប្រាស់ផ្ទៃពោងជីវអណ្តែតទឹកសរុប ៦៧២០ដុំ អាចផ្ទុកចំនួនមនុស្សឈរលើស្ពានក្នុងពេលតែមួយបាន ១៣៦០នាក់ ដោយគិតមួយម៉ែត្រក្រឡាសម្រាប់មនុស្សម្នាក់។ ស្ពាននេះអាចផ្ទុកទម្ងន់សរុបបាន៤៥៧តោន ដោយក្នុងពោងជីវមួយដុំអាចផ្ទុកបានទម្ងន់៦៨គីឡូក្រាម។ លក្ខណៈពិសេសរបស់ពោងអណ្តែតទឹកនេះ គឺជាប្រភេទជីវ ស៊ូត ធន់ ហើយអាចធន់នឹងអាកាសធាតុបានយ៉ាងល្អបំផុតមិនមានប្រតិកម្មនឹងពន្លឺថ្ងៃ និងភ្ញៀវថែមទាំងមិនធ្វើឱ្យទឹកប្រែពណ៌ ឬបង្កជាសារធាតុពុលផ្សេងៗដល់ទឹកឡើយ។

ស្ពានអណ្តែតទឹកនេះគឺជាសមិទ្ធផលមួយក្នុងចំណោមសមិទ្ធផលដ៏ធំធេងជាច្រើនទៀតនៃការងារអភិរក្សរមណីយដ្ឋានអង្គរ។ សមិទ្ធផលទាំងអស់នេះ គឺសម្រេចបានដោយសារប្រទេសរួចផុតពីសង្គ្រាម មានសន្តិភាព ស្ថិរភាពពេញផ្ទៃប្រទេស ដែលកើតឡើងតាមរយៈគោលនយោបាយឈ្នះឈ្នះ របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។







ការងារអភិវឌ្ឍន៍សហគមន៍ទេសចរណ៍ក្នុងរមណីយដ្ឋានអង្គរ
សហគមន៍សាមគ្គីដើម្បីអភិវឌ្ឍន៍ទេសចរណ៍ចារយណ៍ពាយណ៍ជតជាក

នៅឆ្នាំ២០១៣ អាជ្ញាធរជាតិអប្សរា សហការជាមួយប្រទេសអូស្ត្រាលី និងអង្គការយូណេស្កូ ក្នុងក្របខ័ណ្ឌអនុវត្តគម្រោង «ក្របខ័ណ្ឌគ្រប់គ្រងបេតិកភណ្ឌអង្គរ» ដែលមានគោលដៅចូលរួមពង្រឹងការអភិរក្ស និងលើកតម្លៃបេតិកភណ្ឌអង្គរ តែលម្អការគ្រប់គ្រងទេសចរណ៍ និងផ្តល់ផលប្រយោជន៍ដល់ប្រជាពលរដ្ឋក្នុងតំបន់អង្គរតាមរយៈទេសចរណ៍ បានបង្កើតសហគមន៍មួយឈ្មោះថា «សហគមន៍សាមគ្គីដើម្បីអភិវឌ្ឍន៍ទេសចរណ៍ចារយណ៍ពាយណ៍ជតជាក» ដែលចូលរួមដោយប្រជាជនរស់នៅក្នុងភូមិភូដ៌ និងលាងដែដែលស្ថិតក្នុងឃុំលាងដែ ស្រុកអង្គរជុំ ខេត្តសៀមរាប។ ខ្សែទស្សនាជម្មជាតិ ដោយជិះកង់ ដើរ និងជិះទូក នៅចារយណ៍ជីយតជាក (វាលពាជជាក) កំពុងត្រូវបានបង្កើតឡើង និងគ្រប់គ្រងដំណើរការដោយសហគមន៍ផ្ទាល់។

ក្នុងឆ្នាំ២០២២ អាជ្ញាធរជាតិអប្សរា ក្រោមជំនួយរបស់អង្គការGIZ តាមរយៈអង្គការយូណេស្កូ បានរៀបចំជំរុញដំណើរការសកម្មភាពសហគមន៍ខាងលើនេះឡើងវិញ ដោយមានការធ្វើបច្ចុប្បន្នភាពខ្សែទស្សនាឡើងវិញអោយមានភាពទាក់ទាញ ធ្វើការបណ្តុះបណ្តាលសមត្ថភាពសហគមន៍ ព្រមទាំងពង្រឹងការងារទីផ្សារនិងផ្សព្វផ្សាយ។



ការដាក់រៀបចំខ្សែទស្សនាចរថ្ងៃលិច-ថ្ងៃរះ ជៅតំបន់រមណីយដ្ឋានអង្គរ

បច្ចុប្បន្នជៅក្នុងរមណីយដ្ឋានអង្គរ មានទីតាំងគយគន់ថ្ងៃលិច និងថ្ងៃរះដ៏មានភាពទាក់ទាញ និងពេញនិយមចំនួនពីរគឺ ប្រាសាទអង្គរវត្ត និងប្រាសាទភ្នំបាខែង។ ដើម្បីធ្វើឱ្យមានភាពសម្បូរបែបនិងបញ្ចៀសការកកកុញលំហូរនៃភ្ញៀវទេសចរជៅក្នុងតំបន់អង្គរ ហើយដើម្បីឱ្យស្របជៅតាមចក្ខុវិស័យរបស់អាជ្ញាធរជាតិអប្សរា ព្រមទាំងអនុសាសន៍របស់អ្នកជំនាញការ អាយស៊ីស៊ី-អង្គរ អាជ្ញាធរជាតិអប្សរា បានស្នើ និងរៀបចំខ្សែទស្សនាគយគន់ថ្ងៃលិច និងថ្ងៃរះដែលមានសក្តានុពលនៅប្រាសាទភ្នំក្រាម ស្រះស្រង់ ខ្នោងទ្វារទន្ទេរ្ញុំ កំពែងអង្គរធំ(ប្រាសាទជ្រុងទិសនិរតី) និងបាកយណ៌ាងលិច បន្ថែមទៀតក្រៅពីប្រាសាទអង្គរវត្ត និងប្រាសាទភ្នំបាខែង។

ខ្សែទស្សនាថ្ងៃលិច និងថ្ងៃរះនៅប្រាសាទភ្នំក្រាម ត្រូវបានរៀបចំនិងដាក់ដំណើរការសាកល្បងមុនគេ ដើម្បីបានបទពិសោធន៍ល្អៗ ឈានជៅអនុវត្តនៅទីតាំងផ្សេងៗបន្តបន្ទាប់ដូចខាងក្រោម៖

១. ខ្នោងទ្វារទន្ទេរ្ញុំ
២. ប្រាសាទជ្រុងគាគនិរតី
៣. បាកយណ៌ាងលិច
៤. ស្រះស្រង់


ថ្ងៃរះនៅស្រះស្រង់


ថ្ងៃលិចនៅបាកយណ៌ាងលិច


ថ្ងៃលិចនៅខ្នោងទ្វារទន្ទេរ្ញុំ



ថ្ងៃលិចនៅកំពែងអង្គរធំ (ប្រាសាទជ្រុង)


ថ្ងៃលិចនៅប្រាសាទភ្នំក្រាម






ខ្សែទស្សនានៅប្រាសាទថៅសាយទេវតា និងប្រាសាទធម្មនន្ទ





ខ្សែទស្សនានៅតំពែនក្រុងអង្គរធំ




ការដាក់រៀបចំខ្សែទស្សនាចរក្នុងប្រាសាទ ដៅតំបន់រមណីយដ្ឋានអង្គរ

គោលបំណងនៃការរៀបចំខ្សែទស្សនា៖

- កាត់បន្ថយការកកស្ទះនៅក្នុងប្រាសាទ
- បង្កើនគុណភាពនៃការទស្សនា
- ផ្តល់ឱ្យបទពិសោធន៍ល្អៗជូនទេសចរ
- លើកតម្លៃសម្បត្តិបេតិកភណ្ឌ
- ផ្តល់សុវត្ថិភាពជូនភ្ញៀវ និងប្រាសាទ
- បង្កើតផលិតផលទេសចរណ៍ថ្មី
- ពន្យារយៈពេលស្នាក់នៅរបស់ទេសចរ

ខ្សែទស្សនានៅប្រាសាទបាយ័ន








ខ្សែទស្សនានៅប្រាសាទនាគព័ទ្ធ









ទីលានបដិសណ្ឋារកិច្ចព្រះសាទបន្ទាយស្រី

ទីលានព្រះសាទបន្ទាយស្រី ជាទីលានបដិសណ្ឋារកិច្ចភ្ញៀវទេសចរ ដំបូងនៅក្នុងរមណីយដ្ឋានអង្គរ ដែលសម្ពោធនៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០០៩ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចតេជោហ៊ុន សែន** នាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរជាតិអប្សរា **ឯកឧត្តម** Roldophe S. Imhoof ឯកអគ្គរដ្ឋទូតស៊ុយសប្រចាំកម្ពុជា **ឯកឧត្តម** Olabiyi Babalola J. Yai Rifan ប្រធានក្រុមប្រឹក្សាប្រតិបត្តិនៃអង្គការយូណេស្កូ។

គោលបំណងនៃការរៀបចំទីលានបដិសណ្ឋារកិច្ចភ្ញៀវនេះឡើង គឺក្នុងគោលបំណងធ្វើឱ្យព្រះសាទបន្ទាយស្រី ក្លាយជាទីតាំងស្វាគមន៍ភ្ញៀវជាតិ អន្តរជាតិ ប្រកបដោយសោភ័ណភាព សណ្តាប់ធ្នាប់ល្អ និងបង្កើនភាពទាក់ទាញបន្ថែមទៀតជូនជា សួនច្បារ តូបលក់ជូរវត្ថុអនុស្សាវរីយ៍ ចំណតរថយន្ត ឯលវែស បន្ទប់ទឹកចំនួន០៦ទីតាំង កាហ្វេនិងភោជនីយដ្ឋាន ពាង់អង្គុយសម្រាក ភាពទស្សនាត្រពាំង និងទេសភាពផ្សេងៗ។ ក្រៅពីនេះក៏មានមណ្ឌលទទួលស្វាគមន៍ភ្ញៀវទេសចរ ការផ្តល់ព័ត៌មានផ្សេងៗ ការសង្គ្រោះបឋមដល់ភ្ញៀវទេសចរ ការទទួលផ្ញើអីវ៉ាន់ភ្ញៀវដែលមិនអាច ឬពិបាកយកតាមខ្លួនក្នុងពេលចូលទស្សនាប្រាសាទ លើសពីនេះទៀតនៅអនាគតក្នុងករណីមានភ្ញៀវទេសចរច្រើនលើសលុបចូលទស្សនាប្រាសាទបន្ទាយស្រី ដែលជាប្រាសាទតូចមួយ អគារបកស្រាយព័ត៌មានវប្បធម៌នៃទីលានបដិសណ្ឋារកិច្ចនេះ មានតួនាទីជាទីតាំងសម្រាប់ភ្ញៀវរង់ចាំសិន និងដើម្បីបង្កើនចំណេះដឹងដល់ភ្ញៀវទេសចរមុនពេលចូលទស្សនាប្រាសាទ ដោយសារមានការតាំងពិព័រណ៌បង្ហាញពីសិល្បៈ សាសនា ស្ថាបត្យកម្ម និងប្រវត្តិនៃប្រាសាទបន្ទាយស្រី។


ប្រាសាទបន្ទាយស្រី
Banteay Srei Temple

















ការរៀបចំចំណតរថយន្តមុខច្រាសាធអង្គរវត្ត

អាជ្ញាធរជាតិអប្សរា បានរៀបចំចំណតសម្រាប់យានយន្តគ្រប់ប្រភេទ ដែលមានបរិវេណធំទូលាយ ស្ថិតនៅខាងមុខច្រាសាទអង្គរវត្តឆៀងខាងស្តាំ។ ការរៀបចំចំណតនេះ ទទួលបានការគាំទ្រពីសំណាក់អ្នកបើកបរយានយន្តនិងរ៉ឺម៉កកន់បីជាច្រើន ដោយពួកគេបានបង្ហាញស្មារតីចូលរួមទទួលខុសត្រូវខ្ពស់ចូលចត និងដាក់ក្បៀវចុះតាមទីតាំងដែលបានកំណត់។ សកម្មភាពទាំងនោះបានធ្វើឱ្យសណ្តាប់ធ្នាប់សាធារណៈនិងរបៀបរៀបរយនៅមុខច្រាសាទ អង្គរវត្តមានភាពកាន់តែល្អប្រសើរ។







ក្នុងគោលបំណងបញ្ចៀសភាពកកស្ទះនិងភាពគ្មានសណ្តាប់ធ្នាប់នៅមុខប្រាសាទអង្គរវត្ត អាជ្ញាធរជាតិអប្សរាសូមអំពាវនាវឱ្យក្រុមហ៊ុន ឬទីភ្នាក់ងារទេសចរណ៍ ម្ចាស់យានយន្ត មគ្គុទ្ទេសក៍ទេសចរណ៍ ចូលចតយានយន្តក្នុងចំណតដែលអាជ្ញាធរជាតិអប្សរាបានរៀបចំរួចរាល់ ដើម្បីឱ្យសណ្តាប់ធ្នាប់នៅប្រាសាទអង្គរវត្តមានរបៀបរៀបរយស័ក្តិសមជាគោលដៅទេសចរណ៍ដ៏ទាក់ទាញរបស់កម្ពុជា។





ស្វាគមន៍ស្គាល់ឈ្មោះប្រាសាទក្នុងតំបន់រមណីយដ្ឋានអង្គរ

យើងសង្កេតឃើញថា មានភ្ញៀវទេសចរជាតិនិងអន្តរជាតិមួយចំនួនពុំចាន់ស្គាល់ឈ្មោះប្រាសាទនៅក្នុងតំបន់អង្គរដែលខ្លួនកំពុងតែទស្សនា និងខ្លះទៀតពុំចាន់អាចសម្គាល់ទិសចូលទស្សនាប្រាសាទនីមួយៗបាននៅឡើយទេ។ អាជ្ញាធរជាតិអប្សរាបានផលិតស្លាកសម្គាល់ឈ្មោះប្រាសាទរួចរាល់នៅឆ្នាំ២០១៩ ក្នុងគោលបំណងផ្តល់ព័ត៌មាន និងតម្រង់ទិសភ្ញៀវទេសចរ តាមរយៈការបង្ហាញពីឈ្មោះប្រាសាទ និងលើកកម្ពស់សោភ័ណភាព និងលើកតម្លៃប្រាសាទក្នុងតំបន់អង្គរ។

ស្លាកឈ្មោះប្រាសាទផលិតពីថ្មភក់ ដែលមានរូបរាងស្រដៀងនឹងសន្ទឹកសីមាបែបបុរាណប៉ុន្តែខ្នាត ដែលមានចំនួនសរុប១១៨ផ្ទាំង ដោយបែងចែកជា៣ទំហំខុសៗគ្នា ឱ្យស្របតាមទេសភាព ប្បជម៌នៃទីតាំងប្រាសាទនីមួយៗ និងក្បែរភ្ញៀវទេសចរដែលអាចមើលឃើញ។ ស្លាកទំហំធំមានចំនួន១៨ស្លាក កំពស់១,៥ម បណ្តោយ០,៩ម និងកម្រាស់០,៣ម ស្លាកទំហំមធ្យមមានចំនួន៥២ស្លាក កំពស់១,២ម បណ្តោយ០,៧ម និងកម្រាស់០,២៣ម។ ស្លាកទំហំតូចមានចំនួន៥០ស្លាក មានកំពស់១ម បណ្តោយ០,៦ម និងកម្រាស់០,២ម។ ផ្ទាំងស្លាកឈ្មោះប្រាសាទនេះ បង្ហាញជូនន្ូវព័ត៌មានសំខាន់ៗមួយចំនួនពាក់ព័ន្ធនឹងប្រាសាទដូចជា ឈ្មោះប្រាសាទ អាយុកាលសាងសង់ប្រាសាទ ទិសច្រកចូលប្រាសាទ និងអមដោយស្លាកសញ្ញា (Logo) ចំនួន៤គឺ ស្លាកសញ្ញាអាជ្ញាធរជាតិអប្សរានៅចំកណ្តាលខាងលើឈ្មោះប្រាសាទ និងស្លាកសញ្ញា៣ផ្សេងទៀតដែលនៅខាងក្រោមគឺ ស្លាកសញ្ញាយូណេស្កូ ស្លាកសញ្ញាបេតិកភណ្ឌពិភពលោក និងស្លាកសញ្ញាអនុសញ្ញាក្រុងឌ្បាអេផ្ទាំ១៩៥៤ សម្រាប់ការការពារសម្បត្តិវប្បធម៌ក្នុងគ្រាមានជម្លោះប្រដាប់អាវុធ។

ការស្តារជាស្ពានឈើ ដៅទ្វារសាធរបេដមាលា





សំណង់ស្ពានឈើខ្នាត់ខ្វែងនៅក្នុងប្រាសាទបេដមាលាប្រវែង៦១៥ ម៉ែត្រ (រាប់ទាំងជណ្តើរ) បានសង់ថ្មីជំនួសស្ពានឈើចាស់ក្នុងគោលបំណងបង្កើនទ្វៃភាពទាក់ទាញដល់ទេសចរគ្រប់ជាតិសាសន៍ ដើម្បីផ្តិតយកទិដ្ឋភាពដ៏ស្រស់ត្រកាលនៃប្រាសាទនិងផ្តល់ភាពងាយស្រួលក្នុងការទស្សនាសំណង់ស្ថាបត្យកម្មខ្មែរដ៏ធំមួយនេះ។

ស្ពាននេះចំណាយឈើអស់៨៣ម៉ែត្រគូប ដែលធ្វើពីឈើតគីរ ផ្ទឹកនិងកំណ មានការរចនាស្ពាត រឹងមាំអាចជន់បានរហូតដល់ជាង១០ន្នាក់ និងបានពង្រីកទំហំពី៨០សង់ទីម៉ែត្រទៅ១.៥០ម៉ែត្រនៃស្ពានចាស់ ដើម្បីទេសចរងាយស្រួលដើរទស្សនាទៅវិញទៅមក។

ការគ្រាលស្តារលើឫសឈើ ដៅទ្វារសាធតាព្រហ្ម






ដើមឈើធំៗនិងឫសធំៗ ដែលមានវ័យចំណាស់នៅប្រាសាទតាព្រហ្ម គឺជាផ្នែកមួយដ៏ទាក់ទាញសម្រាប់ភ្ញៀវទេសចរជាតិ និងអន្តរជាតិ។ ពួកគេតែងផ្តិតយកទិដ្ឋភាពទាំងនោះ នៅពេលបានមកដល់ប្រាសាទម្តងៗ។ ជាមួយនឹងកំណើនទេសចរជាច្រើនមកដល់ប្រាសាទតាព្រហ្ម វាក៏បានបង្កហានិភ័យផងដែរ។ ហានិភ័យត្រង់ភ្ញៀវទេសចរបានដើរជាន់ឫសឈើនៅក្រោមដីដោយមិនដឹងខ្លួនដែលវានឹងបង្កាក់ដំណើរលូតលាស់របស់ដើមឈើទាំងនោះ។

គោលបំណងនៃការគ្រាលស្តារនេះគឺដើម្បីបង្កើនការលូតលាស់របស់ដើមឈើនិងថែរក្សាបរិស្ថានជុំវិញឱ្យបានល្អប្រសើរឡើងវិញ។ ការគ្រាលស្តារនេះ បានធ្វើឡើងនៅតាមទីតាំងឫសឈើចំនួន៦កន្លែងនិងនៅតាមរង់ទស្សនាប្រវែងជាង៦០០ម៉ែត្រ។

ផែនការអភិវឌ្ឍន៍តំបន់ទេសចរណ៍សៀមរាប-អង្គរ
២០២០-២០៣០



TOURISM DEVELOPMENT PLAN (TDP)

FOR

THE DESTINATION SIEM REAP-ANGKOR

(2020-2030)

A – NATIONAL AND INTERNATIONAL CONTEXT

B – THE CURRENT SITUATION OF TOURISM IN SIEM REAP-ANGKOR

C – SWOT ANALYSIS

D – SHARING AND WORKING SESSIONS WITH STAKEHOLDERS

E – VISION, OBJECTIVES, AND PROPOSED ACTION PLANS

F – ACTION SHEETS

G – ANNEX: SHARING REPORTS

May 2020

ការថែទាំស្មៅជុំវិញប្រាសាទអង្គរវត្ត







ការថែទាំផ្លូវដើរជុំវិញប្រាសាទអង្គរវត្ត









សម្ភារក្បៀវក្វេចឬបាត់ក្នុងអំឡុងពេលទស្សនាប្រាសាទ ដូចជាទូរសព្ទដៃ កាបូបស្ពាយ កាបូបដៃ ចោរលួចយក កាបូបលុយ ម៉ាស៊ីនថត កាតវីសា លិខិតឆ្លងដែនជាដើម។ ករណីនេះ ភ្នាក់ងារទេសចរណ៍របស់អាជ្ញាធរជាតិអប្សរាបានជួយស្វែងរក និងបានសហការជាមួយនគរបាលការពារបេតិកភណ្ឌ និងនគរបាលទេសចរណ៍ប្រគល់សម្ភារជូនម្ចាស់វិញករណីម្ចាស់មកសួរកន្លែងៗ ឬ ប្រគល់ឱ្យនគរបាលទេសចរណ៍រក្សាទុករង់ចាំម្ចាស់ដើមមករក។



ករណីក្បៀវមានបញ្ហារបួសស្នាមដៃលបណ្តាលពីការអស់ ឬជំពប់ដើងជួលត្រូវចង្កោះដៃដើង បែកក្បាល ខ្សល់គរ ជួលសន្ធប់ ត្រូវចង្កាក់ឯកទេសណ៍ ពុលអាហារ លង់ទឹក ស្វាភាំ ជំងឺស្តង់ជាន់ប្រចាំកាយ។ល។ ភ្នាក់ងារទេសចរណ៍របស់អាជ្ញាធរជាតិអប្សរា បានជួយសង្គ្រោះបឋមចំពោះករណីស្រាលល្មម និងសហការជាមួយអ្នកពាក់ព័ន្ធបញ្ជូនទៅកាន់មន្ទីរពេទ្យក្នុងករណីរបួសធ្ងន់ធ្ងរ។

ការសាងសង់បង្គោលអង់តែន បែបដើមឈើសិប្បនិម្មិតជាក្នុង រមណីយដ្ឋានអង្គរ

ដោយសារបច្ចេកវិទ្យាមានការអភិវឌ្ឍជារៀងរាល់ថ្ងៃ តម្រូវការរបស់ប្រជាជនក្នុងតំបន់អង្គរ ក្រុមការងារនៃអាជ្ញាធរជាតិអប្សរា និងភ្ញៀវទេសចរ មានតម្រូវការទំនាក់ទំនងគ្នាទៅវិញទៅមកជាចាំបាច់ អាជ្ញាធរជាតិអប្សរាបានស្នើសុំអនុសាសន៍ណែនាំពីកិច្ចប្រជុំ អាយស៊ីស៊ីអង្គរ និងបានសម្រេចអនុញ្ញាតឱ្យសាងសង់បង្គោលអង់តែនបែបដើមឈើសិប្បនិម្មិត ចំនួន១៨ដើម នៅក្នុងការផ្តល់ភាពងាយស្រួលដល់ក្រុមហ៊ុនសេវាទូរស័ព្ទនានាក្នុងប្រទេសកម្ពុជា អាចផ្តល់សេវាទូរស័ព្ទនៅក្នុងរមណីយដ្ឋានអង្គរ ដោយផ្តើមចេញពីការសាងសង់បង្គោលអង់តែន០៦ដើម ជាការសាកល្បងជាមុនសិនដោយមានការចុះ MoU រវាងអាជ្ញាធរជាតិអប្សរា និងក្រុមហ៊ុន CAMTower Link Communication Co.Ltd នៅក្នុងខែមីនា ឆ្នាំ២០១៦។

ក្រុមហ៊ុនបានទទួលការអនុញ្ញាតឱ្យសាងសង់បង្គោលអង់តែនបែបដើមឈើសិប្បនិម្មិតចំនួន១២បង្គោលបន្ថែមក្នុងជំហានទី៦ និងសាងសង់រួចរាល់កាលពីខែវិច្ឆិកា ឆ្នាំ២០២១។

បច្ចុប្បន្នរមណីយដ្ឋានអង្គរអាចប្រើប្រាស់សេវាទូរស័ព្ទគ្រប់ប្រព័ន្ធក្នុងទំនាក់ទំនងគ្នាបានល្អប្រសើរ ដែលអាចជួយសម្រួលដល់ការងារដែលប្រើប្រាស់បច្ចេកវិទ្យាផងដែរ។



ពិធីបុណ្យរំលឹកគុណអង្គរ

ពិធីបុណ្យរំលឹកគុណអង្គរ ប្រារព្ធឡើងក្នុងគោលបំណងសំខាន់គឺ ដើម្បីអបអរសាទរការចុះមណ្ឌិយដ្ឋានអង្គរ ទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោក នាថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៩៦ ក៏ដូចជា ដើម្បីរំលឹកគុណដល់បុព្វការីជនគ្រប់ជំនាន់ ព្រះមហាក្សត្រជំនាន់មុនគ្រប់ព្រះអង្គ ដែលបានកសាងប្រាង្គប្រាសាទនានា បន្សល់ទុកនូវសម្បត្តិបេតិកភណ្ឌសិល្បៈ និងវប្បធម៌ជាច្រើនទៀតជាគុណប្រយោជន៍ផ្នែកសង្គម និងសេដ្ឋកិច្ចដល់ប្រជាជនកម្ពុជា នាពេលកន្លងមកបច្ចុប្បន្ន និងទៅអនាគត និងដើម្បីបំផុសឱ្យក្មេៀវជាតិ និងអន្តរជាតិ០១នាក់ ចូលរួមទស្សនាអង្គរយ៉ាងហោចណាស់០១ដង ក្នុងមួយឆ្នាំៗលើយចង់មកថែមទៀត។









ក្រុមតន្ត្រីពិធីប្រុងពលី ចរិវណ
ខាងមុខប្រាសាទភ្នំបាខែង
បុណ្យដឹងគុណមហាវិរៈជួនតាៗ





ក្រុមតន្ត្រីពិធីបួងសួងលើ
ប្រាសាទភ្នំបាខែង
បុណ្យដឹងគុណមហាវិរៈជួនតាៗ





ក្រុមតន្ត្រីពិធីបួងសួងនៅមុខ
ប្រាសាទអង្គរ ព្រឹត្តិការណ៍បុណ្យ
រំលឹកគុណអង្គរ



គម្រប់ខួប២៥ឆ្នាំនៃការបង្កើតអាជ្ញាធរជាតិអប្សរ

នៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២០ ជាខួប២៥ឆ្នាំ (១៩ កុម្ភៈ ១៩៩៥-១៩ កុម្ភៈ ២០២០) ដែលអាជ្ញាធរជាតិអប្សរត្រូវបានបង្កើតឡើង អនុលោមទៅតាមគោលការណ៍មួយក្នុងចំណោមគោលការណ៍ចាំបាច់សម្រាប់លក្ខខណ្ឌនៃការចុះបញ្ជីរមណីយដ្ឋានអង្គរជាសម្បត្តិបេតិកភណ្ឌពិភពលោក។ ក្នុងឱកាសនោះក៏មានរៀបចំពិព័រណ៌រូបថតសកម្មភាពរបស់អាជ្ញាធរជាតិអប្សរក្នុងរយៈពេល២៥ឆ្នាំកន្លងមកទាំងការអភិរក្ស ការជួសជុល និងការអភិវឌ្ឍក្នុងរមណីយដ្ឋានអង្គរ ដើម្បីតាំងបង្ហាញជូនសាធារណជនទស្សនាកម្សាន្ត និងស្វែងយល់។ ក្រៅពីនេះ ក៏មានរៀបចំពិធីសាសនាផងដែរ។











កន្ទុងមកនេះ អាជ្ញាធរជាតិអប្សរាសម្រេចបានទូរសិទ្ធផលជាច្រើនក្នុងនោះរួមមានការងារអភិរក្ស ជួសជុលប្រាង្គប្រាសាទ ការអភិវឌ្ឍវិស័យទេសចរណ៍ ការស្តារ និងដាក់ឱ្យប្រើប្រាស់ឡើងវិញនូវប្រព័ន្ធធារាសាស្ត្របុរាណសម័យអង្គរ ការជួសជុល និងកសាងប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធរូបវន្តទាំងា ជាពិសេស កិច្ចការសហគមន៍ក្នុងក្រុង/ស្រុកទាំង៥ នៃរមណីយដ្ឋានអង្គរ ដែលទាំងអស់នេះបានចីងកំពុងចូលរួមចំណែកលើកកម្ពស់គម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋក្នុងតំបន់មានការប្រែប្រួល និងរីកចម្រើនគួរឱ្យកត់សម្គាល់។



មរតកអរូបីជាអង្គរ

មរតកអរូបីសំដៅលើចំណេះដឹង ជំនាញ កិច្ចពិធី ទំនៀមទម្លាប់ប្រពៃណីដែលវិវឌ្ឍន៍ និងផ្ទេរពីជំនាន់មួយទៅជំនាន់មួយទៀត។ ជាទូទៅមរតកអរូបីងាយនឹងបាត់បង់ ព្រោះមរតកនេះនៅជាប់នឹងមនុស្សម្ល៉ោះហើយការប្រតិបត្តិ និងការផ្ទេរចំណេះដឹង ការសិក្សាចងក្រងឯកសារ គឺជាការចាំបាច់ឱ្យខាងតែបាន។ មរតកវប្បធម៌ និងអរូបីពុំអាចផ្តាច់ចេញពីគ្នាបានទេ។



ពិធីសុំទឹកភ្លៀងនៅប្រាសាទនាគពិន្ទ



ពិធីទ្វេរលេង

នៅអង្គរ ក្រៅពីលក្ខណៈពិសេសនៃស្ថាបត្យកម្មប្រាសាទដែលបញ្ជាក់ជាសម្បត្តិបេតិកភណ្ឌពិភពលោក អ្នកស្រុកអង្គរដែលរស់នៅជុំវិញប្រាសាទមានទំនាក់ទំនងជិតស្និទ្ធទៅនឹងប្រាសាទ និងបរិស្ថាននៃតំបន់អង្គរ។ ចំពោះអ្នកស្រុក ប្រាសាទជាទីសក្ការដែលមានអមនុស្ស (អ្នកតា) រស់នៅ ហើយគេអាចពឹងពាក់អាស្រ័យអមនុស្សទាំងនោះសម្រាប់កិច្ចការសង្គម កសិកម្ម និងការព្យាបាល។ ឯបរិស្ថាននៅអង្គរផ្តល់អំណោយផលដល់កិច្ចការហត្ថកម្មមួយចំនួនជំនួសម្រាប់ការងារប្រចាំថ្ងៃ និងជួយដល់សេដ្ឋកិច្ចគ្រួសារខ្មែរតផង។ ការបន្តប្រតិបត្តិប្រពៃណីតាំងពីបុរាណនោះធ្វើឲ្យអង្គរបន្តមានជីវិតរស់រវើកជួចដែលយើងដឹងជាខ្មែរថា «មរតករស់»។

មាត្រា៦នៃអនុសញ្ញាស្តីពីការការពារបេតិកណ្ឌវប្បធម៌អរូបីឆ្នាំ២០០៣ មានចែងអំពីនិយមន័យ និងវិស័យទាំង៥គឺ៖ ១) ប្រពៃណីតាមការចងចាំ ២) សិល្បៈទស្សនីយភាព ៣) កិច្ចប្រតិបត្តិសង្គម ជំនឿសាសនា ពិធីបុណ្យ ៤) ចំណេះដឹងប្រពៃណីទាក់ទងជាមួយធម្មជាតិ និងចក្រវាឡ ៥) សិប្បកម្មប្រពៃណី។ វិស័យទាំង៥ខាងលើនេះ នៅអង្គរមានស្ទើរគ្រប់ផ្នែក។

ពិធីទ្វេរចេត្រ និង ពិធីឡើងមាយ

ស្រូវជាដំណាំកសិកម្មយ៉ាងសំខាន់ក្នុងជីវិតអ្នកស្រុកអង្គរ ក៏ដូចជាខ្មែរទូទៅដែរ រាប់តាំងពីកើតរហូតដល់ស្លាប់។ ក្នុងដំណើរ«វដ្តស្រូវ» មានដំណាក់កាល៦សំខាន់ៗគឺ ពេលចាប់ផ្តើមដាំដុះ និងពេលប្រមូលផលរួច ហើយដំណាក់កាលទាំង៦នេះមានឥទ្ធិពលធំធេងទៅលើការរស់នៅ។ ម្ល៉ោះហើយទាំងនេះពុំមែនជាការគាប់ជួនទេ ដែលមានកិច្ចពិធីសំខាន់ៗទាក់ទងនឹងកសិកម្មក្នុងដំណាក់កាលទាំង៦ ខាងលើនោះ។ តាមតំបន់នានានៃប្រទេសកម្ពុជា ជួនគេឲ្យសារសំខាន់ទៅលើពេលបើកវដ្ត មានន័យថាបុណ្យធ្វើនៅខែពិសាខ ព្រោះជាពេលចាប់ផ្តើមមានភ្លៀងធ្លាក់ដូចជានៅតំបន់ប្រាសាទសំបូរព្រៃគុកជាដើម។ ស្រុកខ្លះទៀតគេឲ្យសារសំខាន់ទៅពេលបិទវដ្ត មានន័យថាធ្វើបុណ្យខែដែលការប្រមូលផលរួចរាល់រាងខែបុស្ស ឬខែមាឃ។

រីឯតំបន់អង្គរវិញ យើងសង្កេតឃើញជាទូទៅថា គេធ្វើទាំង៦គឺ ពិធី«ទ្វង់ចេត្រ»នៅពេលចាប់ផ្តើមវស្សា និងពិធី«ឡើងមាឃ»នៅពេលវស្សាចប់។ ពិធីទ្វង់ចេត្រច្រើនតែធ្វើនៅដើមខែពិសាខដែលក្មៀងចាប់ផ្តើមធ្លាក់ និងជាខែដែលអាចចាប់ក្តួរភស់បាន។ ចំពោះថ្ងៃដើរមកធ្វើពិធីទ្វង់ចេត្រនោះតែងតែនុសគ្នាបន្តិចបន្តួចពីភូមិមួយទៅភូមិមួយទៀត នោះជានៅតំបន់អង្គរជាមួយគ្នាក៏ដោយ ដ្បិតពេលវេលាក្នុងវដ្តមិនតម្រូវពេលណា ថ្ងៃណាជាចំណាត់នោះទេ។ ទ្វង់ចេត្រ សម្រាប់អ្នកស្រុកអង្គរ គឺមានន័យថា ទ្វង់ផុតខែចេត្រចូលទៅខែពិសាខ ដែលជាខែធ្លាក់ក្មៀងអាចក្តួរជាស់ដីបាន ពោលគឺជា«វដ្តស្រូវ» ឬជា«វដ្តវស្សា» ធ្វើស្រែ។ ពិធីនេះផ្សារភ្ជាប់វៀងកសិកម្ម និងជំនឿជីវិតល ពោលគឺអ្នកតា។ ហេតុនេះហើយបានជាកិច្ចពិធីនេះច្រើនធ្វើនៅក្បែរខ្នមអ្នកតា។ ជួនកាលធ្វើនៅវត្ត ដ្បិតមកពីអ្នកតាប្រចាំភូមិនៅក្នុងវត្តដែរ ហើយកិច្ចពិធីទាំងប៉ុន្មានពុំមានព្រះសង្ឃជាចម្បងទេ។ចំណែកឡើងមាឃក៏ជាពិធីឡើងអ្នកតាដែរ ដ្បិតគេនិយមធ្វើនៅក្នុងខែមាឃ ជាពិសេសថ្ងៃ៣កើត ខែមាឃ ឬពោះជាឃ្លាតបន្តិចក្តីក៏ច្រើនតែធ្វើនៅខែនេះដែរ។ ពិធីឡើងមាឃនេះធ្វើនៅតាមខ្នមអ្នកតា ឬសាលាឆាន់ក្នុងភូមិ។ តាមពិតទៅ ខែមាឃជាខែដែលការប្រមូលផលស្រូវបានបញ្ចប់រួចរាល់ទាំងស្រុង ពោលគឺជាការបិទបញ្ចប់វដ្តស្រូវនៃឆ្នាំនោះ។ ជាទូទៅ ភូមិដែលនៅតំបន់អង្គរឡើងមាឃនៅខ្នមអ្នកតាតែមួយល្ងាចប៉ុណ្ណោះ។ នៅល្ងាចនោះ គេធ្វើនំបញ្ចុកតាមផ្ទះរៀងៗខ្លួន រួចយកទៅប្រជុំគ្នានៅមុខខ្នមអ្នកតា។ ភូមិខ្លះមានបញ្ចូលអ្នកតា និងមានភ្ងេងអារក្សយ៉ាងអធិកអធមផង។ កត្តាភូមិសាស្ត្រក៏ធ្វើឱ្យកិច្ចពិធីឡើងមាឃខុសគ្នាពីតំបន់មួយទៅមួយដែរ។ នៅភូមិបន្ទោងមានត្រពាំងបុកណាមួយឈ្មោះត្រពាំងបីង។ មុនថ្ងៃឡើងមាឃ១ថ្ងៃ អ្នកភូមិនាំគ្នាចុះចាប់ត្រីរួមគ្នាដើម្បីយកទុកឡើងមាឃ។ ត្រពាំងនោះត្រូវគេមើលថែមិនឱ្យអ្នកណាចុះរកត្រីក្នុងត្រពាំងមុនថ្ងៃឡើងមាឃឡើយ។ អ្វីដែលជាសង្កេតឃើញជារួមមួយទៀតគឺ ក្នុងពិធីឡើងមាឃតែងមានពូនភ្នំស្រូវដែលស្រូវទាំងនោះជាស្រូវថ្មី ទើបប្រូតកាត់មកប៉ុន្មានខែមុននេះ ក្នុងគំនិតឱ្យស្រូវបរិបូណ៌ សម្បូណ៌សប្បាយសម្រាប់ឆ្នាំខាងមុខបន្តទៀត។


ពិធីឡើងមាឃ


ពិធីឡើងមាឃ


ចាប់ត្រីឡើងមាឃ

សុំទឹកភ្លៀង

មកដល់សព្វថ្ងៃនេះ កសិកម្មនៅតែជាវិស័យមួយសំខាន់សម្រាប់អ្នកស្រុកអង្គរៗ អ្នកស្រុកនៅតែពឹងផ្អែកលើទឹកភ្លៀង ដូច្នេះហើយនៅរដូវវស្សា ពេលខ្លះភ្លៀងធ្លាក់មកពុំត្រូវតាមពេលវេលា ពេលខ្លះកំពង់ភ្លៀងទឹកមិនគ្រប់គ្រាន់ធ្វើឲ្យសំណាបក្រៀមស្វិត ពេលខ្លះភ្លៀងធ្លាក់ច្រើនពេកធ្វើឲ្យសំណាបរលួយខ្វះកំមាន ពាំងនេះហើយជាកង្វល់យ៉ាងធំរបស់អ្នកស្រុកអង្គរៗ នៅដើមរដូវវស្សា បើកាលណាត្រូវធ្លាក់ភ្លៀង ហើយនៅតែបន្តកំពង់សួតអូសបន្ទាយយូរទៅទៀតអ្នកស្រុកអង្គរតែងធ្វើពិធីសុំទឹកភ្លៀង។ កិច្ចពិធីសុំទឹកភ្លៀងនេះធ្វើខុសគ្នាពីភូមិមួយទៅភូមិមួយ តែភាគច្រើនប្រើតែកិច្ចពិធីនៅក្នុងជំនឿជីវិលល តែក៏មានបញ្ចូលកិច្ចព្រះពុទ្ធសាសនាខ្លះដែរ ដូចជា និមន្តព្រះសង្ឃចម្រើនព្រះបរិត្តជាដើម។

នៅតំបន់អង្គរ ចំពោះភូមិណាដែលនៅជិតប្រាសាទតែងតែរៀបចំធ្វើពិធីសុំទឹកភ្លៀងនៅប្រាសាទតែម្តង ដូចជា នៅប្រាសាទបាគង ប្រាសាទប្រែរូប ប្រាសាទមេបុណ្យខាងកើត ប្រាសាទនាគព័ន្ធ ប្រាសាទបន្ទាយសំរ៉ែ ប្រាសាទលោក់ទាង និងប្រាសាទវត្តអញ្ចាៗលៗ ដូចបានពោលមុននេះបន្តិច ក្នុងតំនិតអ្នកស្រុកសព្វថ្ងៃ ប្រាសាទជាលំនៅរបស់អ្នកតា។ ក្រៅពីសុំទឹកភ្លៀង គេជឿថាអ្នកតាទាំងនោះនឹងជួយបញ្ជៀសជម្ងឺរាតត្បាតនានាពីអ្នកស្រុកផង។ ក្នុងពិធីនេះដែរគេមានកិច្ចបញ្ចូលអ្នកតា ដើម្បីប្រាស្រ័យជាមួយអ្នកតាបង្ហាញទុក្ខកង្វល់ផ្សេងៗនៅក្នុងភូមិគរ។ តែក៏មានកិច្ចមួយចំនួនបាត់លែងមានការប្រតិបត្តិតទៅទៀតដែលនេះជាការវិវឌ្ឍន៍មួយជំដែរ។ នៅប្រាសាទលោក់ទាងខាងជើងភ្នំបូក គេចំណាំទៅធ្វើកិច្ចនៅខាងមុខប្រាសាទដោយបានសូនដីនិម្មិតជាស្រះ និងសូនរូបសត្វក្នុងទឹកដូចជា កង្កែប ត្រី ក្រពើ ខ្យង អន្ទង។លៅ ហើយយកអ្នកភូជាតិទឹកមកដោតជាំក្នុងស្រះនិម្មិតទៀតផង។ បន្ទាប់មកនិមន្តព្រះសង្ឃគង់ក្នុងស្រះនិម្មិត ហើយស្រង់ទឹកពាំងកណ្តាលថ្ងៃត្រង់ហាក់ដូចជាភ្លៀងកំពុងធ្លាក់មកប្រាកដមែន។


ពិធីសុំទឹកភ្លៀងនៅប្រាសាទនាគព័ន្ធ

ចំណែកនៅប្រាសាទនាគព័ន្ធវិញ មានស្រះបុពណ៌ដែលជាចនាសម្ព័ន្ធរបស់ប្រាសាទស្រាប់។ នៅកិច្ចបុងក្រោយ អ្នកស្រុកដើរប្រទក្សិណជុំវិញស្រះកណ្តាល ហើយចាក់ទឹកចូលទៅនៃស្រះពាំង៤ដើម្បីឲ្យហូរចេញតាមមាត់ចម្លាក់ដែលនៅទិសពាំង៤នោះ។ ស្រះនេះត្រូវគេដឹងឮជាទូទៅថាជា «អនោត្តស្រះ» ឬ «អនវតប្ត» ក្នុងគម្ពីរព្រះពុទ្ធសាសនា។

បុណ្យសព (ចម្រើនភ្នើង)

ពីតំបន់មួយទៅតំបន់មួយពិធីទាក់ទងនឹងការស្លាប់ គឺតែងធ្វើខុសគ្នាជានិច្ច។ ជាពិសេសអ្នកនៅខាងលើតំបន់អង្គរ គេពុំយកសពដែលបានស្លាប់មួយថ្ងៃ ឬពីរថ្ងៃទៅបូជានោះទេ ពោលគឺ គេចែកពិធីនេះជាពីរដំណាក់កាល៖ នៅដំណាក់កាលទីមួយ ក្រោយធ្វើបុណ្យបានមួយថ្ងៃ ឬពីរថ្ងៃក្រោយស្លាប់ គេយកសពទៅកប់នៅតាមគោកខ្ទោច ឱ្យព្រះធរណីនិមន្តដើម្បីឱ្យដី និងទឹកដែលនៅក្នុងដីរំលាយរាងកាយជាមុនសិន។ ដំណាក់កាលទីពីរគេគាស់យកឆ្អឹងឬហៅថា "លើកសព" ដែលរាងកាយរលេះរលួយអស់ ក្រោយកប់បាន១ឆ្នាំ ឬពី៣ ទៅ៥ឆ្នាំ មកបូជា ដោយអ្នកភូមិខ្លះហៅថា ពិធីបូជាសព អុជសព បញ្ចេះបុគ្គល ឬចម្រើនភ្នើង ដើម្បីឱ្យភ្នើង និងខ្យល់រំលាយបង្គើយទើបចាត់ទុកថាបុណ្យសពបានចប់សព្វគ្រប់។ កិច្ចពិធីក្នុងដំណាក់កាលទាំងពីរខាងលើនេះ បង្ហាញថា រូបរាងកាយយើងម្នាក់ៗ ផ្គុំឡើងដោយធាតុដី ទឹក ភ្នើង និងខ្យល់ ហើយរលាយទៅវិញក៏ដោយធាតុទាំងបួននេះដែរ។



កិច្ចរៀសពឱ្យបុគ្គល



រមៅ និងកិច្ចចម្រើនភ្នើង

ពិធីនេះច្រើនធ្វើនៅវែមាយ ឬជល្ហុន ហើយធំដុំណាស់ ពិសេសពេលគេធ្វើចូលគ្នាជាមួយព្រះសពព្រះចៅអធិការវត្តណាមួយ។ ទីចម្រើនភ្នើង គេធ្វើមេរុខ្ពស់សន្ធឹមកណ្តាលវាលស្រែ មានធ្វើភេនបុណ្យនៅខាងស្តាំ និងកន្លែងផ្សេងៗដែលតំណាងឱ្យឋានសួគ៌ដែលគេនិម្មិតនៅលើដី ព្រោះតំនិតនៃពិធីនេះធ្វើយ៉ាងណាគឺរកពេលវេលាឱ្យអ្នកដែលបានស្លាប់ហើយទៅចាប់ជាតិខ្មៀតបាន។ ក្នុងពិធីចម្រើនភ្នើងអាចមានភ្ញោច ឬបុគ្គលលើសពី១ ស្ថិតនេះជាឱកាសល្អដែលមនុស្សច្រើនមកជួបជុំគ្នាឱ្យការចំណាយតិច។ ពិធីនេះមានកិច្ចច្រើនដំណាក់កាលណាស់ដែលរៀបរាប់ចោះៗដូចជា កិច្ចលួចសព កិច្ចរំកិលសព កិច្ចបូជាសព កិច្ចប្រែរូបៗល។ នៅភូមិខ្លះមានកិច្ចបំពេរជាតុដែលលាងរួច ដូចបំពេរមកទើបនឹងកើតៗ ទាំងនេះបង្ហាញច្បាស់អំពីជំនឿលើការចាប់ជាតិ។



កិច្ចប្រែរូប



កិច្ចបង្វិលពពិល



កិច្ចបញ្ជូនស្ត្រោចនៅភូមិចំបក់ ឃុំរលួស ស្រុកច្រាសាទបាតង

បញ្ជៀសចង្រៃឧត្បាត

នៅរដូវខែកន្ទេឡើង ពេលនៅរោងវែងសីហា អ្នកភូមិចំបក់ត្រូវធ្វើពិធីបញ្ជូនដើម្បីបញ្ជៀសជម្ងឺ ឬចង្រៃឧត្បាតផ្សេងៗពីភូមិស្រុកតាមទិសខាងជើង។ ចង្រៃឧត្បាតនោះកើតឡើងពីអមនុស្ស ដែលគេស្គាល់ថាស្ត្រោច។ អ្នកភូមិតែងរៀបចំពិធីនេះនៅសាលាធាន់ក្នុងភូមិ ឬនៅផ្ទះអ្នកភូមិណាម្នាក់ក៏បាន។ គេរៀបសង្ឃឹកធំល្មម មានជាក់សំណែនផ្សេងៗដូចជា ក្បាលជ្រូក មាន់ស្ងោរ ម្ហូបម្ហា ចំណីចំណុកបាយស្រី ពែ ទៀន ធូបនៅខាងក្នុងនោះ។ ពេលរសៀលអ្នកភូមិនាំគ្នាសែងសង្ឃឹកចេញពីសាលាធាន់ ឬផ្ទះឥតឱ្យមើលក្រោយសំដៅទៅច្រាសាទព្រៃមន្ទីរ ដោយសែងតាមផ្លូវក្នុងភូមិ ដើម្បីឱ្យអ្នកភូមិចំបក់ទាំងអស់អាចចូលរួមជាច្រាក់កាស និងស្នះអង្គរទៅលើសង្ឃឹក។ ពេលមកដល់ច្រាសាទព្រៃមន្ទីរ គេធ្វើកិច្ចផ្សេងៗដូចជាចូលរួប និងសែនសំណែននៅមុខផ្ដែរច្រាសាទ។ ពេលរួចរាល់កិច្ចហើយ គេដង្ហែសង្ឃឹកទៅទុកចោលនៅជុំបព្រៃខាងកើតច្រាសាទបាតង។ ពីមុនមកតាមភូមិនីមួយៗនៅស្រុកច្រាសាទបាតងក៏មានពិធីនេះដែរ។ ភូមិខាងក្រោមបញ្ជូនមកខាងលើ អ្នកភូមិខាងលើត្រូវធ្វើពិធីបញ្ជូនសង្ឃឹកនោះបន្តទៅខាងជើងបន្តទៀត។



សង្ឃឹក និងសំណែន



កិច្ចបញ្ជូលអ្នកតានៅមុខផ្ដែរច្រាសាទព្រៃមន្ទីរ



សម្ពោធវត្តបានដងដោយយកប្រាសាទបានដងធ្វើជាផ្ទៃតភូមិ

សម្ពោធភូមិ

កិច្ចដែលទាក់ទងនឹងផ្ទៃតភូមិគេតែងហៅថា "សម្ពោធ" មិនថាកិច្ចជាប្រក្រតី (ដាច់អាណត្តិភូមិ) ធ្វើដោយមានគ្រោះថ្នាក់អ្វីមួយ ឬធ្វើឡើងក្នុងការបង្កើតភូមិនោះជាលើកដំបូងឡើយ។ តាមមើលទៅប្រហែលជាការសម្ពោធដំបូងមុនគេនោះឯងដែលធំជាងគេបំផុត។ ដ្បិតធ្លាប់ឃើញថា មុននឹងយកបង្គោលថ្មីមកដាំឲ្យទៅជាផ្ទៃតភូមិនោះ ត្រូវធ្វើកិច្ចវែងឆ្ងាយណាស់ ដូចជាហៅព្រលឹង បង្វិលពពិល ចងអំបោះឱ្យបង្គោលដើម្បីឲ្យបង្គោលនោះមានជីវិតអីយនៅពេលបញ្ចុះនោះខ្លៀតសោត គេសុទ្ធតែបញ្ចុះគាថានៅបាតដីខ្លៀតផង។ ដូច្នេះហើយបានជាអ្នកខ្លះហៅផ្ទៃតភូមិនេះថា "អាថាន់"។ ដែលហៅថា «ព្រះភូមិ» គឺចំណុចកណ្តាលនៃភូមិ ដែលគេដាំបង្គោលមួយ ឬច្រើ ហើយដែលគេចាត់ទុកថាជា «ផ្ទៃតភូមិ» នេះឯង។

អាយុកាល ឬអាណត្តិនៃផ្ទៃតភូមិខុសគ្នាពីមួយទៅមួយ។ ជាមធ្យមអាណត្តិនោះមានប្រមាណ៣ឆ្នាំតែបើនិយាយតាមក្បួនពុំច្រាកដថាដូច្នោះទេ ដ្បិតត្រូវមានការគន់គូរដោយផ្អែកទៅលើឈ្មោះភូមិនោះខ្លៀត។ តើត្រូវធ្វើដូចម្តេចដើម្បីឱ្យដឹងថា អាណត្តិភូមិចប់នៅពេលណា? បើយោងតាមក្បួនគឺគេរកអាយុនោះតាមឈ្មោះភូមិ ដោយយកព្យញ្ជនៈដែលនៅចុងឈ្មោះមកគន់គូរដើម្បីដឹងថាតើប៉ះលើសត្វអ្វី។ ឧទាហរណ៍ឈ្មោះភូមិរើល មានអក្សរ «ល» នៅខាងចុង ដែលប៉ះចំសត្វដំរីឈ្មោល រីឯចំនួនឆ្នាំដែលត្រូវនឹងសត្វនេះ គឺ១៦ មានន័យថាអាណត្តិភូមិមាន១៦ឆ្នាំ។ ដូច្នេះគេត្រូវសម្ពោធភូមិ១៦ឆ្នាំម្តងៗ។ មួយវិញទៀត ទោះជាសម្ពោធដោយប្រការណាមួយក៏ដោយ ដូចជាទាក់ទងនឹងអាណត្តិ, ឧត្បាតកើតឡើងក្នុងភូមិ, បង្កើតតែងតាំងព្រះភូមិមុនដំបូង កំតម្រូវឱ្យរៀបចំបង្កក់ភូមិទាំងមូលជាមុនសិន គឺព្រះសង្ឃនិមន្តសូត្របញ្ជៀសចង្រៃតាមផ្ទះឥតមានលែងផ្ទះណាមួយឡើយ។

ក្រៅពីសម្ពោធភូមិដូចបានបង្ហាញពីខាងលើនេះ យើងធ្លាប់ឃើញកាលពីខែមេសា ឆ្នាំ២០១៥ នូវកិច្ចពិធីទាក់ទងនឹងសម្ពោធវត្តបានដងដែលគេទុកខានធ្វើជាង១០ឆ្នាំមកហើយ។ កិច្ចពិធីសម្ពោធនេះ ធ្វើដោយសារអ្នកភូមិចំណុះជើងវត្តបានដងមានគ្រោះថ្នាក់ច្រើ ទេះតែស្ងប់តៗគ្នាដោយហេតុអាក្រក់ផ្សេងៗ។ ម៉្លោះហើយទើបព្រះសង្ឃ និងពុទ្ធបរិស័ទចំណុះជើងវត្តមួយចំនួនតិចគ្នារៀបចំសម្ពោធនេះឡើង ដោយយកប្រាសាទបានដងជាផ្ទៃតភូមិនៃភូមិទាំង៨ដែលជាចំណុះជើងវត្ត។ កិច្ចពិធីនេះមិនខុសគ្នាពីកិច្ចសម្ពោធទេ ពោលគឺមានរៀបចំពានទិសនៅជ្រុងឦសានប្រាសាទ ដោយមានគ្រឿងរណ្តាប់ប្រកបដោយក្តីផ្កាផ្លែឈើ ក្បាលជ្រូក និងគ្រាប់ធញ្ញជាតិជាដើម។ ចំណែកនៅតាមទិសទាំង៨ អ្នកភូមិទាំង៨ភូមិផ្សេងៗគ្នាដែលជាចំណុះជើងវត្ត បានរៀបចំកំត្រុដិ និងនិមន្តព្រះសង្ឃចម្រើនព្រះបរិត្តដោយមានខ្សែអំបោះនៅក្បាច់ពីទិសមួយទៅមួយហើយបន្តមកដល់ប្រាង្គកណ្តាលប្រាសាទបានដង។ ពាក្យ «សម្ពោធ» ទីនេះសំដៅលើការធ្វើឱ្យថ្មីឡើងវិញ។ សម្ពោធវត្តបានដងក៏ដូចសម្ពោធភូមិដែលនៅជុំវិញប្រាសាទបានដងឱ្យថ្មីឡើងវិញ ប្រៀបដូចនឹងលោកទាំងមូលវិលពីកលិយុគមកកួតយុគវិញ។



កិច្ចប្រុងពាលី



កិច្ចដេកអង្គរោម

កោរជុក

"កោរជុក" ជាពិធីធ្វើវ័យមួយក្នុងចំណោមពិធីធ្វើវ័យដទៃទៀតក្នុងដំណាក់កាលនៃជីវិតមនុស្សខ្មែរតាំងពីកើតដល់ស្លាប់។ ពិធីនេះជាការរៀបចំឲ្យសាមីខ្លួនត្រៀមនឹងចូលក្នុងភាពពេញវ័យ។ ដូច្នេះហើយត្រូវធ្វើមុនពេញវ័យ ដែលជាធម្មតាត្រូវធ្វើចាប់ពីអាយុ៩ ទៅ១៣ឆ្នាំ ហើយអាយុរបស់សាមីខ្លួនពិធីត្រូវតែមានអាយុសេស ពុំត្រូវគត់ទេ ហើយចំនួនក្មេងដែលត្រូវកោរនោះក៏ជាចំនួនសេសដែរ។ ក្នុងពិធីកោរជុកនេះ គឺក្មេងប្រុស និងក្មេងស្រីអាចធ្វើលាយឡំគ្នាបានពុំបែងចែកគេទេ។ សព្វថ្ងៃ ទំនៀមកោរជុកនៅតាមភូមិមួយចំនួនក្នុងតំបន់អង្គរពុំសូវមានទៀតទេ ទោះជាពិធីនេះជាទំនៀមច្បាប់ធ្វើ ដើម្បីជាមង្គលដល់កូនក្នុងវ័យនេះក្តី។ ពិធីកោរជុក ឬកោរកំប៉ោយ សំដៅលើសក់១ដុំនៅចំបង្ហើយ ឬកំប៉ោយ៣ដុំជាមុំចង្រ្កានចំកណ្តាលក្បាលទុកតាំងពីក្មេងមក ហើយនិងការផ្តាច់នៅថ្ងៃកោរជុក ដែលជាទូទៅច្រើនធ្វើនៅខែមាឃ។

ពិធីកោរជុកមានរយៈពេល១ថ្ងៃ២យប់។ ថ្ងៃទី១ ជាថ្ងៃចូលភោជ ហើយថ្ងៃទី២ ជាថ្ងៃកោរផ្តាច់។ ចំណែកគ្រឿងរណ្តាប់មានៈ បាយស្រីដើមស្នងឲ្យក្មេងដែលនឹងចូលមកវ័យថ្មី បាយព្រលឹង ស្លារកញ្ជើ គ្រឿងអង្គរោម, រណ្តាប់កោរសក់, ព្រះខ័ន និងគ្រឿងតុបតែងខ្លួន។ ពិធីផ្តើមនៅពេលរសៀល ដោយធ្វើកិច្ចប្រុងពាលី បែរមុខទៅកើតរកកន្លែងដើម្បីប្តឹងដល់ម្ចាស់ទឹកម្ចាស់ដីពីដំណើរប្រព្រឹត្តទៅនៃពិធីទាំងមូល។ នៅមុនពេលយប់មានធ្វើកិច្ចសូត្រមន្តដោយក្មេងៗសាមីចូលរួមសំពះព្រះសង្ឃ ដោយមានស្តាយព្រះខ័នលើស្មា។ នៅយប់នេះមានកិច្ចការច្រើនដែលត្រូវធ្វើ ដូចជា បង្វិលពពិលអង្គរោម បង្វិលពពិលឲ្យក្មេង និងសូត្រក្រាំងហៅព្រលឹង។

នៅព្រឹកថ្ងៃទី២ មុនព្រះអាទិត្យរះគេជាស់ក្មេងឲ្យរាអង្គរោម ដោយចាប់យកវត្ថុអ្វីមួយដែលមានក្នុងអង្គរដើម្បីឲ្យអាចព្យាការណ៍អនាគតក្មេងម្នាក់ៗតាមរបស់ដែលវារាវបាន។ បន្ទាប់ពីក្មេងៗលុបលាងខ្លួន និងស្បៀកពាក់រួច ពេលដែលថ្ងៃចាប់រះព្រលឹ។ មានកិច្ចការច្រើនត្រូវធ្វើជាបន្តបន្ទាប់ ដូចជារះកិច្ចធ្វើឆ្មេញ ដែលតម្រូវឲ្យក្មេងទាំងអស់អង្គុយលើស្បែកញ្ជើរៀងៗខ្លួន នៅវាលហាលផ្លែមួយ បែរមុខទៅរកកន្លែងកោរ ពោលគឺបែរមុខទៅរកព្រះអាទិត្យ។ ចប់កិច្ចធ្វើឆ្មេញអាចារ្យនាំក្មេងទៅកន្លែងកោរ ឬកន្លែងម៉ា ដោយប្រទក្សិណ៣ជុំ រួចបង្គាប់ឲ្យអង្គុយនៅទីនោះ។ កន្លែងកោរនេះ គេធ្វើខ្ពស់ផុតពីដីតំណាងឱ្យភ្នំកៃលាស ដែលជាលំនៅរបស់ព្រះឥសូរ។ នៅដើមសតវត្សទី៦០ ពេលធ្វើពិធីកោរជុកបុត្រាព្រះបាទនរោត្តម គេហៅកន្លែងម៉ាថា ភ្នំកៃលាស។ បន្ទាប់មកគេ និមន្តព្រះសង្ឃមួយអង្គ និមន្តគង់ក្នុងបន្ទប់នៅកណ្តាលកន្លែងម៉ា ដើម្បីកោរផ្តាច់ជុក ហើយឪពុកម្តាយ ឬអាចារ្យជាអ្នកកោរសម្លាត


កិច្ចសំពះព្រះអាទិត្យ


កិច្ចកោរផ្តាច់ជុក


កិច្ចកោរត្រាំទឹកក្រោយកោរផ្តាច់ជុក

នេះជាភាពដោយខ្លៀកៗរបស់ភូមិនីមួយៗនៅអង្គរ ឮប់ឃើញមានព្រះសង្ឃតែមួយអង្គគង់លើកនកោរ តែនៅខេត្តកំពង់ចាមឯណោះ មានដល់ទៅ៤អង្គដែលអ្នកស្រាវជ្រាវកន្ទងមកយល់ថា ការដែលមាន៤អង្គ នេះប្រហែលមានទំនាក់ទំនងពិសេសទៅនឹងស្រះទាំង៤នៅប្រាសាទនាគព័ន្ធ។ កិច្ចសំខាន់សម្រាប់ព្រះសង្ឃនោះ គឺត្រាំទឹកលើក្បាលក្មេង។ ត្រង់នេះក្នុងទំនៀមភាពវង្សគេចាត់ទុក ដូចជាទឹកទន្ទេតដ្ឋាហូរឮក់ពីលើមេឃ ទាល់តែព្រះឥសូរយកព្រះកេសមកទ្រសិន ដើម្បីកុំឲ្យទម្ងន់ទឹកនោះធ្វើឲ្យស្រុតផែនដី។ នេះជាទេវកថាល្បីល្បាញមួយនៅឥណ្ឌា និងនៅខ្មែរសម័យបុរាណ។ ជុតពីកោរ និងត្រាំទឹក អាចាវ្យនាំក្មេងមកផ្ទះវិញ រួចឲ្យអង្គុយបង្ហែគ្នារួចស្រាយបាយស្រីដើម យកនំចំណីខុកហូប រួចលើកបាយស្រីនោះផ្តេកវិលជុំក្បាលក្មេង៣ជុំ ទើបយកទៅចោល។ នៅម៉ោងប្រហែល១០ព្រឹក គេកប់បាត្រប្រគេនព្រះសង្ឃជាកិច្ចបញ្ចប់ពិធីទាំងមូល។


បាយស្រីដើមក្នុងពិធីកោរជុក



នាគ



សៀវនាគប្រទក្សិណព្រះវិហារពេជុំ

បួសជាគ

ចំពោះវិស័យមនុស្សប្រុស បួសជាជំណាក់កាលមួយនៃពិធីធ្វើវែយ។ ដើមឡើយពុំមានសាលាបែបទំនើបដូចសព្វថ្ងៃ បើកាលណាគេចង់បំពេញវិជ្ជានានា គេត្រូវទៅរៀននៅវត្តដែលមានព្រះសង្ឃជាគ្រូបាធ្យាយ។ ហេតុនេះហើយទើបមានពាក្យថាស់ថា «បួសរៀន»។ ក្នុងពិធីបំបួសអាចមាននាគតិច ឬច្រើន។ តាមការសង្កេតទូទៅ អ្នកអង្គរធ្វើពិធីនេះនៅមុនចូលព្រះវស្សា។ ក្នុងដំណាក់កាលដំបូងនៃពិធីបួសនេះ គេបានរៀបចំឱ្យសាមីខ្លួន ដែលទើបនឹងកោរសក់ហើយឱ្យនៅក្នុងសភាពជាគ្រហស្ថមិនចំគ្រហស្ថ បុព្វជិតមិនចំបុព្វជិត ប្រុសមិនចំប្រុស ហើយស្រីមិនចំស្រី ព្រោះគេបានសម្ពិតសម្ពាងតែងកាយហាក់ក្លាយជាមនុស្សស្រី តាមរយៈការតុបតែងខ្លួនដោយលាបម្សៅលើខ្លួនឱ្យមានសម្បុរល្អ សម្លៀកបំពាក់ គ្រឿងអលង្ការ និងការលាបលនមុខមាត់។ ក្មេងទាំងនេះហៅថា "នាគ" ដូច្នេះហើយបានជាគេហៅថា "បួសនាគ"។



នបជ្ឈាយ៍យកស្បង់ "ទាក់ក" នាគ



បន្ទាប់ពីរៀបចំខ្លួនហើយ នៅពេលរសៀលគេរៀបចំធ្វើកិច្ចផ្សេងៗជាក្រុមមានទាគអាចតិច ឬច្រើននៅផ្ទះទាគណាមួយមួយគន្លាក់សិន ព្រោះកិច្ចធំៗទាំងអម្បាលម៉ានត្រូវធ្វើនៅវត្ត។ ក្រោយឆ្នងកិច្ចមួយចំនួនរួចហើយ គេបាននាំគ្នាហែទាគចេញពីភូមិរៀងៗខ្លួនផ្តោះទៅវត្តដែលត្រូវបួស។ កិច្ចជជែ្តទាគនេះមានភាពអធិកអធមណាស់ ដោយទាគតែងជិះសេះ បើពុំមានសេះទេ គឺគេឱ្យអង្គុយលើត្រែដោយមានអ្នកសែង ឬក៏អង្គុយលើម៉ូតូដោយមានអ្នកជីកបណ្តើរសុទ្ធសឹងជាសាច់ញាតិ។ ត្រង់នេះមិនខុសអ្វីពីព្រះពុទ្ធអង្គ កាលទ្រង់យាងទៅសាងព្រះផ្នួសគង់លើសេះសនោះទេ។ ឈុតនេះក៏មានបង្ហាញតាមចម្ងាក់ជ្រាសទដែរ។ នៅមុខក្បួនហែនេះ មានស្ត្រីជាម្តាយធំ ឬបងស្រីជាអ្នកទូលត្រែដើរមុខ ព្រមទាំងមានក្មេងកំដរ។ ក្បួនជជែ្តទាគនេះកាន់តែរីកធំឡើងៗ ពេលទៅជួបគ្នានៅកន្លែងណាមួយឃើញថាមានមនុស្សកុះករគាន់តាប់។ លុះដល់វត្តក្បួនត្រូវហែប្រទក្សិណព្រះវិហារ៣ជុំសិន។ បើអ្នកនៅជិតជ្រាសាទអង្គវត្តគេហែប្រទក្សិណជុំវិញជ្រាសាទ៣ជុំសិន មុនទីងទៅហែជុំវិញព្រះវិហារនៃវត្តទីមួយៗ។ កិច្ចសំខាន់ចុងក្រោយ គឺកិច្ចបំបួសដែលអាចធ្វើនៅរសៀលថ្ងៃជជែ្តល ឬនៅព្រឹកស្អែកបាន តែកិច្ចនេះត្រូវធ្វើនៅក្នុងព្រះវិហារ។ ទាគទីមួយៗត្រូវចេះសូត្រធម៌បួស ដើម្បីធ្វើយទ្ធងជាមួយនឹងបណ្ឌាយ៍ ឬព្រះសង្ឃដែលត្រូវធ្វើកិច្ចជាមួយខ្លួន។ ចុងក្រោយបង្អស់ គឺនឹងបណ្ឌាយ៍យកស្បង់ ·ទាក់ក· ទាគ។ ពេលនេះហើយដែលទាគផ្ទាស់ប្រែខ្លួនមកជាបព្វជិត ដោយដោះសំពត់សាវែស្ប និងអលង្ការអស់ពីខ្លួន ហើយត្រង់ចីពរជាអ្នកបួសពេញលេញ។



ច័ន្ទសុត្រកិរីសូត្រ

ចម្រើនអាយុជាពាក្យហៅទូទៅចំពោះពិធី ដែលកូនចៅផ្ទាល់ញាតិមិត្តជិតឆ្ងាយ ឬសិស្សានុសិស្សប្រារព្ធពិធីនេះជូនសាមីពិធីដែលជាមនុស្សមានចំណាស់។ ក្នុងនោះមានដូចជា បច្ច័យបួន, ច័ន្ទសុត្រកិរីសូត្រ និងឆាកមហាបង្សុកូល។ នៅតំបន់អង្គរអ្នកស្រុកនិយមធ្វើពិធី «ច័ន្ទសុត្រកិរីសូត្រ» ដែលហៅឈ្មោះតាមគម្ពីរដែលព្រះសង្ឃយកមកសូត្រក្នុងពិធីចម្រើនអាយុនេះ។ នៅតំបន់អង្គរ ពិធីនេះច្រើនធ្វើពីខែផល្គុនដល់ខែពិសាខ។ ន័យទូទៅរបស់ពិធី គឺធ្វើយ៉ាងណាឱ្យម្ចាស់សាមីមានអាយុវែង តាមរយៈការសន្មតថាសាមីពិធីនោះស្លាប់ ហើយកើតថ្មីម្តងទៀត។ ជូរច្នេះហើយបានជាគ្រឿងរណ្តាប់សំខាន់ត្រូវមានចំនួន១០០ ជូចជាក្តាំខ្សាច់ដែលគេពូនសម្រាប់ពិធី ដើម្បីឱ្យសាមីពិធីមានអាយុវែង ត្រូវនឹងពាក្យឱ្យពរថា «សូមឱ្យបានអាយុ១០០»។ ពិធីនេះស្តែងល្បាស់ពុំត្រឹមតែកិច្ច «បកស្នូរ» និងការដុត «ពុតមឈូស» នោះទេ គឺគេឱ្យមនុស្សមកក្រាបលើ «អង្គរស្នង»។ អង្គរស្នងនេះ គេថ្វាយឱ្យស្មើនឹងទម្ងន់សាមីខ្លួន រួចយកទៅឱយលើកំណាត់សម្លឹងផ្តាំង ដោយយកត្រខ្សោកជូងកំណាត់អំពៅ និងចេក មករៀបធ្វើជាខ្លួនមនុស្ស មានក្បាល ឆ្អឹងខ្នង ឆ្អឹងដៃជើង និងឆ្អឹងជំនីរ រួចវេចខ្ចប់ជាភាងត្រវែង មានន័យថា កញ្ចប់នេះគឺសាមីខ្លួននេះឯង។ នៅក្បែរអង្គរស្នងមានកូនមឈូសធ្វើពីស្រទបចេកមួយ ធ្វើយ៉ាងនេះ ព្រោះគេនឹបកិច្ចថាអ្នកនោះស្លាប់។ ក្នុងរូបនេះគេឱ្យមនុស្សពីរនាក់ ដេកលើអង្គរស្នង ដោយគេគ្របកំណាត់សលើពួកគាត់។ នៅចុងជើងមានពែកាត់ក្តោះពីរ ហើយព្រះសង្ឃសូត្រឆាកទាញសំពត់ស្នូរយកទៅ។ ត្រង់នេះហៅថាកិច្ចបកស្នូរ ដែលបញ្ជាក់ថាពួកគាត់បានកើតជាថ្មី ពុំខុសអ្វីពីកិច្ចដែលនៅតំបន់ខ្វះហៅថា «ឆាកខ្មើយ»។ បន្ទាប់មកគេយកពែទៅចោលនៅទិសតាមអាចារ្យបង្ហាប់ ហើយគេដុតពុតមឈូសនៅក្បែរនោះផង។ ជួនកាលគេធ្វើឱ្យអធិកអធមជាងនេះដោយមានធ្វើ «ឆាកមហាបង្សុកូល» ដែលកិច្ចត្រូវធ្វើដល់ពាក់កណ្តាលយប់។ គេរៀបចំភេណ្ឌឆាក និងធ្វើបុស្បាកនៅចំកណ្តាល។ កិច្ចនេះធ្វើនៅពេលយប់ដោយតម្រូវឱ្យសាមីពិធីក្រាបបង្គំក្នុងបុស្បាកនោះ ហើយព្រះសង្ឃនិមន្តចង្ក្រមតាមផ្លូវដើរដែលគេរៀបចំ។ អ្នកស្រាវជ្រាវយល់ថា កិច្ចត្រង់នេះប្រៀបដូចជាផ្ទៃម្តាយ ឯសាមីពិធីជាជីវិតមួយថ្មីដែលកើតពីនរ។

លៀងមេមត់

«មេមត់» ឬ «អារក្ស» គឺជាខ្មោចជួរចំបូរប្រចាំត្រកូល ហើយមាន «រូបស្នង» ដែលរូបនោះភាគច្រើនជាមនុស្សស្រី។ «រូប» ដើរតួនាទីសំខាន់ក្នុងការចូលមេមត់ ឬអារក្សមើលរកហេតុនៃវិបត្តិតូចធំដែលកើតឡើងជាប់ខ្លួន, ក្នុងគ្រួសារ ឬតាមការពិនិត្យពាក់ព័ន្ធអ្នកស្រុកជិតឆ្ងាយ។ ដើម្បីឱ្យរូបចូលបានត្រូវតែមាន «តោក» ហើយរូបត្រូវពាក់ខ្សែដង្កត់អង្កុយបត់ជើងមុខតោក មានបិតខឿន ដោយសម្ងឹងភ្នើងមិនពត្រិចភ្នែក ព្រមទាំងបង្វិលតោកលៃវង់លើកន្ទេល ជួនកាលមួយក្បែតកំចូល ជួនកាលមួយសន្ទុះជំទើបចូលក៏មាន។ ក្រៅពីរូបនៅមានស្មំម្នាក់ ឬពីរនាក់ជួយនិយាយប្រែភាសាដើម្បីស្តាប់គ្នាយល់។ ពេលអ្នកជម្ងឺជាសះស្បើយដោយធ្វើតាមពាក្យខ្មោចប្រាប់ឱ្យសែនព្រេន គេនឹងដឹងគុណអមនុស្សនោះដោយរៀបចំពិធីលៀង។ ក្រៅពីនោះក្នុងមួយឆ្នាំ ឬពីរឆ្នាំម្តងគេត្រូវលៀងមេមត់ ឬអារក្សម្តង។

នៅតំបន់អង្គរ គេចំណាំលៀងមេមត់នៅខែមាឃ ឬអាចធ្វើក្នុងពេលពិសេសណាមួយនៅពេលមានរូបមេមត់មានជម្ងឺធ្ងន់ៗ។ ន័យសំខាន់នៃពិធីលៀងមេមត់នោះគឺ ព្យាបាលជម្ងឺ។ គេជឿថា មនុស្សម្នាក់ៗ តែងមានគ្រូកំណើត ឬជួរចំបូរ ជាពិសេសអ្នកកើតមកមានជាប់សុំណុំសង្វារ អមនុស្សនេះអាចធ្វើឱ្យរូបស្នងនោះមានជម្ងឺ។ ហេតុនេះដើម្បីការពារកុំឱ្យឈឺ គេត្រូវលៀងមេមត់ប្រចាំឆ្នាំ។ យើងយកពាក្យ «លៀង» មកពិនិត្យក៏អាចយល់បានថា ពាក្យនេះសំដៅលើការធ្វើឱ្យសប្បាយរីករាយ ដើម្បីញ៉ាំងបរិយាកាសឱ្យកាន់តែសប្បាយរីករាយ ក្មេងជាត្រឿងល្អាប់យ៉ាងសំខាន់។ ពិធីនេះគគ្រឹកគគ្រេងណាស់ ព្រោះមានរូបស្នងច្រើននៅក្នុមិជាមួយគ្នា ឬនៅភូមិជិត។ ធ្វើរួមគ្នាពេញមួយយប់ក្នុងរោងមួយដែលគេរៀបចំ។ ក្មេងលេងនៅពេលនោះត្រូវគេស្គាល់ជាទូទៅថា «ក្មេងមេមត់» ឬ «ក្មេងអារក្ស» លេងដើម្បីអន្ទងហៅខ្មោចជាគ្រូកំណើត ឬជួរចំបូររបស់ខ្លួន។ ពេលចូលរូប តាំងនោះក្រោកឡើងកំតាមចង្វាក់ក្មេងក្រោមឥទ្ធិពលអាការសោហ៊ោកំមានៗជួរចំបូរនីមួយៗមានវត្ថុសម្គាល់ដោយយកឈើ ឬផ្លែជួងធ្វើជាជើងទម្រនិងយកស្ទឹកខ្នោតកាត់ក្បាច់លម្អផ្សេងៗអាស្រ័យតាមលក្ខណៈពិសេសរៀងៗខ្លួនដែលគេអាចដឹងបានដោយការរកគ្រូមើលៗ។ ស្ទឹកខ្នោតកាត់ជាក្បាច់នោះហៅថា «កន្ទង់» ដែលមានឈ្មោះដូចជា កន្ទង់សីមាញីឈ្មោលកន្ទង់ខាតព័ទ្ធលៗ។ ឯរូបតូចៗហៅថា សេកៗ កម្មវិធីចាប់ផ្តើមពីល្ងាចរហូតដល់កណ្តាលអធ្រាត្រ ឬពេលព្រឹកព្រលឹមក៏មានអាស្រ័យទៅលើរូបមេមត់ចូលត្រប់គ្នាឬនៅ។



រូបកំពុងសម្ងឹងភ្នើងខឿន


ក្មេងមេមត់ ឬក្មេងអារក្ស

ពិធីបុណ្យក្រឡាន

ពិធីដែលគេយកក្រឡានរួមនឹងផ្លែឈើ ភោគផលជាច្រើនប្រភេទ ទៅបុណ្យចោលដើម្បីឱ្យព្រះសង្ឃនិមន្តទៅទស់យក ហៅថា ពិធីបុណ្យក្រឡាន។ អ្នកអង្គរនិយមធ្វើពិធីនេះនៅក្រោយរដូវប្រូតកាត់ហើយ។ គេតែងធ្វើនៅពេលរសៀលនិងបន្តរហូតដល់យប់ជ្រៅ។ គោលបំណងនៃពិធីគឺអបអរការប្រមូលផលកសិកម្ម និងធ្វើបុណ្យឧទ្ទិសដល់ញាតិការដែលបានស្លាប់ទៅហើយ។

កម្មវិធីសំខាន់ៗ ដែលគេធ្វើក្នុងពិធីនេះមានដូចជាគេរៀបចំគ្រឿងណ្តាប់មាន ក្រឡាន អន្សម ផ្លែឈើ ត្រី សាច់ អំបិល ស្ករស ធូប ទៀន យកមកបុណ្យចោលនៅកន្លែងណាមួយនៃពិធី រហើយគ្របស្វ៊ីករឈើពីលើ រួចអុជធូបទៀន។ បន្ទាប់មកក៏និមន្តព្រះសង្ឃសមាទានសីលហើយនិមន្តព្រះសង្ឃមួយអង្គ ធ្វើពុតង្គបីជុំយ៉ាងស្ងប់ស្ងាត់ដើម្បីពាករបស់ទាំងនោះ។ អ្នកចូលរួមអង្គុយសំពះដោយក្តីគោរព និងស្ងៀមស្ងាត់បំផុត។











អ្នកបន្តវេន

ភាតព្វកិច្ចរបស់អាជ្ញាធរជាតិអប្សរ ធ្វើយតបទៅនឹងការកិច្ចដែលបានស្នើឡើងដោយអង្គការ UNESCO ក្នុងការគ្រប់គ្រងរមណីយដ្ឋានបេតិកភណ្ឌពិភពលោក តម្រូវឱ្យមានការបណ្តុះបណ្តាលមនុស្សជំនាន់ក្រោយៗ កម្មវិធីអប់រំបេតិកភណ្ឌ បណ្តុះបណ្តាលធនធានមនុស្ស ព្រមទាំងកម្មវិធីបញ្ជោបចំណេះដឹងបេតិកភណ្ឌជូនដល់មហាជនទូទៅផងៗ



បាឋកថា ស្តីពី
·ទំនាក់ទំនងច្រើនសែបយ៉ាងរវាងមាតាអ្នកបើយ និង អ្នកប៉ែ



អាជ្ញាធរជាតិអប្សរាបានចាត់ទុកការបណ្តុះ-បណ្តាលធនធានមនុស្សជាបញ្ហាអាទិភាពមួយក្នុងចំណោមការងារអាទិភាពផ្សេងៗទៀតៗ យោងលើគំនិតនេះ អាជ្ញាធរជាតិអប្សរាតែងតែកំណត់ឱ្យកាតព្វកិច្ចបរទេសដែលអនុវត្តគម្រោងនានានៅតំបន់អង្គរត្រូវតែបញ្ចូលមន្ត្រីខ្មែរដើម្បីធ្វើការជាមួយដើម្បីរៀនសូត្រ និងអនុវត្តជាក់ស្តែងជាមួយអ្នកជំនាញការបរទេសៗ


ក្រៅពីអនុវត្តជាក់ស្តែងនៅតាមការដ្ឋាន អាជ្ញាធរជាតិអប្សរាក៏បានសហការជាមួយស្ថាប័នបរទេសមួយចំនួន ដើម្បីផ្តល់ការបណ្តុះបណ្តាលមន្ត្រីជំនាញខ្មែរឱ្យទទួលបានការសិក្សានៅក្រៅប្រទេសចាប់យកជំនាញសំខាន់ៗដែលពាក់ព័ន្ធការងារអភិរក្ស ជួសជុល និងអភិវឌ្ឍន៍ដោយចីរភាពនៅក្នុងរមណីយដ្ឋានអង្គរៗ តាមរយៈគម្រោងនេះ មន្ត្រីជំនាញមួយចំនួនបានបញ្ចប់ថ្នាក់បណ្ឌិត ថ្នាក់អនុបណ្ឌិត និងជំនាញផ្សេងៗជាច្រើនៗ ចំណែកមន្ត្រីជំនាញជាច្រើនទៀតដែលមិនបានទៅបន្តការសិក្សានៅក្រៅប្រទេសក៏ទទួលបានការបណ្តុះ-បណ្តាលដោយសាស្ត្រាចារ្យល្បីៗលើពិភពលោកជាច្រើន ដោយការបណ្តុះបណ្តាលវគ្គខ្លីៗទៅតាមភាពចាំបាច់នៃការងារបម្រុងនឹងការចុះអនុវត្តជាក់ស្តែងនៅតាមការដ្ឋានផងៗ


Introduction to Conservation Science -
stone, deterioration, conservation,
case studies
Hans Larsen





















មជ្ឈមណ្ឌលបណ្តុះបណ្តាលអង្គរ

ការសម្រេចបង្កើតឡើងនូវមជ្ឈមណ្ឌលបណ្តុះបណ្តាលអង្គរនេះ គឺធ្វើយតបទៅនឹងអនុសាសន៍លើកឡើងរបស់កិច្ចប្រជុំលើកទី៦៣នៃគណៈកម្មាធិការអាយស៊ីស៊ី-អង្គរ ដើម្បីអភិវឌ្ឍន៍ធនធានមនុស្ស សម្រាប់ថែរក្សាការពារ និងអភិរក្សនូវសម្បត្តិបេតិកភណ្ឌវប្បធម៌។

វត្ថុបំណងសំខាន់នៃការបង្កើតឡើងនូវមជ្ឈមណ្ឌលបណ្តុះបណ្តាលអង្គរនេះ គឺដើម្បីពង្រឹងការងារបណ្តុះបណ្តាលអំពីជំនាញបច្ចេកទេសបេតិកភណ្ឌ ដល់មន្ត្រីបុគ្គលិកជំនាញរបស់អាជ្ញាធរជាតិអប្សរា រួមទាំងអ្នកពាក់ព័ន្ធទាំងឡាយឱ្យគេទទួលបាននូវចំណេះដឹង វិធីសាស្ត្រ និងបច្ចេកទេសក្នុងការការពារ ថែទាំ និងអភិរក្សសម្បត្តិបេតិកភណ្ឌឱ្យបានត្រឹមត្រូវល្អ ប្បាស់ លាស់ និងមានការទទួលខុសត្រូវខ្ពស់ ដើម្បីអាចទប់ស្កាត់បាននូវការបំផ្លិចបំផ្លាញទាំងឡាយ ទាំងកត្តាមនុស្សក៏ដូចជាកត្តាធម្មជាតិមកលើសម្បត្តិវប្បធម៌ជាតិយើង។ កិច្ចការនេះមានភាពចាំបាច់ណាស់ដែលតាមការឱ្យអាជ្ញាធរជាតិអប្សរាទិតៗជាប្រចាំលើការងារពង្រឹងសមត្ថភាពឱ្យដល់មន្ត្រីបុគ្គលិករបស់ខ្លួនដើម្បីអាចបំពេញការកិច្ចក្នុងការការពារថែរក្សា និងអភិរក្សទ្រព្យសម្បត្តិបេតិកភណ្ឌវប្បធម៌ជាតិឱ្យបានគង់វង្សល្អ។





ការអប់រំបេតិកភណ្ឌអង្គរ ដៅតាមសាកលវិទ្យាល័យ

ការយល់ដឹងអំពីបេតិកភណ្ឌរបស់ខ្លួននឹងជំរុញឱ្យយុវជនរីរឹតតែស្រឡាញ់និងមានឆន្ទៈមុតមាំក្នុងការថែរក្សាអភិរក្សឱ្យបានគង់វង្ស។ កាលបើយុវជនដែលជាទំពាំងស្នងឫស្សីមានការយល់ដឹងច្បាស់ និងរួមចំណែកថែរក្សាហើយនោះ បេតិកភណ្ឌដូនតានឹងអាចតាំងនៅយូរអង្វែងតជំនាន់រៀងឆ្ងាយទៅទៀត។ ដូច្នេះមានតែការអប់រំទេដែលអាចសម្រេចបំណងនេះបាន។



អាជ្ញាធរជាតិអប្សរាដែលមានបេសកកម្មលើការងារអភិរក្សនិងអភិវឌ្ឍន៍រមណីយដ្ឋានអង្គរបានបំពេញតួនាទីនេះ តាមរយៈក្រុមការងារសហគមន៍ដែលមានគ្រប់ទាំងឥក្រុងស្រុកក្នុងរមណីយដ្ឋានអង្គរ តែងចុះអប់រំប្រជាពលរដ្ឋតាមទីតាំងទាំងនេះជាប្រចាំដើម្បីឱ្យពួកគាត់បានយល់ដឹង និងចូលរួមថែរក្សាបេតិកភណ្ឌអង្គរ។




អាជ្ញាធរជាតិអប្សរាក៏បានដំណើរការចុះអប់រំបេតិកភណ្ឌតាមសាកលវិទ្យាល័យជាបន្ថែមទៀតក្នុងទិសដៅបណ្តុះផ្នត់គំនិតយុវសិស្សទាំងអស់ឱ្យចេះស្រឡាញ់ និងចូលរួមថែរក្សាបេតិកភណ្ឌទាំងអស់គ្នា។ កម្មវិធីអប់រំបេតិកភណ្ឌក្រោមប្រធានបទ «បេតិកភណ្ឌដើម្បីទាំងអស់គ្នា ទាំងអស់គ្នាដើម្បីបេតិកភណ្ឌ» ដោយអនុវត្តនៅតាមសាកលវិទ្យាល័យក្នុងខេត្តសៀមរាប។

ការអប់រំបេតិកភណ្ឌដល់សិស្សានុសិស្សក្នុងតំបន់រមណីយដ្ឋានអង្គរ

អាជ្ញាធរជាតិអប្សរាបានបង្កើតកម្មវិធីអប់រំបេតិកភណ្ឌក្នុងតំបន់អង្គរ ដើម្បីផ្សព្វផ្សាយទៅតាមសាលាមួយចំនួនក្នុងតំបន់អង្គរឱ្យកុមារបានស្គាល់ យល់ដឹង បណ្តុះគំនិតស្រឡាញ់ និងចូលរួមថែរក្សាទ្រព្យមរតកវប្បធម៌រូបីនិងអរូបីដែលមានក្នុងភូមិរបស់ខ្លួន។

មេរៀនសំខាន់ៗនៅក្នុងកម្មវិធីអប់រំ គឺនិយាយអំពីប្រវត្តិ និងភូមិសាស្ត្រនៃភូមិនីមួយៗ តួនាទីកុមារក្នុងការរួមចំណែកថែរក្សាបុរាណដ្ឋានក្នុងភូមិ និងការអប់រំបរិស្ថាន ដែលបង្រៀនដោយអ្នកជំនាញបុរាណវិទ្យា និងអ្នកជំនាញបរិស្ថាន មានលក្ខណៈសាមញ្ញទ្វីៗ ងាយយល់ និងងាយអនុវត្តតាម សមស្របតាមកម្រិតថ្នាក់ រួមទាំងការយល់ដឹងរបស់កុមារ។

ការអប់រំបេតិកភណ្ឌនេះ ក៏បានយកសៀវភៅពាក់ព័ន្ធនឹងចំណេះដឹងខ្មែរ ចំនៀមទម្លាប់ប្រពៃណី ប្រវត្តិសាស្ត្រ បំណែនថ្មីៗរក្សាទុកក្នុងបណ្ណាល័យរបស់សាលាសម្រាប់សិស្សអានបង្កើនចំណេះដឹងនិងកម្សាន្ត។







កម្មវិធីអប់រំបេតិកភណ្ឌកុមារក្នុងតំបន់អង្គរ

«កម្មវិធីអប់រំបេតិកភណ្ឌ» ជាកម្មវិធីថ្មីមួយដែលអាជ្ញាធរជាតិអប្សរាបង្កើតឡើងដើម្បីអប់រំដល់សិស្សានុសិស្សនៅតាមសាលាបឋមសិក្សា និងវិទ្យាល័យឱ្យស្គាល់អំពីបេតិកភណ្ឌអង្គរ ដែលខ្លួនកំពុងរស់នៅជាមួយបណ្តុះគំនិតស្រឡាញ់ និងការពារបេតិកភណ្ឌក្នុងតំបន់ខ្លួនឱ្យបានល្អប្រសើរ។ កម្មវិធីនេះមានការចូលរួមសហការពីមជ្ឈមណ្ឌលយុវជនកម្ពុជា អង្គការគាំពារមរតក វិស័យឯកជន និងលោកគ្រូអ្នកគ្រូនៃសាលាគោលដៅក្នុងតំបន់។

គោលបំណងនៃកម្មវិធី ដើម្បីផ្តល់វិកាសឱ្យកុមារដែលកើត និងរស់នៅក្នុងតំបន់រមណីយដ្ឋានវប្បធម៌-ប្រវត្តិសាស្ត្រ យល់ដឹងពីភាពមរតកវប្បធម៌របស់ខ្លួន និងបណ្តុះគំនិតកុមារឱ្យផ្តួតជ្រាបពីតម្លៃមរតកវប្បធម៌។ ជាពិសេស ពួកគេអាចធ្វើជាអ្នកស្នងមរតកវប្បធម៌នៅសហគមន៍របស់ខ្លួនលើវិស័យថែរក្សាការពារ ត្រប់ត្រងភាពមរតកវប្បធម៌នាពេលអនាគតបានយ៉ាងល្អ។

ចំពោះសិស្សបឋមសិក្សាបង្រៀនមូលដ្ឋានឱ្យស្គាល់ទូទៅអ្វីជាបេតិកភណ្ឌ? ដោយសិក្សាក្នុងថ្នាក់ និងចុះសិក្សានៅតាមរមណីយដ្ឋាន ប្រវត្តិសាស្ត្រ សារមន្ទីរ និងជាត់គំនូរពណ៌ជាដើម។ រីឯសិស្សវិទ្យាល័យ បង្រៀនពីសេចក្តីណែនាំទូទៅនៃប្រវត្តិសាស្ត្រ បុរាណវិទ្យា នរវិទ្យា និងវិធីសាស្ត្រស្រាវជ្រាវដែលអាចធ្វើឱ្យយុវជនអនុវត្តស្រាវជ្រាវចង់ត្រង់ឯកសារដោយខ្លួនឯងនៅក្នុងសហគមន៍របស់ខ្លួន។



កម្មវិធីខាងលើក៏បានដឹកនាំកុមារចេញក្រៅសាលា ដើម្បីបង្រៀនបន្ថែមអំពីការជាត់ពណ៌និងអានសៀវភៅទាក់ទងការអប់រំផ្នែកវប្បធម៌ និងបេតិកភណ្ឌដើម្បីបញ្ជាបចំណេះដឹងក្រៅពីសិក្សាក្នុងថ្នាក់ ឬសិក្សាតាមរមណីយដ្ឋាននិងយល់អំពីស្ថានភាពជាក់ស្តែងកំពុងប្រឈមប៉ុណ្ណោះទេ កុមារទាំងនោះថែមទាំងបានផ្តល់ចំណេះដឹងនេះដល់កុមារដទៃនិងសហគមន៍ខ្លួនៗ។









ដំណើរទស្សនកិច្ចទៅកាន់ប្រាសាទ និងសារមន្ទីរព្រះនរោត្តមសីហនុ អង្គរក៏បានយកមកអនុវត្តសម្រាប់ការអប់រំលេងតែកណ្តាលនេះផងដែរ។

តាមការសង្កេតកន្លងមក ការអប់រំនេះបានផ្លាស់ប្តូរឥរិយាបថរបស់ក្មេងៗពីការមិនដឹងអ្វីទាំងអស់ មកជាដឹង ហើយស្រឡាញ់ ចូលចិត្ត និងលះបង់ពេលវេលាដើម្បីចូលរួម ទោះបីជាត្រជាយ និងមានការជំរុញពីមាតាបិតាពួកគេជាខ្លាំងផងដែរ។

ព្រះរាជសកម្មភាព
និង
សកម្មភាព
ក្នុងតំបន់រមណីយដ្ឋានអង្គរ



ព្រះករុណាព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ
ប្រទានក្រឿងតន្ត្រីសម្លេងរាំយ៉ាដង់ដែលប្រើដោយជនជាតិខ្មែរ ដល់ឯកឧត្តម វ៉ែល មូលីវ៉ែល



ព្រះករុណាព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ
យាងពិនិត្យការដ្ឋានជួសជុលខិលអភិរក្សនៅទីលានស្ពេចព្រះតម្កល់



សម្តេចព្រះមហាក្សត្រី នរោត្តម មុនីនាថ សីហនុ
យាងពិនិត្យការដ្ឋានជួសជុលខិលអភិរក្សនៅទីលានស្ពេចព្រះតម្កល់



ព្រះរាជពិធីច្រត់ព្រះនង្គ័ល ក្រោមព្រះរាជធិបតីភាព
ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
នៅព្រះលានជល់ដំរី ក្រុងអង្គរធំ



ពិធីសម្ពោធចិត្តការដ្ឋានតតិក្សាប្រាសាទបន្ទាយស្រី
ក្រោមព្រះរាជធិបតីភាពព្រះករុណា ព្រះបាទសម្តេច
ព្រះបរមនាថ នរោត្តម សីហមុនី



ពិធីចិត្តការដ្ឋានប្រាសាទបាភ្នួន
ក្រោមព្រះរាជធិបតីភាពព្រះករុណា ព្រះបាទសម្តេច
ព្រះបរមនាថ នរោត្តម សីហមុនី



រូបភាពតន្ត្រីសង្ហារឹមព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ
នរោត្តម សីហមុនី នៅប្រាសាទព្រះពិន្ទុរ



ពិធីចិត្តគប់អាសាទរខួប៦៥ឆ្នាំនៃការបង្កើតគណៈកម្មាធិការ
អាយស៊ីស៊ុី-អង្គរ ក្រោមព្រះរាជធិបតីភាពព្រះករុណា
ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី



ពិធីសម្ពោធសារមន្ទីរព្រះនរោត្តម សីហនុ-អង្គរ
ក្រោមព្រះរាជធិបតីភាពព្រះករុណា ព្រះបាទសម្តេច
ព្រះបរមនាថ នរោត្តម សីហមុនី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ជាយុវរដ្ឋមន្ត្រី
នៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន



សម្ពោធដាំដំបារីក អង្គរ បេតិកភណ្ឌពិភពលោក



ពិធីសូត្រមន្តឧទ្ទិសសេចក្តីសុខជូនព្រះរាជាណាចក្រកម្ពុជា



ឃ្លាខោលទទួលជាសម្បត្តិបេតិកភណ្ឌ
ប្បេតមាតរូបីរបស់មនុស្សជាតិ



ទស្សនកិច្ចប្រាសាទអង្គរវត្ត



ប្រតិភូការណ៍អង្គរសង្ក្រាន្ត



ពិធីសំណេះសំណាលមៀកភូមិវត្តឯក



សម្ពោធទីលានបដិសណ្ឋារកិច្ចប្រាសាទបន្ទាយស្រី



ពិធីបុណ្យមហាសន្និបាតប់ប្រចាំឆ្នាំ



រដ្ឋមន្ត្រីបរិស្ថានអាស៊ានចូលរួមជាកិច្ចនៃសន្និសីទអនុស្សាវរីយ៍នៅសួនច្បារមុខអង្គរវត្ត



សំណេះសំណាលសិស្សានុសិស្សសាលាអ៊ិនសហគមន៍ស្រះស្រង់



មហាសន្និបាតលើកទី៤១ និងខួបលើកទី៧នៃអគ្គនាយកដ្ឋានយូណេស្កូ



ពិនិត្យការដ្ឋានស្តារបាលខាងមុខប្រាសាទអង្គរវត្ត



សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន និង លោកជំទាវ Michelle Obama
ចំពេលទស្សនៈកិច្ចនៅក្នុងព្រះបរមរាជវាំង



ព្រះចៅស៊ុលតង់ Hajji Hassanal Bolkiah Mulzzaddin Waddaulah
ព្រះមហាក្សត្រនៃប្រទេសប្រ៊ុយណេ



ឯកឧត្តម Maithripala Sirisena អតីតប្រធានាធិបតីស្រីលង្កា



ឯកឧត្តម Moon Jae-In អតីតប្រធានាធិបតីសាធារណរដ្ឋកូរ៉ៃ និងលោកជំទាវ



លោកជំទាវ Aung San Suu Kyi ទីប្រឹក្សារដ្ឋនៃសាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា



ឯកឧត្តម János Áder ប្រធានាធិបតីនៃសាធារណរដ្ឋហុងគ្រី និងលោកជំទាវ



ឯកឧត្តម Li Keqiang នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋប្រជាមានិតចិន



លោកជំទាវ Audrey Azoulay អគ្គនាយិកាយូណេស្កូទៅប្រាសាទអង្គរវត្ត



លោកស្រី Angelina Jolie



ឯកឧត្តម JAGDEEP Dhankar អនុប្រធានាធិបតីនៃសាធារណរដ្ឋឥណ្ឌា
និងលោកជំទាវ



សកម្មភាពការិយាល័យតំណាងអាស៊ាន ចំពោះមុខក្នុងតំបន់អង្គរ



ឯកឧត្តម S. JAISHANKAR រដ្ឋមន្ត្រីក្រសួងការបរទេសនៃសាធារណរដ្ឋឥណ្ឌា
និងលោកជំទាវ



សេចក្តីថ្លែងអំណរគុណ

សូមថ្លែងអំណរគុណជាជ្រាលជ្រៅចំពោះ លោកជំទាវបណ្ឌិតសភាចារ្យ គៀង សកុណា រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងជាប្រធានក្រុមប្រឹក្សាគណៈអាជ្ញាធរជាតិអប្សរដែលបានជ្រោមជ្រែងនិងផ្តល់ការអនុញ្ញាតឱ្យរៀបចំចងក្រងសៀវភៅនេះឡើង។

ឯកឧត្តមជាយកា

ឯកឧត្តម ហង់ ពៅ — អគ្គនាយកអាជ្ញាធរជាតិអប្សរ

គ្រប់គ្រងការងារទូទៅ

ឯកឧត្តម ឃុត កុសល — អគ្គនាយករងអាជ្ញាធរជាតិអប្សរ

ប្រឹក្សាយោបល់

ឯកឧត្តម ជុំ សុភមករា — អគ្គនាយករងអាជ្ញាធរជាតិអប្សរ
ឯកឧត្តម យិត ចាន់ជារដ្ឋ — អគ្គនាយករងអាជ្ញាធរជាតិអប្សរ
ឯកឧត្តម តឹម សុជិន — អគ្គនាយករងអាជ្ញាធរជាតិអប្សរ
លោកជំទាវ ចៅស៊ុន កិរិយា — ទីប្រឹក្សាអាជ្ញាធរជាតិអប្សរ

អត្ថបទ

លោក ភ័ន ផល្លា
លោក ទស្សៈ សុមនាថ
លោក សោម សុផាភ័ត
លោក ជូ ភ័ន្តីណា
លោក ឆុច បញ្ចាបញ្ញា
លោក សេង សុធាភ័ក្ត្រ
លោក ស៊ុន ពិសី
លោក តាន់ សុផល
លោក អ៊ឹម សុខរិទ្ធី
លោក គៀង សុឃីម
លោក ទិន ទីណា
លោក ម៉ូត លីណា

រូបភាព

លោកជំទាវ ចៅស៊ុន កិរិយា
លោក ហាប់ តឹមអាន
លោក វង្ស ផល្លីន
លោក គា រក្សា
លោក ជា វណ្ណៈ
លោកស្រី អ៊ីសា រីហ៊ីណា
លោក ហ៊ុំ រិទ្ធី
លោក យី សុថា
លោក សៃម វណ្ណា


វចនា

លោក ឆុន ប៊ុនថុន
លោក ឆោម មករា
លោក រ៉ែង អង្គរែល



កិច្ចការពារមេតិកភណ្ឌវប្បធម៌ជាការកិច្ចរបស់កូនខ្មែរគ្រប់ៗរូប

ទ្វារចូលប្រាសាទបាយ័ន


រៀបចំដោយ
អាជ្ញាធរជាតិអប្សរា
ឆ្នាំ២០២២